

កម្ពុជសុនិយា

ក្រុមជំនុំជំនៀមទម្លាប់
COMMISSION DES MŒURS & COUTUMES

ទស្សនាវដ្តី ផ្សាយខាងសាសនា ទំនៀម អក្សរសាស្ត្រ

បោះពុម្ពផ្សាយដោយគណៈកម្មការមួយ មាន :

និពន្ធនាយក - អ្នករៀបចំ : លី ធាបតែង

គណៈកម្មការនិពន្ធ :

ព្រះពោធិវង្ស - សូរ-ហាយ

លោក ឌីក-គាម អ្នកស្រី រេជ-សល់

បញ្ជីរឿង

អត្ថបទ	ទំព័រ
១— ផ្នែកសាសនា	
១— ទស្សនៈពុទ្ធសាសនា កិក្ខុ អ៊ុក អ៊ាន រៀបរៀង	៣៣៨
២— រឿងនាងសាមាវតី (ត) លោក ប៊ូ-ប៉ូ ប្រែ-រៀបរៀង	៣៥២
២— ផ្នែកអក្សរសាស្ត្រ	
៣— វិចារណកថា : តើអ្នកដាតិមានវិញ្ញាណឬទេ ? លោក ង៉ែង-ជ្រឿ រៀបរៀង	៣៦៣
៤— រឿងសាមកុក ឧកញ៉ា ន្ហូ-កន ប្រែរៀបរៀង	៣៦៨
៥— ស្រាវជ្រាវអំពីស្នែនខ្មែរ លោក លី ធាមតេង រៀបរៀង . . .	៣៩៣
៦— មង្គលឡើងផ្ទះថ្មី លោក ធយ ស៊ីដាត រៀបរៀង	៨០៩
៣— ផ្នែកកំណាត់—ប្រឌិតិការណ៍	
៧— ព័ត៌សម្ភោធ ទេសចរិការ វត្តសុមុនីរតនារាម ស្តើង ធួរ រៀបរៀង . .	៨១៥

តម្លៃជាវ :

មួយឆ្នាំមាន ១២ សៀវភៅ . . . ២៣០រ០០ ៛

អាណត្តិសូមដាក់ថា : លោកនាយកវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា

ទស្សនៈពុទ្ធសាសនា

ភិក្ខុ អ៊ុត-អាឯ
វត្តកែវព្រះភ្លើង ភ្នំពេញ-រៀបរៀង

ព្រះពុទ្ធសាសនា ជាសាសនាមួយ សម្បូរទៅដោយពាក្យប្រៀនប្រដៅ ដែលច្រកបដោយខ្លឹមសារ មានសារប្រយោជន៍ ជំមានតម្លៃខ្ពង់ខ្ពស់ ច្រើនណាស់ ។ បណ្តាពាក្យប្រៀនប្រដៅទាំងអស់នោះ មានពាក្យប្រៀនប្រដៅខ្លះ ត្រូវគ្នានឹងពាក្យប្រៀនប្រដៅ របស់អ្នកប្រាជ្ញទាំងឡាយរំពីបូរាណ ដែលមនុស្សក្នុងលោកគេបានចេះថារៀងៗមក តាំងអំពីមុនពុទ្ធកាលកំមាន ។ ចំណែកពាក្យប្រៀនប្រដៅខ្លះ ជាពាក្យប្រៀនប្រដៅដ៏ខ្ពង់ខ្ពស់បំផុត លើសពីគំនិតរបស់មនុស្សបុថុជ្ជនទាំងអស់ ដែលក្រៅអំពីព្រះសម្ពុទ្ធចេញ ឥតមានអ្នកណាមួយ មានគំនិតគិតឃើញអាចមានសមត្ថភាពយល់ចាក់ធ្លុះដ៏ឆន្ទៈសន្ធូរអាចកំចាំង ដ៏ជ្រាលជ្រៅនៃបរមនុះបានឡើយ ។

ព្រះពុទ្ធសាសនា បានចាប់បដិសន្ធិ មានកំណើតកើតនៅនាមជ្ឈមប្រទេស ។ កាលដែលព្រះពុទ្ធសាសនាមិនទាន់ឧប្បត្តិកឡើងមានជារូបរាង មនុស្សខ្លះទៅនៅអាស្រ័យក្នុងប្រទេសនុះ បាននាំគ្នាប្រព្រឹត្ត

ប្រតិបត្តិ តាមលទ្ធិសាសនាព្រាហ្មណ៍ខ្លះ តាមសាសនាដទៃទៀតខ្លះ ដែលជាផ្លូវប្រតិបត្តិតឹងពេកក៏មាន ធូរពេកក៏មាន គួយ៉ាងដូចជាប្រព្រឹត្តបង្អត់អាហារខ្លួន ឲ្យលំបាកវេទនាពេកយ៉ាងឥតអំពើ ដេកលើបន្ទាប់ចុះត្រាំទឹកដើម្បីលាងជម្រះបាប អាងភ្លើងនៅវេលាថ្ងៃ ក្នុងគិម្ហរដូវ ជាដើម ។ ទោះយោបល់ការប្រព្រឹត្តបែបនេះ គ្មានបានលទ្ធផល គ្មានឃើញកើតប្រយោជន៍ប៉ុនកំភួនដៃក៏ដោយ ក៏ឥតមានជនណាគ្រាក់រឭក មានគំនិតគិតឃើញថាការប្រព្រឹត្តបែបនេះឥតប្រយោជន៍សោះ ហើយនាំគ្នាវេលាស់ខ្លួនឆាកទៅប្រតិបត្តិតាមបែបថ្មីទៀតឡើយ ។

លុះមកដល់ពុទ្ធសម័យ ជាសម័យដែលអង្គព្រះសម្ពុទ្ធបានត្រាស់ដឹងឡើង ទ្រង់បានសម្តែងធម៌ជាលើកតម្បង ប្រោសកិកុចំនួនប្រាំរូបដែលហៅថាធម្មចក្កប្បវត្តនសូត្រ ដើម្បីកែប្រែរុះរើសេចក្តីប្រតិបត្តិដ៏សៅហ្មងគ្រោតគ្រាតទាំងនោះចោលចេញ ។ ហើយឲ្យកែប្រែចិត្តតាមគន្លងធម៌ដែលព្រះអង្គយល់ច្បាស់ជ្រាបច្បាស់ ថា មានប្រយោជន៍ពេញ ។ ធម៌ទេសនាជាបឋមនោះ ទ្រង់ត្រាស់សម្តែងថា :

ទ្វេមេ កិក្ខវេ អន្តា បព្វជិតេន ន សេវិតព្វា

ប្រែថា : ម្នាលកិកុទាំងឡាយ អន្តធម៌ គឺធម៌ជាផ្លូវប្រតិបត្តិអមខាងដ៏លាមកអាក្រក់ទាំងឡាយពីរប្រការនេះ បព្វជិតមិនគួរសេពគប់ គឺថា មិនគួរប្រព្រឹត្តឡើយ ។

ឯអត្តធម៌នេះ គឺជាធម៌ប្លែក ដែលកើតមានឡើងនៅក្នុងទ្រឹស្តីនៃលទ្ធិសាសនា មានមុនពុទ្ធសាសនាទៅទៀត ។ ចំណែកអត្តធម៌នេះឯង បើប្រៀបធៀបទៅនឹងធម៌របស់ព្រះពុទ្ធបរមគ្រូ ដែលព្រះអង្គបានរកទៅទៀតឃើញ គឺមានសភាពជាធម៌ ដែលមានលក្ខណៈតឹងពោនិងធូរពោក ។ ឯធម៌ព្រះសម្ពុទ្ធទើបជាធម៌កណ្តាល ។

ឯអត្តធម៌ ២ ប្រការនោះគឺ :

១ - អត្តកិលមថានុយោគៈ ប្រែថា ការប្រព្រឹត្តខ្ជួនឲ្យលំបាក ។ ធម៌នេះគឺជាឈ្មោះនៃទ្រឹស្តីតាំងមូលរបស់សាសនាដេន, បានជាព្រះសម្ពុទ្ធឲ្យឈ្មោះដូច្នេះ ព្រោះថាសាសនាដេនគេមានប្រព្រឹត្តិធម៌ពីរយ៉ាងគឺ :

ក - តបៈ គឺជាកិច្ចការ ឬជាវិន័យ ដែលពួកអ្នកកាន់សាសនាព្រាហ្មណ៍ត្រូវតែធ្វើឲ្យដូចជាពួកអចេលក៍ មិនស្លៀកពាក់ខោអាវ អាំងភ្លើងឈរហោលថ្ងៃ ចុះត្រាំទឹក ប្រព្រឹត្តអត់អាហារ ។ ដូច្នេះ ជាពិធីដើម្បីហាត់ពត់ចិត្តរបស់គេឲ្យអស់កិលេស ។ ព្រះសម្ពុទ្ធទ្រង់នឹកគន់ថាធម៌នេះ ជាធម៌ថោកទាបលាមក ដែលមនុស្សខ្លួនឯងមិនគួរនឹងយកខ្ជួនទៅលាយឡំទេ ។ នៅក្នុងលទ្ធិសាសនាព្រាហ្មណ៍ ក្នុងសម័យព្រាហ្មណ៍តបធម៌ជាពិធីខ្ជូនាទាងផ្លូវកាយ ឯវិធីខ្ជូនាផ្លូវចិត្តគឺ :

២ - យោគៈ ពួកអ្នកកាន់សាសនាព្រាហ្មណ៍ ដោយយល់

ឃើញថា តថវិធី ជាវិធីត្រាន់តែទូន្មានផ្លូវកាយ មិនមានប្រសិទ្ធិភាព ដល់ផ្លូវចិត្តផងទេ ៖ គេក៏នាំគ្នាធ្វើពិធីមួយទៀត ដែលហៅថា "យោគៈ" សម្រាប់អប់រំផ្លូវចិត្ត ។ តែទោះជាយ៉ាងណាក៏ដោយ ក៏ការអប់រំផ្លូវចិត្តនេះ នៅតែមិនអាចធ្វើចិត្តឲ្យជ្រះស្រឡះ រកមោក្សៈ ឬ និព្វានេះបានឡើយ ។

២ - ឥតាមសុខល្លិកានុយោគៈ នេះជាទ្រឹស្តីរបស់ពួកសាសនាព្រាហ្មណ៍ដែរ ប៉ុន្តែមានសេចក្តីផ្ទុយទៅនឹងទស្សនៈខាងដើម ។ ទស្សនៈនេះ យល់ទិដ្ឋន្យាល់ទូវគោលគំនិតនិងបុព្វហេតុ ដែលនាំឲ្យគេបានទទួលទូវសុភមង្គលមានជាអាទិ៍ថា បុព្វហេតុនៃសុភមង្គល ស្ថិតនៅលើបុគ្គលម្នាក់ ។ ដែលចេះលៃលកយ៉ាងណាឲ្យសម្បូរទៅដោយគ្រឿងកាម ពោលគឺការស៊ីផឹក ស្ទៀកពាក់ ទីលំនៅ ឲ្យបានហ៊ឺហាឥតភ្លក់ឱ្យតែបានប្រសើរឡើង ។ ការស៊ីឆ្ងាញ់ ការដេកស្រួល ការប្រើប្រាស់ទូវគ្រឿងអលង្ការនឹងនាំឲ្យគេបានសុខចម្រើនគ្រប់វិស័យ ។ ទស្សនៈពួកនេះ ចាត់ចោលទូវអ្វីដែលជាបរលោក ។ ព្រះពុទ្ធជាម្ចាស់ ទ្រង់រិះគន់ទូវគោលនៃលទ្ធិនេះថា ជាគំនិតថោកទាប គម្រក់អពមង្គល ហើយដែលសុទ្ធតែឈឺមុខឈានឆ្ពោះទៅរកសេចក្តីវិនាសតាំងអស់ ។

ដោយគោលគំនិតទាំងពីរខាងលើ ជាគោលគំនិតធ្វេងបំផុត និងស្លាំបំផុត ទើបបានជាព្រះពុទ្ធជាម្ចាស់ទ្រង់បានប្រកាន់យកផ្លូវមួយ ដែល

ដែលជាផ្លូវកណ្តាល សម្រាប់ធ្វើជាមធ្យោបាយដឹកនាំមនុស្ស ឲ្យប្រព្រឹត្ត
ទៅបានដោយស្រួល ។ ការណីទាំងពីរខាងលើនេះ បើប្រៀបធៀបទៅ
នឹងដីរកាពារបស់ព្រះអង្គកាលដើម ក៏មានការស្របស្រួលនឹងគ្នាដែរ ។
ខណៈមួយ គឺព្រះអង្គទ្រង់គង់នៅក្នុងភពសមត្តិ ដែលជារយៈពេល
សប្បាយដោយកាមគុណ ។ រយៈពេលពីរ គឺព្រះអង្គធ្វើទុក្កកិរិយា។
រយៈពេលទាំងពីរនេះ លុះព្រះអង្គបានត្រាស់ដឹងឡើងក្នុងលោក ព្រះអង្គ
ទ្រង់រិះគន់ថា ជាអំពើថោកទាប មិនមានផ្លូវ. មិនមានប្រយោជន៍សម្រាប់
អ្នកប្រតិបត្តិទេ ។

ចុះសេចក្តីប្រតិបត្តិជាកណ្តាលដូចម្តេច ? សេចក្តីប្រតិបត្តិជាកណ្តាល
នោះ គឺ ធម៌ដែលដនទួទៅគួរស្វែងរក មានអង្គប្រាំបី ដែលហៅថា
អដ្ឋង្គិកមគ្គ ជាធម៌អាចញុំាងជនអ្នកប្រតិបត្តិ ឲ្យចេញចាកផុតសឹកសត្រូវ
គឺកិលេស ។

ឯអដ្ឋង្គិកមគ្គ នោះគឺ :

សម្មាទិដ្ឋិ ការយល់ឃើញត្រូវ ១, សម្មាសង្កប្បោ
សេចក្តីត្រិះរិះត្រូវ ១, សម្មាវាចា សម្តីត្រូវ ១ សម្មាកម្មន្តោ
ការងារត្រូវ ១, សម្មាអាជីវោ ការចិញ្ចឹមជីវិតត្រូវ ១, សម្មា-
វាយាមោ ព្យាយាមត្រូវ ១, សម្មាសតិ សេចក្តីរឭកត្រូវ ១,
សម្មាសមាធិ ការតម្កល់ចិត្តឲ្យនឹងត្រូវ ១ ។

អដ្ឋង្គិមគ្គនេះហើយ ដែលជាផ្លូវកណ្តាល ជាផ្លូវប្រសើរខ្ពង់ខ្ពស់ ដែលព្រះអរហន្តពាំងឡាយ មានព្រះសម្ពុទ្ធជាដើម ព្រះអង្គបានដើរប្រកបដោយសុខស្រួល ហើយបន្លឹមបន្លាញប្រាប់ដល់ពុទ្ធបរិសទ្យពាំងឡាយថា នែអ្នកពាំងឡាយ ចូរដើរទៅតាមផ្លូវនេះឯងចុះ ។

ទៅមានធម៌ដែលជារបស់ពុទ្ធសាសនាម្យ៉ាងទៀត ដែលហៅថា សច្ចធម៌ ជាធម៌ប្រកាសនូវពាក្យពិតពាក្យមែន ។

បញ្ហាសច្ចៈនេះ ដែលបានចោទឡើងនៅក្នុងសង្គមមនុស្សគ្រប់មជ្ឈដ្ឋាន បានពាំទ្យអ្នកប្រាជ្ញពាំងឡាយខំប្រឹងដោះស្រាយទៅតាមអត្តនោម័តិ ដើម្បីស្វះស្វែងរកសច្ចៈនេះ ។ យើងអាចចោទសួរថា សច្ចៈជាអ្វី? អ្នកណាបង្កើតសច្ចៈ? សច្ចៈនេះ មាននៅក្នុងលោកនេះ ឬក្នុងលោកខាងមុខស្ថិតនៅក្នុងសង្គមមនុស្ស ឬស្ថិតនៅលើបុគ្គលម្នាក់ៗ ឬក៏ស្ថិតនៅក្នុងវត្ថុធម្មជាតិគ្រប់ថែបយ៉ាង? ដរាបណាមានបញ្ហានេះចាប់ចោទឡើង នោះយើងត្រូវតែខំប្រឹងប្រើមធ្យោបាយគ្រប់ថែបយ៉ាង ដើម្បីវែកញែកធ្វើមើលសច្ចៈនេះឲ្យឃើញច្បាស់ ។ មជ្ឈដ្ឋានសាសនា ពួកតាហិរសាសនា គេបានអះអាងថា សច្ចៈ ស្ថិតនៅលើព្រះអាទិទេព ។ អាទិទេព គឺជាតួព្រះចរិបុណ្ណសច្ចៈ ។ គេខំប្រឹងប្រតិបត្តិគ្រប់ថែបយ៉ាង គឺដើម្បីមើលឲ្យឃើញព្រះអាទិទេពនេះឯង ។ ដរាបណាគេមើលឃើញព្រះអាទិទេព គេក៏បានទទួលនូវសច្ចៈដែរ ពោលគឺបានសុខបានសម្រួច

ដល់មោក្ស: ។ មជ្ឈដ្ឋានអ្នកទស្សនវិទូ ភាគខ្លះដែលមិនទាក់ទងទៅនឹងសាសនាបានពន្យល់ថា សច្ច:ស្ថិតនៅក្នុងសង្គមមនុស្សនេះឯង ។ ដរាបណាគេចំរើនាសង្គមមនុស្សឲ្យបានស្អាតបរិសុទ្ធ ប្រាសចាកអំពើអយុត្តិធម៌ សម្របសម្រួលនូវដំណើរការរបស់មនុស្សឲ្យបានស្រួល ពេលនោះឯងសច្ច:នឹងកើតឡើងភ្លាម ។ មូលដ្ឋាននៃសច្ច:ក្នុងសង្គមមនុស្សនេះឯង ពោលគឺចរិយាសីលធម៌នេះឯង ។ ទស្សនវិទូប្រភេទនេះ សង្កត់ខ្លាំងទៅលើសង្គមមនុស្ស ជីវភាពមនុស្សធម្មតា ដោយគេចំពន្យល់តែអំពីវិបត្តិគ្រប់បែបយ៉ាង ដែលប៉ះទង្គិចរវាងមនុស្សនិងមនុស្ស សង្គមមនុស្សនិងសង្គមមនុស្ស បើគេដកចេញនូវអ្វីដែលជាវិបត្តិនេះហើយ ពេលនោះ គេនឹងរកឃើញនូវអ្វីដែលជាសុខ ។

មជ្ឈដ្ឋានអ្នកវិទ្យាសាស្ត្រ ដើម្បីនឹងទាញយកសច្ច:បាន គេត្រូវធ្វើការពិសោធន៍ ។ ក្រោយការពិសោធគេបានលទ្ធផលយ៉ាងណា លទ្ធផលនោះឯងជាសច្ច: ។ ពួកអ្នកវិទ្យាសាស្ត្រ ដែលជាពួកអ្នកសម្ភារនិយម គេឲ្យតម្លៃជាច់ខាតទៅលើការពិសោធន៍ ។ ដរាបណាគេធ្វើការពិសោធន៍ ៧ ឲ្យផលមិនខៀងចាត់ម្តងយ៉ាងនេះ ម្តងយ៉ាងនោះ គេមិនទទួលថាសច្ច:ឡើយ ។ នឹងទទួលថាជាសច្ច:បាន លុះត្រាតែមានសភាពដូចជា ២×២=៤ ។

ចំណែកសច្ច:នោះក្នុងព្រះពុទ្ធសាសនា ដែលហៅថា សច្ចធម៌ ដែល

ព្រះពុទ្ធបរមគ្រូនៃយើង ចានស្រាវជ្រាវរកអស់រយៈពេល ៦ ឆ្នាំ ទើប
ឃើញនោះ មាន ៤ ប្រការគឺ :

- ទុក្ខសច្ច: ទុក្ខជារបស់ពិត,

- សមុទយសច្ច: ហេតុដែលនាំបណ្តាលឲ្យកើតទុក្ខ ជា
សេចក្តីពិត,

និរោធសច្ច: ការរំលត់ទុក្ខជាសេចក្តីពិត,

- មគ្គសច្ច: ផ្លូវនាំកាន់ការរំលត់ទុក្ខជាសេចក្តីពិត ។

សច្ចៈធម៌ ទាំងបួនប្រការនេះ ជាធម៌មានអាថ៌កំបាំងដ៏ជ្រាលជ្រៅ
មានសេចក្តីកំបាំងនឹងគិតដឹងប្រាជ្ញារបស់មនុស្សប៉ុប្បុរដ្ឋនទាំងអស់ ។ កាល
ដែលមិនទាន់មានព្រះពុទ្ធសាសនា ត់តមានអ្នកណាមួយស្រាវជ្រាវរកឃើញសច្ចធម៌នេះឯងឡើយ ។ លុះមកដល់ពេលដែលព្រះសម្ពុទ្ធ ចាន
ត្រាស់ដឹងឡើងក្នុងលោក ទើបទ្រង់សម្តែងសច្ចធម៌នេះ ឲ្យមនុស្សទាំង
អស់ ចានស្គាល់ច្បាស់លាស់ ជាក់ច្បាស់ប្រាកដក្នុងខ្លួន ។

សច្ចធម៌ទាំងបួនប្រការនេះហើយ ដែលនាំបណ្តាលឲ្យមនុស្សអ្នក
មានប្រាជ្ញាទាំងឡាយ ដែលចានឮចានស្តាប់ហើយគិតតាមចំនាក់ចំនង
តាមស្រទាប់ធម៌នេះទៅ ក៏យល់ដោយប្រត្យក្ស ថាជាធម៌ពិតមែន ។

នៅមានទស្សនៈពុទ្ធសាសនាម្យ៉ាងទៀត ដែលសម្រាប់អប់រំមនុស្ស
ឲ្យចេះគិតគូរពិចារណា ដល់រូបកាយ ឲ្យឃើញថា មិនទៀង ជាទុក្ខ

និងមិនមែនជារបស់ខ្លួន ដែលមានឈ្មោះថា ព្រះវិន្ត្រៃលក្សណ៍ ដើម្បីជាប្រយោជន៍ សម្រាប់ញុំាងមនុស្សពាលឲ្យ កុំឲ្យមានសេចក្តីស្រើនក្នុងរូបកាយខ្លាំងពេក ។

ទស្សនៈពុទ្ធសាសនា ដែលនាំមកសម្តែងនេះ យើញថាគិចគួចណាស់ ។ នៅមានច្រើនតទៅទៀត ពោលគឺច្រើនហួសគណនា ព្រោះព្រះសម្ពុទ្ធជាម្ចាស់ត្រាស់ដឹងឡើង ចាន់សម្តែងព្រះធម៌ដែលជាពាក្យសម្រាប់ប្រៀនប្រដៅអស់ចំនួន ៤៥ ឆ្នាំ ទើបព្រះអង្គបរិនិព្វាន ។

ព្រះសង្គីតិកាចារ្យពាំងឡាយ ចានសង្គាយនា ប្រមែប្រមូល រួចរួមទុក នូវពុទ្ធវចនៈជាបីផ្នែកដែលហៅថា ព្រះវិន្ត្រៃបិដក គឺសុត្តន្តបិដក ១ វិនយបិដក ១ អភិធម្មបិដក ១ ។

ម្យ៉ាងទៀត ព្រះពុទ្ធសាសនា ប្រៀនប្រដៅមនុស្ស ឲ្យមានប្រយោជន៍ ឲ្យបានសេចក្តីសុខ មិនមែនប្រៀនប្រដៅ ឲ្យបានប្រយោជន៍ បានសេចក្តីសុខ ក្នុងលោកខាងមុខដែលយើងមើលមិនឃើញនោះទេ ពោលគឺជាពាក្យប្រៀនប្រដៅឲ្យបានប្រយោជន៍ក្នុងលោកខាងមុខផង ក្នុងលោកនេះផង ។ តួយ៉ាងដូចជាព្រះអង្គទ្រង់ប្រដៅមនុស្សមិនឲ្យប្រព្រឹត្តនូវអបាយមុខ ៦ យ៉ាង គឺ :

មិនឲ្យធ្វើសុក ១ មិនឲ្យដើរលេងតាមប្រកល្លក់ក្នុងវេលាយប់ ១ មិនឲ្យដើរលេងល្បែងមហោស្រព ១ មិនឲ្យលេងល្បែងភ្នាល់មានបៀ ប៉ោដាដើម ១ មិនឲ្យសេពគប់ពាក់ព័ន្ធយកមនុស្សខូចធ្វើជាមិត្រភ័ក្តិ ១ មិន

ឲ្យខ្ជិលធ្វើការរកស៊ី ១ ។

ពាក្យប្រៀនប្រដៅមានប៉ុណ្ណោះជាដើម សុទ្ធតែជាពាក្យប្រៀនប្រដៅនាំមនុស្សអ្នកប្រព្រឹត្តតាម ឲ្យបានប្រយោជន៍ដ៏ឧត្តុង្គឧត្តម និងសេចក្តីសុខគួរជាទីប្រាថ្នា នៅក្នុងបច្ចុប្បន្ននេះឯង ។

ជាពិសេសទៅទៀត នៅពេលដែលនឹងយាងបរិនិព្វាន ព្រះអង្គបានត្រាស់ផ្តាំចំពោះពុទ្ធបរិស័ទទាំង ៤ ថា :

« សង្ខារេនមិទានិ ភិក្ខវេ ដែលកើតឡើងហើយ តែងតែវិនាសទៅវិញជាធម្មតា អ្នកទាំងឡាយ ចូរញុំាងកិច្ចការរបស់ខ្លួន ឲ្យសម្រេចដោយមិនប្រមាទចុះ » ។

បច្ឆិមពុទ្ធវចនៈ នេះជាទស្សនៈពុទ្ធសាសនាម្ល៉ាង ដែលមានសារៈប្រយោជន៍ ប្រកបដោយទឹមសារជាវិបុលផុត ។ ព្រះពុទ្ធដីកានេះព្រះអង្គបន្ទន់ចង្ញាក់ថាយើង ដែលមានជាតិជាមនុស្សហ្នឹង មិនត្រូវដេកស្ទឹម ឈរតុបដៃ ដកដង្ហើមចោល ដោយសេចក្តីធ្វេសប្រហែសទេ ពោលគឺត្រូវក្រោកឡើងធ្វើការងារ ដើម្បីជាប្រយោជន៍ដល់ខ្លួន ដល់ជាតិ ដល់សាសនារបស់ខ្លួន ។

កិច្ចការដែលជាប្រយោជន៍ដល់ខ្លួននោះ ឋានដល់ការងារសព្វសារពើ មានតាំងពីពាណិជ្ជកម្ម កសិកម្ម ធ្វើជារដ្ឋការ មានគាហាន់ជាដើម ប្តូរតាំងតែពីក្រសួងណាមួយ ទៅតាមសទ្ធាភាពរបស់ខ្លួន ដែលជា

មធ្យោបាយ អាចជួយលើកតម្កើងដីវគាពរបស់ខ្លួនឲ្យរស់នៅបានសុខស្រួល ។

ឯការងារសម្រាប់ជួយប្រទេសជាតិនិងសាសនានោះ បានដល់ការថែរក្សា ឧបត្ថម្ភ នូវប្រទេសជាតិនិងសាសនារបស់ខ្លួនហ្នឹង ឲ្យស្ថិតនៅជាស្ថាពរអស់កាលជានិច្ចនិរន្តរ៍តទៅ ។ បើប្រសិនជាយើងម្នាក់ៗហ្នឹង ចេះតែធ្វេសប្រហែស ខ្ជះខ្ជាយ អត្តឃាដេកស្ងៀមមើលចំណាំគ្នាទៅវិញទៅមកនោះ ប្រទេសជាតិរបស់យើង សាសនារបស់យើង មុខជាដុនជាបតើតមហន្តរាយ ធ្លាក់ទៅក្នុងដម្រៅនៃការឈ្លានពានរបស់ពួកបរទេសនោះពុំខានឡើយ ។ ព្រោះហេតុនេះ យើងមិនត្រូវខ្ជះចិត្ត យកចិត្ត ឬក៏ស្និទ្ធស្នាលជាមួយនឹងពួកបរទេសអស់នេះ យកមកធ្វើជាមិត្តភក្តិសោះឡើយ ។ ព្រោះពួកនេះមិនមែនស្រឡាញ់យើងដោយស្មោះ ជាងយើងស្រឡាញ់ចង់ប្លន់ជាតិយើងនោះឡើយ ។

ឧទាហរណ៍ ដូចជាសព្វថ្ងៃនេះ សាធារណរដ្ឋខ្មែរយើង សាសនារបស់យើង កំពុងបានទទួលនូវការឈ្លានពានដ៏កំណាចយោរយៅបំផុតអំពីពួកទមិឡយៀកកុងយួនខាងដើង ។ តាមប្រវត្តិសាស្ត្របានចារបញ្ជាក់ច្បាស់យើងថា ពួកគេជាសត្រូវសួពូជរបស់ជាតិខ្មែរយើងសាសនារបស់យើង តាំងពីកាលណាកាលណាមកម្ល៉ះ ។ ឥឡូវនេះ ពួកគេហ្នឹងទៀតហើយ ដែលចូលមកប្លន់ទឹកដីយើង បំផ្លាញសាសនារបស់

យើង ដូចជាអស់លោក-អ្នកជាពុទ្ធបរិស័ទ ឃើញស្រាប់ ។ ដូច្នេះ ដើម្បីញ៉ាំងសាធារណរដ្ឋខ្មែរយើងនិងសាសនារបស់យើង ឲ្យមានជំហរមាំទាំ ត្រូវតែបង្ហូនខ្មែរយើង សុះក្រោកឡើង ដោយរួមជាមួយនឹងរដ្ឋាភិបាលស្រោចស្រង់ជាតិ ការពារដោយសេចក្តីអង់អាចក្លាហាន ។

កិច្ចការដែលមានមកប៉ុណ្ណេះជាដើមនេះ បើជនណា បានធ្វើ ឬបានជួយចាត់ចែងគ្នាទៅវិញទៅមកទៅតាមកម្លាំងសមត្ថភាពរបស់ខ្លួននោះ បើខុសជាស្ងាប់ ទៅគ្រាន់តែអស់ឱ្យលស់ដកដង្ហើមចេញចូល ក៏ពិតមែនហើយ ជននោះឯង ក៏ខុសដូចជាមានជីវិតរស់នៅដែរ សមដូចពុទ្ធភាសិតថា អប្បមោទោ អបណ្ឌិ បរិ ប្រែថា “ការមិនប្រមាទ ជាផ្លូវនៃសេចក្តីមិនស្ងាប់,, និងមួយទៀតថា អប្បមត្តោ ន មីយតិ ប្រែថា ជនទាំងឡាយណាមិនប្រមាទ ជនទាំងឡាយនោះ ឈ្មោះថាមិនស្ងាប់ ។

ហេតុដូចម្តេច ឬជាព្រះសម្ពុទ្ធត្រាស់ថា ជនដែលមិនប្រមាទ ឈ្មោះថាមិនស្ងាប់ ? ព្រោះថា ជនដែលមិនមានសេចក្តីប្រមាទនេះ គោលគឺជាអ្នកមានសតិសម្បជញ្ញៈទៅក្នុងខ្លួនជានិច្ច ជាអ្នកដួយឈឺឆ្អាលដួយខ្នះខ្នែងចំពោះកិច្ចការទាំងពួង មានកិច្ចការសម្រាប់ប្រទេសជាតិ ឬកិច្ចការសម្រាប់សាឬទាជាដើម ។ ឧទាហរណ៍ដូចជាពួកយុទ្ធជនយុទ្ធនារីយើង ដែលជាអ្នកអង់អាចក្លាហាន ឬបានឈរមុខគ្នោះចូលទៅទប់ទល់នឹងពួកខ្មាំង ដើម្បីញ៉ាំងពួកល្មោភទឹកដីអស់នេះឲ្យផុយចេញរំពីសាដោ-

រណរដ្ឋខ្មែរ ដើម្បីធ្វើឲ្យសាធារណរដ្ឋខ្មែរយើងសាសនារបស់យើងបានរុងរឿងឡើងវិញ ដោយមិនខ្វាចអំពីការឲ្យឃាត់ មិនខ្វាចអំពីសេចក្តីស្លាប់ សុខចិត្តយកជីវិតទៅធ្វើជាបង់ការពារ ដើម្បីឲ្យជាតិខ្មែរស់ឲ្យសាសនាថ្កុំថ្កើងរុងរឿង ។ ពួកយុទ្ធជន យុទ្ធនារីទាំងអស់ហ្នឹង បើទុកជាស្លាប់ទៅ ក៏ឈ្មោះថារស់នៅដែរ ព្រោះកិត្តិយសកិត្តិស័ព្ទរបស់យុទ្ធជនយុទ្ធនារីទាំងអស់នេះ នៅតែរស់រើកជានិច្ចនិរន្តរ៍ នោក្នុងទំព័រប្រវត្តិសាស្ត្រ ។ ព្រោះហេតុដូច្នោះហើយ បានជាព្រះសម្ពុទ្ធទ្រង់ត្រាស់ថា បើទុកជាស្លាប់ហើយ ក៏ដូចជាមានជីវិតរស់នៅដែរ ។

ផ្ទុយទៅវិញ អ្នកដែលមានសេចក្តីប្រមាទតាំងសិបក្នុងចិត្តហើយ បើទុកជារស់នៅដោយដង្ហើមចេញចូលក៏ដោយ ក៏ឈ្មោះថាស្លាប់ស្រេចទៅហើយ សមដូចពុទ្ធភាសិតថា យេ បមត្តា យថា មតា ប្រែថា „បុគ្គលពាំនាំយាយឯណាប្រមាទហើយ ពួកបុគ្គលនោះឈ្មោះថាស្លាប់ទៅ„ ហើយបទនិងបទថា បមាទោ មច្ចុនោ បទំ ប្រែថា „សេចក្តីប្រមាទ ជាផ្លូវនៃសេចក្តីស្លាប់„ ។

ហេតុអ្វីបានជាព្រះសម្ពុទ្ធត្រាស់ថា បុគ្គលប្រមាទ បើទុកជារស់នៅក៏ទុកដូចស្លាប់? ព្រោះថា បុគ្គលដែលមានសេចក្តីប្រមាទ មានតំនិតហ្នឹងស្លាប់ស្លូកតែម្តង ។ បើទុកជាប្រទេសជាតិរបស់ខ្លួនសាសនារបស់ខ្លួនត្រូវពួកទមិឡបួលមកបំផ្លាញ ក៏ធ្វើហាក់ដូចជាមិនឃើញមិនឮមិនដឹង

អ៊ីចឹង ។ បុគ្គលប្រកែកនេះ បើគុកជាមានដីវិតរស់នៅ អស់កប្ប អស់កល្បក៏ដោយ ក៏គុកដូចជាស្លាប់ស្រេចទៅហើយ ។ ព្រោះហេតុនោះ ហើយបានជាព្រះសម្ពុទ្ធទ្រង់ត្រាស់ថា „សេចក្តីប្រមាទជាផ្លូវនៃសេចក្តី ស្លាប់” ។

អ្នកប្រាជ្ញតំងឡាយ តែងត្រេកអរក្នុងផ្លូវនៃសេចក្តីមិនប្រមាទជា និច្ច ទំប្រឹងរក្សាទ្វារសេចក្តីមិនប្រមាទ ប្រៀបដូចជាគេរក្សាទ្វារទ្រព្យសម្បត្តិ ដូច្នោះដែរ សមដូចពុទ្ធភាសិតថា : អប្បមាទញ្ច មេធាវី ធនំ សេដ្ឋំវ រក្ខតិ ប្រែថា „អ្នកប្រាជ្ញតែងរក្សាទ្វារសេចក្តីប្រមាទនេះ ដូចជាគេរក្សាទ្វារទ្រព្យដ៏ប្រសើរ” ។



រឿងព្រះនាងសាមាវតី

[ត]

លោក ប៊ូ-ប៉ូ ប្រែ-រៀបរៀង

ទើនោះ ព្រាហ្មណ៍និយាយទំនឹកវិយាថា នាងអើយ ឯងឃើញមន្តដូចក្រតើក្នុងពាងទឹក ដូចចោរនៅកណ្តាលផ្ទះ ស្ងៀមទៅចុះ ។

នាងព្រាហ្មណីឆ្លើយថា ព្រាហ្មណ៍ អ្នកចង់និយាយដូចម្តេច ក៏និយាយដូច្នោះទៅចុះ នេះមិនមែនជាស្នាដៃរបស់អ្នកសេតបញ្ញាតាមគុណទេ ។

ព្រាហ្មណ៍គន់រកវាងនេះខ្វះវាងនោះខ្វ ឃើញព្រះសាស្តាហើយច្រាច់កវិយាថា នេះគឺបុរសនោះ ហើយទៅពោលថា សមណៈ ខ្ញុំឲ្យធីតា ដល់លោកដើម្បីឲ្យជិញ្ចឹមក្បែរគ្នា ។

ព្រះសាស្តាមិនបានត្រាស់ថា តថាគតមានសេចក្តីត្រូវការដោយធីតារបស់អ្នកឬថាមិនត្រូវការឡើយ ត្រាស់ថា ព្រាហ្មណ៍ តថាគតនឹងច្រាច់ហេតុមួយដល់អ្នក កាលគេទូលថា ច្រាច់ចុះ សមណៈក៏ត្រាស់ច្រាច់អាការៈ ដែលមានជាប់តាមព្រះអង្គចាប់ដើមអំពីចេញទ្រង់ព្រះផ្នួសដើម្បីមហាគុណរហូតដល់គល់ដើមជ្រៃដ៏ជាទីសម្ងាត់អាស្រ័យ នៃអ្នកគង្វាលពពែ និងពិធីការដែលពួកមារធីតាមក ដើម្បីរម្ងាប់សេចក្តីសោក

របស់មារនោះអ្នកពោលពាលដោយសេចក្តីថា ឥឡូវនេះ សិទ្ធាថិនឹង
គន្ធនវិស័យអញទៅហើយ លួងលោមព្រះអគ្គដោយអំណាចនៃកេនាង
កុមារីតូចៗជាដើម ហើយគ្រាស់ព្រះគាថានេះ មានសេចក្តីថា ៖

ព្រោះឃើញនាងតណ្ហា នាងអរតី និងនាងរគា សេចក្តីពេញ
ចិត្តក្នុងមេថុន នៅតែមិនបានមានដល់តថាគតបន្តិចសោះ ធ្វើម្តេចនឹងមាន
ព្រោះឃើញកូនក្រមុំអ្នកនេះ ដែលពេញទៅដោយមូត្រនិងការីស នាង
នេះសូម្បីតែដើងតថាគតក៏មិនចង់យកទៅច័ពាល់ផង ។

ក្នុងវេលាចប់គាថា ព្រាហ្មណ៍នឹងព្រាហ្មណីតាំងនៅក្នុងអនាគាមិផល
ហើយ ។

ចំណែកនាងមាគន្ធិយាកូនក្រមុំ នឹកចង់អាឃាត(ប្រទូសរ៉ាយ) ក្នុង
ព្រះសាស្តាថា បើព្រះសមណៈនេះមិនមានសេចក្តីត្រូវការដោយអញ ក៏
គួរតែប្រាប់សេចក្តីមិនត្រូវការ ប៉ុន្តែ នេះលោកមកថាអញដល់ឲ្យទៅជា
មនុស្សពេញទៅដោយមូត្រនិងការីស (ដូចសាកសព) ល្អើយចុះមិនអីទេ
ចាំអញអាស្រ័យសេចក្តីឃាដិយណិ ដោយជាតិត្រកូល ប្រទេស គោត្តសម្បត្តិ
យសនិងវ័យ ឲ្យកស្តាដូច្នោះហើយ និងដឹងរបស់ដែលនឹងគប្បីធ្វើ
ដល់សមណៈគោតម(គាល់តែបាន មិនឈប់ទេ) ។

មានសំណួរថា ចុះព្រះសាស្តាទ្រង់ជ្រាបការកើតឡើងនៃសេចក្តី
អាឃាតរបស់នាងក្នុងព្រះអគ្គដែរឬទេ ។

មានចម្ងល់ថា ទ្រង់ជ្រាបពិតប្រាកដណាស់ ។

សំនួរ- កាលបើទ្រង់ជ្រាបហើយ ហេតុអ្វីបានជាត្រាស់ព្រះគាថានេះ ។

ចម្លើយ- ព្រះអង្គត្រាស់ដោយអំណាចនៃនាគប្តីប្រពន្ធ(តែម្យ៉ាង) ។ ធម្មតាព្រះពុទ្ធទាំងឡាយមិនទ្រង់វល់អើពើ និងការអាឃាតឡើយ ទោះជាធំដុំយ៉ាងណាក៏ដោយ ទ្រង់សម្តែងធម៌ ដោយអំណាចនៃអ្នកគួរសម្រេចមគ្គនិងផលតែម្យ៉ាងប៉ុណ្ណោះ ។

មាតាបិតានាគមាណវិកានោះ ក៏ប្រគល់ឲ្យប្អូនប្រុសឈ្មោះមាគន្ធិយៈ ជាឪពុកមារបស់នាង រួចក៏កាន់សម្លាក់ព្រះសាស្តាបួសទាំងពីរនាក់បានសម្រេចព្រះអរហត្តហើយ ។ ចំណែកនាយមាគន្ធិយៈ រំពឹងគិតថា បុត្រីក្រមុំអញបើមិនគួរសមដល់អ្នកថ្លៃកខាបទេ ជាគួរគួរសមតែដល់ព្រះពុទ្ធមួយអង្គប៉ុណ្ណោះ ហើយនាំនាងទៅកាន់នគរកោសម្ពី តាក់តែងដោយគ្រឿងអាភរណៈទាំងពួងរួចហើយបានថ្វាយដល់ព្រះបាទឧទេន ក្រាបទូលថា សូមព្រះតេជៈ ព្រះអង្គ កែវគឺស្រីសមគួរដល់ល្អងធួលីព្រះបាទ (ខ្ញុំព្រះអង្គសូមថ្វាយចំពោះព្រះអង្គ) ។ ព្រះពុទ្ធាទតឃើញនាងមានព្រះពាលវស្នេហាកើតហើយ ព្រះពុទ្ធានុភាពទ្រង់ចាត់ស្រីក្រៅរយឲ្យជាបរិវារបស់នាងហើយ ទ្រង់តម្កល់ទុកក្នុងតំណែងព្រះអគ្គមហេសី ។ នេះរឿងក្បែរព្រះនាងមាគន្ធិយា ។

ព្រះបាទឧទេននោះ មានព្រះអគ្គមហេសីបីអង្គ ហាននាងវប្បាំ
មួយពាន់ប្រាំរយនាក់ជាបរិវារ មានវត្ថុនិពាន្ធដូចពាណិនាមកនេះ ។
ក៏ក្នុងសម័យនោះឯង ក្នុងព្រះនគរកោសម្ពីមានសេដ្ឋីបីនាក់ គឺ
យោសកសេដ្ឋីមួយ កុក្កុដសេដ្ឋីមួយ ឃោសិតសេដ្ឋីមួយ ។ លោក
សេដ្ឋីទាំងនោះឃើញព្រះតាបសប្រាំរយមកអំពីព្រៃហិមវន្ត ក្នុងកាលថ្ងៃ
ដំណើរសម្បូរបាយិកា ត្រាច់ទៅដើម្បីតិក្ខាក្នុងព្រះនគរជ្រះថ្លាទិមន្តឲ្យគង់
ឲ្យបរិភោគហើយ កាន់យកប្តេជ្ញាទិមន្តឲ្យឈប់នៅក្នុងសម្នាក់អស់បួនខែ
ហើយ ឲ្យពួកលោកប្តេជ្ញាដើម្បីមកវិញ ក្នុងគ្រារដូវភ្លៀងបញ្ជានៅ
ហើយ ។ តាំងអំពីនោះមក សូម្បីពួកព្រះតាបសនៅក្នុងព្រៃហិមវន្ត
អស់ ៨ ខែហើយ ឃាននៅក្នុងសម្នាក់សេដ្ឋីទាំងនោះបួនខែ ។ ក្នុង
សម័យជាចំណែកដទៃទៀត ព្រះតាបសទាំងនោះមកអំពីព្រៃហិមវន្តឃើញ
ដើមជ្រៃធំមួយដើមក្នុងដងព្រៃ ហើយនាំគ្នាអង្គុយឈប់សម្រាកត្រង់គល់
ឈើនោះ ។ ព្រះតាបសដែលជាប្រធានក្នុងពួកនោះនឹកក្នុងចិត្តថា
ទេវតាដែលស្ថិតក្នុងដើមឈើនេះគប្បីជាការណ៍ណាស់ហ្ន៎ បើទេវតានេះ
ឲ្យទឹកផាន់ហើយ ។ ព្រះតាបសនឹករកទឹកសម្រាប់ឆ្ងូត ។ សូម្បីទឹក
សម្រាប់ឆ្ងូត ទេវតាក៏ឃានថ្វាយហើយ ។ អំពីនោះលោកនឹកចង់
ឃាននាវជន ។ ទេវតាក៏យកមកថ្វាយ ។ ទើបព្រះតាបសនឹករំពឹង
ថា ទេវតានេះឲ្យរបស់ដែលពួកយើងនឹក ។ ត្រង់ឃ៉ាង ធ្វើម្តេចហ្ន៎យើង

ទាំងព្រាយគប្បីឃើញទេវតា ។ ទេវតានោះទម្លាយដើមឈើចេញមក សម្តែងបង្ហាញខ្លួនហើយទើនោះពួកតាបសទើបបានសួរទេវតាថា ទេវកដ សម្បត្តិរបស់អ្នកធំកន្តូច ធ្វើអ្វីទុកមកហ្ន៎ ទើបបានសម្បត្តិនេះ ។

ទេវតាឆ្លើយ- កុំសួរឡើយ លោកម្ចាស់ ។

ពួកតាបសអង្វរ- ប្រាប់ផងចុះ ទេវកដ ។ ទេវតាអៀនខ្មាស ព្រោះកម្មដែលខ្លួនធ្វើទុកតែបន្តិចបន្តួចសោះមិនអាចប្រាប់បាន ប៉ុន្តែកាលបើត្រូវពួកតាបសដដែកសួរញយៗ ពេក ទើបប្រាប់ថា បើវូរ្នោះចាំស្តាប់ចុះ ហើយក៏ដំណាលរឿងរបស់ខ្លួនប្រាប់ ។

ដូចបានឮមក ទេវតានោះ(ជាតិមុន)ជាមនុស្សក្រមម្រេះទុគ៌តម្នាក់ស្នែង ការងារឈ្លួលក្នុងសម្នាក់លោកអនាថបិណ្ឌិកសេដ្ឋី ហើយអាស្រ័យការងារនោះចិញ្ចឹមជីវិត ។ តមក កាលដល់ថ្ងៃឧបោសថមួយ អនាថបិណ្ឌិក មកអំពីវិហារហើយ សួរថា ថ្ងៃនេះជាថ្ងៃឧបោសថ អ្នកណាប្រាប់ដល់អ្នកស៊ីឈ្នួលហើយឬនៅ ។

មនុស្សក្នុងផ្ទះ មិនបានប្រាប់ទេ លោកម្ចាស់ ។

សេដ្ឋី- បើវូរ្នោះចូរជាំបាយល្ងាចទុកដើម្បីគេផង ។

លំដាប់នោះ ពួកអ្នកគ្រួទើបជាំបាយប្រមាណអង្គរមួយបត្ថ: (មួយកំបងដៃ) ទុកដើម្បីគេ ។ ថ្ងៃនោះ គេ(ទៅ)ធ្វើការក្នុងព្រៃ ត្រឡប់មកដល់វេលាល្ងាច កាលគេដួសបាយឲ្យហើយ មិនទាន់បរិភោគដោយ

សំគាល់ថាអញមិនទាន់ឃ្លានទេនឹកថាក្នុងថ្ងៃដទៃ។ ក្នុងផ្ទះមានសេចក្តីកោលាហលធំដោយសូរសម្រែង ស្រាប់តែយំគ្នាថា ចូរឲ្យបាយ ចូរឲ្យសម្លរ ចូរឲ្យអន្ទក់ (ប៉ុន្តែហេតុអ្វី) ថ្ងៃនេះស្ងាត់សម្រែង ដេកគ្រប់គ្នា ដូសអាហារខុក ដើម្បីអញម្នាក់ឯងប៉ុណ្ណោះ នេះដូចម្តេចអេះ ហើយសួរថា មនុស្សស្រែពីនោះបរិភោគរួចហើយឬនៅ ។

មនុស្សក្នុងផ្ទះ- គេមិនបរិភោគគ្រប់គ្នា អ្នក ។

ភូនឈ្លស - ដោយហេតុអ្វីណា៎ះ ។

មនុស្សក្នុងផ្ទះ- ក្នុងចំនួនថ្ងៃឧបោសថ ក្នុងផ្ទះនេះ គេមិនដាំបាយល្ងាចទេ គេរក្សាឧបោសថគ្រប់គ្នា ដោយខ្ជិលផុតសូម្បីតែភូនក្មេងទៅហ៊ុងដោះ លោកមហាសេដ្ឋីក៏ចាត់ឲ្យខ្ញុំមាត់ចេញដែរ ហើយឲ្យគេដាក់ចតុមធុរសចូលក្នុងមាត់ ឲ្យធ្វើឧបោសថហើយ គាល់ប្រទីបប្រេងត្រអូបនេះភ្លឺឡើង ក្មេងតូចក្មេងធំចូលទីដំណេកស្ងាធ្លាយខ្លួតឹសាការៈ (អាការៈ ៣២) ពួកយើងក្មេចប្រាប់ដល់អ្នកទ្វារការៈនៃថ្ងៃនេះជាថ្ងៃឧបោសថ ព្រោះហេតុនោះ ឃានជាដាំបាយខុកដើម្បីអ្នកតែម្នាក់ឯង អរញ្ជើញបរិភោគចុះ។

ភូនឈ្លស - បើខ្ញុំរក្សាឧបោសថក្នុងពេលនេះបាន ខ្ញុំក៏គប្បីរក្សាដែរ ។

អ្នកក្នុងផ្ទះ - ការរក្សាឃានឬមិនឃានេះ លោកសេដ្ឋីដឹង ។

ភូនឈ្លស- បើដូច្នោះ អ្នកគាំងឲ្យអាណិតសួរលោកបើស ។

គេទាំគ្នាសួរលោកសេដ្ឋីហើយ ។ លោកប្រាប់សេចក្តីយ៉ាងនេះឥឡូវ
នេះ គេមិនមានបំបាត់ទេ ឲ្យតែមាត់ចេញហើយអធិដ្ឋានអង្គឧបោ
សថ នឹងបានឧបោសថកម្មពាក់កណ្តាល ។

កូនឈ្លួលបានស្តាប់ហេតុផលនោះហើយបានធ្វើតាមនោះ ។ កាល
គេធ្វើការពេញមួយថ្ងៃនៅឃ្លាន (ហើយរក្សាឧបោសថអត់អាហារដូច្នោះ
ទើបឲ្យលាក្នុងពេលយកម្រើក ។ គេយកខ្សែបង់តែនោះ កាត់ពុងខ្សែ
ទុកបម្រុងនៀល ។ លោកសេដ្ឋីជ្រាបហេតុនោះហើយ មានអ្នកកាន់
តប់ភ្លើងប្រើឲ្យមនុស្សយកចតុមធុរសមកកាន់សម្លាក់គេហើយសួរថា ឈឺ
អ្វី កូន ។

កូនឈ្លួល – ឲ្យលាក់ម្រើកដល់ខ្ញុំ លោកម្ចាស់ ។

សេដ្ឋី – បើដូច្នោះ ឯងចូរក្រោកឡើងទំពាស៊ីថ្នាំនេះ ។

កូនឈ្លួល – លោកម្ចាស់ ចុះលោកពីសាហើយឬទេ ។

សេដ្ឋី – សេចក្តីមិនសប្បាយមិនបានវានដល់ខ្ញុំទេ ឯងចូរទំពាស៊ី
ចុះ ។

កូនឈ្លួល – លោកម្ចាស់ កាលខ្ញុំធ្វើឧបោសថ នៅមិនអាចនឹងធ្វើ
ឲ្យពេញទីបាន សូម្បីតែឧបោសថកម្មពាក់កណ្តាលបែរខ្ញុំ កុំបានកែល
ខ្លះខាតទៅរួយ និយាយដូច្នេះមិនត្រូវថ្លា (ដើម្បីទំពាស៊ីថ្នាំសោះ) ។

បើពុតជាលោកសេដ្ឋីនិយាយអង្វរថា អ្នកឯងកុំធ្វើយ៉ាងហ្នឹង គេ

ក៏នៅតែមិនច្បាស់ថា តាលអរុណរះឡើងធ្វើមរណកាលហើយ ឬ
ដូចផ្កាដែលស្វិតស្រពោនទៅដូច្នោះ តើតជាទេវតាក្នុងដើមឈើនោះ ។

ហេតុដូច្នោះ ទេវតានោះដំណាលសេចក្តីនេះចប់ហើយនិយាយតទៅ
ទៀតថា លោកសេដ្ឋីនោះកាន់អានព្រះពុទ្ធថាជារបស់អញ កាន់អានព្រះ
ធម៌ថាជារបស់អញ កាន់អានព្រះសង្ឃថាជារបស់អញ ខ្ញុំបានសម្បត្តិនោះ
ដោយផលនៃឧបោសថកម្មពាក់កណ្តាល ដែលបានអាស្រ័យលោកសេដ្ឋី
នោះធ្វើហើយជាច្រើនជាតិ ។

ព្រះតាបសច្រំាយស្តាប់ពាក្យថា ព្រ ពុទ្ធ ប៉ុណ្ណោះ ក្រោកឡើង
ប្រណម្យអញ្ជលីដល់ទេវតាពោលអង្វរថា សូមអ្នកពោលថា ព្រះពុទ្ធ
អញ្ជើញទៅទេវតាប្តេជ្ញាថា ខ្ញុំពោលថា ព្រះពុទ្ធ ដូច្នេះបីដងហើយ ឋិតឋិ
ឧទានថា សូមឱ្យសម្លេងប្រកាសនេះឯងកុំបានត្រឹមតែ [illegible] ហើយពោល
ថា ឋបិត្រទេវតា អ្នកឱ្យពួកខ្ញុំស្តាប់ [illegible] ដែលមិនធ្លាប់ស្តាប់ក្នុង
សែននៃកប្បមិនតិចហើយ ។

លំដាប់នោះ អន្តេវាសិកតាបសបានពោលភាក្យនេះ នឹងអាចារ្យថា
បើដូច្នោះ ពួកយើងទៅកាន់សម្នាក់ព្រះសាស្តាចុះ ។

តាបសអាចារ្យ – កូនទាំងឡាយ សេដ្ឋីនោះមានឧបការដល់ពួក
យើងជាច្រើន ថ្ងៃស្អែក យើងទទួលគិច្ចាទៅចុះគេ ប្រាប់ដំណឹងដល់
គេរួចចាំទៅ បង្អង់សិនចុះកូនទាំងឡាយ ។

ពួកតាបសឈប់នៅហើយ ។ ថ្ងៃព្រឹកឡើង ពួកសេដ្ឋីចាត់ចែងបបរនិងកត្តុក ឲ្យមនុស្សក្រាលអាសនៈទុកដាំងថា ថ្ងៃនេះ ជាថ្ងៃពួកលោកជាម្ចាស់នៃយើងគាំងឡាយមកដល់ ហើយការទទួលនាំពួកលោកទៅកាន់ផ្ទះឲ្យគង់ហើយឃាន់ច្រវែនកិក្ខាហើយ ពួកតាបសធ្វើតត្តកិច្ចរួចហើយពោលថា លោកមហាសេដ្ឋី ពួកអាត្មានឹងទៅ ។

សេដ្ឋី- បពិត្រលោកដ៏ចម្រើនគាំងឡាយ លោកទទួលប្តេជ្ញារបស់ពួកខ្ញុំទុកក្នុងបួនខែ មានក្នុងរដូវក្តៅនេះមែនឬទេ នឹងទៅឯណាក្នុងឥឡូវនេះ ។

តាបស- ឃានតុម្ហាណីដ៏ថា ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ កើតឡើងហើយក្នុងលោក ត្រាំដូច្នោះ ពួកអាត្មានឹងទៅកាន់សម្នាក់ព្រះសាស្តា ។

សេដ្ឋី- ចុះការទៅកាន់សម្នាក់ព្រះសាស្តាអង្គនោះ គួរដល់លោកគាំងឡាយតែប៉ុណ្ណោះទេឬ ។

តាបស- សូម្បីមនុស្សភ្លក្ខដទៃក៏ទៅបានមិនហាមឃាត់ទេ លោក។

សេដ្ឋី- បើដូច្នោះ ត្រូមបង្អន់ចាំបន្តិចសិន ព្រះគុណាពួកខ្ញុំធ្វើការរៀបចំស្រេចហើយ នឹងទៅដែរ ។

តាបស- កាលពួកលោកធ្វើការរៀបចំ ដំណើរយើងយូរនឹងមានដល់អាត្មាគាំងឡាយ ពួកអាត្មានឹងទៅមុន លោកគាំងឡាយតាមមកខាង

ក្រោយ ពោលដូច្នេះហើយ ពួកតាបសទៅមុខ ឃើញព្រះសម្មាសម្ពុទ្ធ ហើយពោលសរសើរ ថ្វាយបង្គំហើយគង់ក្នុងចំណែកម្ខាង ។

ទើបព្រះសាស្តាទ្រង់ត្រាស់អនុបុព្វីកថា សម្តែងធម៌ដល់ពួកតាបស ហើយ ។ ក្នុងទីបំផុតព្រះទេសនា តាបសតាំងអស់បានសម្រេចព្រះអរហត្ត ព្រមដោយបដិសម្ភិទាទូលសូមបព្វជ្ជា ទ្រទ្រង់ជាត្រនិងចីវរដ៏សម្រេចដោយឫទ្ធិបីដូចជាព្រះថេរៈមានវស្សាមួយរយ ក្នុងលំដាប់នៃព្រះតម្រាស់ថា ឯថ តិក្ខត្តុំ ម្នាលភិក្ខុទាំងឡាយ ជាតិទុមកចុះ ដូច្នេះតែម្តង។

សេដ្ឋីតាំងបីនាក់នោះឯង យកវរទេះប្រាំរយ ។ ម្នាក់ផ្ទុកទានុបករណ៍មានសំពត់គ្រឿងសៀកដណ្តប់ សប្បិ ទឹកឃ្មុំ និងទឹកអំពៅជាដើម ទៅដល់ព្រះនគរសាវត្ថីហើយចូលទៅកាន់ព្រះជេតពន ថ្វាយបង្គំព្រះសាស្តា ហើយ ស្តាប់ព្រះធម្មកថា ក្នុងវេលាចប់កថា តាំងនៅក្នុងព្រះសោតាបត្តិផល ហើយឲ្យទានប្រមាណត្រឹមកន្ទុះវែងនៅក្នុងសម្លាក់ព្រះសាស្តា ហើយចូលអាភធនាព្រះសាស្តា ដើម្បីស្តេចទៅកាន់ព្រះនគរកោសម្ពីភាល ព្រះសាស្តាទ្រង់ប្រទានប្តេជ្ញាត្រាស់ថា ម្នាលគហបតីតាំងឡាយចូរណាព្រះតថាគតត្រែកអរក្រៃលែងក្នុងទីអាលនេះគ្រាប់ទូលថា ពួកខ្ញុំព្រះអង្គ សូមព្រះអង្គស្តេចទៅតាមដំណឹងដែលពួកខ្ញុំព្រះអង្គបញ្ជូនមកថ្វាយគួរ ហើយទៅដល់ព្រះនគរកោសម្ពី សាងមហាវិហារបីកន្លែងគឺ ឃោសការាមដ៏សាង ឃោសំតារាមកុក្កដសេដ្ឋីសាងកុក្កដារាម ជាវារិការាមសេដ្ឋីសាង ជាវារិការាម

ហើយបង្ហានដំណឹងទៅក្រាបទូល ដើម្បីប្រយោជន៍ដល់ព្រះសាស្តាស្តេចមក ។ ព្រះសាស្តាទ្រង់ព្រះសណ្តាប់ដំណឹងរបស់គេហើយ ក៏បានស្តេចទៅក្នុងព្រះនគរនោះ ។ គេតាំងឡាយទូលអញ្ជើញស្តេចព្រះសាស្តាឲ្យចូលក្នុងវិហារហើយប្រគល់ថ្វាយដោយពាក្យថា យើងខ្ញុំព្រះអង្គ សូមថ្វាយវិហារនេះដល់កិក្ខុសង្ឃមកអំពីទិសបួន មានព្រះពុទ្ធជាប្រធាន ដូច្នេះបីដងហើយផ្ទាស់វេនគ្នាប្រតិបត្តិ ។ ព្រះសាស្តាគង់នៅក្នុងវិហារមួយ ។ មួយថ្ងៃ ស្តេចគង់ក្នុងវិហារបស់អ្នកណា រមែងស្តេចត្រាច់ទៅដើម្បីចំណូលបាតត្រង់ទ្វារផ្លូវនៃអ្នកនោះឯង ។

ក៏សេដ្ឋីបីនាក់នោះ មានឧបាសិកាមួយ តែជាឯអ្នកក្រឯកម្រង៉ផ្លាឈ្មោះ សុមនៈជាអ្នកបម្រើ ។ គេនឹងលោកសេដ្ឋីទាំងនោះយ៉ាងនេះ ខ្ញុំធ្វើឧបការដល់លោកអស់កាលដ៏យូរ ខ្ញុំចង់ទទឹងព្រះសាស្តាឲ្យទ្រង់សោយ លោកកុំឲ្យព្រះសាស្តាដល់ខ្ញុំមួយថ្ងៃចុះ ។

សេដ្ឋី – បើដូច្នោះ ម្នាលនាយ ចូរឲ្យទ្រង់សោយមួយថ្ងៃចុះ ។

សុមនៈ ប្រពៃហើយ លោក គេនោលដូច្នោះហើយ និមន្តព្រះសាស្តាហើយ ចាត់ចែងការសក្ការៈ ។

គ្រានោះ ព្រះរាជា (ឧទេន) ព្រះរាជទានតម្លៃកម្រង៉ផ្លាដល់ព្រះនាងសាមាវតី មួយថ្ងៃក្រាំបីកហាបណៈ ។ (នៅមានត)

វិចារណកថា :

តើរុក្ខជាតិមានវិញ្ញាណឬទេ

ចំពោះបញ្ហានេះ អ្នកប្រាជ្ញជាច្រើនតែងមានយោបល់ផ្សេង ។ គ្នា អ្នកខ្លះជាវុក្ខជាតិឥតមានវិញ្ញាណទេ អ្នកខ្លះថាវុក្ខជាតិមានវិញ្ញាណ ។

យើងសូមលើកយកបញ្ហាដែលថាវុក្ខជាតិមានវិញ្ញាណ មកពិចារ-ណាដោះស្រាយជាបឋម ។ ចុះហេតុដូម្តេចបានជាគេថាវុក្ខជាតិមាន វិញ្ញាណ ។ បានជាគេថាវុក្ខជាតិមានវិញ្ញាណដែរ ព្រោះគេសង្កេតឃើញ ថា វុក្ខជាតិមានដុះឬកើត លូតលាស់មានផ្ទៃក្នុង រួចងាប់ឬស្វាប់ទៅវិញ ។ ចំណែកឯសត្វផងទាំងពួង ក៏មានកើតចំរើនលូតលាស់ ធំបន្តិចម្តងៗ លុះទី បំផុតក៏ត្រូវស្វាប់ទៅវិញ ដូចគ្នាទាំងវុក្ខជាតិផងដែរ ។ ដូច្នេះហើយបាន ជាគេថាវុក្ខជាតិក៏មានវិញ្ញាណដូចជាសត្វដែរ ។ គេអាងទៀតថា ព្រោះ មានវុក្ខជាតិខ្លះក៏មានចលនាស្មើរនឹងសត្វដែរ ដូចជាដើមប្រក្រាម ។ នេះ បើកាលណាមនុស្ស ឬ សត្វណាទៅធ្វើឲ្យប៉ះពាល់ដល់ជាងក់ ឬ ដើមវា ។ ក៏ខ្មាក់ស្លឹក ខ្មាក់ជាងរួចរញ្ជួយមួយរំពេច ឯការរញ្ជួយនេះហើយ សឲ្យ យើញថាដើមប្រក្រាមនេះមានវិញ្ញាណ ព្រោះវិញ្ញាណប្រែថាដឹងអារម្មណ៍ ឬចាប់អារម្មណ៍ផ្សេង ។ គឺដឹងថាក្តៅ ដឹងថាត្រជាក់ ដឹងថាមានភ្លើមកប៉ះ

ពាល់ ម្ល៉ោះហើយដើមប្រក្រាបក៏ត្រូវតែរញួមកាលណាមានអ្វីមកប៉ះពាល់វា ដោយយកហេតុនេះជាគ្រឿងអាង ទើបគេចាត់ទុកថាដើមរុក្ខជាតិមានវិញ្ញាណ ។ ម៉្យាងទៀតគេពោលអាងថា រុក្ខជាតិក៏ត្រូវការចំណីអាហារដូចជាសត្វរស់ដែរ កាលណាបើខ្វះដីជាតិ ខ្វះទឹក រុក្ខជាតិក៏ត្រូវតែស្លាប់ ។ ដោយអាងហេតុដូចពោលមកនេះហើយ ទើបគេពោលថារុក្ខជាតិមានវិញ្ញាណ ។

ចំណែកអ្នកប្រាជ្ញខ្លះពោលថា រុក្ខជាតិឥតមានវិញ្ញាណទេ ។ ចុះបើឥតវិញ្ញាណ ហេតុដូចម្តេចក៏រុក្ខជាតិ មានការកើតដុះលូតលាស់រួចត្រូវស្លាប់ទៅវិញដូចសត្វដែរ? អ្នកប្រាជ្ញនេះពោលអះអាងថា រីឯការកើតដុះលូតលាស់និងការងាប់នេះ ទុកជាសភាវគតិរបស់សង្ខារទាំងឡាយក្នុងលោក កុំថាឡើយតែរុក្ខជាតិ សូម្បី ដី ថ្ម ភ្នំ រួមសេចក្តីទៅអ្វីៗ ទាំងអស់ក្នុងលោកមែនតែធ្លាក់ចុះទៅក្នុងអនិច្ចតាធម៌ដូចគ្នាទាំងអស់ ។ រីងរុក្ខជាតិកកើតឡើងដោយការផ្សំជាតុទាំងបួន គឺជាតុទឹក ជាតុដី ជាតុភ្លើង និងជាតុខ្យល់ ។ នៅពេលដំបូង គឺជាតុទាំងបួននេះផ្សំគ្នា ប្រសុំចូលគ្នាជារុក្ខជាតិអ្វីមួយមានដើមស្មៅជាដើម រួចក៏ចាប់ដុះលូតលាស់ឡើង ។ ចំណែកការដុះលូតលាស់នេះក៏អាស្រ័យដោយហេតុទាំងបួន ជាខាងក្រៅដែរ គឺថាជាតុដីត្រូវនៅប៉ះគ្នានឹងជាតុដីខាងក្នុង ជាតុទឹក ក៏ត្រូវប្រស្រ័យគ្នានឹងជាតុទឹកខាងក្នុង ជាតុភ្លើងក៏ត្រូវទៅជាក់ទងនឹងជាតុភ្លើងខាងក្នុង ជាតុ

ខ្យល់ក៏ត្រូវទៅអស្រ័យនឹងធាតុខ្យល់ខាងក្នុងដែរ លុះធាតុទាំងបួននេះទៅ ប៉ះប្រស្រ័យគាក់ខន្ធនឹងធាតុទាំងបួនខាងក្រៅរបស់រុក្ខជាតិ ទើបរុក្ខជាតិនោះក៏កកើតដុះលូតលាស់ឡើង ជាលំដាប់តរហូតទៅតាល់តែអស់កម្រិតវាទើបវាត្រូវវិនាសទៅវិញ គានពួកគឺថាខ្លះក៏ធាប់ដល់កម្រិត ខ្លះក៏យូរពាប់រយឆ្នាំទៅក៏មាន ។

រីឯអ្នកអាងថាមានដើមរុក្ខជាតិខ្លះដូចជាដើមប្រក្រាបនេះ មានចលនានេះខ្មាក់ស្ងឹក និងមែក ជាដ ក្នុងពេលដែលមានភ្លៀងប៉ះពាល់វានោះ ចេះតែសភាវៈគតិរបស់វាតែប៉ុណ្ណឹងឯង តែទឹងថាដើមប្រក្រាបចេះរត់ចេះដើរដៀសចេញខ្លាចអន្តរាយមកប៉ះពាល់នោះ គឺអត់មានឡើយ ។ ប្រសិនជាគេយល់ថាដើមប្រក្រាបមានវិញ្ញាណ ព្រោះតែចេះរញ្ជួយ ចេះខ្មាក់ស្ងឹក ជាដ នៅពេលដែលមានអ្វីទៅប៉ះពាល់នោះ យើងសូមលើកយកម៉ាស៊ីនសព្វយ៉ាងដែលគេតាក់តែងរួចស្រេចដូចម៉ាស៊ីនទាឡិកាជាដើម តែគេមួលភ្លៅទៅចេះដើរ ១ ថ្ងៃវាល់ល្ងាចក៏មាន ១ ថ្ងៃ ១ យប់ក៏មាន១ អាទិត្យក៏មាន ហើយចេះចង្អុលម៉ោងនេះ ។ល។ ១.២-៣-៤-៥ រហូតដល់ ១២ រួចផ្ទាស់មកចង្អុលពី ១ ទៅទៀតឥតមានមនុស្សណាទៅជាញាក់ឡើយ ដូច្នេះគួរតែថាទាឡិកាមានជីវិត និងមានវិញ្ញាណដែរទើបត្រូវ ។ រឿងម៉ាស៊ីននិងរឿងរុក្ខជាតិនេះ មានចំនងមិនជាខុសគ្នាប៉ុន្មានឡើយ ព្រោះវត្ថុទាំងពីរនេះ សុទ្ធតែផ្សំជាធាតុទាំងបួន រួចទើបកកើតឡើង បើខ្វះធាតុណាមួយ ក៏វត្ថុ

ទាំងពីរនេះមិនអាចនាំទៅយ៉ាងបានឡើយ ។

ពាក្យថាវិញ្ញាណនេះប្រែថាសភាវៈដឹងសព្វគ្រប់ ឬប្រែថាចិត្តតែម្តងក៏បាន ។ រីឯរូបសត្វផងទាំងពួងមានមនុស្សជាដើម ក៏ត្រូវផ្សំដោយធាតុទាំងបួនគឺមហាភូតរូបនេះឯង ទើបកកើតឡើង ហើយចម្រើនលូតលាស់រួចទាស់ស្លាប់ទៅវិញដូចរុក្ខជាតិដែរ តែហេតុដូចម្តេចក៏សត្វមានចលនា ? ចំណែករុក្ខជាតិគ្មានចលនា ប្រសិនបើមានខ្លះ ក៏ជាសភាវគតិរបស់វាតើមកពីហេតុអ្វី ? វាមកពីមនុស្សមានវិញ្ញាណ រួចចលនាមនុស្សនេះទៀតមិនជាសភាវៈគតិដូចជាចលនាដើមប្រក្រាបឡើយ គឺថាដើមប្រក្រាបចេះតែទម្លាក់ស្លឹករួចញោមដល់ឃ្លាបន្តិចទៅក៏ស្លឹកវានោះងើបឡើងវិញ រួចបើមានភ្លឺមកប៉ះពាល់ក៏ទម្លាក់ស្លឹកទៀត ហើយចេះតែដូច្នេះរហូតៈទៅ ប្រសិនមានអ្វីមកប៉ះពាល់ទៀត ។ បើកាលណាហើយដើមប្រក្រាបមានវិញ្ញាណដូចមនុស្សនោះមុខជាឈប់ដុះទៅត្រង់កន្ទែងហ្នឹងទៀតហើយ ។ ទៅរកដុះទៅកន្ទែងដទៃដែលគ្មានអ្វីមកទំនាន់នោះ នេះមិនដូច្នេះ សូម្បីគេយកដំបងមកសំពងគាល់តែខ្លួច ក៏ដើមប្រក្រាបមិនព្រមដើរចេញទៅណា គឺទៅស៊ូទ្រាំគាល់តែវិនាសអន្តរាយ ។ ត្រង់នេះហើយដែលហៅថារុក្ខជាតិឥតមានវិញ្ញាណទេ ដែលមានចលនាបន្តិចបន្តួចគឺជា សភាវ គតិរបស់វាតែប៉ុណ្ណោះឯង។

រីឯវិញ្ញាណនេះជាវត្ថុធាតុធំណាស់ គឺចេះដឹងសព្វ គឺថា ចេះដឹងថាឈឺ ថាក្តៅ ថាត្រជាក់ ហើយត្រូវដើរចៀសចេញ ត្រូវដើរស្វះស្វែង

រកកន្លែងណាដែលផ្តល់សេចក្តីសុខដល់ខ្លួន ទើបអាស្រ័យនៅត្រង់កន្លែងនោះតទៅ ។

ចុះបើសត្វនិងមនុស្សមានវិញ្ញាណដូចគ្នា ហេតុដូចម្តេចក៏មនុស្សមានការចម្រើនជាងសត្វ ? ចំពោះរឿងនេះ គឺមានកត់អាថ៌កំបាំងមួយដ៏ធំ និង ដ៏សម្ងាត់នៅក្នុងខ្លួនមនុស្ស ជាអាថ៌កំបាំងដែលមនុស្សភាគច្រើនមិនសូវដឹងយល់ដល់ប៉ុន្មាន ។ រីឯអាថ៌កំបាំងនោះគឺ ធម្មសញ្ញានេះឯង ។ គឺការណ៍នេះហើយដែលធ្វើឲ្យមនុស្សមានសភាពប្លែកពីសត្វតិរច្ឆាន ។

ចំពោះសេចក្តីសន្និដ្ឋានស្តីពីរុក្ខជាតិមានវិញ្ញាណដូចជាមនុស្ស ឬ មិនមានវិញ្ញាណនេះ យើងក៏យល់ថារុក្ខជាតិពិតជាគ្មានវិញ្ញាណអ្វីបន្តិចបន្តួចឡើយ ។ ហេតុដូច្នេះហើយទើបការសម្លាប់រុក្ខជាតិ ក្នុងគម្ពីរព្រះពុទ្ធសាសនា គេហៅថារុក្ខជាតិសូត្ត គេមិនហៅដូចពាក្យលោកវោហារនេះទេ ព្រោះពាក្យវាស្លាប់ត្រូវតែកើត ហើយការកើតនេះត្រូវឲ្យមានវិញ្ញាណទៅសណ្ឋិតនៅក្នុងរូបនោះផង ។ ដូច្នេះយើងយល់ថាលោកអ្នកប្រាជ្ញណាដែលយល់ថារុក្ខជាតិមានវិញ្ញាណនោះ គឺពិតជាយល់ដោយកត្តព្រឡឹងដ៏ពិតប្រាកដ ។

ដេង ត្រីវ

៩-១០-៧១

រឿងសាមកុក

ឧកញ៉ាវិបុលរាជសេនា ន្ង - កន

ប្រែ - រៀបរៀង

(ត)

> រឿងសាមកុកកុកដាយុទ្ធសាស្ត្រ អ្នកវាងវៃឆ្លាសបើបានអាន
> នឹងចេះឧបាយកលចំណាន ទាំងមានសន្តានស្នេហាជាតិ
>
> ——យួរ-អ៊ុន

ខើបខុងចេង យកតម្រានោះមកណែនាំឲ្យកៀងអ៊ុយមើលហើយប៉ា តម្រាក្របឈើនេះបងស់យើងគិតខ្វួនឯង តែនៅមិនទាន់ធ្លើល្ប្ងមើល បើអ្នកយកទៅហើយត្រូវធ្លើមើលឲ្យដឹងចុះ ឫញ៉ាំម្ដងឫនព្រួញ ១០ កៀងអ៊ុយតំនាប់ហើយទទួលទុក ខុងចេងថា : អ្នកចូរទំនុកចំរុងផែនដីតាមតម្រានេះចុះ ឯស្រុកសែឈួននោះ គ្មានសត្រូវកន្ងឯចូលទៅធ្លើអន្តរាយឫនទេ ព្រោះគយផ្លូវនោះជាច្រកប្រហាបក្នុងជាច់ស្រយាលឆ្ងាយណាស់ អ្នកចូរកាំងតែតំបន់អ៊ីមចេងនោះមួយ ព្រោះពីនោះមានសត្រូវច័ងនឹងកន្ងឯចូលទៅធ្លើអន្តរាយតែផ្លូវនោះឯង ហើយខុងចេងឲ្យហៅម៉ាតាយចូលទៅទ្បែបប្រាប់ថា : បើយើងស្ងាប់ហើយអ៊ុយអៀនទឹងប្រែចិត្តជាក្បត់នឹងព្រះចៅទ្បៅសៀន ចូរអ្នកឯងទៅនៅទឹងអ៊ុយអៀនក្នុងបន្លាយ ហើយរិះគិតកំចាត់ចេញឲ្យឫន ម៉ាតាយទទួលបណ្ដាំហើយក៏

លាចេញទៅនៅទីឯអ៊ុយអៀន ។

ខុងបេងឲ្យហៅខ្ជួនអៀវឆីចូលទៅទៀត ហើយប្រាប់ថា : ខ្ជួន យើងនឹងដល់ទូវសេចក្តីស្ងាប់ក្នុងគ្រានេះហើយ, ឯអ៊ុយអៀនទីឯប្រែក្បត់នឹងព្រះចៅឡៅសៀន អ្នកឯងចូរយកសំបុត្រនេះទុក បើមានការក្រលំ-ជ្បាកវិញ ត្រូវឲ្យហែកស្រោមសំបុត្រនេះមើល ហើយត្រូវធ្វើតាមគ្រប់ប្រការ ឯអ្នកដែលទីឯសម្ងាប់អ៊ុយអៀនមានខ្ជួនចំរុងហើយ អៀវឆីយំហើយក៏ទទួលសំបុត្រលាចេញទៅ, ខុងបេងចង្អាប់ការស្រេចហើយក៏សន្ទប់ជាត់ស្មារតីទៅយូរណាស់ លុះដល់ពេលព្រលប់ទើបខុងបេងភ្ញាក់ដឹងស្មារតីឡើងវិញ, ហើយតែងសំបុត្រសំដែងពីអាការឈឺធ្ងន់ ចាត់ចំរើសេះឲ្យចូលទៅក្រាបទូលព្រះចៅឡៅសៀន ។

ព្រះចៅឡៅសៀនជ្រាបសេចក្តីក៏មានព្រះទ័យតក់ស្លុតមហិមា ទ្រង់ជាត់លីហុកថាព្រះពន្ធចំរើឲ្យទៅសួរអាការជម្ងឺ បើខុងបេងនឹងមានបណ្តាំជាយ៉ាងម្តេច ក៏ត្រូវឲ្យចាំពាក្យពេចន៍នោះទៅក្រាបទូលតាមការ លីកុកក៏ថ្វាយចង្កៀលទៅដល់ចន្លោយតែសាន ហើយចូលទៅសួរខុងវេងដំកថាថា ព្រះចៅឡៅសៀនជ្រាបថាប្រសាសន៍ឈឺធ្ងន់ ព្រះអង្គក៏ទ្រង់មិនសប្បាយព្រះទ័យសោះ ទើបទ្រង់ត្រាស់ប្រើខ្ញុំបាទឲ្យមកសួរ ខុងបេងក៏ឆ្លើយថា ខ្ជួនយើងនេះតាំងចិត្តគិតថា ទីឯនៅធ្វើកជការតបស្នងធួនព្រះតេជគុណឥឡូវឥតបុណ្យវាសនាបានជាធ្វើតាមមិនសម្រេច មានអកុសលកម្មមក

ផ្តាច់ឲ្យអស់អាយុក្នុងពេលត្រឹតែស្អែកនេះហើយ ខ្ញុំនអ្នកនៅក្រោយកំបូរតាំងចិត្តសុចរិតដល់ព្រះមហាក្សត្រិយ៍ គឺព្រះចៅឡៅសៀនជាម្ចាស់ចុះឲ្យដូចជាខ្ញុំនយើង ទោះអ្នកនឹងប្រើមនុស្សធ្វើការអ្វី ។ គប្បីប្រមាណឲ្យស្គាល់ការធ្ងន់ស្រាល ហើយឲ្យស្គាល់តម្រិះប្រាជ្ញាមនុស្សដែលនឹងប្រើទៅធ្វើធ្វើការអ្វីគប្បីឲ្យត្រូវនឹងការដែលធ្វើបាននឹមប្រើ ឯការខាងឥហានឹងតម្រាពិព័យសង្គ្រាមនោះ យើងក៏បានទុកជាក់មុខងារនោះឲ្យកៀងអ៊ុយជាស្រេចអស់ហើយ អ្នកឯងចូរវិលត្រឡប់ទៅក្រាបទូលព្រះចៅឡៅសៀនវិញចុះ ថាយើងមានបុណ្យវាសនាតិចណាស់ វេលានេះនឹងសូមក្រាបថ្វាយបង្គំលាស្ងាប់ហើយ។ យើងនឹងតែងសំបុត្រទៅក្រាបថ្វាយជាក្រោយ លំហុកក៏ត្រឡប់ទៅវិញ ។

ក្រោយពីនោះមក, ខុងចេងឲ្យឥហានគ្រាហ៍លើកឡើងរទេះបរចេញទៅមើលត្រួតត្រាការខាងមុខបន្តិច, ពេលនោះជាទេសកាលរងាណាស់ ខុងចេងក៏កំរើកពេគខ្លាំងឡើង ភ្នាក់ងារកំម្មីម្នាំបូលបន្តិច ខុងចេងដកដង្ហើមធំហើយថា ខ្ញុំនយើងមានចិត្តស័ត្យទៀងត្រង់នឹងផែនដីណាស់ មិនគួរដល់ខ្លួវសេចក្តីស្ងាប់សោះ ហេតុព្រោះទេពតាមិនជួយទេ ហើយឲ្យហៅអៀងើទៅផ្តាំថា ខ្ញុំនយើងអស់បុណ្យវាសនាហើយ, អ្នកឯងហើយត្រូវធំក្លាតធំទ័ព ត្រូវតែគិតកំជាប់ចងចិត្តសេនាឥហានកុំឲ្យបែកចិត្ត, ឯអង់ប៉ង់, ម៉ាតាយ, លៀវហ្ស៊ូ ទៀវអេក,

ទៀតនឹ ពាំង ៤ នាក់នេះ សុទ្ធតែជាមនុស្សសុចរិតទៀងត្រង់អ្នកចូរដួយ
ទំនុកបំរុងឲ្យដួចខ្លួនយើង, មួយទៀតបើអ្នកនឹងលើកទ័ពត្រឡប់ទៅវិញ
កុំធ្វើឲ្យចែកការជាចលាចល ត្រូវប្រើកលទៅជាប្រក្រតី, ទោះបើបើ
សត្រូវវាដឹងនឹងតាមទៅ ក៏ត្រូវដួយគ្នាពង្រាងកំឲ្យមាំកុំឲ្យមានអន្តរាយ
ដល់កងទ័ពឯកៀងអ៊ុយសោត គេក៏មានតម្រិះប្រាជ្ញានិងថ្វីដៃខ្លាំងពូកែ
មែន យើងក៏បានបង្គាប់ការពាំងពួងទុកជាក់ជាស្រេច បើអ្នកធ្វើអ្វី ឲ្យ
គប្បីប្រឹក្សាពីគ្រោះនឹងកៀងអ៊ុយ, អៀវធីទទួលបណ្តាំហើយក៏អង្គុយយំ
ជំនួក ។

ឧកញ៉ាបេនឧសរ្ជាហ៍សរសេរសំបុត្រថ្វាយព្រះចៅឡាសៀន មាន
សេចក្តីថា : ខ្ញុំព្រះបង្គំជាខ្ញុំឧកញ៉ាបេនសូមក្រាបថ្វាយបង្គំលាព្រះអង្គ សូម
ទ្រង់ជ្រាប ព្រោះតាំងចិត្តឧស្សាហ៍ធ្វើពាក្យការថ្វាយតាមសតិបញ្ញាវៀង
មកពេញកំឡាំង ព្រោះតាំងចិត្តគិតឃើញថា : ព្រះវរកដបិតារបស់ព្រះ
អង្គទ្រង់មានព្រះករុណាចិញ្ចឹមរក្សាឲ្យខ្ញុំព្រះបង្គំជាខ្ញុំ បានធ្វើធំដល់ត្រឹម
នេះ ព្រះករុណាគុណមិនមានទីបំផុត ចិត្តខ្ញុំព្រះបង្គំជាខ្ញុំក៏មានវិតក្ក
នៅ ព្រោះសត្រូវខាងជើងខាងត្បូងក៏ពុំទាន់កបភាពតែឥឡូវជាកម្មនាំអត្ត-
ភាពមកដល់ទ្បូវសេចក្តីស្លាប់ ចិត្តក៏នៅឈឺចាប់គ្រប់ភាវៈខ្សល់ដង្ហើមចេញ
ចូលនៅឡើយ, បើខ្ញុំព្រះបង្គំស្លាប់ហើយសូមព្រះអង្គទ្រង់រក្សាទ្បូវសេចក្តី
ស័ត្យពិតធម៌ បំរុងរក្សាសេនាគហានទ្បូវអស់អាណាប្រជាខ្មែរស្តេចឲ្យនៅ

ជាសុខក្សេមក្សាន្តតាមបុព្វណាពជ្រវៃណ៏ សូមកុំឲ្យទ្រង់បង់ធំពីអំណត់គិតតែស្តាប់ពាក្យមនុស្សព្រោលចណ្ឌាលកាចនោះឡើយ, ចើព្រះអគ្គផ្តន់ព្រះឱយបានហើយទើបប្រទេសស្រុកទឹងបានសុខជាប្រក្រតីទៅ ឯក្នុងទីហាន់លំនៅនៃខ្ញុលព្រះបង្គំជាខ្ញុំនោះ មានដើមមនសម្រាប់ចិញ្ចឹមនាងនៅជល់ ៨០០ ដើម, ដីស្រែ ៥០ រ៉ៃ, ឯទីស្រែទឹងចម្ការមនប៉ុណ្ណោះក៏ល្មមសមគួរដល់កិរិយាបុត្រចរបស់ខ្ញុលព្រះបង្គំជាខ្ញុំចិញ្ចឹមជីវិតបានហើយ, ឯទ្រព្យចរបស់ក្រៅពីនោះដែលមាននៅក្នុងផ្ទះខ្ញុលព្រះបង្គំទាំងអស់, សូមព្រះអគ្គទ្រង់មានព្រះបង្គាប់ឲ្យជញ្ជានចូលទៅទុកដាក់ក្នុងព្រះឃ្លាំងមហាសម្បត្តិ ជាព្រះពជទ្រព្យសម្រាប់ចែកចាយឲ្យខ្ញុំព្រះពជការ គឺសេនាពាហនជាដើម, លុះសារសេរចប់ ក៏ច្រកដាក់ក្នុងស្រោមប្រគល់ទុកឲ្យមនុស្សខ្ញុកទុកចិត្តបំរុងនាំទៅថ្វាយ ។

ទើបខុងចេងផ្តាំអៀវនីថា : បើយើងស្លាប់ហើយកាលណា កុំឲ្យបង្អាប់ពាហនមានទុក្ខសោកយំស្រែណោះអាណោះអាល័យកាន់ទុក្ខអ្វីឡើយ ចូរធ្វើកិរិយាព្រះឆើយកន្តើយដោយប្រក្រតីធម្មតាដូចយើងនៅរស់ កុំឲ្យកិត្តិ-ស័ព្ទនោះខ្ចាយខ្ចរឮទៅដល់ពួកសត្រូវខ្មាំងថាយើងស្លាប់ ឲ្យអ្នកចាត់ការធ្វើមឈូសសម្រាប់ដាក់សពយើងឲ្យអង្គុយ ហើយឲ្យយកអង្ករ ៧ គ្រាប់សម្រាប់ដាក់ក្នុងមាត់ ហើយឲ្យតាំងគោមក្តើង ១ អុចដំកល់ទុកពីក្រោមសពយើង, ប្រាថ្នាទឹងរក្សាផ្កាយសម្រាប់រក្សាអាយុយើងកុំឲ្យបាត់ទៅ

បើក្តីដ៏តាមនោះលែត់ទៅតាលណា, ផ្តាបសម្រាប់អាយុយើងសូន្យបាត់ទៅតាលណោះ, បើសុម៉ាអ៊ុមិលផ្តាបយើងមិនឃើញហើយកំអាងនឹងថាយើងស្ងាប់ជាក្រោកដ តន់ទឹងលើកខ័ពជាប់តាមទៅធ្វើអន្តរាយដល់កងខ័ពយើងមិនខាន បើសុម៉ាអ៊ុឃើញផ្តាយយើងនៅលើអាកាសទេ តន់តែមិនអាចលើកខ័ពមកញាំញី អ្នកចូរលើកកងខ័ពត្រឡប់ទៅ បើឃើញសុម៉ាអ៊ុលើកខ័ពជាប់ដីតដោយតាម ចូរអ្នកលើរាហាទាយញែកជាបែកខ្ចប់ទាំងពុកឲ្យមាំ យើងយកប្រយុទ្ធខ្លួនយើងជាកឲ្យអង្គុយលើរាទេះបរទៅជាកណ្តាលពួកគាហាន បើសុម៉ាអ៊ុឃើញតន់តែទឹងកិតភ័យខ្លាចថយទៅឯង អៀនីកំទួលធ្វើតាមបង្គាប់ត្រប់ប្រការ ។

លុះវេលាយប់, ខុងបេងឲ្យភាហានលើកគ្រាហ៍ចេញទៅរទាងមុខពង្រុលឲ្យគាហានមើលផ្តាយ យើងហើយ ថា ផ្តាយដែលទៅខាងទិសពាយ័ព្យនោះឯង គឺថាផ្តាយសម្រាប់អាយុបេស់យើង គាហានទាំងពួងមើលទៅឃើញផ្តាយសម្រាប់អាឃុ ខុងបេង នោះអន់ស្រអាប់ប្តី មើលទៅបីដូចជានឹងភ្លាក់ចុះមកពីលើអាកាសវែហាស៍, ខុងបេងក៏ឲ្យគាហានលើកគ្រាហ៍ចូលទៅខាងក្នុង រោលនោះខុងបេងក៏ក្តុកស្មាតើស្រដីមិនរួចអស់ចៅក្រាំងា ទិដ្ឋបណ្តាអាយខ័ព នាយកងទាំងពួងឃើញដូច្នោះក៏ភ័យជ្រួលចលំគ្នា ទួលលី ហុកជាព្រះពជបំរើមកដល់ពីស្រុកសែឈួន ចូលទៅឃើញ ខុងបេង និយាយមិនចេញសោះ ក៏នាំគ្នាយំសោកស្រណោះ

អាល័យ លីហុកថា : ខ្ញុំខ្ញុំគ្មានទិស្ស័យបានជាមកមិនខាន់ ឃើញថា វេលានេះអស់បានពាក្យសំខាន់ក្នុងបណ្តាំនាំទៅក្រាបថ្វាយព្រះចៅ ឡៅសៀនហើយ ទេពតាអើយ! សូមឲ្យលោកមកជួយមហាឧបភជដ្ឋងចុះ ខ្ញុំ ខ្ញុំ ខ្ញុំ

ក្នុងខណៈនោះ កងទ័ព ឧត្តរបេង ឮថាឆ្កើតសេចក្តីវិប្បរិយោគស្លុតស្ងប់ខ្លួនទៅទាំងបន្ទាយ ព្រះពាយក៏ចណ្តាលបោកបក់ភ្លាក់ចុះមក, មេឃអាកាសដេរដាស ពពកអួរអាប់ធន់ងងឹតសព្វទិសា បណ្តាទាយទ័ពទាយកនិងគាហានានាដែលបានដឹងសេចក្តីច្បាស់ហើយ ឮតក់ស្លុតរន្ធត់វិញ្ញាណមនុស្សម្នាទាំងប៉ុន្មានក៏នាំគ្នា ខ្លួញយំ ដំឌក រួចក៏ហាមឃាត់គ្នាឲ្យស្ងៀមស្ងាត់បាត់យំសោកទៅវិញ, តៀង អ៊ុយ និង អៀង ធី ក៏បានត់ការរៀបសពតាមទម្លាប់ខំនៀម និងធ្វើតាមបណ្តាំដែល ឧត្តរបេង ផ្តាំទុកនោះគ្រប់ប្រការ, ហើយក៏ត្រួតត្រារៀបចំពលគាហាន និងលើកកងទ័ពត្រឡប់ទៅក្រុងសែឈួនវិញ រៀបឲ្យកងគ្រោយបណ្តាយទៅជាកងមុខ ។

ឯសុមា អ៊ីនោះ លុះដល់ពេលកណ្តាលយប់ស្ងាត់ ដែល ឧត្តរបេង ស្លាប់នោះ ក៏ចេញទៅមើលផ្តាយឃើញផ្តាបេសម្រាប់អាយុ ឧត្តរបេង មហាឧបភជ ស្រុកសែឈួន ក្រហមជាពណិឈាម ធ្លាក់ចុះមកកណ្តាលបន្ទាយ ឧត្តរបេង ដល់ ៣ ដង ហើយត្រឡប់ឡើងទៅតាំងទៅទីដដែលវិញ តែវស្មីស្រអាប់មិនដូចប្រក្រតី, សុមាអ៊ី ក៏គិតថា: ឧត្តរបេង ស្លាប់ហើយទើបមានសេចក្តីសោមនស្សត្រេកអរ គិតនឹងលើកទ័ពទៅវាយបន្ទាយ ឧត្តរបេង ក្នុងខណៈនោះ ទើបមកពិចារណាគិតថយក្រោយវិញថា ហេតុដែលឃើញនោះនឹងជឿយកជាការពិតពុំទាន់បាន ខ្លាចក្រែង ឧត្តរបេង ឃើញថាយើងមិនបានលើកទ័ពចេញចំបាំងដាយរំលងមកហើយ ទើបក្លែងធ្វើ

ឧបាយយកគាហានចេញទៅពួនបង្កប់ចុកក្រៅបន្ទាយទេដឹង បានជាឲ្យ
ដុតផ្ទាក្តើងចោល ខម្ងាក់ពីលើកំពូលភ្នំ គីសាន ដើម្បីនឹងឲ្យយើងសម្គាល់
ឃើញថា ខុនបេង ស្លាប់ទៅហើយ យើងមុខជាមានចិត្តការម្រើកលើក
កងទ័ពទៅចោមវាយ គាហានខុនបេង និងចេញស្តាត់ខ្លួបប្រសព្វជាប់
ពីក្រោយឲ្យយើងថ្លស់ការ, សុមាអ៊ី គិតតាមប្រាជ្ញាឃើញដូច្នោះក៏ផ្ទំមិន
លើកទ័ពចេញទៅ ហើយតម្រូវឲ្យហៃ ហ៊ីប៉ា នាំគាហានប្រមាណ ៥០
នាក់ ចេញទៅស៊ើបស្តាប់ការឲ្យដឹងចាំ ខុនបេង ស្លាប់ហើយឬទៅ ?
ហៃ ហ៊ីប៉ា ក៏នាំគាហានចេញទៅតាម សុមាអ៊ី បង្គាប់ ។

និយាយពី អ៊ុយ អៀន, កាលក្នុងពេលយប់ដែល ខុនបេង ស្លាប់
នោះក៏ដេកមិនឲ្យលក់សោះ, យូរបន្តិចក៏លក់កាំង ១ ស្របត់ ស្រាប់តែ
យល់សប្តិឃើញថាកំបុតក្បាល មានភ្នំសង្កត់ដើមទ្រូងតាប់មកពាំង ធ្វេងស្តាំ
អ៊ុយ អៀន ភ្ញាក់ឡើងក៏គិតសង្ស័យ ទើបស្រាយយល់សប្តិឲ្យទៀវទិតនាយ
គាហានស្តាប់, ទៀវទិតពិគ្រោះមើលឃើញថា យល់សប្តិនោះគាចណាស់
ទើបភ្លែងទំនាយថា លោកយល់សប្តិនោះល្អណាស់ ដែលមានភ្នំនោះ
ឧបមាដូចខ្លែងខ្លួនបាន ព្រោះជាតិមកនោះ ក៏មានភ្នំមានបុទ្ធិមានកម្លាំង
ជាច្រើន, ក្នុងរឿងនិមិត្តលោកនេះគំរើដូចជាមកសម្តែងបុទ្ធិ, អ៊ុយ អៀន
បានឮដូច្នោះក៏មានសេចក្តីត្រេកអរណាស់ថា បើសមប្រកបដូចសេចក្តី
ទំនាយរបស់អ្នកគាយនេះ យើងនឹងតបគុណឲ្យដល់ខ្នាត ទៀវទិតធ្វើជា

ខ្ទួលពាក្យហើយក៏ចេញទៅចាត់ចាហានលើកចេញពីបន្ទាយប្រទះគ្នា និង ប៊ី ហ៊ុយ ។ ក៏ដណ្តឹងសួរថា អ្នកឯងនេះលើកពលចេញពីបន្ទាយទេឬ? ខៀវទិត ឆ្លើយថា : ទើបលើកចេញមកទេខ្ញុំមកឈៀងចូលទៅក្នុងបន្ទាយ អ៊ុយ អៀន ។ និយាយពីយល់សប្តិឲ្យស្តាប់ ហើយខៀវទិតក៏ពណិនារឿងយល់សប្តិ អ៊ុយ អៀន នឹងភ្លែងទំនាយនោះឲ្យ ប៊ី ហ៊ុយ ស្តាប់គ្រប់ប្រការ ប៊ី ហ៊ុយ សួរថា : ហេតុម្តេចបានជាអ្នកឯងដឹងថាយល់សប្តិនោះកាច ? ខៀវទិតឆ្លើយថា ខ្ញុំឃើញកាចព្រោះអក្សរក្នុងនោះប្រកបគ្នា ២ តួ ទើបហៅថាក្នុង បើនឹងញែកចេញថា ១ តួម្តង មើលថាមិត្រក្នុងធ្វើប្រទុសក៉ាយ បានជាខ្ញុំភ្លែងទំនាយយកមកមកប្រៀប ប្រាថ្នានឹងឲ្យ អ៊ុយ អៀន មានចិត្តកម្រើក ។

ប៊ី ហ៊ុយ ក៏រំឭកហាមថា : បើដូច្នោះអ្នកឯងមិនត្រូវនិយាយឲ្យនរណាដឹងទេ ហើយ ប៊ី ហ៊ុយ ក៏លៃទៅបន្ទាយវិញ ចូលទៅកេ អ៊ុយអៀន ហើយបណ្តេញមនុស្សឲ្យដើរចេញ, ប៊ី ហ៊ុយ និយាយប្រាប់ អ៊ុយ អៀនថា កាល ខុង ចេង ខៀចស្តាប់បានបង្គាប់ពុតថា ឲ្យលើកកងទ័ពត្រឡប់ចូលទៅក្រុងវិញ ហើយថាឲ្យអ្នកលើកទាហានពាក់ពីក្រោយ ឥឡូវនាយទ័ពនាយកងទាំងពួងនឹងលើកទៅតាមលំដាប់ អ្នកជានាយក្រោយនឹងឲ្យគេលើកទៅមុន រួចសឹមលើកពលទៅតាមក្រោយគេឬ ម្តេច ?

អ៊ុយ អៀន សួរថា: ខុង ចេង តាំងនរណា ឲ្យធ្វើមេទ័ពធំ ? ប៊ីហ៊ុយ

ក្រាប់ថា : ខុងហេងតាំងខុកឲ្យកៀកអ៊ុយនិយាយពីការខាងតាហាន សម្រាប់តែណាហេញចំរ៉ាង, តាំងអៀវនីឲ្យកាន់អាជ្ញាសិទ្ធិចគ្គាប់បញ្ជានាយតាហានទំងតាហានតាំង, អ៊ុយអៀនថា : អៀវនីគ្រាន់តែជាមន្ត្រីតូចសោះ ដែលនឹងឲ្យឡើងស័ក្តិយសកាន់អាជ្ញាសិទ្ធិចគ្គាប់បញ្ជាលើនាយតាហាននោះមិនគួរសោះគួរណាស់ត្រឹមតែឲ្យនាំសពខុងហេងត្រឡប់ ទៅស្រុកប៉ុណ្ណោះ, ឯទ្ងនយើងនិងនាំពលតាហានចេញទៅធ្វើការសង្គ្រាមយកសេចក្តីគាប់ប្រសើរទើបគួរប្រពៃ ឯខុងហេងតែម្នាក់ស្លាប់យ៉ាងនេះនឹងលះលើកការផែនដីវិលវៃទៅស្រុកនោះមិនត្រូវទេ, ប៊ីហ៊ុយថា: ពីដើមខុងហេងបានខុកថា បើខុងហេងបង្គាប់ខុកថា បើខុងហេងស្លាប់ហើយឲ្យលើកវិតត្រឡប់ទៅស្រុកសិន ដែលអ្នកនឹងទៅធ្វើការសឹកតទៅនោះនឹងមិនធ្វើទុសពាក្យបណ្តាំខុងហេងទេឬ ?

អ៊ុយអៀនតបថា : ការសឹកគ្រានេះ បើកុំតែបងមិនស្តាប់ពាក្យយើង ។ នឹងធ្វើការជាកលខុចាយទៀង ។ មុខជាឥឡូវយកជ័យស្រុកឡុកអៀងជាស្រេចទៅហើយ, ឯទ្ងនយើងក៏ជាមាំមួនធំដែរ តីបានដាមេកងខំតមុខ ឥឡូវអែតអំពីខុងហេងទៅហើយ ដែលនឹងឲ្យយើងធ្វើជាកូនសំរាយទៅចាំការពារពីក្រោយអៀវនីដូច្នេះយើងមិនសុខចិត្តឡើយទេ, ប៊ីហ៊ុយក្តែងថា អ្នកហ៊ានការពារណាស់ ខ្ញុំនឹងទៅក្រាប់អៀវនីឲ្យយក

ត្រាសម្រាប់មុខងារមេកងធំមកប្រគល់ឲ្យអ្នកវិញ្ញេបសមគួរ, ថាហើយ
ក៏លាទៅរកអៀវធីក្នុងបន្ទាយធំ ហើយអធិប្បាយសេចក្តីឲ្យស្តាប់គ្រប់
ប្រការ ។

អៀវធីបានឮហើយក៏អស់សំណើចថា : អ៊ុយអៀននោះ មហា
ឧបាសជបានទំនាយខុសថា បើលោកនោះអស់បុណ្យវាសនាទៅកាលណា
អ៊ុយអៀនក៏នឹងកំរើកចិត្តឡើងកាលណោះ, ឥឡូវឃើញសម្រេចដូច
មហាឧបាសជថាមិនខុស រៀលនេះបើអ៊ុយអៀនធ្វើប្រការយ៉ាងណាក៏
ដោយ តាមតែគំនិតប្រាជ្ញាវាចុះ, ទើបឲ្យអៀនអ៊ុយនាំតាហានលើកចេញ
ទៅជាកងត្រួយប្រយោជន៍នឹងបានការពារខ្លាំងសត្រូវ ហើយអញ្ជើញ
សតខុនបេនឡើងកាន់កាន់វេជ នឹងលើកវួយន្តឡើងកាន់រេនេះ ឲ្យ
លើកទ័ពដើរជាប្រក្រតីទៅតាមបណ្តាំខុនបេន ។

ឯអ៊ុយអៀនទៅវង់ថាអ៊ីហ៊ុយយូរណាស់ ទើបប្រើម៉ាតាយឲ្យឃុំនាំ
តាហាន ១៥ នាក់ដុះសេះទៅស៊ើបស្តាប់ការឲ្យដឹងថានាយកងណាខ្លះដែល
លើកទៅនោះ; ម៉ាតាយត្រឡប់មកប្រាប់អ៊ុយអៀនថា : កងទ័ពទាំងអស់
នោះបានលើកទៅខ្លះហើយ អៀវធីឲ្យអៀនអ៊ុយនាំតាហានលើកទៅជា
ក្រោយ, អ៊ុយអៀនបានឮដូច្នោះក៏ខឹងណាស់ថា ដែលអៀវធីឲ្យ
អៀនអ៊ុយលើកទៅជាកងក្រោយនោះគឺជាវាបង្អាបមើលងាយ ហើយ

និយាយនឹងម៉ាតាយថា ដែលអៀនធ្វើដូច្នេះ តើអ្នកឯងនឹងជួយយើងឬទេ? ម៉ាតាយថា ខ្ញុំបាទក៏មានសេចក្តីខឹងណាស់ដែរ, ព្រោះអៀនធ្វើដូច្នេះ ខ្ញុំបាទមិនចូលចិត្តគាំងពីដើមមក រាល់នេះខ្ញុំបាទសុំចូលខាងលោក ដើម្បីនឹងបានជួយគ្នានឹងសម្លាប់អៀនចេញឲ្យបាន អ៊ុយអៀនឮដូច្នោះក៏មានចិត្តត្រេកអរ មិនបានដឹងកលម៉ាតាយ ទើបចាត់គាហានត្រមគ្នា ហើយក៏លើកប្រតាត់តម្រង់ទៅចាំស្ទាក់នៅដើមផ្លូវ ចំណាងនឹងចាំធ្វើឲ្យអន្តរាយអៀន ។

ឯហ៊ីប៉ាកាលទៅលបស្តាប់ឃើញដូច្នោះ ក៏ស្រួតទៅប្រាប់សុម៉ាអ៊ុថា : ឥឡូវកងទ័ពស្រុកសៃឈ្នះលើកត្រឡប់ទៅវិញហើយ សុម៉ាអ៊ីឮដូច្នោះក៏ស្ទុះតន្ត្រៃដើងហ៊ោយថា ឯខុងបេងនោះមុខស្លាប់ពិតប្រាកដហើយ សុម៉ាអ៊ុក៏ចាត់គាហានហើយឡើងសេះនាំសំបុត្រទាំង ២ ស្រួតទៅដល់បន្ទាយខុងបេងក៏មិនបានឃើញមនុស្សម្នាសោះ, ទើបនាំគាហានស្រួតដឹតដោយតាមទៅដើងកុំមួយអន្លើ សុម៉ាអ៊ីត្រឡែកទៅឃើញគាហានខុងបេងដើរទៅខាងមុខជាច្រើនស្រាប់តែឮសូរផាវ ឮងសូរគាហានស្រែកហ៊ោពីលើចង្កេះភ្នំពាំងសងខាងផ្លូវ ឯគាហានខុងបេងដែលលើកទៅក៏ប្រញាក់ប្រញាន់នាំគ្នាសាមកក្រោយសុម៉ាអ៊ីឃើញខុងបេងកាន់ផ្ទៃពេមសត្តូបក់ទៅលើរេះ ឃើញខង់ដ័យចារឹកអក្សរថា "ខុងបេងទ័ព"

សុមាអ៊ីភ័យស្លុតចិត្ត ឈប់បង្អង់នៅទីនោះគិតថា ខ្ញុំបើមិនមែនដល់ន្ទូវសេចក្តីស្លាប់ទេ, ខ្ញុំអញ្ជើញមកត្រូវកាលខ្ញុំបើងទៀតហើយ ទើបទ្រាថយទ័ពនឹងត្រឡប់មកវិញ ។

ក្មេងអ៊ុយក៏បរសេះចុះមកពីលើភ្នំហើយស្រែកថា : សុមាអ៊ីត្រូវកលមហាឧបាជហើយនឹងរត់ទៅណាបាន, តាហានសុមាអ៊ីស្តាប់ជាក៏ភ័យខ្លាក់ថ្លើមទាំងអស់គ្នា កំនាំគ្នាខ្លាក់គ្រឿងសស្ត្រាវុធពីដៃ ស្ទុះរត់រៃទៅត្រសុកវុកពានលើគ្នាជាន់គ្នាស្លាប់ពិការជាច្រើន, សុមាអ៊ីក៏បរសេះពុះចំហោយរត់ត្រឡប់ទៅវិញ ខ្ទួលឮសំឡេងហៃហ៊ូថ្ម៉ា, ហៃហ៊ូហ៊ុយបរសេះមកកំផ្តើមមុខសេះសុមាអ៊ីហើយថាឈប់នៅសិន. សុមាអ៊ីឮដូច្នោះតែតែភ័យមួយសារទៀត ទើបគិតថា ត្រូវតាមទៅកាត់យកក្បាលខ្ញុំនឹងបាន, ទើបយកដៃស្ទាបក្បាលមើលក៏មិនដឹងថាខ្ញុំនៅទេ រឹតតែបង្ខំបរសេះរត់ទៅ, ហៃហ៊ូថ្ម៉ា ហៃហ៊ូហ៊ុយស្រែកថា លោកកុំភ័យខ្លាចអ្វី ទ័ពស្រុកសែឈ្នះវិលទៅវិញហើយ សុមាអ៊ីស្តាប់ម្តងទៀតទើបឈប់ស្រឡះស្មារតីជាគ្នាឯងក៏ឈប់នៅ ប្រមូលបាទាហានខ្លះហើយក៏នាំគ្នាចូលទៅកងជម្លាយវិញ ។

លុះកន្លងមក ២ ថ្ងៃ មានពួកអ្នកស្រុកនៅទីនោះចូលទៅក្រាបសុមាអ៊ីថា : កងទ័ពសែឈ្នះកាលដែលលើកត្រឡប់ទៅនោះ ខ្ញុំបាទបានឮ

សំឡេងខ្លួញយំអីនៅឯ ឯរនេះដែលជោគទេដ៏សាលាចេញមកមិនមែនខុនរបន់ទេ គឺជារបួយន្តទេតើ គេធ្វើចន្ទុំប្រាប់ថាទីនឲ្យលោកខ្លាច ឯខុនបេនោះស្លាប់យូរហើយ ។

សុមាអ៊ីបានឮដំណឹងច្បាស់ដូច្នោះ ក៏ដូចគេក្បាត់ខ្លួនទាំងមានអំណរជាទីបំផុតទើបថា យើងបានប្រមាណគ្នាការមិនខុស ព្រោះយើងយើញថាខុនបេនស្លាប់ហើយជាប្រាកដ តែនៅមិនទាន់ច្បាស់លាស់ពីថ្លៃណា ឥឡូវទើបបានដឹងពិត យើងក៏គិតនឹងលើកទ័ពទៅតាមឲ្យទាន ទើបសុមាអ៊ីឲ្យប្រុងប្រៀបរៀបជាកងទ័ពត្រប់ ។ គន់ ហើយក៏លើកទ្ធនតាមទៅដល់ដំបន់ជ:ងាន់ថា យើញថាមិនទាន់ហើយក៏លើកវិលត្រឡប់មកវិញ ហើយនិយាយនឹងអស់នាយទាហាន ដែលខុនបេនស្លាប់ទៅហើយកន្លងវេលានេះ អស់គេយើងទាំងឡាយក៏បានដង្ហើយជាសុខនឹងបានដេកកំលត់យ៉ាងស្ងួតបំពង់ក្អែកជិត លុះត្រឡប់ទៅដល់ទីបន្ទាយខុនបេន ក៏ដើរមើលបៃជាតបន្ទាយតួចធំដែលខុនបេនបានតាំងទុកនោះ យើញត្រូវតាមរបៀបកងទ័ពដ៏ឈ្លាសក្រាម ហើយជាធម្មាសត់បញ្ជាមនុស្សក្នុងលោកនេះ នឹងរកអ្នកឯណាឲ្យចេះដឹងប្រហែលនឹងខុនបេននេះគ្មានសោះឡើយ ថាហើយសុមាអ៊ីក៏កំជាប់ថាហានឲ្យត្រួតត្រាត្រប់ទីតយជាន ប្រើនដំបន់ជាមាំមួនណាស់ ហើយក៏លើកទ័ពត្រឡប់ទៅស្រុក

ស្រុកឡុកអៀង ។

និយាយពីអៀងនឹកអៀងអ៊ុយ លុះលើកទ័ពអមសពខុនបេនទៅដល់ដំបន់ចៀងគោ ជាមាត់ផ្លូវនឹងចូលទៅស្រុកសែឈួន ក៏បញ្ជាប់កងទ័ពហើយប្រាប់អេហ៏ពលទាំងអស់ថា : ខុនបេនខ្លួលមរណភាពហើយត្រូវតែយើងទាំងអស់គ្នាស្វែកពាក់សកាន់ទុក្ខតាមទំនៀម នោះពួកទាហានទាំងអស់ឮដូច្នោះ ក៏តក់ស្លុតរន្ធត់ស្មារតី ដោយសេចក្តីអាឡោះអាល័យខុនបេនណាស់ ក៏នាំគ្នាប្រុះប្រុណាយំសោក ខ្លះក៏យកក្បាលបោកខ្លប់នឹងថ្មសិលាបែកចេញឈាមទៅខ្លះ ខ្លះក៏ដួលសន្លប់សុបសៅទៅពីនោះច្រើនណាស់ រំលោះនោះស្រាប់តែឮសូរសំឡេងទាហានស្រែកហ៊ោគឹកកង ឃើញមានអន្ធឹះក្លិនឆេះឡើងពីមុខច្រកភ្នំ អៀងឆីក៏ចាត់នាយកងឲ្យ ។ ឲ្យស្រូតវូតទៅមើល ហើយមកប្រាប់ថា អ៊ុយអៀនលើកទាហានមកចាំស្កាត់ពីមុខច្រើនណាស់ ។

អៀងឆីឮដូច្នោះក៏ភ័យណាស់ ហើយនិយាយថា : មហាឧបាជ្ឈាលមុននិទាឥន្ទិច្ចកម្មបានផ្តាំទុកថា អ៊ុយអៀនទឹងចេញជាក្សត់ត្រូវកំណើតមែនប្រាកដតាមប្រសាសន៍មហាឧបាជ្ឈា ដែលអ៊ុយអៀនមកតាំងទ័ពឈប់ស្កាត់ទ័ពយើងពីមុខដូច្នេះ អស់អ្នកឯងគ្មានទឹងយល់ឃើញប្រការម្តេច? ប៊ីហ៊ុយឆ្លើយថា : ដែលទឹងតាំងក្បត់ថ្វាយដែនទឹងអ៊ុយ

អៀនខោះ យើងក៏មិនត្រូវគោរពគោតញញើតខ្លាចឡើយ តែថាការខោះ យើងត្រូវតែបកសំបុត្រចូលទៅក្រាបទូលព្រះចៅឡាវសៀនឲ្យ ជ្រាបមុនសិន ដើម្បីនឹងបានការប្រុងប្រយ័ត្នកុំឲ្យថ្លង់ការ, អៀវធីថា : ផ្លូវទៅសានខោះគាត់តម្រង់ទៅស្រុកសៃលួនបាន ហើយក៏តែងសំបុត្របកចាត់ប៉ារើសេះឲ្យទាំចូលទៅក្រាបទូលថ្វាយ សូមជ្រាបគ្រប់ប្រការ ។

ឯព្រះចៅឡាវសៀនតាំងព័ជ្ឈានជ្រាបដំណឹងថាខុនបេងមានជម្ងឺឈឺវេលាណាព្រះអង្គក៏ដែងទ្រង់ព្រះវិតក្កមិនសប្បាយសោះ កាលខុនបេងអនិច្ចកម្មខោះ ព្រះចៅឡាវសៀនទ្រង់យោងចូលត្រឡាព្រះបន្ទំផ្ទុលក់ស្កល់ ក៏ទ្រង់ព្រះសុបិននិមិត្តឃើញភ្ញាក់ខ្លួនឡើងទាំងភ័យខ្លាចតើមបារម្ភព្រះបន្ទំយាងចេញតងំក្នុងព្រះកងកេងរួមជួបជុំនាម៉ឺនមុខមន្ត្រី ក៏ទ្រង់ស្រាយព្រះសុបិននិមិត្តឲ្យមន្ត្រីទាំងពួងស្តាប់ ទៀវចុយក្រាបទូលថា : កាលពីយប់មិញខ្ញុំលេព្រះបង្គំជាខ្ញុំបានឃើញផ្កាយសម្រាប់មហាឧបរាជធ្លាក់ចុះខាងទិសឦសាន ទូលព្រះបង្គំជាខ្ញុំឃើញថានឹងមានភ័យដល់មហាឧបរាជ ដែលព្រះអង្គទ្រង់ព្រះសុបិននិមិត្តនោះក៏ប្រែកចរសេចក្តីគ្នាណាស់, ព្រះចៅឡាវសៀនបានទ្រង់ជ្រាបដូច្នេះ ក៏ដែងតែទ្រង់ព្រះបរិតក្កខ្វាំងណាស់អស់មានសេចក្តីសប្បាយ ។

លុះកន្លងមក ៥ ថ្ងៃ លើហុកចូលទៅក្រាបទូលតាមបណ្តាំខុងបេង ដែលបានផ្តាំទុកគ្រប់ប្រការ ហើយទូលថា : ឥឡូវនេះ មហាឧបភជទូលអនិច្ចកម្មទៅហើយ ព្រះចៅឡៅសៀនទ្រង់ព្រះសណ្តាប់ឮសំភ័ភ័យណាស់ត្រាស់ថា : ដែលខុងបេងទូលអនិច្ចកម្មនោះ ដូចហាក់ខេរ-តា មកប្រហារជីវិតយើងឯងកំទ្រង់ព្រះកន្សែងសោកាត្រាតែដួលសន្លប់ចុះ នោះពួកខ្ញុំទាំងពួង កំនាំគ្នាចូលទៅគ្រាប់ត្រកងតែឲ្យដឹងព្រះស្មារតីឡើង ហើយអញ្ជើញព្រះអង្គចូលទៅលែងខាងក្នុង ព្រះចៅឡៅសៀនក៏មិនបានចេញទ្រង់និយាយពាក់ការជាច្រើនថ្ងៃ ឯអស់មុខមន្ត្រីទាំងប៉ុន្មានទាំងអាណាប្រជានុពស្ត្រីបណ្តាដែលមានកន្លងស្រុកសែឈួន ក៏សឹងតែមានសេចក្តីសោកយំស្រណោះអាឡោះអាល័យខុងបេងពេញទាំងដែនក្រុង ។

ឯលីដេរឿមតាំងពីត្រូវទោសជកហូតងារចេញចាកដំណែងវិលមកក៏ធឹងថាខ្លួនប្រព្រឹត្តខុសពិត តែតនឹងតាំងខ្លួនឲ្យល្អឡើងវិញ ដើម្បីនឹងឲ្យខុងបេងប្រើប្រាស់តទៅ លុះដឹងថាខុងបេងទូលអនិច្ចកម្មហើយ ក៏ឲ្យមានសេចក្តីស្រណោះអាឡោះអាល័យយំសោកជាខ្លាំងណាស់ តែឃើញឮស់ថា ប៉ើជាមានមហាឧបភជខ្មៅតនឹងរើសរកចិត្តឬតំនិតមារយាទឲ្យដូចខុងបេងគ្មានឡើយ លីដេរឿមតែហើយក៏តែតែកើតទុក្ខទ្រមក្រំគ្រាទៅជាឈឺជាប់ តំធ្វើការណ៍រិយាទៅ ។

ខ្ញុំ:នោះមានបំរើសេះនាំសំបុត្រអ៊ុយអៀនចូលមកទូលព្រះចៅ
ខ្សៅសៀនមានសេចក្តីថា : អៀវធីចេញជាក្សត់នឹងពួកជាវដណ្តើមយក
សតមហាឧបភដុកហើយគប់គិតនឹងពួកខ្មាំងសត្រូវ នឹងលើកទ័ពចូល
មកធ្វើសេចក្តីអន្តរាយដល់ស្រុកសែឈួន ទូលព្រះបង្គំជាខ្ញុំបាននាំខាហាន
មកស្កាត់នៅមាត់ផ្លូវចៀងគោ ។

ព្រះចៅខ្សៅសៀនបានស្តាប់ដូច្នោះ ក៏គ្រាស់ប្រឹក្សានឹងបណ្តាមុខ
មន្ត្រីទាំងពួងថា បើប្រសិនណាអៀវធីជាក្សត់មែន នោះអ៊ុយអៀនក៏
មានថ្វីដៃល្មមតស៊ូគ្នានឹងអៀវធីបានណាស់ ហេតុម្តេចក៏បានប្រឡាស
លើកទាហានស្រុតមកស្កាត់ផ្លូវពីមុខវិញដូច្នេះ, ម៉្យាងទៀតពីដើមនោះ
យើងក៏បានឮព្រះក្រសែព្រះវរពជបិតាគ្រាស់ថា ខុងចេងទំនាយទុកថា
អំណើះតទៅមុខអ៊ុយអៀនទំនងប្រែជាក្សត់ ព្រោះមានលក្ខណៈជាមនុស្ស
អាក្រក់ច្រើនដណាស់ គិតនឹងឲ្យសម្លាប់ចេញតែរឿយ ។ តែហាក់
ដៅយមានអ្នកឯទៀតយាត់ខាំងកំងក ព្រោះយើញថាអ៊ុយអៀនមានថ្វីដៃ
ច្បាន់ជាអធ្យាស្រ័យទុកប្រើការ ឧបភដូចជាតឿនកូនខាហានប៉ុណ្ណោះ
ដែលអ៊ុយអៀនពោលទោសអៀវធីមកនោះ លុះយើងនឹងដឿធ្វើតាមទៅ
ក្រែងអៀវធីទៅជាល្អទេ ក៏នឹងប្រែចិត្តឲ្យគិតគ្រឡប់ជាខូចអាក្រក់ទៅ
វិញ ត្រូវតែយើងនៅគិតការញ៉ាំន្នេះចាំមើលថាំស្តាប់សព្វដំណឹងឲ្យដឹងពិត
សិនចុះ អស់មុខមន្ត្រីក៏យល់យើញតាម ។

ខណៈនោះខ្ញុំលមានបំរើសេះគាន់សំពុត្រអៀវធីចូលមកថ្វាយព្រះ
ចៅឡៅសៀនមានសេចក្តីថា : កាលមហាឧបរាជនៅមិនទាន់មរណភាព
នៅឡើយ បានផ្តាំទុកដាកថាថាឲ្យអ៊ុយអៀនលើកតាហានៅជាកង
ក្រោយ, ក្នុងវេលាដែលនឹងបណ្តាយទ័ពធំវិលមកក្រុងសែឈួនវិញ
លុះមហាឧបរាជខ្ញុំលអនិច្ចកម្មទៅ អ៊ុយអៀនមិនធ្វើតាមសោះ ។
វេលាដែលថយទ័ពធំមកនោះ អ៊ុយអៀនត្រឡប់ជាក្បត់នាំតាហានស្រួត
ទៅស្លាក់ពីមុខនៅត្រង់ផ្លូវចៀងគោ ប្រាថ្នានឹងដណ្តើមយកសពមហាឧប
រាជទៅឲ្យសត្រូវ, ព្រះចៅឡៅសៀនជ្រាបដូច្នោះ ក៏យកសំពុត្រទាំង២
ច្បាប់នោះ ទៅប្រឹក្សានឹងនាម៉ឺនទាំងពួងថា នរណានឹងយើញយ៉ាងម្តេច។

ដៀវអ៊ួនក្រាបទូលថា : ឯចិត្តអ៊ុយអៀននោះជាមនុស្សឫទ្ធិស្បាគ្មាន
សត្យានុសត្យសោះ, គិតតែលើកតំពស់តាំងខ្លួនជាធំ លុះឃើញអៀវ
ធីបានតាំងជាមេទ័ពក៏មានចិត្តមានមិនចំណុះចុះចូល បានជាត្រឡប់ប្រែ
ចិត្តគិតក្បត់ ប្តឹងគោលគោសតីអៀវធីវិញ, ឯអៀវធីនោះពេញជាមនុស្ស
មានចិត្តស័ត្យទៀងត្រង់ណាស់ បានជាមហាឧបរាជកប់អានប្រើប្រាស់
មកយូរហើយ មិនមានទាស់អធ្យាស្រ័យអ្វីសោះទូលព្រះបង្គំជាខ្ញុំសុំ
ទូលជានាខ្លួនអៀវធីថាជាមនុស្សល្អប្រាកដ បើប្រសិនណាជាអៀវធី
ត្រឡប់ជាក្បត់វិញ, សូមឲ្យព្រះករុណាយកខ្លួនទូលព្រះបង្គំជាខ្ញុំទ្រមាំង
ពុត្រកប់ឃោនៅប្រាសាទនេះចុះ ។

ព្រះចៅឡៅសៀនសួរថា : ដែលអ៊ុយអៀនថាក្បត់ឥឡូវនេះ តើយើងនឹងគិតកំចាត់ចេញប្រការម្តេច ? ដៀវអួនក្រាបទូលថា : ព្រះអង្គកុំទ្រង់ព្រះវិតក្កឡើយ ជាជាខ្ញុំទូលព្រះបង្គំហើយហ្នឹង ព្រោះខ្ញុំទូលបង្គំជាខ្ញុំឃើញថា មហាឧបរាជបានប្រាប់កលឧបាយទុកនឹងអៀវធី ឲ្យរិះគិតកំចាត់អ៊ុយអៀនចេញជាពិតណាស់ ដល់នេះស្រាប់តែបីហ៊ុយចូលទៅគាល់ព្រះចៅឡៅសៀន ហើយទូលពីរឿងអ៊ុយអៀនប្រែចិត្តក្បត់នោះថ្វាយទ្រង់ព្រះសណ្តាប់ត្រាប់ប្រការ ព្រះចៅឡៅសៀនទ្រង់ជ្រាបដូច្នោះ ក៏ប្រឹក្សានឹងបណ្តានាម៉ឺនមុខមន្ត្រីទាំងពួង ហើយឲ្យតាំងអ៊ុនទៅនិយាយបញ្ចុះបញ្ចូលយកចិត្តអ៊ុយអៀនទុក នោះតាំងអ៊ុនក៏ក្រាបថ្វាយបង្គំលាចេញទៅ ។

ឯអ៊ុយអៀននោះ, លុះលើកទ័ពទៅតាំរវទៅផ្ទះវៀងគោ ហើយក៏លើកកំលៃចូលទៅតាំងខ្ចាប់ខ្ជួនទៅមាត់ផ្លូវចាំកុក ក៏មានចិត្តគិតត្រែកអ-ថាគ្រានេះមុខជាសមប្រកបនឹងគំនិតគិតរបស់ខ្លួនជាប្រាកដហើយ, ខណៈនោះ អៀវធី និង កៀងអ៊ុយ ក៏ចាត់ប្រើហោបេង ឲ្យនាំទាហាន ៣០០ នាក់ ទៅប្រចាំការខាងក្រោយ ហើយក៏បង្គំលើកទ័ពធំនាំសតុងបេង ប្រតិការត់ផ្លូវនឹងទៅស្រុកហាន់តុង, ហោ បេង ក៏នាំទាហានទៅប្រចាំការពីក្រោយទៅ, លុះឃើញ អៀវធី និង កៀងអ៊ុយ លើកទៅផុតជំបន់ចាំកុកហើយ ក៏ឲ្យទាហានស្រែកហោរឡើងជាទ័ពក្បត់ពញ្ជរឹចិត្ត អ៊ុយ អៀន

ចំរើលភ្នែត អ៊ុយ អៀន ក៏ចូលទៅច្រាប់ អ៊ុយ អៀនថា អៀនឆី និងអៀន
អ៊ុយ នាំសព ខ្ញុំ បេង រត់កាត់ផ្លូវតម្រង់ទៅស្រុក ហាន់តុង វិញទៅហើយ
ហោ ប៉ែង នាំពាហានទៅចាំការពារពីក្រោយ ហើយបង្គាប់ឲ្យពាហាន
ស្រែកហ៊ោកញ្ជែវចំអកឲ្យកងថៃមទៀត ។

អ៊ុយ អៀន ឮដូច្នោះក៏ខឹងខ្លាំងណាស់ ទើបពាក់ក្រឹសកាន់លំពែង
ឡើងសេះនាំពាហានស្រួតតាមទៅ, ហោ ប៉ែង ឃើញ អ៊ុយអៀន តាម
ទៅដឹតកំណាច់ខ្នង ហើយយកសែសេះចង្អុលមុខ អ៊ុយ អៀនហើយស្រែក
ជេរថា មហាឧបាជដើបអនិច្ចកម្ម នៅមិនពាន់ត្រជាក់ខ្លួនប្រាណផង
ហេតុម្តេចឯងមកប្រែចិត្តគិតក្បត់ដូច្នេះ, ហើយស្រែកប្រកាសប្រាប់អស់
ពាហាន ដែលមកជាមួយនឹង អ៊ុយ អៀននោះថា បណ្តាពួកអស់អ្នកពាល់
គ្នានេះ កាលមហាឧបាជនៅរស់នៅឡើយ លោកក៏មិនដែលធ្វើអ្វីឲ្យ
ខាស់ចិត្តខ្លួនពាល់គ្នា ហេតុអ្វីអ្នកពាល់គ្នាមកបួលដៃជាមួយនឹងអាក្បត់ដូច្នេះ
ខ្លួនមិនគិតដល់បុត្រភរិយាទេឬ ? ចូរអ្នកទាំងអស់ទាំងគ្នាបួលទៅខ្លួលយក
បៀវត្សឯក្រុង សែឈ្នួនវិញប្រសើរជាង នៅជាមួយនឹងអាក្បត់ ដើម្បីនឹង
ឲ្យខំនុកបំរុងបុត្រភរិយាគេទៅ ពាហានទាំងពួងឲ្យឮដូច្នោះក៏យល់ឃើញ
ត្រូវណាស់ នាំគ្នាក្រឡាស់រត់ចេញតី អ៊ុយ អៀន អស់ប្រហែលពាក់
កណ្តាល ។

អ៊ុយ អឿន ឮ ហោប៉ែងថាដូច្នោះ ថែមទាំងឃើញពួកភាហានរបស់ខ្លួនតស៊ូទៅច្រើនទៀតក៏ឲ្យខឹងក្តៅខ្លាំងណាស់ ទើបបរសេះកាំលែងចូលទៅប្រយុទ្ធគ្នា ន៏ងហោប៉ែងបាន ១០ ក្លែង ហោប៉ែងលក់កម្លាំងន៏ង អ៊ុយ អឿន តុំបានក៏ញាក់សេះរត់ទៅ, អ៊ុយ អឿនបានចំណាប់ក៏បំផ្លាយសេះតាមទៅតែម្នាក់ឯង ភាហាន ហោប៉ែងឃើញក៏ព្រួតគ្នាចាប់ជួចម្រុះមកលើខ្លួនសន្ធឹកណាស់ ក៏ញាក់សេះរត់ថយទៅវិញ ឃើញភាហានរបស់ខ្លួនទៅស្តើងស្តួចតិចណាស់ក៏តែតែខឹង តែប្រឹងធ្វើកំឡាដេញតាប់ភាហានរបស់ខ្លួនស្ទាបអស់ប្រហែល ៨ នាក់ ឬ ១០ នាក់, ភាហានទាំងនោះខ្លះភ័យខ្លាចក៏រាំអាចរត់ចេញ. អ៊ុយ អឿន ឃើញម៉ាតាយនាំភាហានទៅជាប្រក្រតីក៏ស្រែដាថា :ខ្លួនអ្នកជាមនុស្សមានចិត្តសត្យត្រង់ន៏ងយើង បើយើងធ្វើការបានសមប្រកប តាមគំនិតដែលយើងគិតទុកហើយ ន៏ងឲ្យបំណាប់ឡើងអ្នកឲ្យដល់ខ្នាត ហើយក៏នាំម៉ាតាយនិងភាហានទាំងពួងតាមហោប៉ែងទៅ ចម្ងាយផ្លូវប្រហែល ២១០ សិន (៨គី) លុះមិនទាន់ហើយក៏ឈប់នៅទីនោះ, ទើបប្រឹក្សានិងម៉ាតាយថា : យើងត្រូវនាំគ្នាទៅចូលទៅធ្វើកជការខាងចោយយ៉ាងវិញ ឬ ប្រការម្តេច ?

ម៉ាតាយក្លែងធ្វើឆ្លើយតបថា : លោកមានប្រសាសន៏នោះមិនគួរទេធម្មតាជាជាតិភាហានហើយ ប៉ែគិតការអ្វីត្រូវគិតឲ្យសម្រេច ទើបនឹងប្រាកដ

កេរ្តិ៍ឈ្មោះទៅខាងមុខវែងឆ្ងាយ ដូចខ្លួនលោកវិលាខេះកំមានថ្ងៃដែរ ទាំងព្រួតបង្រួមដោយសតិបញ្ញាគិតការជ្រៅជ្រះណាស់ ក្នុងស្រុកសែលួនក្តី ស្រុកហានតុងក្តី ទឹងរកនរណាតថ្ងៃដែនឹងលោកគ្មាន, ខ្ញុំបាទសុំអាសាវយកស្រុកសែលួនឲ្យបានទៀត លោកកំនឹងបានជាធំ អ៊ុយ-អៀន មិនបានដឹងខុបាយសោះ កំតែតែមានសេចក្តីកេរាយត្រេកអរ ទើបនាំគ្នាស្រួតលើកទៅតាំងនៅដិតកំពែងស្រុកហាន់តុង ។

ឯគឿន អ៊ុយ ឡើងទៅនៅលើសើនកំពែង ឃើញ អ៊ុយ អៀន តាំងបន្ទាយនៅដិតដើងកំពែងស្រុកក៏ភ័យណាស់ ទើបប្រឹក្សានឹង អៀវ ឆីថា: អ៊ុយ អៀន មានឥទ្ធានតិចទេ តែកំឡាំងថ្ងៃដែរទាំងពួកណាស់ ហើយបានទាំងម៉ាតាយ ខុកជាកម្លាំងផង, បើដូច្នេះតើយើងនឹងគិតកំចាត់ប្រការម្តេចទើបបាន អៀវ ឆី ឆ្លើយតបថា: បានឲ្យសំបុត្រខុកហើយផ្តាំភាក្យជ្រៅខុកទៀតថា ឯ អ៊ុយ អៀន ទំនៃប្រជាក្បត់ បើវាលើកតាមមកដល់ដើងកំពែងស្រុកហើយ ត្រូវឲ្យយកសំបុត្រនោះមកឈរមើលប្រការ ១ ទៀត លោកបានផ្តាំប្តេជ្ញាខុកលើមាតាយ ។ កំទៅទៅជាមួយ ទឹង អ៊ុយ អៀន បំណងនឹងចាំធ្វើការបំផ្លាញវាហើយ ។ អៀវ ឆី កំហែកសំបុត្រនោះមើលឃើញសេចក្តីថា បើឡើងសេះចេញទៅបំផ្លាញទឹង អ៊ុយ អៀន សឹមឲ្យបើកស្រោមសំបុត្រជាន់ក្នុងមើលទៀត ។

គៀង អ៊ុយ ឃើញដូច្នោះក៏មានសេចក្តីត្រេកអរណាស់ ទើបនិយាយនឹង អៀវ ធី ថា: លោកចូរយកសំបុត្រនោះទុកទៅចុះ ខ្ញុំនឹងចេញទៅតស៊ូ នឹង អ៊ុយ គៀង ជាមុន លោកចូរនាំទាហានជួនទៅតាមក្រោយអៀវ ធី យល់ឃើញតាម គៀង អ៊ុយ ក៏ឡើងសេះនាំទាហានចេញទៅស្រែកដេរ អ៊ុយ អៀន ថា កាលមហាឧបភដទៅរស់នៅឡើយ លោកក៏មិនដែលធ្វើអ្វីឲ្យខ្ញុំនាសតូចចិត្ត ហេតុម្តេចខ្ញុំនបានជាមកត្រឡប់ប្រែចិត្តក្បត់ដូច្នេះ, អ៊ុយ អៀន តបថា: មិនមែនជាការដោយសារឯងទេ ឯងចូរស្រួតត្រឡប់ទៅប្រាប់ អៀង ធី ឲ្យពេញខ្ជូនមកចាំឆ្លងតខ្ញុំនឹងអញទើបត្រូវ ។

(ទៅមានត)

ការស្រាវជ្រាវអំពីល្ខោនខ្មែរ

លោក លី - ជាមតេង រៀបរៀង

ប្រទេសជាតិនីមួយ ។ តែងរក្សា និងពង្រីកវប្បធម៌ជាតិខ្លួនពុំដែលសល់ទាន ។ ខ្មែរយើង ក៏បានចំពង្រីកវប្បធម៌ជាតិគ្រប់ផ្នែក គ្រប់វិស័យដែលធ្លាប់មានមកហើយស្រាប់តែ ប្តូរទើបតែគាត់តែងឲ្យមានឡើងថ្មីក្តី ។ ហេតុបានជាខិតខំក្នុងវិស័យនេះ ព្រោះជនជាតិយើង ក៏ដូចជនជាតិនានាដែរ យល់ច្បាស់ថា វប្បធម៌ជាគ្រឿងបណ្តុះនិស្ស័យមនុស្ស ពង្រីកស្មារតីមនុស្ស ឲ្យមានប្រាជ្ញាវាងវៃ ចេះគិតកិច្ចការអ្វីមួយបានវែងឆ្ងាយ ។ មិនតែប៉ុណ្ណោះ មនុស្សម្នាក់ ។ តែងមានមនោសញ្ចេតនាប្រចាំកាយហើយមនោសញ្ចេតនានោះឯង ចេះត្រូវការឲ្យមានចំណីអាហារជានិច្ចកាលដែរ គឺថា បើបរិភោគចំណីចាស់ ផ្អែតឆ្អន់ហើយ គោរតែត្រូវការឲ្យទទួលម្ហូបចំណីថ្មីៗទៀត ។ និយាយឲ្យច្បាស់ថា បើយើងធ្លាប់ស្រេបរសជាតិសិល្បៈចាស់ផ្អែតឆ្អន់យូរលង់ហើយ ក៏ត្រូវការគាត់តែងឲ្យបានជាសិល្បៈថ្មីមកដំទួស ឬមកបន្ថែមទៀត ទើបមានការចូរចិត្តទៅទៀត ។ គាស្រ័យហេតុនេះហើយ បានជាអ្នកគុបតែងសិល្បៈចេះតែធ្វើនវកម្មទៅតាមរបៀបថ្មី ។ ជាធម្មតា ពិសេស គឺសិល្បៈដែលចេញជារូប ជាកាយវិការ ជាទស្សនិយភាពយ៉ាងច្បាស់លាស់ ដូចជាក្បាច់រាំនិងល្ខោននេះឯង ។

ល្ខោនខ្មែរយើង កំមានប្រវត្តិវែងឆ្ងាយ ដូចជាល្ខោននៅប្រទេសនានាដែរ ។ បុព្វបុរសយើងចេះបង្កើតវប្បធម៌ កំចង្កើតល្ខោននេះឯងទុកមកឲ្យយើងដែរ ។

ពាក្យថា "ល្ខោន" តាមវចនានុក្រមពន្យល់ថា: ក្លាយមកពីភាសាសៀមថា "ឡ:ខន" (១) ដែលបានន័យថា: មហោស្រពមួយប្រភេទលេងតាមរឿងវែងឬខ្លី ។ ដូច្នេះ បើគិតពីពាក្យហៅឈ្មោះនេះ នាំឲ្យអ្នកខ្លះជ្រឡំថា ខ្មែរទើបតែមានល្ខោននៅសម័យដែលខ្មែរទទួលវប្បធម៌មកពីសៀមមកវិញ គឺរវាងសតវត្សទី ១៧-១៨-១៩ ។

កំប៉ុន្តែតាមពិតមិនដូចនោះទេ កាលមុននឹងមានពាក្យថា "ល្ខោន" កាលនោះ យើងមានឈ្មោះផ្សេងហៅថាអ្វីទៅទៀត ដូចតំណត់ហេតុរបស់ជីវតាក្វាន់ ដែលសរសេរតាំស្រុកយើង សម័យគ.ស. ១២៩៧ ថា: គេលេងរបាំមហោស្រពមួយយ៉ាងហៅថា "អៃឡាំ" ទំនងជាក្លាយពីពាក្យខ្មែរយើងថា រៃ គឺលេងរបាំដំណាលជារឿងនៅពេលចូលឆ្នាំ (២) ។ តាមសិលាចារឹកតិមានអាសាសរបស់ឥសីស្ត្រីឈ្មោះត្រន្ទេវីថា: ឥសីនេះខ្លួន

១- តាមការស្រាវជ្រាវរបស់លោកសីដែស (Bulletin S.E.I. 1963)ថា ឡ:ខន មកពី រចាំភោល ឬ លចាំភោល ។ ភោលជាប្រភេទស្មៅមួយបែប ។ រចាំភោល = រចាំស្មា ។

២- សូមអានសៀវភៅ កំណត់ហេតុរបស់ ជីវ តាក្វាន់ អំពីប្រទៃណា អ្នកស្រុកចេនឡាចាត់ចែងប្រែឆ្លាស់ពីភាសាចិន ដោយ លី ធាមគេង ។

ឯង ចានប្រជុំផ្តុំពួកក្មេងស្រី ។ នៅក្នុងវាំងធ្វើជា "ក្រមុំរបាំ" ហើយកវីនេះ
ទៀត ចានតាំងសរសេរឿងជកស្រង់ពីជាតកនានា សម្រាប់ឲ្យក្រមនេះ
សម្តែងផ្សាយឲ្យអ្នកស្រុកមើល ។

ខាងនេះ បញ្ជាក់ថា ខ្មែរសម័យសតវត្សទី ១៦-១៣ ឯនោះ មាន
ក្រមរបាំសម្តែងរឿងច្បាស់ណាស់ទៅហើយ គ្រាន់តែពុំចាន់ពេញឈ្មោះ
ថ្មីថា "ល្ខោន" នៅឡើយ ប៉ុណ្ណោះ ។

ឥឡូវនេះ យើងសូមអធិប្បាយតែប្រវត្តិល្ខោន ចាប់ពីមានពាក្យហៅ
ថា "ល្ខោន" នេះមក ហើយសូមពយពន្យល់តែតាមការដែលយើងស្រាវ-
ជ្រាវឃើញហើយ ចំណែកឯតែមានដែលមិនចាន់ច្បាស់ កំពុងតែស្រាវ-
ជ្រាវនៅឡើយតទៅមុខទៀតនោះ យើងសូមទុកមួយអន្ទឹងសិន នឹងមាន
អធិប្បាយបន្ថែមនៅពេលក្រោយទៀត ។

ពាក្យល្ខោន ខើបតែបញ្ចេញឥទ្ធិពលខ្លាំងនៅពេលសតវត្សទី ២០ យើង
នេះ គឺសំចាន់តើតមកពីពួកមជ្ឈដ្ឋានអ្នកធំ អ្នកខ្ពស់ មានស្តេច ឬ មន្ត្រីធំៗ
ជាដំបូង ។ ចំណែកអ្នកស្រុកសម័ញ្ញ ពោះជាមានទំយមការសម្តែងសិល្ប:
ជាទស្សនីយភាពរបៀបគ្នានេះ ក៏គេហៅឈ្មោះថាអ្វីផ្សេង ។ ទៅទៀត
ដូចជាហៅថា យីកេ អាប៉ែ, ណាំង, ខោល(រឺបាំពាក់មុខស្អា) ជួរចុះ
ជាដើម ។ ប៉ុន្តែរបៀបបែបទាំងនេះខ្លាយតទ្ធិតលបន្តិចម្តងៗ មកពីឥទ្ធិ-

ពលស្មោនចេះតែផ្សាយខ្លាំងឡើង ។ ចម្ការលស្បែកសិល្ប:ប្លែក ។ មកពី
ប្រទេសក្រៅ ច្រើនឡើង ។ ផ្ទះគ្រប់ទៅគ្រប់ស្រុកភូមិ កាន់តែសុស
សាយឡើងវែរ ។ ទំនួលអ្នកស្រុកបានជួបប្រទះក្លែកនឹងសិល្ប:ប្លែក។
ទៅ រ័ងរិតតែចូលចិត្ត តាមបែបបទដែលហៅថា "ស្មោន"នោះ កាន់តែ
ខ្លាំងសព្វភូមិស្រុក ។

ក្រុមស្មោនដែលឧបត្ថម្ភកពាក្យនេះជាឈ្មោះនោះ គឺក្រុមស្មោនទៅ
កងកំង ដែលហ្វូងន·ពត្តម បានចាត់ចែងឲ្យមានឡើង ហើយឧបត្ថម្ភ
តេញចុះ ដោយឲ្យប្រាក់ឈ្នួនពួកភូនកំ និងរើសយកគ្រូ មកពីស្រុក
សៀម ដែលចេះច្បាប់កំ ចេះតាក់តែងកាយ ចេះដឹកវឿង ចេះបង្ហាត់
ភូនកំ ។ ពួកគ្រូប៉ាំងនេះ ច្រើនមានឈ្មោះថា ឃុន ឬ ជា ម៉ម
(ប្រពន្ធហ្វូង)ផង ។ ហើយ ឃុន-ម៉ម ទាំងនោះ ចង់ឲ្យគាប់ព្រះទ័យ
ហ្វូង ក៏រក្សាស្ថិតស្ថានក្រុមស្មោនខ្លួនឲ្យបានវែរនៅ សម្រាប់លេងថ្វាយ
ស្តេច ទតក្រសាល ទៅពេលបុណ្យទានផ្សេង ។ ទោះបីក្រុមខ្លួនល្អក្តី
មិនសូវល្អក្តី ក៏ទំរកលិ្បចឲ្យបានប្លែកៗគ្នា ដូចមានពាក្យទំនុកទំនើរ
បេះពួកចាស់ ។ នៅក្រុងភ្នំពេញ ដែលហ្វាប់ចេញចូលកងកំងពីដើម
ហ្វាប់ដំណាលលេងទាល់តែចាំមាត់ថា : "ស្មោន ឃុនចាន់ដូចផ្កាត្រកៀត
ស្មោនឃុនព្រះញាតដូចផ្កាត្រកួន ស្មោនម៉ែមស្លួនដូចយួនហាត់ចោយ" ។

មប្រុសាសន៍លោកតា ជុំ ហ្វូង ដែលជាអ្នកចូលចិត្តស្មោនខាំងជាន់

ចាស់ជាន់ថ្មី លោកនិយាយប្រាប់យើងថា ចានជាចាដូច្នេះព្រោះ :

១ - ឃុនចាន់ ជាទីសំណព្វព្រះទ័យហួន តែមានមេស្បាចាយច្រើន រចនាល្ងោនចានល្អ ទើបប្រដូចទៅនឹងផ្កាត្រកៀត ។

២ - ឃុនព្រះញាតិ ក៏ជាទីសំណព្វព្រះទ័យដែរ តែរៀបចំក្រោយម្ហ៉ាះហើយ ល្ងោនគាត់អន់ជាងឃុនចាន់បន្តិច ។

៣ - ចំណែក ម៉ម សួន ជាម៉មថ្នាក់តូចជាងគេ ហើយមិនសូវមានមេស្បាចាយគ្រប់គ្រាន់ ក៏រើសរកកូនចិនយួនឲ្យស្ម័គ្រចូលមកកាំ ។

ប៉ុណ្ណោះ យើងដឹងថា មានល្ងោនចីវង់ហើយទៅពេលដំណាលគ្នានេះ ។ តែបើតាមយើងយល់ ក្រុមចុំនិងក្បាច់រោងនេះ ជាកេរ្តិ៍របស់ខ្មែរដែលទ្ធាប់មានស្រាប់ពីដើមមក គ្រាន់តែគ្រូល្ងោនចាំងនេះយល់ល្បិចពត់ហាត់ពីស្រុកសៀមមកបញ្ចូលបន្ថែម ហើយកាឡៃបទពោលទៅតាមសៀមពាក្យហៅគួ ហើយនិងគ្រឿងប្រដាប់កំភ្លាយទៅតាមសម្ដីសៀម តែប៉ុណ្ណោះ ដូចជាតួឯកស្រី ហៅ«ណាងអ៊ិក» ទាងឯក ឯតួឯកប្រុសហៅ «ណាយវ៉ូង» (នាយភេង) ។ល។ ល្ងោនចាំងនេះ តួរាំសុទ្ធតែស្រីហើយតួមិនមានច្រៀង ឬចេញវាចាឡើយ ទៅពេលចាក់ក្បាច់ គឺមានអ្នកបើកគ្រាំងអានពាក្យតាមគ្រាំង ពួយជារឿងប្រាប់ជាក្បាច់រាំ ហៅថា«អ្នកពោល» ដោយឡែក ។ ដូច្នេះ តួរាំត្រូវតែធ្វើកាយវិការឲ្យចានស្របតាមពាក្យពោល និងតាមចង្វាក់ភ្លេងប៉ុណ្ណោះឯង ។

លោកតា ដុំ ហួន (សព្វថ្ងៃអាយុ ៨០ ឆ្នាំ)និយាយទៀតថា : នៅឆ្នាំ ១៩២០ មានមន្ត្រីខ្លះបង្កើតក្រុមល្ខោននៅស្រុកកំណើតដែរ ដូចជាឧកញ៉ាយោធាទន្តីន់ លោកមានក្រុមល្ខោនមួយរបៀបជាក្រុមយីកេ ប៉ុន្តែបញ្ចូលក្បាច់កំពាក្យពេលរបៀបល្ខោនកំប៉ ឬ ល្ខោនហ្វូង ។ មានមន្ត្រីខាងវេស៊ីជគ្គម្នាក់ទៀតនាមថី អ៊ី មានក្រុមល្ខោនមួយវង់ដែរ លេងតាមបែបល្ខោនហ្វូងសុទ្ធ ប៉ុន្តែបញ្ចូលឱ្យតួច្រៀងខ្លួនឯងផង ពិសេសក្នុងពេលកាប់រឿងថ្ងៃងងុក ថ្ងៃងសេចក្តីសប្បាយ, . . ។ ស្រុកបាលគ្នានេះទៀត មានក្រុមយីកេមួយទៀតដែរ ដែលប្រែបែបទៅតាមរបៀបល្ខោនហ្វូងនេះដែរ គឺក្រុមរបស់លោកចៅអៀម ដែលមានគ្រូបង្ហាត់ជាតិសៀមឈ្មោះនាម ចៅស្រីដតឡយ ។ ក្រុមនេះលេងជារបៀបយីកេសុទ្ធ ប៉ុន្តែតែងត្រឿងនិងភ្លេងពិណពាទ្យដូចល្ខោនហ្វូង ។

មកដល់ពេលមួយ រវាងគ.ស. ១៩២៧ ដែលធ្វើបុណ្យអគិសេកហ្វូងមុនីវង្សខ្មែរសោយព្រះជន្ម, គេលនោះ ក្រុមល្ខោនពីរវង់ដែលមានស្រាប់នៅប្រទេសយើង គឺល្ខោន"នាយវិញ" លេងនៅកំពង់ម្ជូ ត្រង់ផ្សារស៊ីញែក និងក្រុមល្ខោននាយ"អួន" ដែលជាជាតិសៀមមកពីឈៀងម៉ៃ ហើយមកសង់នៅធ្វើល្ខោនក្នុងស្រុកយើងយូរឆ្នាំហើយ ។ ក្រុមល្ខោនទាំងពីរនេះ គេរៀបចំទៅតាមរបៀបដែលខ្មែរនិយម គឺលេងរបៀបយីកេ ប៉ុន្តែបូលតួច្រៀងខ្លះ និងការលៀសម្ងួនបំពាក់ទៅតាមល្ខោនហ្វូងព្រមទាំង

ប្រកបទំនឹងក្ងេតពិណពាទ្យលាយឱ្យមានតួប្រុសផង ។

ដើម្បីប្រកបពេលបុណ្យកាលកិសេកគ្រានេះ ឱ្យបានអធិកអធម មានក្រុមល្ខោន "ប្រមោច័យ" (១) ចូនក្រុមទៀត បង្កើតឡើង ដោយមានមេដឹកនាំ សុទ្ធតែជាស្រីសៀមដែលបានមករស់នៅក្នុងក្រុមល្ខោនខ្មែរយូរឆ្នាំហើយ ។ មេល្ខោនទាំងនោះ មានឈ្មោះដូចតទៅ : ឃុនតេត, ម៉ែម៉ែន ម៉ែចាម៉ាយ និងម៉ែសាងៀម ពាក្យហៅថា ម៉ែ ។ នេះ គឺសម្គាល់ពួកស្រីគ្រូល្ខោន ។ ល្ខោនប្រមោច័យ ឬ ចាមោច័យនេះ លេងក្លាយជារបៀបល្ខោននិយាយ (Théâtre parlé) មកពីស្រុកអឺរុបទៅវិញ ។ មានគ្រឿងតុបតែងធាក, ស្លៀកពាក់តាមបែបធម្មតា ដូចអ្នកស្រុកភូមិរៀមនរៃទេន ប៉ុន្តែមានច្រៀងលាយខ្លះ ហើយមានក្ងេតគ្រឿងផ្ទុំប្រកបផង ដំនាន់នោះគេហៅ ក្ងេតមុយហ្ស៊ិក (Musique) ល្ខោនចាមោច័យលេងជារបៀបចែកជាឈុត ជាធាក ហើយតួមានប្រុសមានស្រី ។ ល្ខោនចាមោច័យ ៤ ក្រុមនេះ ចាននាំគ្នាជាប់ជើយណាស់ ព្រោះដំពើចក្នែកអ្នកស្រុកខ្មែរ ទទួលក្នុងពេលបុណ្យធំនោះមានបណ្តាជនទេវត្តក្រៅមកកកកុញទីក្រុងភ្នំពេញផង ក៏នាំឱ្យសិល្បៈនេះឯង លាស់ល្បាញទៅតាមទេវត្តនានា ។ មិនយូរប៉ុន្មាន ក្រុមល្ខោននេះ ក៏បានទៅលេងដល់ខេត្តធំៗផង ដូច

---

១ — បើចង់ស្រាវជ្រាវបន្ថែមអំពីល្ខោនប្រមោច័យ សូមអានអត្ថបទការស្រាវជ្រាវមួយរបស់អ្នកនិពន្ធ លី ធាមតេង ចុះផ្សាយក្នុងកម្ពុជសុរិយា លេខ ៣ ឆ្នាំ ១៩៦៤ ។

ជា ប៉ាត់ដំបង កំពង់ចាម ជាដើម ។

សម័យនេះហើយ ជាសម័យបែកសាយខាងសិល្បៈល្ខោន ព្រោងព្រាតឡើង នៅទីក្រុងនិងនៅខេត្តធំ ។ ។

នៅភ្នំពេញមានក្រុមល្ខោនចំរើនដែលលេងជាច់យូរត្រែលមកហើយ, ហើយចេះតែទំត្រដរប្រណាំងប្រជែង ជាមួយការផ្លាស់ប្តូរវិវត្តឡើង នៃពួកអ្នកចំណូលថ្មី ។ ក្រុមទាំងបីនោះគឺ :

១- ល្ខោនអ្នកប្រែង លេងជាបែបល្ខោនហួងសុទ្ធសាធ លាយតែត្រង់ឲ្យតួកំមានច្រៀងផង ប្រកបទំនងក្ងេងពិណពាទ្យ ។

២- ល្ខោនក្រឡាបឆ្លាំហ៊ុំ លេងរបៀបចម្រុះ នាំឲ្យមានពាក្យកំប្លែងហៅថា ល្ខោនឆាប់ឆាយ គឺកំភ្លាច់ខ្លះ ច្រៀងបែបថ្មីខ្លះ ស្លៀកពាក់គ្រឿងបុរាណផង គ្រឿងទំនើបផង មានក្ងេងពិណពាទ្យ ក្ងេងត្រែ ក្ងេងស្គរ លេងលាយលុកគ្នា ។

៣- ល្ខោនម៉ាមសយសង្ហាន លេងជាបែបល្ខោនក្បាច់ "ល្ខោនហួង" ដែរ ប៉ុន្តែសម័យនោះឥទ្ធិពលបារាំងចូលមកខ្លាំងពេក ក៏ក្លាយទៅបែបបារាំងខ្លះ ដល់ក្រោយមក មានឥទ្ធិពលល្ខោនឥណ្ឌាយបែបអឺរុបចូលមកទៀតក៏ក្លាយទៅទៀតដែរ ។

នៅឯខេត្តប៉ាត់ដំបងនោះមានល្ខោនមួយវង់ប្រចាំស្រុកយូរមកហើយ។ អ្នកម្ចាស់ល្ខោនចេះតែបែកមតិគេនេះតមកក្លូនចៅតៗគ្នា រហូតដល់សម័យ

ប្រឡូកជាមួយគេនេះឯង គេស្គាល់ឈ្មោះល្ខោននេះថា ល្ខោនចែរៀម ។ ល្ខោននេះ ដំបូងឡើងលេងជាល្ខោនក្បាច់ខ្មែរ តែក្រោយមក ក៏កាន់ប្រែចែបជាបាមោច័យ ឬចែបល្ខោនសម័យថ្មីខ្លះ ហើយទីបំផុត ក៏ក្លាយរូបជាល្ខោនចាសាក់ដែរ ។ គឺមិនមែនតែល្ខោនចែរៀមទេ ដែលក្លាយខ្លួនទៅជាច្រើនសាខោះ ល្ខោននៅក្រុងភ្នំពេញទាំងចាស់ដែលយើងរាប់មកខាងលើ ក៏ចេះតែក្លាយប្រែប្រួលដូច្នេះដែរ ព្រោះហេតុក្រោយពីល្ខោនចាមោច័យអស់ឥទ្ធិពលទៅ មានឥទ្ធិពលពីរកើតឡើងទៀត គឺ :

១- ល្ខោនចាសាក់ .— ល្ខោនចាសាក់នេះ កើតមកពីអ្នកស្រុកកម្ពុជាក្រោម ដែលយើងនិយមហៅថា ស្រុកចាសាក់ ឧទាហរណ៍នៅភូមិភាគដទៃក្រៅពីភូមិចាសាក់ក៏ដោយ ឲ្យតែមកពីស្រុកក្រោម ។ តាមពត៌មានពីលោកតា ឆាត្រន់ ជាអ្នកដឹកនាំយកល្ខោននេះមកចូលស្រុកខ្មែរពីដំបូង ក្នុងឆ្នាំ ១៩៣០ លោកនិយាយថា ដំបូងនៅស្រុកក្រោម ក៏មានក្រុមយីកេ លេងតាមស្រុកភូមិ ដូចនៅកម្ពុជាកណ្តាលយើងនេះដែរ ។ ប៉ុន្តែដល់មើលដដែល ។ យូរពេក អ្នកស្រុកឯនោះក៏ដុញគ្រាន់ មានអ្នកខ្លះចូលចិត្តទៅមើលហាត់ចោយយួន (ល្ខោនច្រៀង) ទៅវិញ ។ ជួនកាលហាត់ចោយនោះ មានតុបតែងឆាកលំអគ្រឿងតាមចែបតែរលឹង (ល្ខោនសម័យថ្មី) ផង ក៏ជាហេតុនាំឲ្យរីតតែប្លែកភ្នែកណាស់ទៅទៀត ។ ម្ល៉ោះហើយ គាត់មានយោបល់មួយ គឺតម្រូវចិត្តអ្នកស្រុក ក៏

យកយ៉ែកេយើងនេះ គាត្បៀទៅជាបែបហាត់ប្រាយ ជាល្ខោនច្រៀង មិនមែនជារបាំរបែរទេ ។ គេលេងមានច្រៀងកប់រឿបទ្ធទងតាមដំណើរឥតមានអ្នកពោល ហើយធ្វើកាយវិការទៅតាមសភាវគតិ គឺលោតវត់ដួល ដើរ ប្រកាប់គ្នា ប្រដេញគ្នា លួងលោមបែបងំគ្នា ទៅតាមសាច់រឿង ។ វេលានោះមានមនុស្សនិយមច្រើន អ្នកស្រុកក្រោមចាស់ៗហៅល្ខោននេះថា យ៉ែកេ ។ ព្រោះមានដើមកំណើតមកពីយ៉ែកេ ។ ល្ខោននេះបានចូលលេងដល់ទីក្រុងព្រៃនគរ តែតែល្បីខ្លៅ មានតាំងយួនៗមើលឥតកុញ្ជាល់យប់ផង រហូតដល់មានអ្នកពីភ្នំពេញទៅឃើញក៏បបួលដឹកនាំមកលេងស្រុកខ្មែរ ។ លុះមកដល់ ក៏បានជោគជ័យយ៉ាងខ្លាំង ព្រោះល្ខោននេះ មានកាយវិការហ៊ឹកហ៊ាក់ហ៊ាសហួន មើលមិនធុញ ។ លេងនៅភ្នំពេញ រួចដឹកនាំទៅលេងខេត្តខ្មែរ តែទៅតែខេត្តនៅតាមមាត់ទឹក ដូចជាកំពង់ចាម ក្រចេះ កំពង់ឆ្នាំង ព្រោះក្រុមល្ខោននេះគេនៅទំនងទូកប៉ុកចាយធំ បើលើកទៅណាងាយទូក មានកន្ទែងដេកនៅបាយទឹកនិងប្រដាប់ប្រដាសម្រាប់ធ្វើពេទ្យពីរទាំងសំពត់កៅអីដែកបត់ អាចតម្លើងបានភ្លាម ។ ពីណាក៏បាន ឲ្យតែមានដីក់ល ។ ពួកតួនាំ សុទ្ធតែក្រមុំកម្ងោះត្រឹមត្រូវពិតប្រាកដ មានរូបស្អាត ។ មានចាស់ៗជាគ្រូ លេងជាតួស្តេច ជាតួឪពុកព្រះឥន្ទ ឬតួឥសី ។ល។

ដោយហេតុតែល្បីល្បាញល្ខោនចាស់ដែលអ្នកស្រុកយើងដាក់ឈ្មោះ

ឡូនេះឯង ជានជាល្ខោនបែបឯទៀតៗ ការឡៃខ្លួនទៅតាមបែបល្ខោន ជាសាក់នេះអស់ ព្រោះបើមិនការឡៃដូចគ្នាទេ ទំនងពុំមានមនុស្សមើលឡើយ សូម្បីល្ខោនបែបរៀមទៅឯជាត់ដំបងឯនោះ ក៏តោងតែក្លាយបែបទៅតាមគេដែរ (ពត៌មាននេះ លោកកូយ យក់ហួ ដែលជាមិត្តអ្នកនិពន្ធរបស់ខ្ញុំ និងជាកូនប្រសារបស់បែបរៀមនេះឯងតែម្តង ជានបញ្ជាក់ប្រាប់ខ្ញុំ)។

២ - ល្ខោនសម័យថ្មី .- បែបបទល្ខោនសម័យថ្មីនេះ ជាលិល្យៈ មានពីបស្ចិមប្រទេស ដោយសារកាលនោះ ប្រទេសខ្មែរយើងនៅក្នុងអាណាព្យាបាលជាំង គេក៏ព្យាយាមផ្សាយវប្បធម៌គេដែរ។ មិនតែប៉ុណ្ណោះ ជាំងជានអនុញ្ញាតឲ្យក្រុមល្ខោនសម័យថ្មី គឺល្ខោននិយាយ "Théâtre parlé" របស់ប្រទេសនានាចូលមកលេងស្រុកខ្មែរដើម្បីផ្សាយវប្បធម៌បស្ចិមប្រទេស ថែមទៀត ។ លោកតាដុំ ហួន និយាយថា : កាលនោះមានល្ខោនមកពីសៀម មកពីឥណ្ឌូណេស៊ី និងមកពីស្រុកយួនខ្លះ ។ រឺ៉ាំងនេះ ច្រើនតែជាក្រុមដែលពាដការអាណាព្យាបាល ឬក្រុមសិស្សក្នុងវិទ្យាល័យ មហាវិទ្យាល័យគេបង្កើតឡើង ហើយធ្វើដំណើរទេស្សនាចរណ៍ទៅតាន់ប្រទេសនានាជាដំណើរសិក្សារបស់គេ ។

លុះឃើញល្ខោនសម័យថ្មីនេះញឹកញាប់ទៅ ស្រុកយើងពិសេសក្នុងមជ្ឈដ្ឋានអ្នកចេះដឹង គឺពួកមន្ត្រីរដ្ឋបាលខ្មែរក្តី ខាងមន្ត្រីអាណាព្យាបាល [Protectorat] ក៏នាំគ្នាខ្លួលស្គាល់ភ័ស សិល្បៈនេះ ជាសិល្បៈថ្មី

ប្លែក គួរបង្កើតឲ្យមានក្នុងស្រុកយើងខ្លះ ហើយនាំគ្នាហៅរត់មាត់សិល្បៈ
នេះថា ល្ខោនតេអាត្រ។ (Théâtre) ជាប់ហូតមក ។ គ្រានោះមាន
ខ្មែរមួយក្រុមនាំគ្នាប្រឹងបង្កើតក្រុមល្ខោនសម័យថ្មីនេះខ្លះដែរ ប៉ុន្តែមិនមែន
យកតាមបែបគេសុទ្ធសាជនៃ គឺចេនាទៅតាមការនិយមរបស់ខ្មែរដោយ
លេងជាធាតជាឈុត និយាយធ្វើយធ្ងន់និងស្រួកពាក់តាមសម័យថ្មីហើយ
តែមានផ្សំជាមួយភ្លេង មានច្រៀងដោយអន្ទះ។ និងលាយរបាំអ្នកកំសះ
ផង ហើយរបាំនេះ ច្រើនកំទៅមុនពេលចេញជារឿង។ ដូនគាលក៏កំរបាំ
ខ្មែរដែលការឡើងក្បាច់ពីក្បាច់ល្ខោនបុរាណខ្លះ ឬកំតាមបែបក្បាច់យីកេ
ក៏មាន ក្រៅពីនេះ មានយកលំនាំកំតាមបែបបារ្លេ ពួកបស្ចិមប្រទេស ។
បែបនេះមនុស្សថ្មែកន្លែក ក៏ចូលចិត្តមើលច្រើនដែរ ដូច្នេះបានជាជាប់
ចំលាប់ក្នុងវង់ល្ខោនតរៀងមកតែងតែមុនទីផ្ដួនរឿង គេដួនរបាំ ចិន (ខ្លះ
ហៅថាលោតម៉ាំ) ។ ក្រុមល្ខោនវង់ថ្មីនេះ ពុំមែនកើតឡើងដោយ
នរណាម្នាក់ឡើយ គឺមានសមាគមមួយ រួបរួមមូលដើមទុនមកកសាង
ច្រើនតែមន្ត្រីពដការខ្លះ និងមន្ត្រីក្នុងវាំងខ្លះ មានតាំងឃុនព្រះម្នាង
យិនតាត ជាអ្នកឧបត្ថម្ភផង ។ លោក ដុំ ហួន ទទួលជាអ្នកកាន់កាប់
ទីធាត់ចែងការផ្សាល់ក្នុងល្ខោននេះ ។ លោក ដុំ មៅ ក៏ចាប់ដៃងតែង
រឿងរៀបចំពាក្យពេចន៍ បង្ហាត់និយាយឲ្យត្រឹមត្រូវ មានម្ដង។ លោកប្រែ
រឿងជាកំមកសម្ដែងដែរ ។ ក្រុមនេះបាននាំគ្នាទៅសុំឈ្មោះពីព្រះសព

សម្តេចព្រះសង្ឃរាជ ជួន-ណាត ដែលកាលនោះទៅជាព្រះពុទ្ធយោសាចារ្យ ។ សម្តេចតំប្រតិដ្ឋនាមថ្វាយថា : "ក្រុមល្ខោនវិញ្ញានាតិរម្យ" ។ ពេលចេញសំដែងដំបូង ជានុកាសសម្តេចអតីតធំៗណាស់ មានហ្គង មានរ៉េស៊ីដង់ស៊ុបែរីយ៉ឺ (Résident supérieur) និងមន្ត្រីចាក់ង-ខ្មែរ អ្នកមុខអ្នកការទាំងអស់ មកជួយអបអរសាទរ ។ ល្ខោននេះ លេងបានយូរត្រលែដែរ ប្រកបដោយការល្បីល្បាញ នាំឲ្យវង់តូចៗដទៃទៀត នាំគ្នាប្រឌិតយកបែបបទពីល្ខោននេះ ទៅលេងតាមច្រើនដែរ ។ ប៉ុន្តែដោយលំបាកខាងសម្ភារៈនិង ខាងបច្ចេកទេស ក្រុមនេះក៏ផ្លាស់ដំណើរខ្លួនទៅវិញទៅ ។

បន្ទាប់ពីនោះ ពួកការអាណាព្យាបាល គេបានចាត់អ្នកលេងល្ខោនម្នាក់មកពីស្រុកបារាំង ឈ្មោះ Gui porée ,, មកបង្ហាត់ល្ខោនិយាយនេះឲ្យបានម៉ឺងម៉ាត់ មានឈ្មោះថា "ក្រុមតេអាត្រន៉ូវ៉ែ=Théâtre nouveau" ដែលបង្ហាត់នៅសាលមហោស្រពហៅថា ហ្វីឡាម៉ូនិច Phyllamonique (នៅជិតក្រសួងយោសនាការសព្វថ្ងៃនេះ) ។ ក្រុមនេះមានមន្ត្រីខ្លះចូលហាត់រៀនខ្លះដែរ ច្រើនតែពួកគ្រូនិងមានសិស្សជាច្រើនទៀត ។ គេបង្ហាត់បានចេញសម្តែងច្រើនលើកណាស់ ទៅពីក្រុងនិងទៅខេត្តក្រៅ គឺលេងតាមរបៀបល្ខោននិយាយសុទ្ធសាធតាមក្បួនខ្នាត ។

ដោយសារតម្លៃលែបែបបទល្ខោនចាំងពីរសណ្ឋាន គឺបែបល្ខោន

ជាសាក់ជាស្មោនច្រៀង និងស្មោនតេអាត្រ ជាស្មោននិយាយនេះហើយ ក្រោនជាស្រុកយើនៅសល់តែខ្ចីតិចពីរបែបនេះដែរ ដល់មកសព្វថ្ងៃ ។ ព្រោះថាស្មោនជាសាក់ បេះតែខ្លួនពីរដង់មួយទៅដង់មួយ ពីដង់ធំទៅជាដង់តូចៗនៅតាមស្រុកខែត្រនានា ពិសេសគឺស្រុកខេត្តនៅតាមជួរមាត់ទន្លេធំ មានច្រើនជាងគេ ក្រៅតដល់លេងដូរជាផលានុផលក៏ក្រោន មិនជាប់ទិញសំបុត្រនឹងលុយទេ ព្រោះអ្នកស្រុកមិនគាន់លក់ផលានុផលក្រោន ។ បន្ទាប់ពីក្រុមស្មោន របស់លោកតា ធាត្រន់ ទៅ មានដង់បន្តបន្ទាប់មកទៀត គេហៅថាដង់ទី២-ទី៣ សុំអនុញ្ញាតកាប់ឈ្មោះខ្លះរុកជាប្រវត្តិ គឺក្រុមស្មោនជាសាក់សំខាន់ៗ ទៅក្រុងភ្នំពេញ មានក្រុមស្មោនអ្នកដូនឡា, ស្មោនជាឡាត់អូន, ស្មោនក្រឡាបញ្ជីស្បោង ហើយក្រោយមក មានស្មោនឃុនព្រះអ្នងយិនតាត ស្មោនថៅកែជាក់ស្រែង ស្មោនកេងខ្លួលទំព្លង ។

ចំណែកស្មោននិយាយជាបែបសម័យ គោបើជាផុតពីក្រុម វឌ្ឍនាកម្ម ក្រុមតេអាត្រទ្ធរ៉ូនោះទៅ ក៏នៅសល់ទំនិញពួកសិស្ស ដែលគេលេងម្តងៗ ក្នុងពេលបុណ្យ ដូចជាពេលចែកវង្វាន់ ឬបុណ្យកឋិនរបស់សាលា ជាដើមនេះគេហៅមួយទៀតថា ស្មោនកូនសិស្ស ។ ក្រៅពីសិស្សមានសមាគមខ្លះខាងវប្បធម៌ ដូចជាសមាគមមិត្តសិស្សចាស់ សមាគមអ្នកនិពន្ធខ្មែរ សមាគមបុគ្គលិកសិក្សា ។ល។ ជាធ្លាប់ក្រុមស្មោន

ថៃបន្ទេះ លេងម្តង ។ ដែរ ជាការផ្សាយវប្បធម៌ផង និងជាការរៃអង្គាស បច្ច័យជួយខុបត្ថម្ភសមាគមផង ។ លុះមកដល់ឆ្នាំ១៩៥៥-៥៦ ទើប ពង្កើតជាក្រុមល្ខោនរបស់រដ្ឋឡើង ដោយប្រមូលផ្តុំគ្នាក ដែលបានរៀនវិជ្ជាល្ខោនពិតប្រាកដ មានលោកហង្ស-ធុនហាក់ មកពី ប្រទេសថៃកំង និងអស់លោកដែលធ្លាប់រៀនទៅសាលាតេអាត្រន្ទ្រ៉ូ ឬ ធ្លាប់ហាត់លេងជាច្រើនដងទៀត ដូចជាលោក ឌុច-ស៊ីឌិម លោកអ៊ុំ-ឈឺន លោកពៅ-យូរឡង លោកគង់-លិម ជាដើម ហើយតមកក៏ បង្ហាត់បានអ្នកចូលចិត្តសិល្បៈនេះ បានជាច្រើននាក់ទៀត មានលោក ឆេង-ផុន, លី-គិមអួង, ន្ហួន-កន, ប៊ុល-សំអឿន, មាស-តក, ហ៊ីង-ប៊ុនថុន, ហង្ស-ដួន, ផឹក-សំផេន, ស្រី-ឡុច សៅ-វណ្ណគុណ។ល។ និងអ្នកគ្រូជាច្រើននាក់ទៀត ដែលខ្ញុំសុំអភ័យទោសមិនបានពប់នាម ។ ក្រុមល្ខោន ដែលរៀបចំមានច្បាប់ទម្លាប់ មានការរៀនសូត្រពិតប្រាកដ នេះ ក៏មានឈ្មោះថា "ល្ខោនជាតិនៃប្រទេសកម្ពុជា" ជាប់តមករហូត ហើយសព្វថ្ងៃនេះ នៅក្រោមអំណាចសកលវិទ្យាល័យវិចិត្រសិល្បៈ ហើយក៏នៅតែហៅថា "ល្ខោនជាតិ" ដែរ ។

សេចក្តីអធិប្បាយនេះ បញ្ជាក់ថា ខ្មែរជាអ្នកនិយមល្ខោន តាំង ពីសម័យបុរាណរៀងមកតាំងពីមិនទាន់មានពាក្យហៅថា "ល្ខោន" នោះ

ទៅទៀត ។ រហូតមកដល់ពេលកើតពាក្យហៅថាល្ខោនហើយ ក៏តែតែដុះដាលសាយភាយច្រើនណាស់ទៅទៀត ហើយមានអ្នកបន្តពូជតាំរួចចូលចិត្តស៊ប់ស្ងួនក្នុងសិល្បៈល្ខោននេះ កំច្រើនគ្នាណាស់ ដើម្បីរក្សាពូជវប្បធម៌ខ្មែរនេះ មិនឲ្យសាបរលាបទៅបាន ។

ខ្ញុំសុំបញ្ចប់ការស្រាវជ្រាវប៉ុណ្ណេះសិន តាមដំណើរឯកឃើញ ឯការស្រាវជ្រាវតទៅមុខទៀត ក៏នៅតែធ្វើជាលំដាប់ ។ បើបានឯកសារថ្មីក ឬស្រាស់ជាងនេះ នឹងអធិប្បាយបន្ថែមទៅទៀត ។

មង្គលឡើងផ្ទះថ្មី

លោក ឆយ ស៊ីជាន រៀបរៀង

តាមធម្មតា ប្រពៃណីពីបុរាណរបស់ប្រជាពលរដ្ឋក្នុងសាធារណរដ្ឋ
ខ្មែរ កាលណាគេបានសង់ផ្ទះថ្មរួចហើយ គេតែងតែប្រកបពិធីជា
មង្គល ដើម្បីទៅនៅលើផ្ទះថ្មីនោះ ឲ្យបានត្រជាក់ត្រជំ សុខដុមរមនា
មានជោគជ័យសិរីមង្គល ។

ជាបឋម អ្នកម្ចាស់ផ្ទះ គប្បីរកហោរាគន់គូរ ឬក្សត្រាភស័ ដើម្បី
រកថ្ងៃ ទីឆ្លើងទៅនៅលើផ្ទះនោះ ។ កាលបើបានពេលល្អហើយ
គេក៏រៀបចំវត្ថុផ្សេង ។ ដើម្បីប្រកបពិធីដែលមានជាការចាំបាច់គឺ :

១- ភ្ញីភដ៏រ ឬ គុយរមាស

២ គ្រឿងអលង្ការ

៣- សំពត់ភាវសាវសៀ

៤- សាច់ក្រាក់សុទ្ធ ឬក្រាក់ណែន .

៥- ថ្មបិទមាសមួយដុំ

៦- ដូងពុំបិទមាសមួយផ្លែ

៧- ត្រឡាចបិទមាសមួយផ្លែ

៨- លីកប៉ុកខ្ចីដំ

៨- ស្រួតគង់

១០ ឆ្នាញីសម្បុរបី

១១- កន្ទេល ខ្នើយថ្មី មួយសម្រាប់

លុះបានឫក្សាពេលហើយ ត្រូវរៀបចំហែរបស់ដែលបានរៀប
ចាប់មកនេះ ជាក្បួនតាមលំដាប់លំដោយឲ្យមានអ្នកកាន់ច្រវែងរបស់បូរ
ប្រកបដោយលក្ខណៈផង ដូចតណិនា ខាងក្រោមនេះ :

១- អាចារ្យចាស់ពុំម្នាក់ដើរនាំមុខ កាន់សក្ការបូជា

២- ប្រុសមានគូស្រករម្នាក់ កាន់ក្អមដ៏ប្រពុយរមាស តម្កល់
លើពានប្តោក

៣- ស្រីមានគូស្រករម្នាក់ កាន់ពានតម្កល់គ្រឿងអលង្ការ

៤- ស្រីម្នាក់កាន់ពានដាក់សំពត់អាវសាវរៃស្បៃ

៥- ស្រីម្នាក់កាន់ពានសាច់ប្រាក់ប្រកក្នុងថង់ ឬប្រាក់ឈេន

៦- ប្រុសម្នាក់កាន់ថ្មមណិសិលា បិទមាស មួយដុំ

៧- ស្រីម្នាក់កាន់ដូនពុំបិទមាសមួយផ្លែ

៨- ប្រុសម្នាក់កាន់ត្រឡាចបិទមាសមួយផ្លែ

៩- ក្មេងប្រុសដំទង់ម្នាក់កាន់ពានដាក់លិក្ខដុំកន្ទុំ

១០- ក្មេងស្រីព្រហ្មចារីយ៍ម្នាក់កាន់ស្រួតគង់ដាក់ក្អមពានឫក្ស

១១ – គឺជាទី ស្រីមានគភ៌ បីឆ្នាញ៉ សម្បុរបើ ពាក់ចង្រ្កឹងមាស ម្ជុច្រាក់ ។

១២ – មនុស្សប្រុស-ស្រី កាន់កន្ទេលខ្នើយ

ឯស្ងួនហែ ត្រូវដុំវិញផ្ទះឱ្យជាទក្ខិណាភគ៌ គឺហែពីស្តាំទៅឆ្វេងចំនួន ៣ដុំ ។

កាលណាហែបានមួយដុំ មកដល់ដើងជណ្តើរមុខអាចារ្យនាំមុខ ត្រូវស្រែកសួរអ្នកម្ចាស់ថា :

–អឺ ! លោកម្ចាស់ផ្ទះ

ពេលនេះ អ្នកនៅលើផ្ទះមិនទាន់ឆ្លើយ ។ ស្ងួនហែបានគ្រប់ពីរដុំ អាចារ្យសួរម្តងទៀត តែអ្នកនៅលើផ្ទះមិនទាន់ឆ្លើយទៀត ។ លុះគ្រប់បីដុំ ទើបអាចារ្យហៅទៀតថា :

–អឺ លោកម្ចាស់ផ្ទះ

ម្ចាស់នេះអ្នកម្ចាស់ផ្ទះត្រូវឆ្លើយថា :

–អើ ចុះអ្នកណា ទៅណាមកណា នាំគ្នាអ៊ូអរយ៉ាងនេះ

–សូមទោស លោក យើងខ្ញុំមកពីឆ្ងាយណាស់ សូមជ្រាប

–ចុះមកពីណា អ្នកឋ ឆ្ងាយ តើអ្នកមកពីទាយ មកពីនគរណា

–ជា ! យើងខ្ញុំមកពីនគរកេតុត្តៈ

–ប៉ុះអ្នកមកមានចិត្តប៉ងប៉ំណាងកិច្ចការអ្វី

–ចាស យើងខ្ញុំចាន់លេចឮខ្លីដឹងដំណឹងដល់ថា លោកស្រីលោកប្រុស ចាន់សង់ផ្ទះថ្មយ៉ាងធំទ្រនំខ្ពស់ មែនឬមិនមែន?

–មែន តើអ្នកមានការយ៉ាងណា សូមអ្នកថ្លែងការណ៍ច្រាបមកចុះ

–ដោយយើងខ្ញុំចាន់ដំណឹងនេះ ទើបនាំគ្នាយកគ្រឿងត្រជាក់ត្រជុំចម្រុងចម្រើនមកជូនជាជោគជ័យ សិរីមង្គល មាន់ទាំងកុយពុក ក្តុកស្អុយ មាសប៉ុនដូងតុំ ប៉ុនត្រឡាច គ្រឿងសំពត់អាវសាវសៃរ្ស មាសច្រាក់កែវ កងពាក្ខូសូរ្យកាន្ត មានធ្មៅឡាវសច្ចាបេ ពាក់ដាំតូង បើលោកត្រូវការខ្ញុំមានច្រាច្នាជូនដោយឥតថ្លៃ សុំតែចាយអាស្រ័យមួយពេលប៉ុណ្ណោះ ។

ឯរឿងចាយទឹកមិនមានខ្វះអី បើពិតជូចសំដី សូមអញ្ជើញនាំគ្នាឡើងមកចុះ ។

នៅវេលាអ្នកម្ចាស់អនុញ្ញាតឲ្យឡើងហើយ អាចារ្យត្រូវរៀបចំសែន ស្បាលជណ្តើរ ។

ឯគ្រឿងក្រយាបូជាខោះមានដូចតទៅ

ចំអាបមួយថាស

បង្អែមមួយថាស

ក្បាលជ្រូកស្មោរមួយ

ផ្តិលទឹកមួយផ្តិល ដាក់អម្បោះចំណង់ដៃ

ប៉ាយស៊ីប៉ាកធាមមួយគូ

ស្វាធមិមួយ

កាលរៀបចំហើយអាចារ្យត្រូវសំបូងសម្រួង ប្តឹង ខេពតា ខេត្រ័ក្ស ដំនាងផ្ទះ សុំឲ្យជួយអភិបាលក្សា ចំរើនសិរីសួស្តីធុការពារតទៅ ។

ឯពាក្យសំបូងសង្រ្គងនេះយើងលើកមកដូចជាសណ្តាប់ដូចតទៅ :

ខ្ញុំ - តេជៈម្ចាស់ថ្ងៃ ថ្ងៃនេះថាតាមានឫក្ស អធិមង្គល ខ្ញុំសូមប្តឹងដល់ អស់ព្រះភូមិម្ភា ខេត្តា រក្សាភូមិឋាន វិមានថ្មី តិ្រតពេលនេះ លោក ..... អ្នក ..... បានសង់ផ្ទះរួចហើយ ។ រៀបចំឡើងនៅក្នុងថ្ងៃនេះ សូមខេត្តារក្សាផ្ទះថ្មីនេះ ជួយពិភ័ត្តិរក្សាឲ្យសិរីសួស្តីធុការ សិរីស្តួស្តីជ័យមង្គល វិបុលសុខគ្រប់ប្រការ ចំរើនលាភាតាំងពីពេលនេះរៀងតទៅ ។

និយាយសំបូងសង្រ្គងរួចហើយ អាចារ្យត្រូវចាប់ ម្ហូបចំណីកាត់ត្រៀកជ្រូកមួយចំណិត ដាក់ក្នុងកន្ទោងមួយ រួចច្រួចទឹកបន្តិច ដាក់សែនទៅក្បែរគល់ឈើមួយក្នុងរបងផ្ទះថ្មីនោះ ។

លុះចប់ការសែនហើយ ត្រូវយកអម្បោះចងក្បាលជណ្តើរ រួចច្រួចទឹកសុំពរជ័យ ។

កាលអ្នកហៅបានឡើងទៅដល់លើផ្ទះហើយ អាចារ្យត្រូវរៀបចំចងដៃប្រសិទ្ធិពរដល់ម្ចាស់ផ្ទះ គឺត្រូវក្រាលកន្ទេល ឈរមុខទៅកើតដង្កើមរស់ រៀបរបស់កសុគារ នៅទីជាមួយ រួចអញ្ជើញម្ចាស់ផ្ទះមកអង្គុយក្រាបលើខ្នើយ ហើយចងដៃឲ្យពរស័ព្ទសារធុគារប្រសិទ្ធិឲ្យបានត្រជាក់ត្រជុំចម្រុងចម្រើនជាកិយ្យាភាព ។

តពីនេះទៅត្រូវនិមន្តព្រះសង្ឃចំរើន ពុទ្ធមន្ត តាមប្រពៃណីពុទ្ធសាសនា ដើម្បីបញ្ជៀស ឧបទ្ទវន្តរាយទាំងឡាយទាំងពួង នឹងដើម្បីចម្រើនសុខសួស្តីសិរីមង្គលដល់ម្ចាស់ផ្ទះថ្មីនោះតទៅ ។ លុះចប់កិច្ចចំរើនបត្តិ អ្នកម្ចាស់ផ្ទះតែងតែរៀបចំលៀងភោជនាហារតាមការគួរ ។

ពិធីសម្ពោធឧបោសថាគារ

វត្តសុមុនីរតនារាម សង្កាត់លេខ ១០ ក្រុងភ្នំពេញ

លោក ស្ពឺង ឆ្នរ នាយការិយាល័យ ធម្មការ រៀបរៀង

កាលពីរសៀលថ្ងៃពុធទី២ កញ្ញា ១៩៧១ នៅវត្តសុមុនីរតនារាម សង្កាត់លេខ ១០ ក្រុងភ្នំពេញ មានធ្វើពិធីសម្ពោធ ឧបោសថាគារមួយខ្នង ដែលទើបនឹងសង់ហើយនោះ ក្រោមព្រះអធិបធិការ នៃសម្តេចព្រះសុធម្មាធិបតី សង្ឃនាយក គណៈធម្មយុត្តិកនិកាយ និងលោក ប៊ុំណាច័ន្ទ-ម៉ុល អនុរដ្ឋលេខាធិការក្រសួងធម្មការ ។

នៅវេលាម៉ោង ១៩ មានការជួបជុំមន្ត្រីសង្ឃ - ព្រះសង្ឃ និងពុទ្ធបរិស័ទជាច្រើន ដែលគេសង្កេតឃើញជាអាទិ៍ ខាងផ្នែកព្រះសង្ឃមាន : ព្រះមហាសាសនវង្សាធិបតី និន កេន មេគណក្រុងគណៈធម្មយុត្តិ, ព្រះមហាព្រហ្មមុនី សុខ-យឺន, ព្រះសមាធិញ្ញាណ មាស តន់, ព្រះធម្មត្រៃយ លោកាចារ្យ ពុធ ប៊ុន, ព្រះញាណមូលី ឆឹង អាំង មេគណខេត្តព្រៃវែងគណៈធម្មយុត្តិ ព្រះរតនមុនី ស៊ូ - ញ៉ិយ, ព្រះមហាវីរវង្សាចារ្យ ម៉ា - ឡុង ចៅអធិការវត្តប្រយូរវង្ស, ព្រះធម្មវរោត្តម ជា -សុខ ចៅអធិការវត្តស្វាយពពែ, ព្រះវជិរមេធា ឡេ ឡុង ចៅអធិការវត្តខ្នង

មណីកម ។ ខាងផ្នែកគ្រហស្ថមាន: លោកប៊ុណ្ណច័ន្ទ-ម៉ុល អនុរដ្ឋលេខា ធិការក្រសួងធម្មការ ទំនងសហការី លោកឧត្តមសេនិយត្រី អ៊ុយ សយ, លោក ដុំ យ៉ែម, លោកហ៊ីង-ដួង លោក សឿ-ហ៊ាល លោក អ៊ុន ង្ហួនឆាយ លោក ហោ-កន និងពុទ្ធបរិស័ទ ឧបាសក ឧបាសិកា ចំណុះដើងវត្តជាច្រើនទៀត ដែលយើងសូមអភ័យទោសដោយមិនបាន រៀបរាប់ឲ្យបានសព្វគ្រប់ ។

ក្រោយពីលោកប្រធានគណៈកម្មការវត្ត ថ្លែងរៀបរាប់អំពីការស្ថាបនាវត្ត និងព្រះវិហារថ្មីនេះមក មានធ្វើពិធីមង្គលការព្រះតេនត្រៃយ សមាទានសីល ពិធីចម្រើនព្រះបរិត្ត ហើយទំនងការវេរ ឧបោសថាគារ ប្រគេនព្រះសង្ឃ ដែលមានសម្តេចព្រះសុធម្មាធិបតី សង្ឃនាយកគណៈ ធម្មយុត្តិកនិកាយជាប្រធាន ។ បន្ទាប់មកព្រះសមាធិញ្ញាណមាស-តន់ បានឡើងថ្លែងសេចក្តីអំណរអនុមោទនា ចំពោះសម្តេច មន្ត្រីសង្ឃ ព្រមទាំងពុទ្ធបរិស័ទទាំងអស់ ដែលបាននិមន្ត អញ្ជើញចូលរួមក្នុងពិធីនេះ ។

លុះព្រឹកឡើងថ្ងៃទី ៣ កញ្ញា ១៩៧១ មានធ្វើពិធីវេរកឋិន និងទេសនាជាកិច្ចបញ្ចប់ពិធីបុណ្យ ។

សូមបញ្ជាក់ថា ឧបោសថាគារនេះ ស្ថាបនាអស់ប្រាក់ ១៦២.០៣-

រៀល ដោយមិនគិតពីសម្ភារៈខ្ទះ ដែលគេប្រគេនឥតគិតថ្លៃ និង
ឈ្នួលជាដើមផង។ ។

គណៈកម្មការស្ថាបនា សូមលើកកុសលនេះ ប្រគេនព្រះសង្ឃ និង
ជូនពុទ្ធបរិស័ទគ្រប់ប្រភេទ សូមបានប្រកបដោយសេចក្តីសុខ ចម្រើនកុំបី
ឃ្លៀងឃ្លាតឡើយ ។



អង្គុត្តរនិកាយ

ទស្សនាវដ្តី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ

ឆ្នាំទី ៤៣ ខែ តុលា

ព.ស. ២៥១៥ គ.ស. ១៩៧១

- ភ្នំពេញ -



កម្ពុជសុនិយា

ទស្សនាវដ្តី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ

បេញ្ញារាល់ខែ ពី ពុទ្ធសាសនបណ្ឌិត្យ

ចាត់ចែងបោះពុម្ពផ្សាយដោយគណៈកម្មការមួយ មាន :

និពន្ធនាយក - អ្នករៀបចំ : លី ធាមតេង

គណៈកម្មការនិពន្ធ :

ព្រះពោធិវង្ស សូរ-ហាយ

លោក ផល-ឥត អ្នកស្រី រេជ-សល់

បញ្ជីរឿង

អត្ថបទ	ទំព័រ
១— ផ្នែកសាសនា	
១— ចតុភរិយសច្ច ព្រះភិក្ខុ ប៉ាង ខាត់ រៀបរៀង	៨១៩
២— រឿងនាងសាមាវតី (ត) លោក ប៊ូ-ប៊ូ ប្រែ-រៀបរៀង	៨៣០
២— ផ្នែកអក្សរសាស្ត្រ	
៣— វិចារណកថា : តើមានហានសូគ៌ដោយស្បែកឬទេ?	
លោក ផេង-ត្រីវ រៀបរៀង	៨៤២
៤— រឿងសាមក្រុក ខកញ៉ា នូ-កន ប្រែ-រៀបរៀង	~~៨៤២~~ ៨៤២
៣— ផ្នែកគំណត់—ប្រពត្តិការណ៍	
៥— អង្គការសហប្រជាជាតិខាងការអប់រំ វិទ្យាសាស្ត្រ	
និង វប្បធម៌ (យូណេស្កូ).	៨៤៦

តម្លៃជាវ :

មួយឆ្នាំមាន ១២ សៀវភៅ . . . ២៣០រ០០ ។

អាណត្តិសូមដាក់ថា : លោកនាយកវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា

ចតុរារិយសច្ច

ព្រះភិក្ខុ ប៉ាន ខាត់ រៀបរៀង

ប្រធានៃតុន្តវចនៈបឋមទៅក្នុងអរិយសច្ច ៤ ប្រការ (ចតុភរិយ-សច្ចានិ) ជាធម្មវិជ្ជលព្រះពុទ្ធទ្រង់ប្រកាសមុនដំបូងដល់បញ្ចវគ្គិយភិក្ខុ ហៅថា "ធម្មចក្កប្បវត្តនសូត្រ" នៅឥសិបតនមិគទាយវន សព្វថ្ងៃហៅ "សារនាថ" ដិតក្រុងពារាណសី ។ ទៅក្នុងបឋមទេសនានេះយើងមានអត្ថបទដើមចាំងស្រួនគ្រប់ចាំង ៤ ប្រការ តែខ្ញុំនេះយើងដកស្រង់សេចក្តីដោយសង្ខេបមកនិយាយ ។ តាមពិត អរិយសច្ចនេះមានស្តីរតែគ្រប់ខ្លឹពីរព្រះត្រៃបិដក ព្រោះជាធម្មវិជ្ជលទ្រង់សម្តែងហើយសម្តែងទៀត ដោយសេចក្តីពិស្តារបំផុត និងដោយអនេកបរិយាយ ។ បើយើងសិក្សាអរិយសច្ចនេះគ្រប់អន្ទឹ គ្រប់បរិយាយ គ្រប់វត្ថាធិប្បាយ យើងនឹងបានជាសេចក្តីកាយការណ៍មួយដ៏រៃសរសៃសល ដ៏ពិតប្រាកដ នៃតុន្តវចនៈដែលជាសារវន្តបំផុតទៅតាមគន្ថធម្មអត្ថបទដើម ។

អរិយសច្ច ៤ ប្រការនោះគឺ :

ក្ន - ទុក្ខសច្ច ទុក្ខ ជាសេចក្តីពិត,

១ - សមុទយសច្ច ហេតុដែលនាំឲ្យកើតទុក្ខ ជាសេចក្តីពិត,

ក- និរោធសច្ច ការរលត់ទុក្ខ ជាសេចក្តីពិត,

ឃ - មគ្គសច្ច មាគ៌ាដែលនាំទៅកាន់ការរលត់ទុក្ខ ជាសេចក្តីពិត ។

ក- អរិយសច្ចទីមួយ "ទុក្ខ" ។ សេចក្តីពិតដ៏ប្រសើរទីមួយ ហៅថា ទុក្ខអរិយសច្ច (La noble vérité de la souffrance, The noble truth of suffering) ។ សេចក្តីនេះ បើតាមពុទ្ធដីកា ដ៏វិតសព្វ សត្វមិនមែនជាការសំខាន់អ្វីទេ ការសំខាន់ដែលត្រូវនិយាយ គឺសេចក្តីទុក្ខ= ការឈឺចាប់, ព្រួយ, លំបាក ។ ការប្រែនិងការពន្យល់សេចក្តីពាក្យទាំងពីរនេះ មិនបានជាខ្វះតញ្ចិត្តយើងទេ ហើយច្រើនតែទុសន័យទៀត, ទាំងនេះមកពីធម្មនេះមានតំលៃ ប្រៀបដោយ មានសេចក្តីខ្ពស់លាយឯការពន្យល់សេចក្តីទៀត ច្រើនតែមិនចំន័យតាមពុទ្ធបំណង ជាហេតុនាំឲ្យបុណ្ណាជនខ្លះទៅយល់ច្រឡំ ទៅជាយល់ថា ពុទ្ធសាសនានេះជាទុទ្ទិដ្ឋិនិយម (Pessimisme) ។

សេចក្តីពិត ពុទ្ធសាសនា មិនមែនជាទុទ្ទិដ្ឋិនិយម ឬនឹងថា ជាសុទ្ទិដ្ឋិនិយម (Optimisme) ក៏មិនមែនដែរ ។ បើមើលឲ្យសព្វគ្រប់ទាំងអស់ ពុទ្ធសាសនាជាប្រាកដនិយម (Réalisme) គឺប្រាកដនិយម

ចំពោះជីវភាពនិងពិភពលោកនេះ បើមើលចំពោះវត្ថុ ពុទ្ធសាសនាជា យ៉ាងវត្ថុនិយម (Objectivisme) ។ ពុទ្ធសាសនាមិនមែននាំសត្វលោក ឲ្យដេកលក់ទៅក្នុងឋានសួគ៌ (១) នៃមនុស្សល្ងីល្ងើទេ ឬនឹងថាធ្វើសត្វ លោកឲ្យតក់ស្លុតបុ ឲ្យរកឲ្យល់ចំពោះភ័យដែលគ្រាន់តែមានទៅក្នុងមនោ-គតិក៏ទេដែរ ។ ពុទ្ធសាសនាបង្រៀនតាមសេចក្តីពិត តាមយ៉ាងភូតថា អ្នកគឺអ្វី? "ថាពិភពលោកដែលទៅជុំវិញអ្នកនេះជាអ្វី" ប៉ុណ្ណោះ ទីបំផុត បង្រៀនអ្នកឲ្យចេះដោះ ៗ តាមផ្លូវត្រង់ ទៅកាន់សេរីភាពដ៏សុក្រិត សន្តិ-ភាព សេចក្តីស្ងប់ និង បរមសុខ ។

គ្រូពេទ្យមានច្រើនប្រភេទ ។ គ្រូពេទ្យខ្លះ មើលជម្ងឺ ឃើញ ជម្ងឺស្រាល យល់ថាជាជម្ងឺធ្ងន់ អស់សង្ឃឹមហើយក៏ចោះបង់អ្នកជម្ងឺ ចោលទៅ ។ គ្រូពេទ្យខ្លះទៀត មើលជម្ងឺ ឃើញជម្ងឺធ្ងន់ យល់ថាជា ជម្ងឺស្រាលទៅវិញ និយាយថា "មិនបាច់មើលឬព្យាបាលទេ" ហើយ ក៏លះបង់ការព្យាបាល ដែលជាទំនួលចោលទៅ ដោយគ្រាន់តែ និយាយពាក្យឲ្យធូរទ្រូង ឬឲ្យដកដង្ហើមស្រួលប៉ុណ្ណោះ ។ បណ្តា គ្រូពេទ្យទាំងពីរប្រភេទនេះ យើងគួរហៅគ្រូពេទ្យទីមួយថា ជាគ្រូពេទ្យ ពុទ្ធិដ្ឋនិយម ឯគ្រូពេទ្យទីពីរថាជាគ្រូពេទ្យសុទ្ធិដ្ឋនិយម ។ គ្រូពេទ្យ

១- ក្នុងលទ្ធិសាសនាឥស្លាម មា សេចក្តីថា "សារីរកអាចធ្វើបុណ្យទិញឋានសួគ៌ទុក មុនបាន" ។

ទាំងពីរប្រភេទនេះ សុទ្ធតែប្រកបដោយគ្រោះថ្នាក់ធំៗ ណាស់ដូចគ្នា ។ គ្រូពេទ្យទីបី ពិនិត្យមើលសម្បជ្ញានភេតដោយនិមិត្តហេតុ (Symtome) ត្រឹមត្រូវ យល់ច្បាស់នូវហេតុនិងសភាពជម្ងឺ ឃើញច្បាស់ថា ភេតនេះ អាចនឹងព្យាបាលឲ្យជាសះស្បើយបាន ហើយចាប់ផ្តើមព្យាបាលជម្ងឺនោះ ដោយម៉ឺងម៉ាត់ គ្រូពេទ្យនោះឈ្មោះថាជាអ្នកស្រាវជ្រាវស្រង់នាទីរបស់ខ្លួនពិត ។ ព្រះសម្ពុទ្ធ ចាត់ទុកជាគ្រូពេទ្យទីបីនេះ ។ ទ្រង់ជាគ្រូពេទ្យកោសលជាវិទ្យាឥរ (Scientifique) សម្រាប់មើលជម្ងឺមនុស្សលោក បានជាមានពាក្យក្នុងព្រះសាសនាខ្លះហៅព្រះអង្គថា "កិសក្ក" ឬ "ភៃមជ្យគុរុ" ។

ពាក្យថា "ទុក្ខ" (សំ. ទុ:ខ:) មកពី "ទុ:" ថា "អាក្រក់, លំបាក" + "ខ:" ថា "ខេ" = ខៅបានដោយលំបាក បានសេចក្តីថា ការលំបាក គឺឈឺ ព្រួយ ឬរហមរហាម ជាពាក្យផ្ទុយនឹងពាក្យថា សុខ: មកពី "សុ" ថា "ល្អ, ប្រពៃ" + "ខ:" ថា "ខៅ" = ខៅស្រួល បានសេចក្តីថា ការស្រួល, ការស្រណុក (Confort) ការងាយ ។ ប៉ុន្តែពាក្យថា "ទុក្ខ" ដែលទ្រង់ប្រើក្នុងអរិយសច្ចទីមួយ ជាពុទ្ធទស្សនៈចំពោះជីវភាព និងពិភពលោកនេះ មានអត្ថន័យតម្លៃភាព គឺខៅជាទស្សនវិជ្ជា (Philosophie) មួយ មានសេចក្តីខ្ពស់ខ្ពស្តាយអនេកអនន្តណាស់ ។ ទុក្ខ នៅក្នុងទុក្ខអរិយសច្ចនេះ ក៏

លោកប្រើជាន័យធម្មតាថា "លំបាក, ជម្ងឺ" ដែរ តែមានសេចក្តីខ្ពស់ខ្ពស់លាយហើយជ្រាលជ្រៅណាស់ លោកខុកថាជាឧត្តមគតិតម្លៃរ-
តាដូចជាពាក្យថា ការខ្វះខាត (Imperfection) ការមិនទៀងទាត់ (Impermanence), សោះសូន្យ (Vide), ការមិនមានខ្លួនប្រាណ (Imsubstantialité), តាតាំងអស់នេះ តំបាកនឹងរកពាក្យតែមួយម៉ាត់មកប្រើប្រយ័ត្នឲ្យត្រង់សំខ្លួនវេហារចំពោះទស្សនាគាន (Conception) នៃពាក្យថា "ទុក្ខ" ក្នុងអរិយសច្ចនេះបានណាស់, ដូច្នេះ យើងត្រូវតែទុកពាក្យដើមថា "ទុក្ខ" ដដែល មិនបាច់ប្រែ ប្រសើរជាងការប្រែ ប៉ែប្រែទៅហើយទៅជាខុសន័យវិញ ។

ព្រះសម្ពុទ្ធ ទ្រង់មិនមែនបដិសេធសេចក្តីសុខក្នុងជីវិតនេះទេ តាលណាទ្រង់សម្តែងពីទុក្ខ ទ្រង់សម្តែងពីសតាតសេចក្តីសុខ ជាសេចក្តីសុខផ្សេងពីសុខដែលយើងធ្លាប់យល់ ដូចជាទ្រង់សម្តែងពីសុខ ២ ប្រការគឺ អាមិសសុខ ទំនិ និរាមិសសុខ សម្រាប់ត្រហ្ម្តាតនិងកិក្ខុ-
តាត ។ ក្នុងតម្លៃអង្គតនិកាយ ទុក្ខនិបាត ព្រះសម្ពុទ្ធជាម្ចាស់បានសម្តែងពីសេចក្តីសុខ ៤ ប្រការនេះច្រើនបែបណាស់ ដូច គិហិសុខ, បព្វជ្ជាសុខ, កាមសុខ, នេក្ខម្មសុខ, ឧបធិសុខ (๑), និរុបធិសុខ, សាសវសុខ,

---

- ๑ឧបធិ = កិលេស ។

អនាសវសុខ, អរិយសុខ, អនារិយសុខ, កាយិកសុខ, ចេតសិកសុខ, សប៉ីតិកសុខ, និប្ប៉ីតិកសុខ, សាតសុខ(១), ឧបេក្ខាសុខ, សមាធិសុខ, អសមាធិសុខ, រូបារម្មណសុខ, អរូបារម្មណសុខ ។ សេចក្តីសុខទាំងអស់នេះ លោកចាត់ទុកថា រួមទៅក្នុង "ទុក្ខ" ទាំងអស់ឬម្យ៉ាងចិត្តបរិសុទ្ធិ ដែលកើតពីឈាន សម្រេចបានដោយការបម្រើនសមាធិកម្មដ្ឋានជាន់ខ្ពស់ ហើយរួចពីទុក្ខវេទនា ដែលយើងទុកថា ជាសុខមិនលយឡំដោយទុក្ខ ពុំនោះចិត្តកន្លងឈាន ដែលរួចហើយពីវេទនាទាំងពីរគឺ ទុក្ខវេទនា និង សុខវេទនាក៏ដោយ ចិត្តដែលជាប់ខ្ពស់យ៉ាងនេះហើយ ក៏រួមទៅក្នុងទុក្ខអរិយសច្ចនេះដែរ ។ មួយទៀត កន្លងគម្ពីរមជ្ឈិមនិកាយ ព្រះសម្ពុទ្ធក៏ទ្រង់សម្តែងថា ចិត្តដែលបានខ្ជួលសេចក្តីសុខទៅកន្លងឈានហើយ ចិត្តនេះក៏នៅតែលុះក្នុងអំណាចសាមញ្ញលក្ខណៈគឺ អនិច្ចំ ទុក្ខំ និង វិបរិណាមធម្មំ ដែរ ។ យើងគួរកត់សម្គាល់ថា ពាក្យថា "ទុក្ខ" ដែលព្រះសម្ពុទ្ធទ្រង់យកមកប្រើនេះ ជាពាក្យចេញខែងបង្ហាស់លាស់ណាស់ថា នេះ "ទុក្ខ" មិនមែនគ្រាន់តែដោយហេតុថា "ទុក្ខ" តាមន័យធម្មតារបស់ពាក្យប៉ុណ្ណោះទេព្រោះថា អ្វីទាំងអស់ដែលមិនទៀងទាត់ ក៏ជា "ទុក្ខ" ទៀតដែរ ដូចពុទ្ធភាសិតទ្រង់ត្រាស់ថា "យេ កេចិ ទុក្ខំ តំ ទុក្ខំ" ។

ព្រះសម្ពុទ្ធជាអ្នកប្រាជ្ញប្រាកដនិយម (Réaliste) ទ្រង់ជាអ្នកប្រាជ្ញ

១- សាត = ពន្លែក ។

យថាវត្ថុ (Objectif) ។ ទ្រង់តែងតែសម្តែងធម៌ទៅតាមដំរៀបតាមខ្មុស្សលោក ដែលមានសេចក្តីត្រេកត្រអាលចំពោះកាមគុណទាំង ៥ ប្រការជាធម៌ដែលបុគ្គលខ្លួទៅអាចយល់ច្បាស់លាស់ ដោយអាការ ៣ ប្រការ ដូចសេចក្តីតទៅនេះ ៖

សម័យមួយ (១) ព្រះសម្ពុទ្ធទ្រង់ប្រថាប់ទៅក្នុងវត្តជេតពន ជិតក្រុងសាវត្ថីកាលនោះកិកុសង្ឃចូលទៅបិណ្ឌបាតក្នុងក្រុងសាវត្ថី, ព្រឹកព្រហាមពេក ដើម្បីវេលាចាំពេល ក៏ឈឿងចូលទៅគាន់អាស្រមបរិព្វាជក-អញ្ញតិត្ថី។ បរិព្វាជកអញ្ញតិត្ថីបានសួរកិកុសង្ឃទាំងនោះថា :

១- តម្រេករបស់តាមទាំងឡាយដូចម្តេច = តើ តាមានអំអស្ចារ្យនោ ?

២- អាទីនវៈរបស់តាមទាំងឡាយដូចម្តេច = តើ អស្ចារ្យនោ ?

៣- ការរលាស់ចេញចាកកាមទាំងឡាយដូចម្តេច = តើ ឯសុរ្យរលាំ ?

ក្រោយពីភត្តកាល កិកុសង្ឃទាំងនេះ ចូលទៅគាល់អង្គព្រះសម្ពុទ្ធហើយក្រាបសួរប្រស្នានេះ ។ ព្រះសម្ពុទ្ធទ្រង់ត្រាស់សួរថា :

សេចក្តីទីមួយ :

១- មជ្ឈិមនិកាយ មូលបណ្ណាសក មហាវគ្គទុតិយសុត្រ សៀវភៅទី ២០ ទំព័រ ៣១៤

១- អស្សាទៈ តម្រេកវេទស់តាមចាំងឈ្មោយ ។ ទ្រង់ត្រាស់ថា ចុះតម្រេកវេទស់តាមចាំងឈ្មោយ៥ប្រការនោះ តើដូចម្តេច?

ភិក្ខុចាំងឈ្មោយ! រូបដែលបុគ្គលតប្បីយើញដោយភ្នែក, សំឡេងដែលបុគ្គលតប្បីឮដោយត្រចៀក ក្លិនដែលបុគ្គលតប្បីដឹងដោយច្រមុះ, ផស្សៈដែលបុគ្គលតប្បីដឹងដោយកាយ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីរស់ដែលបុគ្គលតប្បីដឹងដោយអណ្តាត, គេញចិត្ត ជាទីស្រឡាញ់ត្រូវតាមបំណង ជាទីត្រេកត្រអាល ។

ភិក្ខុចាំងឈ្មោយ! សេចក្តីសុខសោមនស្សនេះ តែងកើតឡើងព្រោះអាស្រ័យនូវកាមចាំងនេះ ។

នេះជាអស្សាទៈ តម្រេកក្នុងកាមគុណចាំងឈ្មោយ ។

២- អាទីនវៈ ទោសវេទស់តាមចាំងឈ្មោយ ។ ទ្រង់ត្រាស់ថា ចុះទោសក្នុងកាមគុណចាំងឈ្មោយ តើដូចម្តេច? ភិក្ខុចាំងឈ្មោយ កុលបុត្តក្នុងលោកនេះ ចិញ្ចឹមជីវិតដោយសេចក្តីប្រឹងប្រែង ដោយសិល្បៈណាមួយ គឺជាសិល្បៈកប់ម្រាមដៃ លេខនក្ខុ ប៉ាន់ប្រមាណ(១) កសិកម្ម ពាណិជ្ជកម្ម គោរក្ខកម្ម ឬ ជាពាហន ជាឱជបុរេ ក៏ដោយ ជនចាំងនេះ តែងត្រូវត្រជាក់ ត្រូវក្តៅ រហែម ជួសទាំ ប៉ះពាល់ដោយមូល ត្រូវសេះកូច - ធំចឹកស្ងាប់ខ្លួន ព្រោះហេតុនៃសេចក្តី

១- សង្ខារៈ «រឿងនេះធឿងប៉ាន់ថា ស្រូវស្រែនេះមានប៉ុន្មានគាំ ត្រីក្នុងបឹងមានប៉ុន្មាន ?»

ស្រែកឃ្លាន (ក្រពះ) ។ កិក្ខុតាំងឡាយ នេះ ជាហេសវបស់តាមគុណ តាំងឡាយ ដែលបុគ្គលយើញចំពោះភ្នែក ជាគំនរទុក្ខ មានតាមជាហេតុ មានតាមជាគ្រឿងទ្បើផល មានតាមជាគ្រឿងផ្គួចផ្តើម ជាបច្ច័យនៃតាម តាំងឡាយ, កិក្ខុតាំងឡាយ តាលបើកុលបុត្តតាំងនោះខំប្រឹងវៃប្រឆងដោយ ព្យាយាមយ៉ាងនេះហើយ នៅតែមិនបានកោគៈសម្រេចតាមបំណងទេ គេក្រៀមក្រំចន់ស្រពន់ចិត្ត លំបាកចិត្ត ដេកមិនលក់ដកមិនរហើយ យំ ខ្សឹកខ្សួល គក់ទ្រូងទ្រហោយំ រវែងតន្តីតាំងអស់ស្មារតី ហើយ និយាយថា : ឱ! សេចក្តីប្រឹងវៃប្រឆងរបស់អាត្មាអញនេះ ឥតអំពើសោះ ខេតើ! ឥតផលសោះខេតើ! ។ បើតាលកុលបុត្តតាំងនោះបានកោគៈដូច សេចក្តីប្រាថ្នាហើយ តំកុលបុត្តតាំងនោះ បានទទួលសេចក្តីទុក្ខ ចោ-មនស្សខ្លាំងព្រោះហេតុនៃការរក្សា ដោយមានការព្រួយជានិច្ចថា:១-ព្រះ រាជាវៃជាន់យក, ២- ចោរលួច, ៣- ភ្លើងឆេះ, ៤- ទឹកជន់លិច, ៥- អ្នកទទួលមតិកមិនជាទីពេញចិត្ត ។ បើទុកជាទំរក្សាការពារនូវកោគៈតាំង នោះដូចម្តេចក៏ដោយ តំនៅតែមានអន្តរាយដោយព្រះរាជាវៃជាន់យក ចោរលួច ភ្លើងឆេះ ទឹកជន់លិច, ឬបានទៅដៃអ្នកទទួលមតិកមិនជាទី ស្រឡាញ់ណាមួយតុំខានប៉ុន្មានហើយក៏តែតការក្រៀមក្រំចិត្ត លំបាកចិត្តថា

ទ ! សេចក្តីប្រឹងប្រែងរបស់អាត្មាអញនេះ ឥតអំពើសោះទេតើ ! ឥតផល
សោះទេតើ ! ។ កិក្ខុតាំងឡាយ ! នេះ ជាអាទីនវៈនៃកាមតាំង
ឡាយ ។ល។

កិក្ខុតាំងឡាយ ! កាមនេះជាហេតុ កាមនេះជាគ្រឿងឲ្យទុក្ខវេទនា
កាមនេះជាគ្រឿងដួចផ្តើម ជាបច្ច័យនៃកាមតាំងឡាយ បានជាព្រះរាជា
ទាស់ទែងនឹងព្រះរាជា, ក្សត្រទាស់ទែងនឹងក្សត្រ, ព្រាហ្មណ៍ទាស់ទែង
នឹងព្រាហ្មណ៍, គហបតីទាស់ទែងនឹងគហបតី, មាតាទាស់ទែងនឹងបុត្រ
បុត្រទាស់ទែងនឹងមាតា, បិតាទាស់ទែងនឹងបុត្រ, បុត្រទាស់ទែងនឹងបិតា,
បងប្អូនប្រុសទាស់ទែងនឹងបងប្អូនប្រុស បងប្អូនប្រុសទាស់ទែងនឹងបងប្អូន
ស្រី បងប្អូនស្រីទាស់ទែងនឹងបងប្អូនស្រី, មិត្រសម្លាញ់ទាស់ទែងនឹងមិត្រ
សម្លាញ់, អ្នកតាំងនោះ ឈ្លោះប្រកែកគ្នា ប្រកាន់គ្នាថាខុសខៀវញៀវ
មក ទាស់ទែង កាប់សម្លាប់គ្នាខៀវញៀវមក ដោយដៃខ្លះ ដោយដុំដ
ខ្លះ ច្បាំងគ្នាដោយគ្រឿងសស្ត្រាវុធខ្លះ ហើយស្លាប់អស្សាបចង់ខៀ, ប៉ែ
មិនដល់សេចក្តីស្លាប់ទេ ក៏ដល់នូវសេចក្តីទុក្ខស្ទើរតែស្លាប់ដែរ, នេះឯង
ជាអាទីនវៈនៃកាមតាំងឡាយ ។ល។

– ម្នាលកិក្ខុតាំងឡាយ ! កាមនេះ ជាហេតុ ។ល។ ជាបច្ច័យនៃ
កាមតាំងឡាយ បានជាមនុស្សគាន់ជាវង្វេងខ្លាល គាន់ធ្លុះស្រៀតសរ

ដោយចំពង់ព្រួញ ដើរចូលទៅកាន់សមរភូមិ ដូចមនុស្សហើរចូលភ្លើង តើតជាក្បួនច័ព្ទចាំងសន្ធឹង គាលដែលបាញ់ព្រួញមក ងាជាវឡើង គេបាញ់គ្នាដោយព្រួញ ចាក់ដោយលំពែង គាប់ក្បាលដោយដាវ អ្នកខ្លះស្លាប់ អ្នកខ្លះបានសេចក្តីទុក្ខស្ទើរតែស្លាប់ ក្នុងសង្គ្រាមនោះ ។ ម្នាលភិក្ខុចាំងឡាយ ! នេះជាអាទីនវៈនៃកាមចាំងឡាយ ។ល។

- ម្នាលភិក្ខុចាំងឡាយ ! កាមនេះ ជាហេតុ ។ល។ ជាបច្ច័យនៃកាមចាំងឡាយ បានជាមនុស្សកាន់ដាវនិងខែល កាន់ធ្នូសរៀតសរដោយចំពង់ព្រួញ ចូលលុកបន្ទាយដែលបូកដោយបាយអ គាលដែលគេបាញ់ព្រួញមក ត្បួយលំពែងមក ងាជាវឡើង គេបាញ់ដោយព្រួញ ចាក់ដោយលំពែង បាចសាចអាចម៍គោជ្រាយ រស់ដោយនោសដែក គាប់ក្បាលដោយដាវ ក៏ស្លាប់អស្សាបង់ បើមិនដល់ក្តីស្លាប់ក៏នៅតែស្លាប់ក្នុងបន្ទាយនោះដែរ ។ ម្នាលភិក្ខុចាំងឡាយ នេះជាអាទីនវៈនៃកាមចាំងឡាយ ។

(នៅមានត)

រឿងព្រះនាងសាមាវតី

[ក]

លោក ប៊ី-ប៉ី ប្រែ-រៀបរៀង

ស្រីអ្នកបម្រើរបស់ព្រះនាងឈ្មោះ ខុជ្ជុត្តរាទៅគាន់សម្ដាក់នាយសុមន-មាលាការ (ទិញ) យកកម្រងផ្កាជានិច្ច ។ កាលថ្ងៃនោះ នាងមកដល់ហើយ ជាងកម្រងផ្កាទើបនិយាយថា ខ្ញុំនិមន្តព្រះសាស្ដាទុកថ្ងៃនេះ ទំនងបូជាព្រះសាស្ដាដោយកម្រងផ្កាដ៏ប្រសើរ នាងចូរបង្អន់បន្ទិចសិន ជាសម្ងាញ់គ្នាក្នុងការអង្គាស ស្ដាប់ធម៌ហើយយកកម្រងផ្កាដែលទៅសល់ទៅចុះ នាងទទួលពាក្យអញ្ជើញថា ប្រពៃហើយ ។ នាយសុមនៈអង្គាសភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធានរួចហើយ បានទទួលចាត្រដើម្បីតាំងការដល់ការធ្វើអនុមោទនា ។ ព្រះសាស្ដាទ្រង់ប្រារព្ធព្រះធម៌ទេសនា អនុមោទនាហើយ ។ ឯនាង ខុជ្ជុត្តរាស្ដាប់ធម្មកថារបស់ព្រះសាស្ដាមែនពិតតាំងនៅក្នុងព្រះសោតាបត្តិផលហើយ ។ ក្នុងថ្ងៃដដែរ ។ នាងយកកហាបណៈទុកដើម្បីខ្ជនបួនកហាបណៈ (ទិញ) យកកម្រងផ្កាដោយកហាបណៈបួនទៅ ក្នុងថ្ងៃនោះ (ទិញ) យកកម្រងផ្កាដោយកហាបណៈ គ្រប់តាំងប្រាំពីរទៅ ។ គ្រានោះនាងសាមាវតីថា :

ម្នាលនាង ព្រះរាជាទ្រង់ព្រះរាជទានតម្លៃកម្រងផ្កា ដល់យើងខ្ញុ

គុណប្អូ ។

ខ្ញុំឪពុក- មិនមែនទេ ព្រះនាងម្ចាស់ ។

ព្រះនាង- ចេ៎ដូច្នោះ ធ្វើម្តេចកម្រងផ្កាទើបច្រើន ។

ខ្ញុំឪពុក កន្លងថ្ងៃដទៃ ខ្ញុំម្ចាស់យកទុកដើម្បីខ្លួនបួនកហាបណៈ យកបួនកហាបណៈទៀត (ទិញ)កម្រងផ្កាមក ។

ព្រះនាង- ថ្ងៃនេះហេតុអ្វីបានជាមិនយកទុកទៀត ។

ខ្ញុំឪពុក- ព្រោះខ្ញុំម្ចាស់ស្តាប់ឮអ្នកថា របស់ព្រះសម្ភារសម្ភុទ្ធហើយ សម្រេចធមិហើយ ។

លំដាប់នោះព្រះនាង មិនបានតំហកតំហែងនាងថា មីថាសិចង្រៃ មិនបួរឲ្យកហាបណៈ ដែលមិនយកទុក អស់កាលត្រឹមនេះ ដល់អញវិញ ទេ បែរជាប្រាប់ថា ម្នាលនាងឯង បួរឲ្យខ្ញុំធ្វើកអ្វីតែលឯងធ្វើកហើយខ្លះផង កាលនាងខ្ញុត្ត ទូលថា ចេ៎ដូច្នោះ សូមព្រះនាងជាម្ចាស់មេត្តាប្រោសឲ្យខ្ញុំម្ចាស់ងូតទឹក (ជាមុនសិន) ទ្រង់យកភ្លុមទឹកក្រអូប ៦០ភ្លុមឲ្យនាងងូតរួចហើយ បង្គាប់ឲ្យប្រទានសំពត់សាដកសាចស្តិតម៉ត់ពាក់ ៤ នាងខ្ញុំឪពុកនោះ ស្លៀកមួយជណ្តាប់មួយ ហើយប្រាប់ឲ្យក្រាលអាសនៈ ឲ្យយកផ្ទឹតមួយមក អង្គុយលើអាសនៈ កាន់ផ្ទឹតដ៏វិចិត្រ ហៅស្រីប្រាំរយមកហើយ សម្តែងធម្មិដល់ស្ត្រីមានព្រះនាង

សាមាវតីជាប្រមុខ ដោយលំអានដែលព្រះសាស្តាទ្រង់សម្តែងហើយ ពិតប្រាកដ ។

នាងគ្រប់គ្នាព្រមទាំងព្រះនាងសាមាវតី ស្តាប់ធម្មកថារបស់នាងហើយ តាំងនៅក្នុងព្រះសោតាបត្តិផលហើយ ។ បណ្តានាងទាំងនោះសំពះនាងខុជ្ជុត្តរា ហើយពោលថា នាងចាប់ដើមអំពីថ្ងៃនេះទៅ កុំធ្វើការងារដ៏សៅហ្មងឡើយ នាងចូរតាំងនៅក្នុងឋានៈនៃមាតានិងអាចារ្យរបស់ពួកខ្ញុំទៅគាន់សម្នាក់ ព្រះសាស្តាស្តាប់ធម៌ដែលព្រះសាស្តាទ្រង់សម្តែងហើយ ចូរពោលដល់ខ្ញុំទាំងឡាយ ។ នាងធ្វើដូច្នោះ នាងក្រោយមកទ្រទ្រង់ព្រះត្រៃបិដកហើយ ។ គ្រានោះ ព្រះសាស្តាទ្រង់លើកនាងក្នុងឯតទគ្គដ្ឋានដោយព្រះតម្រាស់ថា តិក្ខុត្តាំងឡាយ រូបនេះគឺខុជ្ជុត្តរា ជាកំពូលនៃឧបាសិកាសាវិកានៃតថាគតក្នុងធម្មកថិកា ។ ចំណែកស្រីទាំងប្រាំរយនាក់ទាំងនោះឯង ក៏បានពោលនឹងនាងយ៉ាងនេះថា នាងពួកខ្ញុំចង់ឃើញព្រះសាស្តា សូមនាងសម្តែងព្រះសាស្តាដល់ពួកខ្ញុំ ខ្ញុំនឹងបូជាព្រះគន្ធដោយគ្រឿងក្រអូបនិងកម្រងផ្កាជាដើម ។

នាងខុជ្ជុត្តរា- នាងម្ចាស់ ធម្មតាពាក្យត្រកូលជាការក្រៃ មិនអាចនឹងនាំនាងម្ចាស់ទាំងឡាយទៅកាន់ក្រៅបានទេ ។

ពួកនាង- នាងកុំឲ្យពួកខ្ញុំវិនាសឡើយ មេត្តាសម្តែងព្រះសាស្តា

ដល់ពួកខ្ញុំឲ្យខានតែបាន ។

នាងខុជ្ជុត្តរ— បើដូច្នោះ ចូរធ្វើប្រហោងត្រង់ជញ្ជាំងកន្ទែងនៅ
របស់នាងម្ចាស់ទាំងឡាយ ប្រមាណគ្រាន់តែអាចមើលឃើញព្រះសា
ស្តាបានហើយ ឲ្យមនុស្សទាំយកគ្រឿងក្រអូប នឹងកម្រងផ្កាដា-
ដើមមក កាលដែលព្រះសាស្តា ស្តេចយាងទៅកាន់ទ្វារផ្ទះសេដ្ឋីទាំង
បីនាក់ ឈរនៅកន្លែងនោះ ។ មើល លើកដៃ ថ្វាយបង្គំនិងបូជាចុះ ។

ពួកនាងធ្វើយ៉ាងនោះហើយ សំឡឹងមើលព្រះសាស្តា ដែលកំ-
ពុងស្តេចយាងទៅទីនីមក ថ្វាយបង្គំនិងបូជាហើយ ។

តមកថ្ងៃមួយ ព្រះនាងមាគន្ទិយាស្តេចចាកចេញផ្លែក្រាសាទរបស់
ខ្លួន ទៅកាន់ដំណាក់របស់ព្រះនាងសាមាវតី និងពួកបរិពាររបស់ព្រះនាង
ឃើញប្រហោងក្នុងបន្ទប់ទាំងឡាយហើយសួរថា នេះជាអ្វី ពួកបរិពារមាន
ព្រះនាងសាមាវតីជាប្រធាន មិនដឹងសេចក្តីប្រកូសកាយ ដែលព្រះនាង
នោះចង់ទុកក្នុងព្រះសាស្តា ពោលតបថា ព្រះសាស្តាស្តេចយាងមកទីនេះ
នេះ ពួកខ្ញុំទៅក្នុងបន្ទប់នេះ ថ្វាយបង្គំនិងបូជាព្រះសាស្តា នាងគិតថា
ព្រះសមណគោតមមកដល់ទីនេះហើយ អញនឹងដឹងរបស់ដែលគប្បី
ធ្វើដល់ព្រះអង្គក្នុងឥឡូវនេះ សូម្បីស្រីទាំងនេះក៏ជាឧបដ្ឋាករបស់ព្រះ
អង្គ នឹងត្រូវដឹងរបស់ដែលនឹងគប្បីធ្វើសូម្បីដល់ស្រីពួកនេះដែរ ហើយ

ទៅក្រាបទូលសេចក្តីដល់ព្រះកជាថា បពិត្រព្រះមហាកជ ស្រីប្រុំរយ
នាក់រួមទាំងព្រះនាងសាមាវតីផង មានសេចក្តីប្រុងប្រយ័ត្នក្នុង ខាងក្រៅ
(ក្សត់) ព្រះជន្មជីពរបស់ព្រះអង្គនឹងមិនមាន ដោយពីរបីថ្ងៃមែនពិត។

ព្រះកជាមិនទ្រង់ជឿដោយទុកព្រះហឫទ័យថា ពួកនាងនឹងមិនធ្វើ
បែបនេះទេ ទុកជាកាលនាងទូលទៀត ព្រះអង្គក៏មិនទ្រង់ជឿដែរ ។

ខាងក្រោយមក កាលព្រះនាងក្រាបទូលយ៉ាងនេះដល់ជាដរហើយ
ព្រះអង្គមិនទ្រង់ជឿ ទើបក្រាបទូលថា បើព្រះអង្គមិនទ្រង់ជឿខ្ញុំម្ចាស់
ទេ អញ្ជើញស្តេចយាងទៅទីលំនៅរបស់នាង ទ្រង់ពិនិត្យមើលចុះ
មហាកជ ។

ព្រះកជាស្តេចហែងទៅឧតយើញប្រហោង ក្នុងបន្ទប់ទាំងឡាយ
ហើយ ត្រាស់សួរថា នេះជាអ្វី កាលពួកនាងក្រាបទូលសេចក្តីនោះ
ហើយ មិនបានខ្វាល់ដល់ពួកនាងទេ មិនត្រាស់អ្វីរសោះឡើយ ជង្គាប់
ឲ្យចិទប្រហោងហើយ ឲ្យធ្វើបង្ហួះប្រហោងគួចទាំងអស់គ្រប់បន្ទប់ ។
ន័យថាបង្ហួចប្រហោងគួចកើតឡើងក្នុងគ្រានោះ ។

ព្រះនាងមានន្ទិយាមិនអាចនឹងធ្វើអ្វី ដល់ព្រះនាងសាមាវតីនឹង
ពួកបរិពារបានហើយ តែងថាអញ នឹងធ្វើបែបដែលគួរធ្វើដល់ ព្រះ
សមណគោតមឲ្យបាន ហើយឲ្យថ្លៃឈ្នួលដល់ពួកអ្នកនាវ ប្រាប់ថា

កាលដែលព្រះសមណគោតម ចូលទៅខាងក្នុងនគរគ្រាប់ទៅ អ្នកទាំង
ឡាយត្រមទាំងពួកឲ្យប្រុស នឹងកម្មករបួរដេរប្រទេចឲ្យរត់ទៅ ។ ពួក
អ្នកមិច្ឆាទិដ្ឋិមិនជ្រះថ្លាក្នុងព្រះរតនត្រ័យ ជាប់តាមព្រះសាស្តាស្តេចចូល
ទាំងក្នុងព្រះនគរ ដេរប្រទេចដោយអង្កាស (១) វត្តជាប់ប្រការ ដូច្នេះ
អាចារ អាគាល អាវង្វេង អាឆ្កួត អាគៅ អាលា អាសត្វនរក
អាសត្វតិរច្ឆាន សុគតិរបស់មិនគ្មានទេ មានប្រាថ្នាខុគ្គតិតែម្យ៉ាងប៉ុណ្ណោះ ។

ព្រះអានន្ទដ៏មានអាយុឮពាក្យ ដេរប្រទេចនោះហើយ ក៏ទូល
ពាក្យនេះនឹងព្រះសាស្តាថា បពិត្រព្រះអង្គ អ្នកនគរទាំងនេះដេរប្រទេច
ពួកយើង ។ ទៅទីដទៃចាកនគរនេះចុះ ។

ព្រះសាស្តា- ទៅទីណា អានន្ទ ។

ព្រះអានន្ទ- ទៅនគរដទៃ ព្រះអង្គ ។

ព្រះសាស្តា- កាលបើពួកមនុស្សក្នុងនគរនោះដេរទៀត ពួកយើង
នឹងទៅទីណាទៀត អានន្ទ ។

ព្រះអានន្ទ- ទៅនគរដទៃ អំពីនគរនេះព្រះអង្គ ។

ព្រះសាស្តា- កាលពួកមនុស្សក្នុងនគរនោះដេរ ពួកយើងនឹង
ទៅទីណា ។

ព្រះអានន្ទ- ទៅនគរដទៃ អំពីនគរនោះព្រះអង្គ ។

๑- ពាក្យត្មុះតិះដៀល ប្រមាថមើលងាយ បង្អាប់បន្ទោក ។

ព្រះសាស្តា- ឆ្នើយ៉ាងនេះ មិនគួរទេអានន្ទ អធិការណ៍កើតឡើងក្នុងទីណា កាលបើវារម្ងាប់ទៅហើយក្នុងទីនោះ ទីធ្លៅក្នុងទីដទៃទើបគួរ ក៏អ្នកទាំងនោះ ពួកណាដេរ អានន្ទ ។

ព្រះអានន្ទ- ព្រះអង្គ វាដេរទាំងអស់ជាន់ថាស: ទិដ្ឋ កម្មករ ។

ព្រះសាស្តា- អានន្ទ តថាគតដូចជាដំរីចូលកាន់សង្គ្រាម កំភាអត់ធន់ចំពោះកូនសរដែលមក អំពីទិសទាំងបួន ជាការ: (នាទី) របស់ដំរីអ្នកចូលសង្គ្រាម ធម្មតាការអត់ធន់ ចំពោះពាក្យសម្តីដែលមនុស្សទ្រុស្តសីលពោល ជាការរបស់តថាគតដូចគ្នាពិត ត្រាស់ដូច្នេះហើយ កាលទ្រង់ប្រាប្តព្រះអង្គសម្តែងធម៌ ក៏ត្រាស់ប៊ព្រះគាថានេះក្នុងទីនាគវគ្គថា:

អហំ នាគោវ សង្គ្រាមេ ចាបាតោ បតិតំ សរំ
អតិវាក្យំ តិតិក្ខិស្សំ ទុស្សីលោ ហិ ពហុជ្ជនោ ។
ទន្តំ នយន្តិ សមិតឹ ទន្តំ រាជាភិរូហតិ
ទន្តោ សេដ្ឋោ មនុស្សេសុ យោតិវាក្យំ តិតិក្ខតិ ។
វរមស្សតរា ទន្តា អាជានេយ្យា ច សិន្ធវា
កុញ្ជរា ច មហានាគា អត្តទន្តោ តតោ វរំ ។

សេចក្តីថា: តថាគតនឹងអត់ធន់ពាក្យស្មើស ដូចជាដំរីអត់ធន់កូនសរ

ដែលធ្លាក់ចាកបំពង់ក្នុងសង្គ្រាម ព្រោះជនដ៏ច្រើនជាអ្នកទ្រុស្តសីល ជនពាំងឡាយរមែងនាំយកពាហនៈ ដែលបង្ហាត់ហើយទៅកាន់ទីប្រជុំ ព្រះរាជាតែងទ្រង់ពាជពាហនៈ ដែលបង្ហាត់ហើយ ក្នុងពួកមនុស្សអ្នកបានបង្ហាត់ហើយ អត់ធន់ពាក្យស្តើសបាន ជាអ្នកប្រសើរ សេះអស្សតរសេះអាជានេយ្យ សេះសិន្ធព ខ្ញុំដ៏ធំក្នុងរាជតែដែលបង្ហាត់ (បានបាទ) ហើយជាសត្វល្អ មនុស្សមានខ្លួនប្លែកហើយ ល្អជាងសត្វនោះទៅទៀត ។

ធម្មកថាបានមានប្រយោជន៍ ដល់មហាជនអ្នកប្រជុំគ្នាហើយ ។ ព្រះសាស្តាទ្រង់សម្តែងធម្មិយាំងនេះ ចប់ហើយត្រាស់ថា អានន្ទ កុំគិតឡើយ អ្នកពាំងនោះនឹងដេរត្រឹមតែ ៧ ថ្ងៃប៉ុណ្ណោះទេ ក្នុងថ្ងៃទី៨នឹងស្ងៀមស្ងាត់ហើយ ព្រោះអធិករណ៍ដ៏កើតឡើងដល់ព្រះពុទ្ធពាំងឡាយមិនយូរហួស៧ថ្ងៃទៀត ។

ព្រះនាងមាគន្ធិយា ជួលមនុស្សឲ្យដេរព្រះសាស្តា ហើយមិនអាចនឹងឲ្យព្រះអង្គរត់ទៅបាន គិតថា អញនឹងធ្វើយ៉ាងណាទៀត ហើយគិតទៅថា នាងសាមាវតីជាដើមពាំងនេះ ជាអ្នកឧបត្ថម្ភក៏ព្រះសមណៈគោតមនោះ នឹងធ្វើសេចក្តីវិនាសដល់ពួកវា ថ្ងៃមួយ ធ្វើការបម្រើនៅក្នុងស្នាន់ សោយទឹកច័ណ្ឌ (ស្រា) របស់ព្រះរាជា បញ្ជូនសាសន៍ទៅដល់

មា (នាយមាគន្ធិយៈ) សេចក្តីថា ខ្ញុំត្រូវការមាន់ មាចូរយកមាន់ស្វាប់៨ មានរស់៨មក កាលមកដល់ហើយ ចូរឈរទៅត្រង់ដើមជណ្តើរ ប្រាប់មនុស្សឲ្យក្រាបទូលអាការ ដែលខ្ញុំនមកដល់ព្រះកជាសូម្បីកាលព្រះអង្គ ចង្អាប់ថាចូរចូលទៅ ក៏កុំចូលទៅ បញ្ជូនមាន់រស់៨ទៅមុន ខាងក្រោយចាំបញ្ជូនមាន់ស្វាប់ទៅ ក៏ព្រះនាងបានប្រគេនសំណូកដល់រាជង្គរក្ស ប្រាប់ថា អ្នកគប្បីធ្វើតាមពាក្យរបស់ខ្ញុំ ។

នាយមាគន្ធិយៈមកដល់ហើយ ប្រាប់ឲ្យមនុស្សក្រាបទូលដល់ព្រះកជា កាលព្រះអង្គត្រាស់ប្រាប់ថា ចូរចូលទៅនិយាយ (នឹងអ្នកទូលព្រះតម្រាស់ទៅ)ថា ខ្ញុំនឹងមិនចូលទៅកាន់អាចានភូមិ (ទីរោយទឹកច័ណ្ឌ)របស់ព្រះកជាទេ ។ ព្រះនាងមាគន្ធិយាប្រើរាជង្គរក្សទៅប្រាប់ថា អ្នកចូរទៅកាន់សម្នាក់មារបស់ខ្ញុំ ។ គេទៅនាំយកមាន់រស់៨ ដែលនាយមាគន្ធិយៈឲ្យមក ទូលព្រះកជាថា សូមព្រះតេជៈ លោកបុរោហិតផ្ញើបណ្ណាការមក (ថ្វាយ) ។

ព្រះកជា- ច្រកៃហើយបេហ្ន៎ សម្ងួឈ្មោះខុត្តរកង្គៈ (គឺសម្ងួការប្តកកូរ) កើតឡើងដល់យើងហើយ តើអ្នកណាគប្បីស្ងួចាន ។

មាគន្ធិយា- ព្រះមហាកជ ស្រីប្រុសរបស់មានព្រះមាន សាមាវតីជាប្រធាន មិនមានការងារ (អ្វីទេ) ដើរលេង សូមព្រះអង្គបញ្ជូនទៅ

ឲ្យពួកគេចុះ ពួកគេស្រេចហើយ នឹងនាំមកថ្វាយ ។

ព្រះពុទ្ធជាម្ចាស់ទ្រង់ចាប់ផ្តើមបញ្ជូនទៅដោយព្រះពុទ្ធដីកាថា ម្នាលភិក្ខុទាំងឡាយ ចូរអ្នកទាំងឡាយទៅ ចូរនាំគ្នាទៅ ដោយប្រការដូច្នេះ

នាងចាំនឡាយក្រោកទៅទូលក្នុម) ពោលថា យកមកចុះអ្នក នេះ
ជាកិច្ចរបស់ពួកយើង ។ គេមកកាន់សម្លាក់ព្រះរាជាហើយព្រះអង្គ
ត្រាស់សួរថា ដូចម្តេចទៅ កូន ក្រាបទូលថា សូមព្រះតេជៈ
ត្រាន់តែខ្ញុំព្រះអង្គប្រាប់ថា (បង្គាប់ថា) នាងម្ចាស់ចូរស្វែងរកទៅដល់
ព្រះសមណគោតមក៏ស៊ុះមកទូលយកមានទៅក្នុម ព្រះអង្គ ។ ព្រះ
នាងមាគន្ធិយាទើបទូលញុះញង់ថា ម៉េលចុះ ព្រះមហាក្សត្រនាងចាំង
នោះមិនធ្លាប់ថ្លាយដល់ព្រះអង្គក៏បាន កាលខ្ញុំម្ចាស់ទូលថា គេមានសេចក្តី
ប្រាថ្នាខាងក្រៅ (ក្សត់) ព្រះអង្គក៏មិនទ្រង់ជឿ ។ ព្រះរាជាសូម្បីទ្រង់ព្រះ
សណ្តាប់ដូច្នោះ ក៏ទ្រង់អត់សង្កត់ព្រះហឫទ័យស្ងៀមឈឹង ។ ព្រះនាង
មាគន្ធិយោគិតថា អញនឹងធ្វើដូចម្តេចស្រួលអេះ ទើបនឹងបានសម្រេច
ផល ។

ក៏ក្នុងគ្រានោះ ព្រះរាជាទ្រង់ផ្ញាស់ប្តូរគន់នោយូរដោយវែងអស់មួយ
សប្តាហ៍ ។ ក្នុងថ្ងៃប្រាសាទរបស់ព្រះនាងចាំង ៣ នេះគឺ ព្រះនាងសាមាវតី
ព្រះនាងវ៉ាសុលទត្តាព្រះនាងមាគន្ធិយា តមក ព្រះនាងមាគន្ធិយាទ្រង់ប្រាប
ថា ស្អែកប្តូនាងស្អែក នឹងស្តេចយាងទៅកាន់ប្រាសាទព្រះនាងសាមា-
វតីទើបបញ្ជូនដំណឹងទៅដល់មា (នាយមាគន្ធិយ:)ថា ខ្ញុំត្រូវការដោយពស់
ដែលមានពិសជ័ក (ប៉ុន្តែ) ចូរដកចង្កឹមចេញហើយផ្ញើទៅឲ្យមួយ ។

គេធ្វើដូច្នោះហើយផ្ទៀវ ។ ព្រះពជាទ្រង់យកតំណហត្ថកន្តៀកាន់ទីព្រះអង្គស្តេចទៅផងដូចគ្នា ។ កន្ត ស្រកតំណានោះមានប្រហោងមួយ ។ ព្រះនាងមាគន្ធិយាលែងតស់ឲ្យចូលទៅដោយប្រហោងនោះ ហើយបិទប្រហោងដោយថ្មចំផ្លា ។ តស់នៅខាងក្នុងតំណអស់ពីរបីថ្ងៃ ។ ក្នុងថ្ងៃព្រះពជាស្តេចទៅព្រះនាងមាគន្ធិយាទូលសួរថា បពិត្រព្រះអង្គដ៏ប្រសើរថ្ងៃនេះ ព្រះអង្គទីឯស្តេចយាងទៅកាន់ប្រាសាទព្រះនាងអង្គណា កាលព្រះអង្គត្រាស់ប្រាប់ថា ប្រាសាទនាងសាមាវតី ទូលជាវិបំតិយដោយមុសាវាទថា បពិត្រព្រះមហាវជ ថ្ងៃនេះខ្ញុំម្ចាស់យើញសុបិន និមិត្ត) មិនជាទីរភាញចិត្តសោះ ព្រះអង្គមិនអាចស្តេចទៅកន្លែងនោះបានទេព្រះអង្គ ។

(ដៅមានត)

វិចារណកថា :

តើមានឋានសួគ៌ដោយខ្លួកឬទេ

បញ្ហានេះមានន័យវែង មានបញ្ហាវែង ហើយនិងកក្ខដាពុទ្ធសាសនិកខ្លះ ចានលើកយកមកចោទហើយដោះស្រាយខ្លះ ។ ទៅហើយ ។ តើគេដោះស្រាយថាដូចម្តេចទៅ ? តាមដែលយើងចានដឹង គេថាឥតមានឋានសួគ៌ឯណាក្រៅពីឋានមនុស្សនេះឡើយ ។ អ្នកមានភោគទ្រព្យច្រើន ដូចជាមហាសេដ្ឋី នាម៉ឺនសព្វមុខមន្ត្រីហូតដល់ទៅស្តេចឬប្រធានាធិបតី អ្នកទាំងនេះហើយគឺជាទេព្តា អ្នកទាំងអស់នេះហើយ គឺជាអ្នកបិតទៅក្នុងឋានសួគ៌ ។ ចូរក្រឡេកមើលទៅសំលៀកបំពាក់ ការសប្បាយ ការរីករាយ ការបរិភោគអាហារភោជន ការសម្អាតអាស្រ័យទៅវិមានច្រាសាទដ៏ធំស្កឹមស្កៃនិងទីដំណេក និងគ្រឿងប្រដាប់ប្រើប្រាស់គ្រប់បែបយ៉ាង នេះទាំងអស់នេះ សុទ្ធសឹងជាវត្ថុដ៏មានតម្លៃសុទ្ធសឹងជាវត្ថុដ៏ស្អាតបរិសុទ្ធមួយថ្លៃ។ គេទៅណាមកណាឥតដែលដើរទេ គឺសុទ្ធតែជិះរថយន្តដ៏ប្រណីត មានឈ្លៀងទៅចាំបម្រើឆ្វេងស្តាំ ក្នុងក្រអូបក្រអែមឈ្ងុយឈ្ងប់ដោយទឹកអប់ដ៏មានតម្លៃ ក្នុងទឹកអប់មួយដប។

ថ្ងៃសុទ្ធតែកប់រយកប់ពាន់ ។ ត្រង់ហ្នឹងហើយដែលហៅថាហាន១សួគ៌
នេះ ត្រង់ហ្នឹងហើយដែលហៅថាហាន១ះខ្ពស់នោះ តើចាំបាច់ទៅរក
ហាន១ខ្ពស់ឯណាទៀត? ។ ដូច្នេះចាំបាច់ទៅធ្វើទាន១ចំពោះព្រះសង្ឃ
ធ្វើអ្វីទៀត ដើម្បីឱ្យបាន១ទៅកើត១ទៅហាន១សួគ៌នោះ ព្រោះហាន១សួគ៌ទៅ
ឯណាក្នុងស្រាប់ទៅហើយ, ប្រសិន១បើចង់ទៅណាទៅដល់ភ្លាម ប្រសិន
បើចង់បរិភោគចំណីអាហារបែបណា ឆ្ងាញ់ណា គឺបានភ្លាម គឺថាចង់
ប្រាថ្នាអ្វីបាន១ដូចចិត្ត១ចង់ ។ ដែលហៅថាហាន១ខ្ពស់ឬហាន១សួគ៌នោះ គឺ
បើប្រាថ្នាអ្វីអាច១សម្រេចដូចចំណង់ភ្លាម ប្រាថ្នាចង់ទៅទីណា គឺបាន
ទៅដល់ភ្លាម ហើដូច្នេះហើយ តើយើងត្រូវទៅរកហាន១សួគ៌ឬហាន១ខ្ពស់
ដល់ទីឯណា គឺហាន១ខ្ពស់នៅតែជិតខ្លួន១នេះឯង ។

រីឯហាន១នរកទៀតក៏នៅតែជិតៗខ្លួន១យើងនេះដែរ ។ ចុះគេចង់
ចង្អុលទីណាថាជាន១រកនោះ? គឺចង់ចង្អុលគុកនេះឯងថាជាហាន១រក
ព្រោះនៅក្នុងគុកមនុស្សត្រូវប្រាសចាកសេរីភាព ហើយមួយថ្ងៃៗ មើល
ទៅទីដេកក៏មិន១សមរម្យ មើលទៅសំលៀកបំពាក់ក៏មិន១សមរម្យ មើល
ទៅអាហារបរិភោគទៀត ក៏ស៊ុកគគ្រុក មិន១សមបើគួរគប្បីភាល់តែសោះ
ចំណែកឯកូនវិញធុំអសោច៌ ព្រោះមនុស្សទោស១តែក៏ដូចជាមិន១ឆ្ងាត
អាវតែមួយ ខោក៏តែមួយ សំលៀកបំពាក់ទៅផ្ទះក៏តែអាវហ្នឹង១ខោហ្នឹង

សំលៀកបំពាក់ចេញក្រៅតែអាវហ្នឹងទោហ៎ិន ក្នុងមួយថ្ងៃគេឲ្យឆ្លងទឹកតែម្តង ដូនកាលគេមិនទាំងឲ្យឆ្លងផង សេចក្តីវេទនាទុក្ខទោសរកពេលទំនេរគ្មាន ដូនកាលគេវាយដូនកាលគេដាក់ គេស្តី គេជេរ តាមអំពើចិត្ត ដូច្នេះហើយទើបគេហៅថាហាន់ននរក គឺគុកនេះឯង ។

សេចក្តីពណ៌នាមកខាងលើនេះប្រសិនបើយើងមិនគិតមិនពិចារណាមិនបានយល់ឲ្យដល់ទីជម្រៅ ក៏យើញថាហាក់ដូចជាពិតអ៊ីចឹងមែន ព្រោះបើគ្រាន់តែក្រឡេកមើលដោយមំសចក្ខុ គឺយើញដូចជាគេថាដ៏ពិតប្រាកដមែន តែបើយើងយកបញ្ញាមកធ្វើជាពន្ធឹសម្រាប់ចំក្ខុ នោះពាក្យដែលគេថាទាំងប៉ុន្មានដូចខាងលើ គឺខុសស្រឡះតែម្តង គឺអ្នកថានោះចេះតែថា ។ ដៅ ឥតមានវិចារណញ្ញាណអ្វីបន្តិចបន្តួចសោះឡើយ ។ ពាក្យសម្តីអស់នេះបើគិតមើលដៅស្មើរតែ ទឹងថាជាពាក្យសំម្តីរបស់មនុស្សជាមិច្ឆាទិដ្ឋិក៏ថាបាន ។ ហេតុអ្វីក៏ថាដូច្នេះ ? ចាន់ជាថាដូច្នេះ ព្រោះអ្នកថានោះជាមនុស្សយកតែរបស់យើញនឹងភ្នែកក្នុងនឹងត្រចៀក . . . មកពោល ។

ប្រសិនបើហាន់មនុស្ស ប្រសិនមនុស្សមានទ្រព្យសម្បត្តិច្រើន ប្រសិនបើស្តេចឬប្រធានាធិបតី ប្រសិនបើនាម៉ឺនសព្វមុខមន្ត្រី គឺសុទ្ធសឹងជាខ្ពើ គឺជាហាន់ខ្ពើមែន ហេតុដូចម្តេចក៏គង់ចិដកដែលជាពុទ្ធដីកានៃព្រះបរមគ្រូសម្មាសម្ពុទ្ធ ចានបែរជាចែកភ្លើងជាបីជ្រើម្តី? តើភ្លើងភាំង ភ

នោះគឺដូចម្តេចខ្លះ ? រីកូមិតាំង ៣ នោះគឺកាមកូមិ ១ រូបកូមិ ១ និងអរូប-
កូមិ ១ ។ តទៀរយើងសូរទុកនូវកូមិ ២ មិនលើកយកមកអធិប្បាយទេ
យើងលើកយកតែកូមិ ១ មកអធិប្បាយដោះស្រាយ គឺកាមកូមិនេះឯង ។
តើអ្វីទៅ ដែលគេហៅថាកាមកូមិនោះ? កាមកូមិ គឺជាកូមិរបស់សត្វ
ដែលបរិភោគកាម ។ តើកាមគឺអ្វី ? ដែលហៅថាកាមនោះ គេសំដៅ
កាមគុណតាំង ៥ មានរូបសំឡេងក្លិនរស់សម្ផស្សនេះឯង ។ តើកូមិ
របស់សត្វដែលបរិភោគកាម មានចែកជាប៉ុន្មានជាន់ ? កូមិនេះមានចែក
ជា ១១ ជាន់តាមព្រះពុទ្ធដីកា ។ តើតាំង ១១ ជាន់គឺអ្វីខ្លះ ? គឺអបាយ-
កូមិ ៤ ឋានមនុស្ស ១ និងឋានសួគ៌ ៦ ជាន់ រួមតាំងអស់ត្រូវជា
១១ ជាន ហើយក្នុងជាន់តាំង ១១ នេះសត្វសុទ្ធតែយកកាមអាហារបរិភោគ
តាំងអស់ ។ ចុះបើព្រះពុទ្ធទ្រង់ចែកជាន់នៃកាមកូមិជា ១១ ជាន់ដូច្នេះ
តើយើងអាចបដិសេធមិនដឹងទេឬអី ? ព្រះពុទ្ធាភិឧណាដែលព្រះអង្គ
ទ្រង់ត្រាស់សម្តែងហើយ ព្រះពុទ្ធាភិឧនោះ សុទ្ធជាពាក្យពិតប្រកែកពុំបាន
ឡើយ ព្រោះព្រះពុទ្ធមិនមែនជាព្រះអាទិទេព ដូចព្រះព្រហ្ម ព្រះឥសូរនិង
ព្រះនារាយណ៍ទេ ព្រះពុទ្ធគឺជាមនុស្ស ១ រូបដែលបានត្រាស់ដឹងដោយការ
ពិចារណា នូវបដិច្ចសមុប្បាទ គឺជាធម៌ប្រាក់ប្រាក់ប្រទន្ឋាតីមួយទៀ

មួយ ដោយអំណាចបារមីចាំង ៣០ ដែលព្រះអង្គទំនាស់ខ្ញុំកមក យូរអង្វែងកប្បមកហើយ ។ ធម៌ដែលព្រះអង្គទ្រង់ត្រាស់ដឹងសុទ្ធសឹងជាធម៌ពិត រកអ្នកប្រាជ្ញណាមកជ្រៀតជ្រែកពុំបានឡើយ ។

. មែនពិត ស្តេចឬប្រធានាធិបតី អ្នកមានទ្រព្យច្រើនឬមានុមុនសព្វមុខមន្ត្រី គេអាចហៅថាខេត្តាបានដែរ តែគេហៅដោយសន្មតិ ។ ដូច្នេះហើយបានជាគេហៅស្តេច ជាបទអាលបទនៈ ថា : បពិត្រព្រះសម្មតិទេព គឺជាខេត្តាកើតឡើង ដោយមនុស្សផងនាំគ្នាបន្តុបដំកើងឡើង ពុំមែនជាខេត្តាមែនទែននោះទេ ប្រសិនបើខេត្តាមែនទែននោះគេពុំហៅថាសម្មតិទេពទេ គឺគេហៅថាឧប្បតិទេព គឺខេត្តាស្ថាប័ទមនុស្សទៅចាប់កំណើតជាខេត្តាតែម្តង ។ ដូចលោកសង្ឃយើងសព្វថ្ងៃ គឺសុទ្ធសឹងជាសម្មតិសង្ឃ កើតដោយក្តីសន្មត ឯសង្ឃពិតប្រាកដនោះគឺព្រះអរិយសង្ឃចាំង ៤ គូ ឬ ចាំង ៨ ឯណោះ មានសោតាបត្តិមគ្គសង្ឃ ជាដើម មានអរហត្តផលជាចុងក្រោយបង្អស់ដូចមានចែងក្នុងសង្ឃគុណស្រាប់ ។

ចំណែកឋានទេវតាមិនមែនទៅទីឆ៖ឋានមនុស្សនេះដែរទេ ប្រសិនបើឋានមនុស្សជាឋានទេវតានោះ តើឋានទេវតាក្នុងឆកាមាវចរភូមិចាំង ៤ មិនខុសទៅហើយ? បើដូច្នេះមែនព្រះពុទ្ធដីកាមិនខុសទេ ដែលថាអបាយ

ភូមិពាំង ๔ គឺនរក ប្រេត តិរច្ឆាន និង អសុរកាយ នោះ ។

បើពុកជាមនុស្សមានបុណ្យប៉ុណ្ណា កំតែមិនហៅថាទេព្តាទេ្បីយ ប្រសិនបើគេហៅ គឺគេហៅដោយសន្មតជូរច្នោះឯង ។ រីឯនរកក៏ជូរច្នោះដែរ បើពុកធ្លាជាមនុស្សទេ្ចលរឆ្ងៃពុកវេទនាយ៉ាងណា ក៏មិនថាពុកជាសត្វនរកពិត ។ នោះ គឺគេហៅដោយសន្មតិបាន ដ្បិតព្រះពុទ្ធទ្រង់ចែកមនុស្សជា ៤ ពួកដែរ គាន់លោមភៅតាមការសង់នោងឯការប្រព្រឹត្តរបស់មនុស្សនោះ។ ។ តើមនុស្ស ៤ ពួកនោះដូចម្តេចខ្លះ ! គឺមនុស្សទេវ៉ា ១ មនុស្សនិរយៈគោ ១ មនុស្សបេតោ ១ មនុស្សតិរច្ឆាននោ ១ ។

មនុស្សណាមានជីវិតាពរស់នៅដ៏ប្រសើរពាំងផ្ទះពាំងសំលៀកបំពាក់ពាំងអាហារគោជន មនុស្សនោះ គេហៅថាមនុស្សទេវ៉ា ព្រោះមានសភាពដូចទេវតា តែដែលថាប៉ុណ្ណេះនេះ គឺគេសំដៅយកតែអាការខាងក្រៅទេ នៅមានអាការខាងក្នុងទៀត លុះណាតែចិត្តគំនិតរបស់មនុស្សប្រកបដោយនិច្ចសីល ហើយវត្តផងពាំងពួងដែលជារបស់ខ្លួន ក៏សុទ្ធតែបានមកដោយធម៌ដោយអំពើសុចរិតទៀត នោះទើបគេហៅថាជាមនុស្សទេវ៉ាទៅកើតមិនត្រាន់តែមានជីវិតាពដ៏ប្រសើរ ហើយឈ្មោះថាមនុស្សទេដ្បិតទេវតាពុំមែនជាមនុស្សថ្នង់គេ ពុំមែនជាមនុស្សល្ងង្វាយទេ ពុំមែនជាមនុស្សស៊ីសំណូក ពុំមែនជាមនុស្សលួចឆក់ប្រវ័ញ្ចា រកទទួលទាន

ដោយអំពើទុច្ចរិតទៅកើតទេ ពួកទេវតា គឺសុទ្ធតែមនុស្សជាប់សីល ៥ ជាដើម ទៅកើត ។

មនុស្សមានជីវភាពដូចនរក គឺមិនចេះមើលនាយកាយ ត្រូវគាប់ៗ ត្រូវសម្លាប់ៗ ហើយរស់នៅ មនុស្សបែបនេះព្រះពុទ្ធទ្រង់ហៅថាមនុស្សនរក ហើយចរិកាគេតែងតែមានទុក្ខសោក ចំណីអាហារឆ្អិនទៅអ្នកំដោយឥតរើសអើងទេ ចេះតែចរិកាគឲ្យតែឆ្អែត ។ ទៅ សំលៀកបំពាក់ផ្ទះសម្បែង ខ្វិលធ្លើនៅខ្វិលរកអាស្រ័យនៅតាមតែបាន ហើយចូលចិត្តតែប្រព្រឹត្តអំពើទុច្ចរិត យ៉ាងនេះឯងដែលគេហៅថាមនុស្សនិរយៈកោ ។

មនុស្សបេតា គឺជាសភាពមនុស្សរស់នៅដូចប្រេត គឺថារស់នៅសុំទានគេស៊ី បាយព្រឹកជាបាយល្ងាច សំលៀកបំពាក់រយ៉ើរយៃ ដេកដោយតាមសំបោងផ្ទះអ្នកដទៃ ចំណែកចិត្តគំនិតរបស់មនុស្សនេះទៀតក៏ជាចិត្តគំនិតប្រេតទាំងស្រុង ប្រសិនបើរកស៊ីមិនបានត្រូវឆក់កឆក់ដៃឲ្យតែបានឆ្អែត ១ គ្រាសិន មនុស្សនេះច្រើនតែដើរអើតងើតទៅតាមផ្ទះលក់អាហារគោជនក្រែងលោជាមានសល់អំពីអ្នកស៊ីមុនទៅបានតាន កំនាំគ្នាហុតលិទ្ធខឹកសំឡីសំណល់នោះទៅ គឺថាជាមនុស្សរស់នៅត្រជាបត្រជួសដូចជាប្រេតដូច្នោះ ។

រីមនុស្សតិរច្ឆានោ គឺជាមនុស្សរស់ដោយប្រព្រឹត្តខឹងនឹងគំនៀម

ខម្លាប់ប្រព្រឹត្តទទឹងនឹងច្បាប់សម្រាប់រដ្ឋ គឺថាធ្វើអ្វី ។ ប្រើនតែផ្ទុយពីអ្នក
ឆ្លាតពាំនាំពួកជូចជាសត្វតិរច្ឆាន ។ មនុស្សពួកនេះឥតស្គាល់ឪពុកម្តាយ
ឥតស្គាល់កូនឬប្រពន្ធកូន ឬ ប្រពន្ធកូនគេ ក៏មនុស្សនេះមិនចេះគោរព
ខ្លើយ ជាមនុស្សចូលចិត្តឈ្លោះប្រកែកយកតែឈ្នះដៃមិនថាឪពុកម្តាយ
កូនប្រពន្ធឬបងប្អូនអ្វីខ្លើយ ប្រសិនបើចិត្តចង់អ្វីហើយ ឥតមានគិតមុខ
ក្រោយទេ គិតតែប្រព្រឹត្តតាមកម្លាំងដៃលខ្លួនមាន ។

រួមសេចក្តីទៅ មនុស្សដែលពោលថា ហាន់ស្ងួតគឺហាន់មនុស្សនិង
ហាន់នកក៏ហាន់មនុស្សដែរ ឈ្មោះថាពោលដោយកំន្តប្រឡំ មិន
គោរពតាមព្រះពុទ្ធដីកា នៃព្រះអរហន្តសម្មាសម្ពុទ្ធលាល់តែសោះ ព្រោះ
ហាន់មនុស្សដាហាន់ទៅប្រែប្រួលជាទិច្ច ដូនតាលអ្នកក្រ ក៏អាច
ក្លាយទៅជាអ្នកមានបាន ហើយផ្ទុយទៅវិញ អ្នកមានបើមិនប្រុង
ប្រយ័ត្នក៏អាចក្លាយទៅជាអ្នកក្រវិញបានដែរ ចំណែកខ្មោតា គឺជា
ខ្មោតាហើយ មិនអាចប្រែក្លាយទៅជាខ្មោតាមាន ឬខ្មោតាក្រ
ខ្លើយ ព្រោះខ្មោតាសោយតែអាហារទិព្វ អាស្រ័យនៅក្នុងវិមានទិព្វ
ជាធម្មតា ។ ចំណែកទ្រព្យសម្បត្តិបុណ្យយសសក្តិរបស់មនុស្ស សុទ្ធ
សឹងជាវត្ថុកើតឡើងដោយការងារផ្ទាល់គ្នាទាំងអស់ ។ តើកើតឡើងដោយ
ការងារដូចម្តេច? គឺថាមនុស្សម្នាក់ដែលបានកើតមកជាមនុស្ស សុទ្ធតែ

មានបុណ្យកុសលបញ្ជានមកឲ្យកើត អាស្រ័យទៅតាមផលបុណ្យតិច ឬ
ច្រើន ហើយមួយ៉ាងទៀតពុំមែនសុទ្ធតែកើតឡើងដោយសារតែបុណ្យម៉្យាង
ប៉ុណ្ណោះទេ គឺត្រូវពឹងនឹងការប្រព្រឹត្តរបស់ខ្លួនផង ថែមទាំងពេលដែលខ្លួន
បានមកកើតជាមនុស្សហើយនោះ គឺថាបើខ្លួនប្រព្រឹត្តខុសនឹងនាំខ្លួនឲ្យ
ទៅជួបនឹងសេចក្តីអន្តរាយ បើខ្លួនប្រព្រឹត្តត្រូវ នឹងនាំខ្លួនឲ្យជួបប្រទះ
នឹងក្តីចំរើនរុងរឿងជាពិតប្រាកដ ។ យើងចង់និយាយថា ដោយអាស្រ័យ
ការសេពគប់នេះជាធំ របស់មនុស្ស ។ ចំណែកឯហានទេវតា រឿង
ការប្រព្រឹត្តឥតមានចែងឬឥតមាននិយាយទេ ដៀបដូចជាអ្នកធ្វើ
ដំណើរហើយចូលកោជន័យដ្ឋាន គឺចាំអង្គុយតែស៊ី មិនចាំបាច់ទៅចាត់
ចែងដោយខ្លួនឯងឡើយ រួចនាំគ្នាដើរចេញទៅព្រលើយ ។

ដោយយោលទៅតាមការប្រព្រឹត្ត និងយោលទៅតាមការមិន
ប្រព្រឹត្តនេះហើយ ទើបយើងសម្រេចថា អ្នកដែលនិយាយថា ហាន
សួគ៌ គឺហានមនុស្សនេះឯង គឺអ្នកថាដូច្នេះឈ្មោះថា ពោលដោយ
កន្ទប្រឡំឬហៅថាមិច្ឆាទិដ្ឋិ ជាន់សេចក្តីថា : ឥតមានហានសួគ៌ដោយឡែក

ហាននរកដោយខ្លួនឯង និងហានមនុស្សដោយខ្លួនឯង ពុំត្រូវយល់ថាហាន
សួគ៌ ហាននរក គឺបែងនោះតែក្នុងហានមនុស្សនេះឡើយ ។

ដេន ស្រីវ

១៦-១០-៧១

រឿងសាមកុក

ឧកញ៉ាវិបុលរាជសេនា ទួ-កន

ប្រែ - រៀបរៀង

(ក)

> រឿងសាមកុកទុកជាឃុទ្ធសាស្ត្រ អ្នកកាងវៃឆ្លាសបើបានអាន
> នឹងចេះឧបាយកលចំណាន ទាំងមានសន្តានស្នេហាជាតិ
>
> ——ឃ្លោ-អ៊ុន

ខណៈនោះ អៀវឆីកំនាំគាហាន ដូនចេញទៅទៅក្នុងកងគាហាន កៀងអ៊ុយ ខ្ជួលបានឮ អ៊ុយ អៀន ស្រែកថាមកដូច្នោះ អៀវឆីកំហែកសំបុត្រមើលឃើញសេចក្តីថា : ឲ្យបះញ្ជោតអ៊ុយអៀន បើប្រសិនណា អ៊ុយអៀន មានចិត្តកំរើបស្រែកថា នរណានឹងអាចសម្លាប់អញបាន នោះសេចក្តីគាំងនេះក៏បានផ្តាំផ្តាច់ខ្ពុកនឹងម៉ាតាយជាអាថ៌កំបាំងហើយ អៀវឆីឃើញសេចក្តីដូច្នោះ ទើបស្រែកប្រាប់ទៅអ៊ុយអៀនថា មហាឧបាសជ្រាបប្រាកដថាឯងនឹងប្រែត្រាត់បាន ជាផ្តាំខុកឲ្យអញសម្លាប់ឯងចេញបើឯងអាចហានដើរមុខឡើងទៅលើអាកាស ហើយស្រែកដោយសម្លេងយ៉ាងខ្លាំងថា នរណាអាចហានសម្លាប់ឯងបាន ឲ្យថាយ៉ាងនេះតែពាក្យម៉ាត់ចុះ រញ្ជួងឹងលើកស្រុកហោនតុងឲ្យឯង ។

អ៊ុយអៀនតបថា : ឯងចាំស្តាប់អញចុះ ហើយក៏ឆើយមុខទៀត
មើលអាកាសស្រែកថា ខរណាអាចហ៊ានសម្លាប់អញបាន រំលានោះ
ម៉ាតាយបញ្ឆេះសេះ នៅពីក្រោយខ្នងអ៊ុយអៀន បានឃើញអ៊ុយអៀន
ឆើយមុខស្រែកទៀតតែពាក្យមួយម៉ាត់ ម៉ាតាយក៏ស្ទុះទៅចំមដិតហើយ
ស្រែកថា អញឯងមានថ្ងៃដៃបានខខួលបណ្តាំ មហាឧបាដខុកថា ឲ្យ
សម្លាប់ឯង ថាហើយក៏លើកគ្រឹបកាប់ត្រូវកអ៊ុយអៀនដាច់ធ្លាក់ចេះពីលើ
ខ្នងសេះ, អៀវធីនិងកៀងអ៊ុយឃើញដូច្នោះក៏មានអំណរណាស់ ទើប
ឲ្យម៉ាតាយយកក្បាលអ៊ុយអៀនចូលទៅក្នុងស្រុកហានតុង ខខួលប្រទះ
និងតាំងអ៊ុង ពាំងសងខាងក៏ធ្វើបដិសណ្ឋារកាន់គ្នាទៅវិញទៅមក ហើយ
ពណិនាប្រាប់រឿងរ៉ាវគ្នាគ្រប់ប្រការ, អៀវធីនិងកៀងអ៊ុយក៏ចាត់ប្រើម៉ា
តាយនិងតាំងអ៊ុនឲ្យនាំក្បាលអ៊ុយកៀន ចូលទៅថ្វាយព្រះចៅឡៅ
សៀនជាមុន ឯខ្លួនអៀវធីនិងកៀងអ៊ុយទៅនាំសពពុងចេងទៅជាក្រោយ
នោះ ម៉ាតាយនិងតាំងអ៊ុនក៏នាំក្បាលអ៊ុយកៀន ចូលទៅដល់ស្រុកសៃ
ឈួន ហើយនាំចូលទៅថ្វាយព្រះចៅឡៅសៀនគ្រាបខូលតាមឲ្យជ្រាប
គ្រប់ប្រការ, ព្រះចៅឡៅសៀនទ្រង់ព្រះសណ្តាប់ហើយ ក៏គ្រាស់ប្រាប់
នាម៉ឺនមុខមន្ត្រីទាំងពួងថា អ៊ុយអៀនធ្វើសេចក្តីខុសបានជាដល់សេចក្តី
ស្លាប់, ឯសេចក្តីគាប់ប្រសើរអ៊ុយអៀន ក៏បានធ្វើមកពីដើម ទើបទ្រង់
ព្រះសព្រះពជទាន ប្រាក់មាសឲ្យបុត្រកំលោតែងការអ៊ុយអៀនតាម

ប្រវេណី ។

ខណៈនោះ អៀវធីនិងកៀងអ៊ុយ កំទាំសពទៅដល់ក្រៅក្រុងសៃ-ឈួន ព្រះចៅឡៅសៀនជ្រាបសេចក្តីគំរាំងគ្រឿងសកាន់ខុកួ ហើយគ្រាស់បង្គាប់នាម៉ឺនមុខមន្ត្រី និងអាណាប្រជានុកស្ត្រីតាំងពួងចណ្តាដែលមាននៅក្នុងស្រុកសៃឈួនតាំងប៉ុន្មាន ឲ្យស្រែកសកាន់ខុកួគ្រប់គ្នា, ចៅយព្រះអង្គទ្រង់ស្តេចដោយវេទព្រះទីនាំងចេញទៅ ទទួលតំទាប់សព ខុងបេងចម្ងាយផ្លូវប្រមាណ ២០០សិន (៨ គ.ម.) ព្រះចៅឡៅសៀន និងនាម៉ឺនតាំងពួង នូវអស់អាណាប្រជានុកស្ត្រទាទា ក៏សឹងតែសោកអាឡោះអាល័យខុងបេងច្រើនណាស់ រួចអញ្ជើញសពខុងបេងចូលទៅរៀបដំកល់ខុក នៅគេហស្ថាន ឲ្យដូកាត់ចៀមជាបុត្រក្បាខុកសិន, អៀវធីទើបយកសំបុត្របណ្តាំខុងបេង ចូលទៅថ្វាយព្រះចៅឡៅសៀន ហើយទូលថា ខុងបេងផ្តាំថាឲ្យយកសពទៅបញ្ចុះខុកនៅក្នុងតែងគុនសាន តែកុំឲ្យកជាកុដិនឹងតែងគ្រឿងសែនឡើយ, ព្រះចៅឡៅសៀន ទ្រង់ជ្រាបតាមសេចក្តីសំបុត្រ និងពាក្យបណ្តាំសព្វគ្រប់ដូច្នោះ ក៏រឹតតែទ្រង់ព្រះតន្ទៃដែរសោកាពន់ប្រមាណណាស់, លុះដល់ថ្ងៃកំណត់ក៏អញ្ជើញសពខុងបេងហែទៅបញ្ចុះខុក នៅក្នុងតែងគុនសាន ហើយតាំងអៀវធីជានាយកខាងក្រសួងក្រុមកំង, តាំងម៉ាតាយ ជានាម៉ឺនដំទួសមុខងារអ៊ុយអៀន ។

លុះកន្លងមកថ្ងៃ១ មានចំរើលស្បាតនាំសេចក្តីចូលទៅថ្វាយដល់ព្រះ ចៅ
ក្បែរសៀនថា កងទ័ពស្រុកកាំងតាំងនាំគាហានប្រហែល ១០ម៉ឺន លើក
មកតាំងនៅមាត់ផ្លូវស្រុកប៉ាគីវ ព្រះចៅក្បែរសៀនជ្រាបដូច្នោះ ក៏ព្រួយ
ព្រះទ័យណាស់ត្រាស់ថា វេលានេះមហាឧបភដើមអនិច្ចកម្ម ស្រុក
កាំងតាំងលើកទ័ពមកតាំងដូច្នេះ នឹងធ្វើប្រទុសរ៉ាយប្រការម្តេច ។

ចៀវអ៊ួនក្រាបទូលថា : សូមឲ្យទ្រង់ចាត់អៀវធី និងអង់ប៉ង់នាំ
ពល ១០ម៉ឺនទៅតាំងទៅស្រុកអេងអាន់ ហើយឲ្យចាត់មន្ត្រីភ្នាក់ងារចូល
ទៅនិយាយការដល់ស៊ុនគួនថា វេលានេះខ្ញុំងចង់ទូលអនិច្ចកម្មហើយ
ច្រើនថ្ងៃនឹង បានស្តាប់កិត្តិសព្ទស្រុកកាំងតាំងថា ស៊ុនគួននឹងគិតប្រការ
ម្តេច ? ព្រះចៅក្បែរសៀនទ្រង់យល់ឃើញត្រូវ ទើបចាត់អៀវធីនិង
អង់ប៉ង់ឲ្យលើកកងទ័ពចេញទៅ ហើយឲ្យចងអ៊ីឡឺងជានាម៉ឺនធំ ព្រោះ
មានសតិបញ្ញា ឲ្យជាកងកូតចេញទៅស្រុកកាំងតាំង តាមពាក្យ
ចៀវអ៊ួថា វេលានោះចងអ៊ីក៏ចេញទៅស្រុកកាំងតាំង ឃើញនាម៉ឺន
ពាំងពួងស្ងៀកសពាក់ស ចងអ៊ីចូលទៅគំនាប់ស៊ុនគួនហើយទូលថា :
ព្រះចៅក្បែរសៀនប្រើទូលបង្គំមកយកសេចក្តីក្រាបទូលថា ដ្បិតខ្ញុំងចង
ទូលអនិច្ចកម្មហើយ ។

ស៊ុនគួនឮដូច្នោះ ក៏ភ្ញាល់ហើយថា : ស្រុកកាំងតាំងនឹងស្រុក

សែឈួនក៏ជាមេត្រីនឹងគ្នា យើងដឹងថាខុនបេងស្លាប់បានជាឡេាកមុន និងកស្តេរស្លៀកពាក់សកាន់ទុក្ខ, ហេតុម្តេចបានជាព្រះចៅឡេាសៀនត្រឡប់ឲ្យលើកកងទ័ពមកតាំងមៅស្រុកអេងអាន ប្រាថ្នានឹងសងសឹក ពីត្រាឡុកស៊ុនដុតទ័ពឡេាពីខួចពល ៧២ មុឺន ទាល់តែឡេាពីរត់ចូលទៅនៅក្នុងស្រុកប៉ែកតេសៀ ទាល់តែទីវង្គតនោះទេដឹងឬ? បងអ៊ីឆ្លើយតបថា: ដែនស្រុកសែឈួនខាងទិសឯកើតរហូតដល់ស្រុកប៉ាគីវ រហូតទៅទិសខាងលិចដល់ស្រុកប៉ែកតេសៀ ព្រះចៅឡេាសៀនគ្រាបថា កងទ័ពស្រុកតាំងតាំង លើកទៅស្រុកប៉ាគីវ បានជាទ្រង់ចាត់កងទ័ពស្រុកសែឈួន ដើម្បីទប់ការពារខុនទៅស្រុកអេងអាន់ ។

ស៊ុនគួនឮដូច្នោះក៏ទ្រង់ព្រះតម្រិះហើយតបថា ដែលឡេាសៀនធ្វើដូច្នេះ ព្រោះយកតាមគំនិតគេងដ៏ ដែលស្លាប់ក្នុងស្រុកសែឈួន ហើយថាតាំងពីយើងដឹងដំណឹងថាខុនបេងស្លាប់នោះ យើងក៏ជាទុក្ខកេឡ្យអាល័យច្រើនណាស់ យើងចាម្តេក្រែងចូរញ៉ាយ ទើងឲ្យលើកទ័ពមកវាយយកស្រុកសែឈួនទេតើ បានជាយើងចាត់កងទ័ព ទៅតាំងស្កាត់ទុកនៅស្រុកប៉ាគីវ ប្រាថ្នានឹងចាំជួយការពារស្រុកសែឈួនប៉ុណ្ណោះ; បងអ៊ីបានឮដូច្នោះ ក៏មានសេចក្តីត្រេកអរណាស់ ស្រាបថ្វាយបង្គំគំនាប់ស៊ុនគួនរហើយថា ដែលទ្រង់គិតដូច្នេះជាការប្រពៃណាស់ ។

ស៊ុនគួនថា: ខ្ញុំនេះ រក្សាសេចក្តីសត្យានុស័ត្យ មិនបានគិត

អាក្រក់ដល់ស្រុកសៃឈ្នួនទេ គ្រាន់ហើយក៏ទ្រង់យកព្រួញជួមកកាច់បំបាក់ជា៤កំណាត់ ហើយស្បថថា បើយើងមានចិត្តគិតអាក្រក់ដល់ស្រុក សៃឈ្នួន សុំឲ្យខ្លួនទឹងកូនចៅរបស់យើងទាំងអស់បានសេចក្តីអន្តរាយដូចជាព្រួញធ្នូនេះចុះ លុះថាហើយក៏ទ្រង់ចាត់ចែងបណ្ណាការទ្រព្យរបស់តាមសមគួរឲ្យបំរើនាំទៅសែនខុនបេង, ចង់អ៊ុកថ្វាយបង្គំលា នាំពរបំរើស៊ុនគួនទឹងរបស់ទ្រព្យទៅសែនសតខុនបេង, លុះទៅដល់ស្រុកសៃឈ្នួនហើយក៏ចូលទៅគាល់ព្រះចៅឡាសៀន ក្រាបទូលស្តេចតាមដំណើរគ្រប់ប្រការ, ព្រះចៅឡាសៀនបានទ្រង់ជ្រាបក៏មានព្រះទ័យសោមនស្សត្រេកអរណាស់ គ្រាន់ឲ្យយកព្រះពរទ្រព្យមកប្រគានចង់អ៊ុជាប់ណាប់រង្វាន់ ហើយព្រះពរទាំងអ្នកបំរើស្រុកតាំងតាំងក៏ថ្វាយបង្គំលាវិលទៅស្រុកវិញ ។

ព្រះចៅឡាសៀន ក៏តាំងចៅអ៊ីនឲ្យលឿនទីជាមហាឧបពរាជតាមបង្គាប់ខុនបេង, តាំងប៊ីហ៊ុយជាកូឈួយពរាជការមហាឧបពរាជ, តាំងង៉ាអ៊ុជានាយទាហានធំ គ្រួតពរាជការខាងស្រុកហាន់តុង, តាំងកៀងអ៊ុយជានាម៉ឺនធំសម្រាប់បង្គាប់បញ្ជាលើនាយទាហានចេញធ្វើការសង្គ្រាម និងនាម៉ឺនទាំងពួងឲ្យទៅតាមលំដាប់, ង៉ាអ៊ុនឹងកៀងអ៊ុយ កាត្រាបថ្វាយបង្គំលាចេញទៅឈរស្រុកហាន់តុង, ឯអៀវធីលុះទៅដល់ផ្ទះក៏មានសេចក្តីត្អូចត្អួច ព្រោះដឹងថា ព្រះចៅឡាសៀន តាំងចៅអ៊ីនជា

មហាឧបាសជនោះ កំនិយាយនិងប៊ីហ៊ុយថា : កាលខ្ញុំបងខ្ញែប
អនិច្ចកម្ម ចានប្រគល់គ្រាសម្រាប់ទីមហាឧបាសជឲ្យយើងខ្ញុក បើជា
យើងនឹងប្រែចិត្តគិតទៅនៅខាងបួយ៉ាយវិញ កំប្រហែលជាចានសេចក្តីសុខ
គឺថាមិនចានទៅក្រោមបង្គាប់ចៅអ្នន ប៊ីហ៊ុយមិនឆ្លើយតបថាម្តេចសោះ
លុះព្រឹកឡើង កំចូលទៅក្រាបទូលព្រះចៅឡាសៀនតាមពាក្យអៀនធី
និយាយនោះគ្រប់ប្រការ ។

ព្រះចៅឡាសៀនចានទ្រង់ជ្រាប កំទ្រង់ព្រះពិរោធខ្លាំងតាំងឲ្យ
ហៅខ្ញុនអៀនធីទៅសួរ អៀនធីកំទទួលសារភាពជាស័ត្យ ព្រះចៅ
ឡាសៀនឲ្យយកខ្ញុនអៀនធីទៅប្រហារជីវិត ចៅអ្នុនចានទទួលសុំព្រះ
ពជាតនទោសថា ពីដើមអៀនធីនេះចានធ្វើសេចក្តីតាប់ប្រសើរក្នុងពជ
ការមកជាច្រើនគ្រា នោះអៀនធីទើបមកបរចាក្ងាត់ក្ងាំងប៉ុណ្ណោះ ទូល
ព្រះបង្គំជាខ្ញុំសូមព្រះពជាតនឲ្យគង់អាយុជីវិត តែសូមឲ្យគ្រាន់តែដក
ហូតងារចេញពីពជការបុះ ព្រះចៅឡាសៀនកំព្រមពជានុញ្ញាតហើយ
ឲ្យដកហូតងារអៀនធីជាពស្តូ បណ្តេញឲ្យទៅនៅស្រុកតែគុន ដែល
ត្រូវឡើងស្រុកហាន់តុង អៀនធីមានសេចក្តីតូចចិត្ត ទឹងអ៊ប្បាយសដល់
អស់បណ្តាពស្តូអ្នកស្រុក កំអារកស្ងាប់ទៅ ។

សាមកុកខ្សែ ៨០

តាំងពីព្រះចៅចួយ័យឲ្យសាងប្រាសាទរាជវាំងក្នុងក្រុងឡុកអៀង ព្រះចៅចួយ័យសម្លាប់នាងម៉ីសីនហេសី តាំងនាងកោយហ៊ុយយីនជាមហេសី សុម៉ាអ៊ីលើកទ័ពទៅវាយស្រុកសៀវតាំង សុម៉ាអ៊ីមានជ័យជំនះឈ្នះវិលមកវិញ, ព្រះចៅចួយ័យប្រឈួនធ្ងន់ សោយទីវង្គត, ព្រះចៅចោហងសោយរាជ្យព្រះជន្ម ៨ វស្សា ចោសងដំនួយរាជការផៃនដី, ចោសងឡើងអំណាច សុម៉ាអ៊ីក្បែងធ្វើឈឺ, សុម៉ាអ៊ីឲ្យចាប់ចោសងនិងបងប្អូនសម្លាប់ ព្រមតាំងប័ក្ខពួកផៃលក្បត់ ១.០០០ នាក់ ។

ឯណានោះ ព្រះចៅឡាសៀនសោយរាជសម្បត្តិកន្លងក្រុងសៃឈួនបាន១៣ឆ្នាំ, ព្រះចៅស៊ិនគួនសោយរាជ្យក្នុងស្រុកកាំងតាំងបាន១ ឆ្នាំ ព្រះចៅចួយ័យសោយរាជ្យក្នុងក្រុងឡុកអៀងបាន ៤ ឆ្នាំ (ព.ស.៧៧៩) តាំងពីស្រុកនោះក៏មិនបានធ្វើសឹកសង្គ្រាមនឹងគ្នាជាយូរឆ្នាំ, អាណាប្រជានុរាស្ត្រតាំងពួង ក៏បានសេចក្តីសុខសប្បាយ, គ្រាកាលព្រះចៅចួយ័យលើកទ័ពត្រឡប់ពីស្រុកហាប់ចា" ទៅប្រថាប់នៅស្រុកហ៊ូតោ ទើបតាំងសុម៉ាអ៊ីជាទីមហាឧបពាជ ហើយឲ្យលើកទៅមើលត្រួតត្រាក្សាបន្ទាយត្រប់ទីតយដំបន់ ហើយសុម៉ាអ៊ីត្រឡប់ទៅស្រុកឡុកអៀង ។

ព្រះចៅចួយ័យក៏ឲ្យ សាងប្រាសាទពាជវាំងក្នុងក្រុងហ៊ូតោ ហើយតាំងម៉ាគិនជាមេកង ឆាំមេជាង ៣០.០០០នាក់ ទំាងភូនជាងសម្រាប់ប្រើធ្វើការ ៣០ម៉ឺនទៅសាងប្រាសាទថ្មី ទំាងជួសជុលបន្ថយសើនកួរស្ថាមក្តោះកន្លងទីស្រុកឡុកអៀង; ហើយឲ្យធ្វើប្រាសាទមួយខ្នង ៦០

ឮថា (៤៤ម៉ែត្រ) នោះម៉ាតិងក៏នាំមេជាង កូនជាងទៅធ្វើការនៅ
ស្រុកឡុកអៀង ។ តាំងសឹមជានាម៉ឺនបើញ្ញាមនុស្សពាំងពួងឃ្លាន់សេចក្តី
លំបាកណាស់ ក៏ទូលព្រះចៅចួយ៉ាយ ថា: ដែលនឹងធ្វើការបង្អែបង្អង់ឲ្យ
យូរដូច្នេះ ទូលព្រះបង្គំជាខ្ញុំយើញថា ពួកជាងទាំងអម្បាលណោះបាន
ប្រការមួយទៀត បារម្ភខ្លាចក្រែងសត្រូវដឹងនឹងលបលើកទ័ពសម្រុក
មក យើញថាស្រុកយើងនឹងប្រមូលពលមហាន់ច្បាងមិនទាន់ ក៏នឹង
ថ្លង់ការដល់សត្រូវទៅ ត្រូវតែបង្អង់ធ្វើការសិន ដើម្បីនឹងបំរុងពល
មហានរក្សាស្រុកទេសញ្ញស្រួលជាង ប្រសិនណាជាមានពលភ្លាំងមក
វេលាណា នឹងប្រមូលគ្នាមាន់ការ ។

ព្រះចៅចួយ៉ាយទ្រង់ព្រះសណ្តាប់ដូច្នោះ ក៏ទ្រង់ខ្លាល់ខ្លាំងណាស់
តែពុំបានត្រាស់តបប្រការម្តេច អស់នាម៉ឺនពាំងពួង ដែលស្តាប់តាំងសឹម
ពាំងប៉ុន្មាន ក៏នាំគ្នាទូលញុះញង់ នឹងឲ្យស្តាប់តាំងសឹមចេញ ទើប
ព្រះចៅចួយ៉ាយតបថា តាំងសឹមនេះជានាម៉ឺនចាស់ពុំ មានសេចក្តីគាប់
ប្រសើរច្រើន ដែលនឹងសម្លាប់ចេញនោះមិនគួរទេ វេលានោះព្រះចៅ
ចួយ៉ាយឲ្យដកហូតងារតាំងសឹមចេញពីរាជការហើយត្រាស់ថា បើតទៅ
មុខនរណានឹងទូលរំលុក ជាការខ្ញុំនឹងសម្លាប់មិនឲ្យកសាងស្រុកឡុកអៀង
ទៀត នឹងឲ្យកាត់ក្បាលចេញ ទៀរបើយើញអស់បណ្តាពស្តុបាន

សេចក្តីលំបាកណាស់ កំពូលឃាត់ព្រះពៅចូយ័យថា សូមកុំឲ្យសាង
ស្រុកឡុកអៀងឡើយ នោះព្រះពៅចូយ័យ ក៏ឲ្យយកខ្នងទៀកៅ
សម្លាប់ជីវិតចង់ ហើយលើកទៅនៅស្រុកឡុកអៀង ទើបឲ្យហៅខ្លួន
ម៉ាគិនទៅសួរថា : យើងចង់ឲ្យសាងប្រាសាទខ្ពស់ជាងមុនទៅទៀត
ប្រាថ្នាខឹងសុំទៅគាឲ្យបានថ្មាំទិព្វយកមកផឹក ឲ្យបានចំរើនអាយុឲ្យវែង។

ម៉ាគិនក៏ពូលថា : ឥតាលគ្រាព្រះពៅហាន់ប៊ូតេទ្រង់ជក សាង
ប្រាសាទខ្ពស់ ១៣ត្បាម (៦៤ម៉ែត្រ) ហើយយកមាសឆ្អិនទៅ
ស្រោបរូបមនុស្សមានដៃសួយថាស ឆេងកសទៀម ទៅកំពូលសសរ
ប្រាសាទ មាសនោះភ្លុះទៅលើដំបូលទើបសន្ធតថាជា ខឹកសួកម្រឹត
យកមកលាយថ្នាំសោយជានិច្ច ប្រាថ្នាខឹងឲ្យដាក់ឡោះឡើងវិញ នោះ
ព្រះពៅហាន់ប៊ូតេក៏មានព្រះជន្មវិសាយីនវែង , ព្រះពៅចូយ័យមាន
ព្រះទ័យត្រេកអរណាស់ ព្រោះត្រូវនឹងចំណង់ដែលចង់ឲ្យព្រះជន្មបានវែង
ទើបគ្រាស់បង្គាប់ឲ្យម៉ាគិនទាល ១០ ០០០ ទៅនាំរូបមនុស្សដែលធ្វើ
ដោយមាសឆ្អិនពីស្រុកខៀងអាន់ យកមក , លុះម៉ាគិនបានទៅដល់
ស្រុកខៀងអាន់ហើយក៏ឲ្យធ្វើជាកន្ទបចង់យោងឡើងទៅ , ហើយចងរូប
មាសនោះ សំពៅតុះមកតាមទន្លេ លុះរូបនោះចុះមកដល់កំពង់ផែនដី
ហើយ ក៏ឃើញមានខឹកក្អែកហូរចេញមកពីក្នែកចាំងសង្ឃាធ ស្រាប់តែ

បង្កើតមេឃដ៏ធំតដ៏តគ្រប់ទិសា ធ្លាក់ខ្សល់ព្យុះសង្ឃរា អសនីផ្គរបាញ់ ច្រាសកំពូលច្រាសាទដ៏សសរមាសនោះ ចាក់ធ្លាក់ចុះមកសង្កត់លើ ពួកពលពាហនដែលទៅធ្វើការ នោះស្លាប់អស់ជាង ១០០ ចំាយ នាក់, ទើបម៉ាគិនឲ្យយករូបមនុស្ស ដាក់លើបញ្ជាអូសនាំយកទៅថ្វាយ ព្រះចៅចូយ័យ ហើយទូលតាមរឿងដែលមានអស្ចារ្យនោះ គ្រប់ប្រការ ទើប ព្រះចៅចូយ័យសួរថា : សសរមាសដែលចាក់ធ្លាក់ចុះមកនោះ ទៅឯណា? ម៉ាគិនទូលថា : សសរមាសនោះធ្ងន់ជាង ១០០ម៉ឺនជញ្ជីង ប៉ើនឯអូសនាំមកឃើញថាមិនបាន ។

ព្រះចៅចូយ័យក៏ឲ្យម៉ាគិនទាំពលវិលទៅលើកសសរ មាសនោះ នាំយកមកបាន ហើយឲ្យសិតរូបមនុស្ស ៤នាក់ ឲ្យឈ្មោះហង្តុង ហើយឲ្យយកទៅតាំងទុកនៅប្រាសាទរ៉ាង ដែលឈ្មោះសុម៉ា រួចឲ្យធ្វើ រូបហង្ស ១ , រូបមករ ១ យកទៅតាំងទុកនៅមុខប្រាសាទ ហើយឲ្យ សាងសួនច្បារដើស្អាតក្នុងព្រះពជរាំង តាំងដាំដើមឈើ ដែលមានផ្កាផ្លែ រឿងហគ្គាជាលំដាប់ច្រើនណាស់ ទើបគ្រាស់ឲ្យចាប់យក សត្វម្ឹគ បក្សី គឺប្រើសត្រាយ ទន្សាយ ទន្សោង ខ្លាឃ្លា រមាំង រមាស ឈ្លូស ក្តាន់ដាដើម មកចិញ្ចឹមទុកក្នុងសួន ឯរូបមនុស្សដែលនាំមកពីស្រុក ខ្មែរអាន់នោះ ក៏ឲ្យតាំងទុកក្នុងសួនសម្រាប់ទុកមើលលេង ទើបឲ្យតាក់

តែងរើសរកស្ត្រីរូបល្អ យកមកទៅលើដំណាក់ច្រើនណាស់ ហើយ
គ្រាស់បង្គាប់ឲ្យម៉ាតិង ត្រួតត្រាលើមេជាង ឲ្យបង្ខំធ្វើប្រាសាទនោះឲ្យ
ហើយជាប្រញាប់ ។

លោះនោះអស់នាម៉ឺនសព្វមុខមន្ត្រី ក៏សឹងតែស្រដីទូលទាស់កុំឲ្យ
ធ្វើប្រាសាទតែគ្រប់ៗគ្នា, ព្រះចៅចួយ៉ីយក៏មិនស្តាប់ ម៉ាតិងក៏បង្ខំត្រួត
ត្រាលើមេជាងរៀងរាល់ថ្ងៃតាមព្រះតម្រាស់, លោះនោះព្រះចៅចួយ៉ីយ
មានព្រះមហេសីឈ្មោះនាងម៉ីសី ចាន់ទៅរួមប្រពៃណីតាំងពីព្រះចៅចួកី
ជាបិតា, ឯក្រោយព្រះចៅចួយ៉ីយមានព្រះស្នំម្នាក់ទៀត ឈ្មោះកោយ-
ហ៊ុយយិន ព្រះចៅចួយ៉ីយសព្វព្រះទ័យច្រើនជាង លើកជាព្រះ
មហេសី ដោយការបំរើបំពាក់មិនខាស់អធ្យាស្រ័យនោះ លោះនោះ
ស្តេចក៏ទៅរួមព្រះបន្ទំតែនឹងនាងកោយហ៊ុយយិន មិនចាន់ចេញទៅដោយ
ពាក្យការប្រហែល ១ ខែចាយ ។

លុះដល់ខែពិសាខឆ្នាំកោនឆ្នូស័ក ជាទសកាលផ្កាឈើកែល្អ
ទើបព្រះចៅចួយ៉ីយ៉ី នាំនាងកោយហ៊ុយយិនចុះទៅ ក្រសាលកណ្តាលទី
សួនផ្កា ហើយសោយសុរាជាមួយគ្នា នាងកោយហ៊ុយយិនទូលថា :
ហេតុអ្វីព្រះអង្គមិនទ្រង់ឲ្យអញ្ជើញព្រះមហេសីមក សេពសុរាផង? ព្រះ
ចៅចួយ៉ីយគ្រាស់តបថា : បើនឹងចង់ឲ្យនាងម៉ីសីមកផងនោះ មុខជា

យើងនឹងផឹកសុកមិនចូលចំពង់កទេ ហើយហាមស្រីចំរើតាំងពួងមិនឲ្យនាំតតិមាន ទៅច្រាប់មហេសីថា: ស្តេចនាំនាង កោយ ហ៊ុយយិន ទៅក្រសាលសួន រៀលនោះស្តេចឲ្យពួកស្រីចំរើច្រៀងខ្ទង់ព្រះសណ្តាប់ ។

ឯនាងម៉ីសីមហេសីមិនបានឃើញព្រះស្វាមីស្តេចទៅដួចដល់ ១ ខែ ជ្រាយក៏មិនសប្បាយចិត្តសោះ, ក្នុងថ្ងៃនោះក៏មិនបានដឹងថាស្តេចយាង ទៅក្រសាលសួនច្បារ នាងម៉ីសីក៏នាំចណ្តាស្រីចំរើទៅប្រមាណ ១២ នាក់ ឡើងទៅលើដំណាក់ស៊ុយហ៊ួទៅច្រាច្នាន់ឲ្យសប្បាយចិត្ត ទទួលបានឮសំឡេងចម្រៀងក៏សួរទៅនាងចាំទ្វារក្សាដំណាក់ថា: សំឡេងចម្រៀងពីណា ? ពួកស្រីនោះទូលថា: មហាក្សត្រិយ៍ស្តេចនាំនាងកោយ ហ៊ុយយិន ទៅក្រសាលសួនច្បារ មាននាងស្រីគ្នាច្រៀងថ្វាយព្រះសណ្តាប់ ព្រះនាងម៉ីសីបានឮដូច្នោះក៏រឹតតែព្រះឫទ័យខ្មោមនស្សពន់ប្រមាណ ទើបនាំស្រី ។ សៅឡើកតាំងប៉ុន្មានត្រឡប់ទៅកាន់ព្រះដំណាក់ដើមវិញ ។

លុះព្រឹកព្រាងស្ងាងព្រះមុរិយា ព្រះនាងម៉ីសីក៏ដើរយាត្រាទៅតាមថ្នល់ក្នុងព្រះពជកំង ចន្លោះព្រះដំណាក់តាំង ២ ក៏ជួបប្រទះនឹងព្រះកស្តាព្រះនាងសើចហើយទូលថា: កាលពីមុំលែមិញព្រះអង្គយាងប្រពាតសួនផ្កា ខ្ញុំម្ចាស់យល់ថាសមព្រះអង្គបានកក្ខន្ធសប្បាយក្នុងព្រះទ័យណាស់ ព្រះចៅភូយ៉ីយឮដូច្នោះក៏ខ្ញែងព្រះក្រោធខ្លាំងណាស់ ត្រាស់បង្គាប់ ១ ន្តីឲ្យចាប់ពួកស្រី ។ ដែលរក្សាព្រះដំណាក់ទិងរក្សាសួនមកដណ្តើងសួរយកការ

ថា ឥឡូវលិមិញអញបានកំដាប់ហាមប្រាម ហេតុម្តេចបានជាអស់ឯងពុំ
គោតខ្លាចនាំរឿងទៅទូលព្រះមហេសីឲ្យជ្រាប ទើបបង្គាប់ទ្វីឲ្យបញ្ឆេះ
ពួកស្រីទាំងនោះទៅឲ្យពេញមួយឃានាំទៅសម្លាប់ ព្រះនាងម៉ាសីឮដូច្នេះ
ក៏ស្តុតព្រះទ័យវិលវៃទៅកាន់ព្រះដំណាក់វិញ ។

ឯព្រះចៅចូយ៉ាយក៏ទ្រង់ទ្រាល់ទឹងមហេសីខ្លាំងណាស់ ទើបប្រគល់
ក្រមីនិងសុភលាយថ្នាំ ហើយនិងព្រៃវៀសម្រាប់ចងរឹតឲ្យទ្វីហើយ
ត្រាស់បង្គាប់ថា : នាងម៉ាសីមហេសីមានទោសទុសជាទម្ងន់ណាស់ ចូរ
យកប្រជាប់ទាំង ៣ មុខទៅធ្វើទោសតាមទោសដោយគួរនឹងរបស់ឯណា
ទ្វីក៏ទទួលយកប្រជាប់ទាំងអស់នោះធ្វើទោស ព្រះមហេសីដល់ទ្វីវិសេចក្តី
ស្លាប់, នោះព្រះចៅចូយ៉ាយក៏តាំងនាងកោយហ៊ុយយិនជាមហេសី ។

លុះកន្លងយូរមក មានសំបុត្រប៊ូយីវ៉ៃមកចៅហ្វាយស្រុកអ៊ីដើរមក
ចូលមកទូលព្រះចៅចូយ៉ាយថា : កងស៊ុនអៀនជាបុត្រកងស៊ុនខងចៅ-
ហ្វាយស្រុកសៀវតាំងគិតក្បត់ លើកខ្លួនជាម្ចាស់អៀនអង តាំងតែង
នាម៉ឺនមុខមន្ត្រីជាច្រើន, ហើយឲ្យសាងរៀងកាំងបន្ទាយគួរសើនកាន់ទុក
ម៉ាំមួនម៉ាំណាស់ ហើយហាត់សមពលសាហានបានចំនួន ១០០ម៉ឺន និង
លើកទៅវាយយកស្រុកឡុកអៀងព្រះចៅចូយ៉ាយឮកិត្តិសព្ទ ក៏ញាប់ញ័រកែត
ក័យតក្កមាត្រាស់ហៅសុម៉ាអ៊ីចូលទៅប្រឹក្សាដួបជុំ នឹងបណ្តានាម៉ឺនតាំងពួង
ទើបសុម៉ាអ៊ីទូលថា : ដែលកងស៊ុនអៀនមានចិត្តកំរើបគិតក្បត់នឹងព្រះ

អង្គនោះ ទូលព្រះបង្គំជាខ្ញុំនឹងសុំអាសានាំពល ៤០.០០០ ក្នុងស្ត្រុកចក្ក ពួករបស់ទូលព្រះបង្គំ ជាខ្ញុំចេញទៅវាយយកស្រុកសៀរតាំងយកខ្លួនកង ស៊ីនអៀនឲ្យត្រាតែបាន ។

ព្រះចៅចូយ៉ាយត្រាស់ថា : ដែលអ្នកនឹងទូលអាសានោះ យើងគាប់ចិត្តណាស់ តែដែលអ្នកនឹងទៅនោះ យើងឃើញថាគាហានក៏តិចផ្លូវក៏ឆ្ងាយជាច់ស្រយាល ខ្លាចក្រែងមិនបានពរជាវគេដឹង ? សុម៉ាអ៊ីទូលថា : ឯការសង្គ្រាមនោះមិនមែនមានគាហានច្រើនទើបបានជ័យជំនះនោះទេ, ដែលទូលព្រះបង្គំនឹងលើកពលទៅនោះ ទោះជាពលគាហានតិច ក៏នឹងសុំធ្វើដោយគំនិតជាឧបាយផ្តល់និងព្រះបារមីនៃព្រះអង្គជួយទ្រទ្រង់ជាទីពឹងពំនាក់ មុខជាមានជ័យដំនះដល់សត្រូវជាប្រាកដ ។

ទើបព្រះចៅចូយ៉ាយសួរថា : អ្នកនឹងគ្នេរឃើញថាកង៏ស៊ីនអៀនមុខជានឹងរិះគិតឆ្លាំងតទៅទៀតឬប្រការម្តេច ! សុម៉ាអ៊ីទូលថា : បើប្រសិនកង៏ស៊ីនអៀនចេញស្រុកចង់ ហើយរត់ទៅលាក់ខ្លួនជួនជ្រកនៅក្នុងព្រៃ បើនឹងលើកតាមក៏ជាការលំបាកព្រោះមិនស្គាត់ផ្លូវ ១នេះឃើញថាកង៏ស៊ីនអៀនគិតការសឹកជាឯកតែម្តង ១មួយទៀតបើកង៏ស៊ីនអៀនលើកចេញមកតាំងបន្ទាយនៅមុខស្រុកសៀរតាំងវិញ ជាសេចក្តីគិតយ៉ាងនោះ, ១មួយទៀត បើកង៏ស៊ីនអៀនលើកទៅតាំង នៅស្រុកសៀរចេ៏ងជាព្រំប្រទល់ដែនវិញ ក៏ជាសេចក្តីគិតយ៉ាងត្រឹម មុខជានឹងចាប់ខ្លួនកង៏ស៊ីន

អៀនបានយ៉ាងដាយ ។

ព្រះចៅចូយ៉ាយសួរថា: អ្នកទឹងចំពាលើកទៅគ្រានោះ ទឹងឲ្យយូរប្រហែលប្រការយ៉ាងម្តេច សុម៉ាអ៊ីក្រាបទូលថា: ឯផ្លូវទឹងទៅស្រុកសៀវតាំងនោះ ធ្វើយជាច់អាល័យណាស់ ទូលព្រះបង្គំជាខ្ញុំគ្រេផ្លូវទៀង ទៅ បើដើរឲ្យដល់ ១ ១០០ ថ្ងៃ បើទឹងរៀសត្រង្គ្រាមក៏អស់ ១០០ ថ្ងៃ ទឹងត្រឡប់មកក៏អស់ ១០០ ថ្ងៃ ដូចគ្នា ទឹងឈប់សម្រាកទាំងទៅទាំងមកអស់ ៦០ ថ្ងៃទៀត គំរប់ ១ ឆ្នាំទើបត្រឡប់មកដល់ទីក្រុងវិញ ព្រះចៅចូយ៉ាយថា: បើអ្នកទៅយូរដល់ ១ ឆ្នាំដូច្នេះ ចុះបើកងចំពាស្រុកសៃលួន ឬស្រុកកាំងតាំងលើកមកធ្វើអន្តរាយស្រុកយើង តើអ្នកទឹងធ្វើប្រការម្តេច សុម៉ាអ៊ីក្រាបទូលថា: សុំកុំឲ្យព្រះអង្គទ្រង់ព្រះតក្កាឡើយ ជាភ្នាក់ងារទូលព្រះបង្គំហើយអាចទឹងរំងាប់ ចាត់ទាហានឲ្យទៅត្រួតត្រាការពារស្រុកជាស្រេច ព្រះចៅចូយ៉ាយមានព្រះទ័យត្រេកអរណាស់ ត្រាស់ថា បើដូច្នោះអ្នកទឹងទៅចុះ សុម៉ាអ៊ីក៏ថ្វាយបង្គំលាចេញទៅចាត់ពលយោធាក្នុងបុរីក្នុងពួកបាន ៤០.០០០ ឲ្យហោដុនជាមេកងទ័ពមុខ លុះបានឫក្សមង្គលសុម៉ាអ៊ីក៏លើកពលចេញចាកស្រុកឡុកអៀង ដើម្បីទឹងកន្ទុំទៅកាយស្រុកសៀវតាំង ។

វេលានោះពួកលក្ខតជឹងការកំនាំពតិមានទៅជ្រាបកងស៊ុនអៀនថា សុម៉ាអ៊ីលើកទ័ពមកទឹងធ្វើអន្តរាយស្រុកយើងហើយ កងស៊ុនអៀនថា សុម៉ាអ៊ីលើកទ័ពមកទឹងធ្វើអន្តរាយស្រុកយើងហើយ កងស៊ុនអៀនសួ

ដូច្នោះកំចាត់ប្រើប៊ីអៀនទិងអៀវចឲ្យទាំពល ៨០.០០០ ចេញទៅកាំងខាំង
ខ័ពសុម៉ាអ៊ីនៅដំបន់លៀវស៊ុន ផុតដែនស្រុកសៀងប៉ោង, ប៊ីអៀនទិង
អៀវចកំលើកទៅដល់ ទើបឲ្យតាំងចន្លាយយ៉ាងមាំដំដល់ ២០០ សិន
(៨.គ.ម.) ហើយឲ្យដឹកគូស្នាមក្លោះខាំងប៉ាំងកំពែងយ៉ាងមាំមួន ។

ឯហោកុនមេកងខ័ពមុខនោះ លុះលើកខ័ពទៅដល់ទល់គ្នា ក៏ឲ្យ
ចំរើសេះម្ខីម្នាទៅច្រាប់សុម៉ាអ៊ី ។ ក៏ប្រកាន់ទិងបណ្តោយតាហានតាំងពួង
ថា : ដែលកងស៊ុនឲ្យលើកតាហានទៅតាំងទប់ខ័ពនៅដំបន់លៀវស៊ុន
នោះ ច្រកថ្នាំងក្លែងទប់ទុកឲ្យយូរ ដើម្បីឲ្យកងខ័ពយើងជាប់ស្បៀង
អាហារ ឯពលយោធាដែលចេញមកនៅទីនោះ យើញថាច្រើនជាកង
ខ័ពយើងច្រើនតាគ យើងត្រូវលើកព័ទ្ធចូលទៅវាយយកស្រុកសៀងប៉ោង
ជាទីដែនគយព្រំប្រទល់ឲ្យបានសិនសន្សឹមគិតការតទៅ នរណាទិងយល់
យើញប្រការម្តេចខ្លះ អស់នាយតាហានកំយល់យើញតាម ទើបសុម៉ា-
អ៊ីឲ្យលើកខ័ពវាងព័ទ្ធផ្លូវទៅទិសខាងត្បូង ។

ឯប៊ីអៀនទិងអៀវចក៏ប្រឹក្សាគ្នាថា : កាលខុងចេងលើកខ័ពទៅតាំង
នៅទីកំគីសាន, សុម៉ាអ៊ីក្លែងខាំងទប់ចម្បាប់មិនឲ្យចេញចំរ្វាងតាល់តែ
ខុងចេងស្លាប់ តម្បាកងខ័ពសុម៉ាអ៊ីលើកមកគ្រានេះផ្លូវឆ្ងាយដល់ ១០ ម៉ឺន
សិន (៤០.០០០គ.ម.) យើងត្រូវតែកាំងទប់ឲ្យខ្ជាប់កុំប្រញាប់ចេញចំរ្វាងទិង
សុម៉ាអ៊ីឡើយ ។ បើសុម៉ាអ៊ីជាប់ស្បៀងហើយ តពិទិងលើកខ័ពថយទៅ

ឯង សឹមយើងលើកគាហានច្រដែងដេញក់យពីក្រោយកុំឲ្យតេ៉ាទៅបាន
មុខជាចាប់ខ្លួនសុ៊ាអ៊ីបានមិនបាន ទទួលចំរើសេះមកច្បាប់ថា : ទ័ព
សុ៊ាអ៊ីលើកតាមក្រោយតម្រង់ទៅទីឆកយយកស្រុកសៀងប៉ោង, ប៊ីអឿនមាន
សេចក្តីគិតក័យពន់ច្រមាណាស់ ទើបប្រឹក្សានឹងអៀវថា : សុ៊ាអ៊ី
លើកទ័ពទៅនោះព្រោះគិតថាគាហានក្តងស្រុកសៀងប៉ោងតិច បើដូច្នេះ
យើងនឹងតាំងនៅទីនេះមិនស្រួលទេ ត្រូវតែថយចូលទៅជួយគ្នាទើបបាន
អៀវចយល់ត្រូវផង កំលើកទ័ពត្រឡប់ចូលទៅ ។

បម្រើសេះឃើញដូច្នោះក៏ទៅច្បាប់សុ៊ាអ៊ីថា : ឥឡូវប៊ីអឿននឹង
អៀវចលើកទ័ពថយចូលទៅនឹងជួយស្រុកសៀងប៉ោងហើយ, សុ៊ាអ៊ីឮ
ដូច្នោះក៏អស់សំណើចហើយថា : ដែលប៊ីអៀវចថយចូលទៅនោះ មុខ
ជាបានការតាមគំនិតយើងគិត, ទើបបង្គាប់ហៃហ៊ូប៉ា និងហៃហ៊ូហ៊ុយ
ឲ្យនាំពលទៅបង្កប់ស្កាត់ទៅក្បែរមោត់ទន្លេចស៊ុយ បើឃើញកងទ័ព
សៀវតាំងថយចូលទៅវិញ ត្រូវឲ្យបរពលចេញចោមកេមប្រសព្វយក
ជ័យជំនះបាន, ហៃហ៊ូប៉ា និងហៃហ៊ូហ៊ុយ ក៏លើកពលចេញពួនបង្កប់,
លុះឃើញប៊ីអឿន, អៀវចលើកទ័ពមកក៏ឲ្យអុជផាវសញ្ញាឡើង, ហើយ
ហៃហ៊ូប៉ា ហៃហ៊ូហ៊ុយ ក៏បរពលចូលក្រលុកប្រសព្វមុខចូលមក ឯប៊ី
អឿន អៀវចមិនគាន់ដឹងខ្លួនសោះ ក៏ផ្ទាស់ការនាំពលយោធាពាក់កណ្តាល
តេ៉ាចេញទៅទិសឧត្តរ ស្រាប់តែច្រទះនឹងកងស៊ុនអឿនលើកគាហានចេញ

មកតាមច្រកភ្នំស៊ីវសាន ប៊ីអៀន អៀវចក៏ពណិទាសេចក្តីតាំងពួនឲ្យ
ស្តាប់ហើយនាំកងស៊ុនអៀនវិលត្រឡប់ទៅដល់មាត់ទន្លេចស៊ុន ទើបប៊ី
អៀនចរសេះចេញទៅឈរមុខទាហាន ហើយស្រែកថា : ពើយអាពួក
សត្រូវ អាឯងកុំគិតកលឃឹកខុកឲ្យយូរគោ ត្រូវបង្ហោញកត្តាមកតចំឡាង
ទឹងអញឲ្យពេញកម្ងាំងទឹងមើលថ្លៃដៃគ្នា ។

ហៃហ៊ីប៉ាពុដូច្នោះ ក៏ខឹងណាស់ ឡើងសេះកាំងជាវចេញទៅចំឡាង
ទឹងប៊ីអៀនបាន ៣ ក្មេង ហៃហ៊ីប៉ាកាប់ប៊ីអៀនធ្លាក់ពីលើសេះស្លាប់
ហើយដេញកាប់ពលរេហ៍វិនាសស្លាប់ច្រើនណាស់ កងស៊ុនអៀនឃើញ
ដូច្នោះក៏ខំទប់នោះពុំបាន នាំអៀវចទឹងពួកទាហានថយរត់ទៅចូលស្រុក
សៀងម៉ែង ហើយឲ្យបិទទ្វារស្រុកឯាត់ទាហានឲ្យត្រួតរក្សាសើនបន្ទាយ
ដោយមាំមួនពុំហ៊ានច្រហែសឆ្ងែស ខណៈនោះបម្រើល្បាតនាំហេតុទៅ
ច្រាប់សុម៉ាអ៊ី ។ បានដឹងសេចក្តីក៏ស្រួតលើកទ័ពចូលទៅតាំងបន្ទាយព័ទ្ធ
ស្រុកសៀងម៉ែង ។

វេលានោះជាទេសកាលវស្សានដូវ ភ្លាក់ភ្លៀងមកត្រូវតាំងយប់
តាំងថ្ងៃពេញ ១ ខែថ្ងាយ ទឹកក៏ជន់លិចផែនដីច្រហែលជាង ២ ហត្ថ
ស្បៀងអាហារវែលបង្ហានមកនោះក៏មិនដាច់ គ្រាន់តែប្រទះទឹកប្រទះ
គោកដរាប តែពលទាហានទឹងសេះក្នុងកងទ័ពសុម៉ាអ៊ីបានសេចក្តីលំបាក
វេទនាទឹងទឹកលិច ឈ្មោះពួយកេងសារវែត្រស្តាំ ទើបនាំសេចក្តីឡើង

ប្តឹងសុមាអ៊ុជាមេទ័ពធំថា ក្មៀងញុកដល់ ១ ខែហ្នឹងហើយនៅមិនទាន់កំណ អស់ទាំងរបស់ពលកំសឹងបានសេចក្តីលំបាកវេទនាទឹងទឹកលិចខ្លាំងណាស់ សូមឲ្យលើកទ័ពទៅតាំងនៅដើងក្នុ ទំរាំតែក្មៀងកំណវេលាណាសឹមគិតការតទៅ ។

សុមាអ៊ុបានស្តាប់ក៏ទឹងខ្លាំងណាស់ថា: យើងមកឡោមព័ទ្ធស្រុកសៀមប៉ែងទុក យើញមុខការចាប់ខ្លួនកងស៊ុនអៀនជិតបានហើយក្នុងពេលត្រឹកស្អែក ហេតុអ្វីខ្លួនមកនិយាយការកែឲ្យយឺតយូរការទៅវិញដូច្នេះ ហើយប្រកាសប្រាប់ដល់ពួកនាយទ័ពនាយកងទាំងពួងថា ឥឡូវនេះតទៅកុំឲ្យនរណាមកនិយាយដូចពួយកេនឡើយ, បើនរណាហើយមិនស្តាប់ យើងនឹងឲ្យកាត់ក្បាលចេញ ហើយដោតផ្ចាលនៅមុខបន្ទាយ ។

លុះវេលាព្រឹកឡើង, ឈ្មោះឈឺលឿនសារ៉ែត្រឆ្លង ក៏នាំសេចក្តីទៅឡើងប្តឹងដល់សុមាអ៊ុទៀតថា ខ្ញុំបានឃើញពាហានទាំងពួងបានសេចក្តីលំបាកណាស់ នឹងរកទីដេកទីអង្គុយគ្មានសោះ ព្រោះទឹកលិចអស់ឈរត្រាំនៅក្នុងទឹកទាំងយប់ទាំងថ្ងៃ, ដូច្នេះមិនស្លាប់អស់ហើយឬ, ទីដណ្តាំបាយបរិភោគក៏គេគ្មាន សុំប្រសាសន៍លើកទ័ពទៅកេទីទួលគោកនៅសិនបើក្មៀងស្រាកវេលាណាសឹមលើកពលយោធាមក ព័ទ្ធឡោមតាមដើមចុះ សុមាអ៊ុឮដូច្នេះក៏ទឹងទៀតថា : ខ្លួនយើងជាមេទ័ពគាន់អាជ្ញាសិទ្ធិ បានហាមាត់ហាមមុខហើយ ហេតុម្តេចបានជាខ្លួនមិនស្តាប់ បង្អាចកន្ទុងអាជ្ញាប្រាថ្នាទឹងឲ្យខូចការយើង, ទើបបង្គាប់ពាហានឲ្យចាប់ខ្លួនឈឺលឿន

យកទៅសម្លាប់ ហើយកាត់យកក្បាលទៅដោតផ្ចាលនៅមុខបន្ទាយ កុំឲ្យពលទាហានទាំងឡាយយកយឿងយ៉ាងតទៅ នោះពួកទាហានទាំងឡាយ យើញដូច្នោះក៏តែងខ្លាចអំណាចសុម៉ាអ៊ីមិនហ៊ានរឹងទទឹងទាស់ពីអ្វីសោះ ។

លុះកន្លងមកថ្ងៃ ១, សុម៉ាអ៊ីក៏លើកបន្ទាយដយទៅតាំងនៅឆ្ងាយអំពីកំពែងស្រុកប្រហែល ២០០ស៊ិន (៨គ.ម.) ចំណងនឹងឲ្យពួកអ្នកស្រុកសៀងប៉ើងនិងទាហានក្នុងស្រុកចេញមករកស៊ីនឹងបានបង្ការបង្ខាល, តាន់គុនមានសេចក្តីសង្ស័យក៏សួរសុម៉ាអ៊ីថា: ពីកាលគ្រាលោកលើកទ័ពទៅច្បាំងនឹងបេងតាត់នោះ លោកបែងទាហានចេញជាផ្លូវ លើកចេញទៅ ៣ថ្ងៃបានដល់ស្រុកសុងយ៉ុង ក៏គិតប្រុងចាប់យកខ្លួនបេងតាត់ឲ្យបាន លោកក៏មានសេចក្តីគាប់ប្រសើរច្រើនណាស់ គ្រានេះលោកលើកកងទ័ពមកមានពលត្រឹម ៤០.០០០ប៉ុណ្ណោះ, ផ្លូវក៏ឆ្ងាយដល់ ១០ម៉ឺនស៊ិន (៤០០០គ.ម.) ហេតុម្តេចបានជាលោកមកតាំងនៅស្ងៀម? មិនលើកសង្កត់ញញួលទៅរាយយកស្រុកឲ្យបានខ្ចុំបានយើញថាលោកភ្លែងមានពលរហ័ឲ្យតែបានសេចក្តីលំបាកទេ។ ឥតប្រយោជន៍សោះ, លោកមើលទៅចុះអស់ពួកពលទាំងអម្បាលម៉ានខ្ពុតលំបាកដោយទឹកភ្លៀងឡើងលិចផែនដីថែម ឥឡូវលោកត្រូវការអ្វីក៏ឲ្យថយទ័ពត្រឡប់មកចុះតិចម្ងាយទៅវិញដូច្នេះ, លោកចង់ឲ្យអ្នកស្រុកនឹងពួកពលសត្រូវចេញមករកស៊ីក្រៅបាន, ឲ្យមានកំឡាំងឬ ?

សុម៉ាអ៊ីឮដូច្នោះ ក៏អស់សំណើចហើយថា: កាលយើងលើកទ័ពទៅ

ច្បាំងឯស្រុកសុងយ៉ុងនោះអស់ពលរេហ៍យើងច្រើន តែស្បៀងអាហារ
តិចជាងគេ បានជាយើងស្រួតធ្វើការយកគរហ៊ាសួសរាន់ បានចាប់យក
ខ្លួនចេងតាត់បាន យើងលើកមកគ្រានេះ ឃើញថាខាហានកងស៊ុនអៀង
មានច្រើន តែស្បៀងអាហារខាងវាមានតិចជាងយើង បានជាយើងគិត
តែបង្អែបង្អង់ទុកមិនប្រញាប់ចេញច្បាំង, ដែលយើងលើកថយមកតាំងនៅ
ឲ្យឆ្ងាយពីស្រុកដូច្នោះ ព្រោះក្លែងឲ្យខាហានកងស៊ុនអៀនដែលអត់ឃ្លាន
គ្មានស្បៀងអាហារវេះចេញពីក្នុងស្រុកឲ្យអស់ទៅ បើកាលណាយើងនៅ
ឃើញថាកម្លាំងកងស៊ុនអៀនថយចុះហើយ យើងក៏បណ្តាយលើកទ័ព
សង្កត់ជាប់យូរយូរយកស្រុកតែម្តង ឲ្យចុះដោយស្រួល គង់មានទំនួល
នឹងចាប់ខ្លួនកងស៊ុនអៀនបានយ៉ាងងាយ, តាន់គុនឮសុម៉ាអ៊ុថាដូច្នោះក៏
ចុនគំនាប់ ហើយសរសើរថា ផ្លូវឧបាយរបស់លោក ដែលគិតយ៉ាងនេះ
វិសេសណាស់ សមគួរជាមេទ័ពធំចម្បងក្នុងទ័ពមែន ។ ។

សុម៉ាអ៊ីក៏ឲ្យពល ១ កងទៅសុំស្បៀងពីស្រុកឡុកអៀន ប្រាប់ថានឹង
ប្រាំពេញបង្ការទុកកុំឲ្យខ្វះខាត ខាហានទាំងអម្បាលណោះគំនាប់លា
សុម៉ាអ៊ូហើយក៏នាំគ្នាស្រួតចូលទៅដល់ក្រុងឡុកអៀង ហើយយកសេចក្តី
ប្តឹងដល់សេនាបតីជាមន្ត្រីធំ ។ តាមការ នោះអស់បណ្តានាម៉ឺនមុខមន្ត្រី
ចតុស្តម្ភក៏ជុំប្រឹក្សាគ្នាហើយយកសេចក្តីក្រាបពិតទូលព្រះចៅចូយ៉ុយថា :
សុម៉ាអ៊ីលើកកងទ័ពទៅវាយស្រុកសៀតាំងគ្រានេះជាទេសកាលរដូវក្តៅ
ខាហានខ្លះសេះក៏ស្បៀងតែមានសេចក្តីលំបាកវេទនា ដោយម៉ាសៃ[illegible]

ខ្ញាំងណាស់, វេលានេះឲ្យមនុស្សមកសុំស្បៀងថែមទៀត, ហេតុនេះ
សូមព្រះអង្គទ្រង់ឲ្យមានសំបុត្រទៅដល់សុម៉ាអ៊ី ឲ្យលើកទ័ពត្រឡប់ចូល
មកសិនបើដល់ទេសកាលខែប្រាំងកំង៉ុសវេលាណា សឹមលើកកងទ័ព
ទៅវាយយកស្រុកសៀវតាំងចុះ គង់ទឹងបាន, ព្រះចៅចូយ៉ុយទ្រង់ជ្រាប
ទើបត្រាស់ថា អស់អ្នកទាំងឡាយកុំព្រួយបារម្ភ, ឯសុម៉ាអ៊ីនោះគេជា
អ្នកមានសតិបញ្ញាមុតមាំណាស់ក្នុងវិទ្វាស់ខាងណាវគ្គសង្គ្រាម មិនហួរទេ
គង់ទឹងឮដំណឹងថាសុម៉ាអ៊ីទឹងមានជ័យជំនះកងស៊ុនអឿន ហើយក៏ត្រាស់
ឲ្យចាយស្បៀងប្រគល់ឲ្យបម្រើសុម៉ាអ៊ី ។

ឯសុម៉ាអ៊ីនោះ, លុះបម្រើចេញទៅសុំស្បៀងហើយ កន្ទុងមក ៣
ថ្ងៃពេលកណ្តាលយប់គ្មានភ្លឺងសោះ, សុម៉ាអ៊ីចេញទៅមើលឫក្សអាកាស
ឃើញឧក្កាបាតធ្លាក់មកពីទិសបូព៌ាឆ្ងៀងឧត្តរ ត្រង់កុំស៊ីសានទៅទិស
អគ្នេយ៍ក្បួតពលរហ័ក្នុងកងទ័ពឃើញថ្លុកក៏ភ័យជ្រួលចាំងអស់គ្នា សុម៉ា
អ៊ីឃាត់ហាមកុំឲ្យខ្លាចថា គឺហេតុចាំងនេះព្រោះទេពតាសម្តែងហេតុឲ្យ
ឃើញថា យើងទឹងមានជ័យជំនះ សត្រូវលែងពីនេះទៅទៀតស្រុក
សៀងប៉ើងទឹងបានមកក្នុងកណ្តាប់ដៃយើង ដែលមានឧក្កាបាតធ្លាក់ចុះ
ត្រង់ណា យើងទឹងបានសម្លាប់កងស៊ុនអឿនត្រង់នោះ, ព្រឹកនេះយើង
លើកចូលទៅធ្វើការវាយស្រុកសៀងប៉ើង ។

លុះវេលាព្រឹកឡើង, សុម៉ាអ៊ីក៏ឲ្យទាហានលើកចូលទៅឡោមព័ទ្ធ

ដុំវិញស្រុក ហើយឲ្យដង្ហែយកអាចម៍ដីទៅចាត់តរជាតំនូកខ្ពស់ឡើង ៤ ទិស, ហើយឲ្យឆ្លៀតឆ្អែងនិងដើងដណ្តើរព័ទ្ធក្លាប់ទៅលើកំពែងគ្រប់នាទី ឲ្យពលធ្វើបាញ់ចម្រុះ ចូលទៅក្នុងកំពែងបីដូចគ្រាប់ភ្លៀង នោះគាហានដែលនៅលើសើនបន្ទាយ ក៏បាញ់ចោះតគ្នាការពារទាំងយប់ទាំងថ្ងៃមិនឈប់ ។

ខណៈនោះ, ពួកគាហានស្រុកសៀមប៉ែងជាប់ស្បៀងអាហារ កងស៊ុនអៀនក៏ឲ្យសម្ងាប់គោតពៃចែកគ្នាស៊ីជំនួសបាយ បណ្តាពលគាហាននិងអ្នកស្រុកក៏បានសេចក្តីក្តៅក្រហាយលំបាកវេទនាខ្លាំងណាស់ ក៏ស្រុះស្រួលបបួលគ្នាថា គ្នាយើងអើយ វេលានេះយើងនឹងស្ងៀមទៅមិនបានទេ មុខជាឆ្លាយស្លាប់ទាំងអស់គ្នាជាអសារអត់ការ យើងត្រូវតែនាំគ្នាគាត់យកក្បាលកងស៊ុនអៀនទាំទៅឲ្យសុម៉ាអ៊ី ទើបនឹងរួចពីសេចក្តីស្លាប់ពល់គ្នា, កាលបណ្តាអ្នកស្រុកនឹងពួកគាហានទាំងពួងបបួលគ្នាដូច្នោះហើយ ក៏មិនបានខ្វាចកងស៊ុនអៀន ។ ដឹងដូច្នោះក៏ភ័យណាស់អស់គិតនឹងចង់ច្បាង, ទើបចាត់ប្រើអងកៀននឹងលីវហ៊ីចេញទៅនិយាយនឹងសុម៉ាអ៊ីថា: យើងសុំចំណុះចុះបួលដោយសុភាពហើយ, អងកៀននឹងលីវហ៊ីទទួលពាក្យហើយក៏ចេញទៅនឹងមនុស្សបម្រើ ៤ នាក់ ហើយប្រាប់គាហានឲ្យនាំបួលទៅគំនាប់សុម៉ាអ៊ីហើយថា កងស៊ុនអៀនឲ្យខ្ញុំបាទបួលមកអង្វរ ន់តួសុំចំណុះបួលលោកសុំជួយធ្វើការពង្គារលោកទៅ ។

សុម៉ាអ៊ីពួដូច្នោះក៏ខឹងណាស់ថា កងស៊ុនអៀនមើលងាយមិនចេញមកខ្ជូនឯងគំនាប់យើង ប្រើឯគាហានឲ្យមកដំនួសវិញ, ដែលធ្វើដូច្នេះគឺវាប្រឆាំងនឹងប្រទូសរ៉ាយយើង ហើយឲ្យយកខ្ជូនអង្គៀនឆិលវ៉ាហ្គ្រៅប្រហារជីវិតចង់ រួចគាត់យកក្បាលប្រគល់ឲ្យចំរើដែលមកជាមួយនោះនាំយកទៅបង្ហាញកងស៊ុនអៀនវិញ ហើយប្រាប់សេចក្តីឲ្យស្តាប់គ្រប់ប្រការ, កងស៊ុនអៀនឃើញដូច្នោះក៏ភ័យខ្លាំងណាស់ ទើបប្រើអ៊ុយអៀនចេញទៅជំរាបសុម៉ាអ៊ីថា: សុំកុំអាលឲ្យខឹងប្រគាន់ទោសៈឡើយព្រឹកស្អែកនេះហើយយើងនឹងឲ្យកងស៊ុនសុីវជាបុត្រ ចេញទៅគំនាប់ខុកជាមិនខាន, ឯខ្ជូនយើងនឹងបណ្តានាម៉ឺនតាំងពួនឹងធ្វើទោសខ្ជូនឯងដោយចំណាងចូលទៅកសុម៉ាអ៊ី, អោលអៀនខ្ជួលពាក្យក៏ចេញទៅ ។

ខណៈនោះ, សុមាអ៊ីដឹងដំណឹងថា: កងស៊ុនអៀនប្រើអោលអៀនឲ្យចូលមក ក៏ភ្លែនរៀបទ ហានឲ្យគាន់គ្រឿងអាវុធសស្រ្តាឈរតម្រៀបគ្នាជា ២ ជួរសងខាង, ឯគោលអៀនោះលុះដើរចូលទៅដល់មុខបន្តាយក៏ឱនចូលទៅគំនាប់សុមាអ៊ីដោយសេចក្តីខ្លាច ហើយដំរាបតាមដំណើរសេចក្តីដែលកងស៊ុនអៀនផ្តាំឲ្យដំរាបគ្រប់ប្រការ, សុម៉ាអ៊ីតបថា: ឯជម្នាការសង្គ្រាមនេះ មានសេចក្តី ៥ ប្រការ ប្រការមួយ បើយើញជាខឹងតបល់ជានហើយ ត្រូវតែចេញតបម្យ៉ាងដោយអង់អាច · ប្រការ

មួយ បើយើញថានឹងតស៊ូមិនបានទេ កុំមិនត្រូវចេញមកតប្បាំងទេ ត្រូវ
តែទៅរក្សាស្រុកឲ្យមាំមួន, ប្រការមួយ បើរក្សាស្រុកខុកមិនបាន ឲ្យរត់
ចេញទៅឲ្យតែរួចខ្លួន, ប្រការមួយ បើមិនរត់ទេ ត្រូវតែចេញមុខ
ទៅតំនាប់ដោយគួរសមល្អ ឲ្យតង់អាយុដូចតទៅប្រការមួយ បើមិន
ចេញទៅសុំអង្វរលន់តួដោយសុភាពទេ ក៏តែស្លាប់! ហេតុម្តេចកង
ស៊ុនអៀនកំមកធ្វើត្រដើយកន្តើយ ឲ្យឯពាហនដទៃចេញមកបរាជ័យ
ឥឡូវឯងត្រូវប្រញាប់
ត្រឡប់ទៅច្បាប់កងស៊ុនអៀនឲ្យហ័សរិះគិតដោយល្អ ទើបនឹងរួចជីវិត,
បើនៅដេកដំនឹងយើង។ ចាប់បានត្រូវតែកាត់ក្បាលដោតផ្ចាលទៅមុខ
ទ្វារស្រុក, អោលអៀនឮដូច្នោះក៏ភ័យណាស់ញ័រអស់ខ្លួនច្រាណ តំនាប់
លាសុម៉ាអ៊ីលទៅច្បាប់កងស៊ុនអៀនគ្រប់ប្រការ, កងស៊ុនអៀនឮ
ដូច្នោះក៏ភ័យណាស់ ទើបលបទៅច្បាប់កងស៊ុនស៊ីវជាបុត្រឲ្យចាត់
ពាហនដែលស្ទុះទុក ពេលយប់នេះ យើងនឹងលបតវេចេញពីស្រុក។

ឯសុម៉ាអ៊ីតតបារម្ភក្រែងកងស៊ុនអៀន នឹងលបតវេចេញពីស្រុក
សៀងចេង ក៏លើកពាហនទៅកៀរដើនក្នុងជិតអគ្គេយ៍ ហើយ
ប្រើឲ្យបុត្រចាំង ២ នាំពាហនទៅពួនបង្កប់នៅជាប្រើនសន្ធាត់, លុះវេលា
កណ្តាលយប់ស្ងាត់ កងស៊ុនអៀន និងកងស៊ុនស៊ីវនឹងពាហនស្ទុះ

ប្រវែល ១០,០០ ក៏បើកទ្វារទៅសាងត្បូង រត់ចេញទៅសំដៅទិស
អាគ្នេយ៍ ចាន់ចម្ងាយប្រវែង ១០០ សិន (៤ គ.ម.) កងស៊ុនអៀន
និយាយថា : គ្រានេះយើងចាន់បបួរលួតផុតពីកណ្តាប់ដៃសត្រូវហើយ
កំពុងតែនិយាយមិនទាន់ផុតមាត់ ស្រាប់តែឮសំឡេងស្រែកហ៊ោពីលើ
ដើងភ្នំទាំងសងខាងផ្លូវ ក្រឡេកទៅឃើញសុម៉ាអ៊ីលើកទាហានទៅស្កាត់
ពីមុខ, ខាងស្តាំសុម៉ាស៊ូ, ខាងឆ្វេងសុម៉ាចៀវ, លើកពលចេញមក
ស្កាត់ទាំងសងខាង, សុម៉ាស៊ូ, សូម៉ាចៀវស្រែកថា : ហើយ! អាកង
ស៊ុនអៀន ឯងក្បត់ហើយទំរាត់ទៅណា, កងស៊ុនអៀនឮដូច្នោះ
ក៏តែតែភ័យណាស់ ទើបស៊ុនសៀនជាបុត្រ ទំរាទាហានពុះ
ចំហរចេញទៅចាន ហើយគេចប្រតកាត់ទៅតាមផ្លូវតូច, ខ្លួល
ប្រទះទំរាហោជុមទាំទាហានចេញមកស្កាត់, ខាងស្តាំហែហ៊ូប៉ាទំរាហែហ៊ូ
ហ៊ុយ, ខាងឆ្វេងចៀវហ៊ូ ទំរាឆាក់លាម, ឯយប្រសព្វទ្ធប់ចូលមក
ឡោមព័ទ្ធជុំខ្លួនកងស៊ុនអៀន; សុម៉ាអ៊ីលើកទាហានទ្រានតាមមកខ្លាត,
កងស៊ុនអៀនឃើញប្រតាល់ខ្លួនណាស់ កំទាំបុត្រចុះពីលើសេះចូលទៅ
លុតជង្គង់គំទាប់សុម៉ាអ៊ីថា : ខ្ញុំចាទសុំចំណុះចុះចូលលោកសុំធ្វើពជការ
តទៅ; សុម៉ាអ៊ីឮហើយធ្វើយប្រាប់ទាហានចាំងភ្លឺថា : យើងឃើញ
ខ្លាចាតឆ្លាក់ ហើយចាទំនាយទុកថា ផុតកំណាត់ ៥ ថ្ងៃហើយ

ឥឡូវយើងបានខ្ជួនកងស៊ុនអៀនប្រាកដមែន បណ្តាគាហានបានឮដូច្នោះ ក៏នាំគ្នាសរសើរថា ប្រសាសន៍ទំនាយនោះដូចទេពតាមកប្រាប់ហេតុ, សុម៉ាអ៊ីថា : កងស៊ុនអៀនទេះមានចិត្តសាហាវណាស់ ទឹងចិញ្ចឹមរក្សាទុកតទៅមុខទៀតមិនបានទេ ត្រូវអែបអ្នកពល់គ្នានាំខ្ជួនវាទឹងកូនទៅសម្លាប់ចោលចេញទើបស្រួល គាហានក៏ធ្វើសម្រេចជីវិតតាមសុម៉ាអ៊ីបង្គាប់, ហើយសុម៉ាអ៊ីក៏លើកទ័ពទៅដល់ដើងកំពែងស្រុកសៀងតាំង, ខ្ជួលហោជុនទាយកងមុខទៅវាយយកបានស្រុកសៀងតាំងមុនសុម៉ាអ៊ីទៅដល់, សុម៉ាអ៊ីក៏លើកពលចូលទៅក្នុងស្រុកសៀងតាំងឲ្យចាប់កវីយាបុត្រនិងប៉ក្ខពួកកងស៊ុនអៀន ខ្លួនអស់មន្ត្រីក្នាក់ជាវេជ្ជពួកបិត្តមួយរយនាក់នោះទៅសម្លាប់អស់ប្រហែល ៧០ ប៉ុយនាក់ ហើយប្រាប់ប្រាមអាណាប្រជាទុកស្តេចឲ្យនៅជាសុខ ទើបអ្នកស្រុកជំរាបសុម៉ាអ៊ីថា : កាលកងស៊ុនអៀនគិតជាក្បត់នោះ កែហួនឌិងលុនតិតបានឃាត់ហាមរាំឮក កងស៊ុនអៀនទើងយកខ្ជួនកែហួនឌឹងលុនតិតទៅសម្លាប់ជីវិតបង់ សុម៉ាអ៊ីឮដូច្នោះ ក៏ចាត់ចែងឲ្យតែងតាំងការសពកែហួនឌិងលុនតិតតាមសមគួរ ហើយឲ្យនាំទៅបញ្ចុះតាមទំនៀម ហើយឲ្យមានប្រាក់ទៅកវីយាបុត្រតាមសមគួរ រួចឲ្យរើយកវេស្ម្រាពីកងឃ្លាំងនោះមកវិលកចែកឲ្យកពលគាហានដែលមានគុណបំណាច់ ហើយលើកកងទ័ពត្រឡប់ទៅ

ដល់ពាក់កណ្តាលផ្លូវ ទើបចាត់បម្រើសេះឲ្យស្រូតរួតនាំពតិមានចូលទៅ
ក្រាបទូលព្រះចៅចូយ៉ីយថា: វាយឃានស្រុកសៀវតាំងហើយ ។

ព្រះចៅចូយ៉ីយមិនសប្បាយព្រះកាយពល កំលើកទៅតង់នៅក្រុង
ហូគា, លុះវេលាយប់ថ្ងៃមួយ ព្រះចៅចូយ៉ីយស្តេចគង់ក្នុងច្រាសាទ
មានឮស្តាប់ចក់ចោកមកវេលត់ទៀនប្រចាំយាម ក្រឡេកទៅឃើញរូបនាង
ម៉ាសីនីនស្រីស្អាត ៨ នាក់ ១០ នាក់ ដើរចូលទៅហើយស្រែកថាអាយុដ៏វិត
ព្រះចៅចូយ៉ីយ ឮដូច្នោះក៏តក់ស្លុតព្រះទ័យខ្លាំងណាស់ ព្រះកេតាស់ក៏
រឹតតែបណ្តាលធ្វន់ចុះ ទើបត្រាស់ឲ្យហៅឡៅហាននិងស៊ុនជជានាម៉ឺនធំ
ទូវចោហ៊ូជាព្រះរាជបុត្រព្រះចៅចូកីចូលទៅគាល់ផ្តាល់ព្រះអង្គ ហើយ
ត្រាស់ថា: យើងមានអាការធ្វន់ណាស់ហើយ នឹងឲ្យចូហានជាព្រះ
រាជបុត្រយើងត្រងរាជសម្បត្តិទៅ តែឥឡូវចូហានទើបបានអាយុ ៨ ខួប
ត្រូវឲ្យចោហ៊ូត្រួតត្រាទិយាយរាជការផែនដីផងចុះ ទំរាំតែចូហានព្រះ
រាជទរសេចម្រើនវ័យវុឌ្ឍនាការ: ឯឡៅហាននឹងស៊ុនដូក៏ត្រូវឲ្យតង់នៅ
ជាំណែងជាដែល ចោហ៊ូបានឮព្រះបន្ទូលដូច្នោះក៏គិតថា ខ្លួនយើងមាន
សេចក្តីខ្វែងត្រង់ ទាំងមានចិត្តអាណិតករុណាអាណាប្រជាខ្មែរស្តាំងណាស់
ដែលនឹងឲ្យជួយធ្វើរាជការផែនដីប៉ុណ្ណោះមិនសមគួរ ហើយទូលថា
ទូលព្រះបង្គំមានសេចក្តីបញ្ជាក់ចិត្តនឹងជួយធ្វើរាជការមិនកើតទេ ។

ទើបព្រះចៅចួយ៉ាយត្រាស់សួរឡៅហាន៦និងស៊ុនជូថា : អស់អ្នកបាន
ឃើញនរណាដែលជាព្រះញាតិវង្ស មានកិរិយាមារយាទបរិសុទ្ធចិត្តស័ក្ស
ត្រង់ ល្អមជួយគាំពារការពារផនដីដ៏ធំទួយចួហាន៦បាន ឡៅហាន ស៊ុន
ហាន៦និងស៊ុនជូ ទើបគិតព្រមគ្នាថា : ចួដ៏នអោះជាប់មានគុណនឹងយើង
វេលានេះចួដ៏នមរណភាពទៅហើយនៅតែចួសន៦ជាបុត្រា យើងត្រូវ
ពិតទូលសុំឲ្យចួសន៦ជួយធ្វើកជការចួហាន៦ជាបណ្តោះអាសន្នចុះ ដើម្បី
ជាទីតបស្នន៦សន៦គុណទៅដល់ចួដ៏នដែលស្លាប់ ទើបព្រមគ្នាទូលថា :
ទូលព្រះបង្គំជាខ្ញុំយល់ឃើញថាចួសន៦ជាបុត្រាចួដ៏ន អោះមានគំនិតមាន-
ហោទ ប្រកបទាំន៦ចិត្តកំជាស័ក្សទៀន៦ត្រង់ គួរជួយផ្គត់ផ្គន់ដល់ព្រះពជ
នុវសដោយស្មោះប្រតៀតការពារកជការផនដីបាន ព្រះចៅចួយ៉ាយយល់
ព្រមជន៦ ទើបតាំន៦ចួសន៦ជាដំនួយកជការ ឲ្យចៅហ្វីជាទីអៀនអន៦
ចេញទៅឈរការពារស្រុកសៀន៦តាំន៦ ហើយត្រាស់ផ្តាំថា បើយើន៦មាន
សំបុត្រហៅសឹមចួលមក ចៅហ្វីក៏ត្រាបថ្វាយបង្គំលាចេញទៅឈរស្រុក
សៀតាំន៦ ។

ឯណៈនោះ ព្រះចៅចួយ៉ាយឲ្យចេញទៅទូលសុមាអ៊ីចួលមកហើយ
ត្រាស់ថា យើន៦ឈឺធ្ងន់ណាស់ហើយ យើន៦តាំន៦ចិត្តថា សូមឲ្យតែ
ល្អមបានឃើញមុខអ្នកបន្តិចប៉ុណ្ណោះក៏អស់ចិត្តហើយ អោះបើយើន៦ស្លាប់

ក៏មិនស្តាយជីវិតឡើយ, សុមាអ៊ីទូលថា: ទូលបង្គំជាខ្ញុំមកដល់
កណ្តាលផ្លូវដំណឹងក្នុងកិត្តិសព្ទថា ព្រះអង្គទ្រង់ប្រឈួនធ្ងន់ ទូលព្រះបង្គំជាខ្ញុំ
ក៏ក្រំចិត្តឥតសប្បាយសោះ បើប្រសិនមានស្វាបហើរហោះផ្ទៅបាន
ក៏ឆាប់មកឲ្យទាន់ចិត្តដែលរំខានមិនបង្អង់ ដែលទូលបង្គំជាខ្ញុំបានមកទាន់
ព្រះអង្គក្នុងពេលនេះ ក៏ជាបុញ្ញកសិថ្លៃថ្លា ឆ្ងាយអ្វីប្រៀបឧបមាពុំបាន
ព្រះចៅចូរយ៉ាយឲ្យអស្ចារ្យចូរហាងជាព្រះកាឥតរសេ ឆាប់ចូរសង់ដំនួយកាជ
ការផែនដី ហើយឆាំងឡៅហង, ស៊ុនដូចូលមក ទើបព្រះចៅចូរយ៉ាយ
ចាប់ដៃសុមាអ៊ីទុកហើយត្រាស់ថា: កាលឡោតាឈើធ្ងន់នៅក្នុងស្រុកប៉ែក
តេសៀនោះ បានឲ្យហៅឡោសៀន ខុងបេងចូលទៅហើយផ្ញើឡោ
សេនេះទុកលើខុងបេង ឡៅពីក៏ធ្វើមរណកាលក៏រីយា ខុងវេងក៏តាំង
ចិត្តគិតខំនុកបំរុងឡោសៀនតមកដោយសុចរិត ចាលតែខុងបេងដល់
សេចក្តីស្លាប់ក្នុងខណៈធ្វើការសង្គ្រាម ឡៅសៀនក៏បានតាំងខ្លួនជាសុខ
នៅក្នុងស្រុកសែឈួន ឥឡូវយើងនឹងឲ្យចូហាងគ្រងរាជសម្បត្តិ ឲ្យចូ
សង់ជាព្រះកាវង្សដួងតាំងនិយាយកាជការផែនដី ចំពោះចូហាងមានអាយុ
ធំចម្រើនឡើង ឲ្យអ្នកនិងកាជវង្សទូវអស់នាម៉ឺនខ្ញុំកាជការជួយគ្នាខំនុកបំរុង
ចូហាងតទៅ ហើយត្រាស់ផ្តាំចូរហាងថា បិតានឹងសុមាអ៊ីនេះកំដូចគ្នា
ឥឡូវបិតាក៏ជិតដល់មរណៈហើយ ចូរចៅទៅផ្ញើខ្លួនទុនកាយគំនាប់សុ-

ម៉ាអ៊ុំទុកជាទំពិតាចុះ ហើយឲ្យសុម៉ាអ៊ុំលើកចូហង៍ឡើងព ចូហង៍កំពុង
កសុម៉ាអ៊ុំយ៉ាងស្ងៀម ។

ព្រះបៅចូយ៉ាយគ្រាស់ផ្តាំសុម៉ាអ៊ុំថា: ចូហង៍វាមានសេចក្តីអាល័យ
ផ្ទៃរូបកាយលើអ្នក ។ ចូរយើញដល់ទ្រូងយើងផងចុះ អ្នកកុំបីក្តៅចួន
សំឡាញ់យើងឡើយ ព្រោះជីវិត យើងជិតស្លាប់ហើយក្នុងថ្ងៃនេះ គ្រាស់
ហើយក៏ទ្រង់កន្ទែងសោកគ្រាតែមានព្រះបន្ទូលពុំចប លើកតែម្រាម
ព្រះហស្តចង្អុលព្រះឧកនឹងចូហង៍កជបុត្រាលុះត្រាផុតរលត់ព្រះជន្ម ព្រះ
បៅចូយ៉ាយសោយរាជសម្បត្តិបាន ១៣ ឆ្នាំ ខណៈកាលក្រុយព្រះជន្ម
នោះ ព្រះជន្មាយុបាន ៣៩ ឆ្នាំ សុម៉ាអ៊ុំក៏ចាត់ចែងតែងរៀបចំព្រះ
បរមសពហៅបៅបញ្ចុះទុកនៅតំបន់កោះបេង៍ឡេង ។

ឯចូហង៍នោះ ក្នុងរឿងវាវោលមិនជាក់ច្បាស់ជាបុត្រអ្នកឯណា
គឺព្រះបៅចូយ៉ាយយកពោចំញឹមជាព្រះរាជបុត្រាតាំងពីពារតូចណាស់ទ្រង់
ក៏ស្រឡាញ់ស្និទ្ធដូចបុត្រកើតពីខ្លួន លុះកន្ទង់មកដល់ខែមាឃខាងរនោច
(ព.ស ៧៨៣) សុម៉ាអ៊ុំនិងចូហង៍នូវអស់នាម៉ឺនមុខមន្ត្រីព្រាហ្មណ៍ក៏
ចាត់ការតែងតាំងកជាកិសេក លើកចូហង៍ឲ្យសោយរាជ្យសម្បត្តិកងទីក្រុង
ចូរហង៍ជាអ្នកជំនួយនិយាយការផែនដី កាលចូរហង៍បានសោយរាជ្យនោះ
បើនឹងមានរាជការអ្វីៗ ចូរហង៍ក៏ប្រឹក្សាពីគ្រោះនឹងសុម៉ាអ៊ុំជាមុន ទើប

សម្រេចសេចក្តីបាន ។

ខណៈកាលចូសឆ័ទៅតីក្នុង ព្រះចៅចូយ័យទ្រង់ជ្រាបសុភុណាកប់អានថាជាព្រះពជវង្ស ហើយយើញថាមានសតិបញ្ញា តែងចូលគាល់គ្រប់ពេលវេលាមិនដែលដាច់ ព្រះចៅចូយ័យទ្រង់មេត្តាអាណិតណាស់ ចូហង៍មានមនុស្សបម្រើស្មើនឹង ៥ នាក់និងតាហាន ៥០០០ ឯមនុស្សបម្រើ ៥ នាក់នោះឈ្មោះហោអាន១, តេងយៀ១ លីឈិន ១ តេងបិត ១ បើអ្នកទាំង ៥ នេះ និយាយពីការអ្វីយ៉ាងណា ចូហង៍ក៏រមែងដឿស្តាប់ ឯហ្ជីហមជាមាម៉ឺនធំខាងភ្នាក់ងារស្រែក៏មានជ្រាបជ្រុតជមុតមាំ ចូសឆ័ក៏កប់អានហ្ជិនហមជាទីគាប់អធ្យាស្រ័យតែងទៅមកវគ្គគ្នា ។

លុះអំណើះតមក ហោអាន់បាននិយាយទឹងចូសឆ័ថា : ខ្ញុំលោកជាពូជព្រះពជវង្ស ព្រះចៅចូយ័យបានតាំងឲ្យជាអ្នកជំនួញពជការផែនដី ខ្ញុំបានយល់យើញថា សុម៉ាអ៊ីសព្វថ្ងៃនេះមានចិត្តករម្រើបទ្រង់ស័ក្តិណាស់ ដែលលោកនឹងទៅគំនាប់សុម៉ាអ៊ីនោះមិនគួរ ចូសឆ័តបថា : សុម៉ាអ៊ីគេជាពីរឱបពជ ខ្ញុំនយើងជាអ្នកជំនួយពជការផែនដី ព្រះចៅចូយ័យ បានត្រាស់ទុកឲ្យយកចិត្តលំអុតលំឱនគ្នាជួយទំនុកបំរុងស្រុកទេសឲ្យបានទៅជាសុខ ឯសុម៉ាអ៊ីនោះគេក៏មានអាយុចាស់ជាងយើងន

ដែលមិនឲ្យយើងទៅគំនាប់គេនោះមិនគួរ ហោអាន់ថា : ចោជនជាបិតា
លោក គ្រាកាលទៅចំរ្បាងនឹងកងទ័ពស្រុកសែឈួនទោះកំបានសេចក្តី
ទីងក្តៅនឹងសុម៉ាអ៊ុតាល់តែបិតាលោកឈឺចិត្តស្លាប់ជីវិតទៅ ឥឡូវខ្លួន
លោកនៅមិនទាន់មានសេចក្តីឈឺចិត្ត គិតទៅគំនាប់សុម៉ាអ៊ុនោះជាសេចក្តី
ប្រពៃណាស់ហើយឬ ?

ចូសង៌បានឮពាក្យព្រួកកំឲ្យនឹកក្តៅក្បាញ់ពេញក្នុងឆក ទើបបែរ
ទៅប្រឹក្សានឹងស្ដេចព័ក្តពួកថា : យើងត្រូវតែគិតពិតទូលព្រះចៅចូហង
ឲ្យលឿនទីសុម៉ាអ៊ុជាអាចារ្យធំ ទើបមិនត្រូវត្រួកបង្គាប់លើយើងបាន
ពួកដំនៃតទាំង ៥ នាក់ ក៏យល់ឃើញផង ទើបចូសង៌ចូលទៅប្រឹក្សានឹង
បណ្តាមុខមន្ត្រីទាំងពួង ថា : សុម៉ាអ៊ុមានសេចក្តីគាប់ប្រសើរច្រើនណាស់
យើងនឹងពិតទូលព្រះចៅចូហង៌ជាអម្ចាស់ឲ្យលឿនទីឡើង ជាអាចារ្យធំ
បំផុត ដើម្បីបានខ្ជិនប្រដៅព្រះពជបុត្រ នូវអស់យើងពាល់គ្នា អស់
បណ្តានាម៉ឺនមុខមន្ត្រីទាំងពួងក៏យល់ព្រមផង ចូសង៌ក៏ចូលទៅទូល
ព្រះចៅចូហង៌តាមសេចក្តីប្រឹក្សាគ្រប់ប្រការ ។

(ទៅមានត)

ផ្នែកកំណត់-ប្រវត្តិការណ៍

ដើម្បីបានជាឯកសារសម្រាប់អ្នកអានយើង គ្រាបក្បាប់ថា: អ្វីហៅថា អង្គការយូណេស្កូ? យើងសូមចុះផ្ញើនូវអត្ថបទខាងក្រោមនេះ ដែលរៀបរៀងឡើងដោយគណៈកម្មការជាតិ ខាងយូណេស្កូ នៃសាធារណរដ្ឋខ្មែរ ។

អង្គការសហប្រជាជាតិ ខាងការអប់រំ វិទ្យាសាស្ត្រ និង វប្បធម៌

(យូណេស្កូ)

ORGANISATION DES NATIONS UNIES POUR L'EDUCATION, LA SCIENCE ET LA CULTURE (U N E S C O)

អង្គការសហប្រជាជាតិបានចាប់តំណើតនៅថ្ងៃទី ២៤ ខែតុលា ឆ្នាំ ១៩៤៥ ហើយបានបង្កើតអង្គការជាច្រើន សម្រាប់សម្របសម្រួលសកម្មភាពរបស់ខ្លួន ក្នុងការបំរើផលប្រយោជន៍ដ៏ខ្ពង់ខ្ពស់ ចំពោះមនុស្សជាតិក្នុងលោក ។ អង្គការសំខាន់ ៗ នៃអង្គការសហប្រជាជាតិមាន ៦ គឺ: មហាសន្និបាត លេខាធិការដ្ឋាន តុលាការអន្តរជាតិ ក្រុមប្រឹក្សាសន្តិសុខ ក្រុមប្រឹក្សាឰបាយ ហើយនិង ក្រុមប្រឹក្សាសេដ្ឋកិច្ចនិងសង្គមកិច្ច ។

ក្រៅពីអង្គការធំ ៗ ទាំងនេះ គេបានបង្កើត "អង្គការឯកទេស" (Institutions spécialisées) *ឬ "អង្គការអន្តរាជ្ជាភិបាល"* (Institutions intergouvernementales) *ចំនួន ១៥ ដែលត្រូវធ្វើសហប្រតិបត្តិការ

យ៉ាងដិតស្និទ្ធរវាងគ្នានិងគ្នា ហើយវាដែលត្រូវធ្វើការចាត់ចងជាមួយនឹងអង្គការសហប្រជាជាតិ តាមរយៈក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច ។

ក្នុងចំណោមអង្គការឯកទេសទាំងនេះ អង្គការដែលមានសកម្មភាពខ្លាំងជាងគេគឺ : "អង្គការ យូណេស្កូ" ។

ក. ដើមកំណើតនៃអង្គការយូណេស្កូ

នៅឆ្នាំ ១៩២៤ គឺនៅចន្លោះពេលសង្គ្រាមលោកលើកទី ១ និង ទី ២ គេបានបង្កើត "សមាគមអន្តរជាតិនៃសហប្រតិបត្តិការខាងវប្បធម៌" មួយនៅទីក្រុងប៉ារីស ក្រោមការឧបត្ថម្ភនៃប្រទេសបារាំង និង ក្រោមការដឹកនាំនៃ "សមាគមប្រជាជាតិ" La Société des Nations) ។

សមាគមអន្តរជាតិនេះបានចាប់អារម្មណ៍យ៉ាងខ្លាំងទៅលើបញ្ហាអប់រំ និង វប្បធម៌ ដោយមានការចូលរួមនៃឥស្សរជនធំ ។ ដែលស្ថាប័នាញក្នុងការស្រាវជ្រាវនិងក្នុងការបង្កើត ព្រមទាំងមានជួយឧបត្ថម្ភពីសាកលវិទ្យាល័យ បណ្ឌិតសភា ហើយនិងសមាគមអ្នកប្រាជ្ញឯទៀត ។ជាច្រើន។

ប៉ុន្តែ តម្លាភាពនៃការទំប្រឹងប្រែងនេះ ច្រើនតែជាគំនិត ដែលធ្វើឡើងដោយសមាគមរបស់ឯកជន ពុំមែនជាកម្លាំងរបស់រដ្ឋាភិបាលទេ ។

នៅពេលសង្គ្រាមលោកលើកទី ២ កំពុងឆេះពាសដាសពេញពិភពលោក គេបានទំប្រឹងរៀបចំវាមកទៀតឲ្យមានសហប្រតិបត្តិការជាអន្តរជាតិខាងវិស័យអប់រំ និងវប្បធម៌ ដោយបានទំនាក់ទំនងហៅគ្រប់មជ្ឈដ្ឋាន

បញ្ជាវន្ត ដូចជា អ្នកអប់រំ អ្នកប្រាជ្ញ អ្នកឯកទេស អ្នកសារពត៌មាន ដើម្បីពង្រីកនូវការយល់ចិត្តគំនិតឲ្យកាន់តែច្បាស់ឡើង រវាងប្រជាជាតិទាំងអស់ក្នុងលោក និងដើម្បីរៀបអង្គការឯកជននោះឲ្យទៅជាអង្គការរដ្ឋ។ សកម្មភាពទាំងអស់នេះគឺធ្វើឡើងក្នុងគោលបំណងស្វែងរកសន្តិភាព ។

ដោយហេតុនេះហើយ ចាន់ជានៅពេលដែលចប់សង្គ្រាមលោកទី ២ តំណាងរដ្ឋចំនួន ៤៤ បានប្រជុំសន្និសីទមួយនៅទីក្រុងប្រេង ក្រោមការចាត់ចែងនៃរដ្ឋាភិបាលប្រទេសអង់គ្លេស និងប្រទេសចាក់ដែង ដើម្បីរៀបចំធ្វើធម្មនុញ្ញ (Acte constitutif) បង្កើតអង្គការរដ្ឋមួយហៅថា អង្គការ "យូរណេស្កូ" ចាន់នយថា : អង្គការសហប្រជាជាតិខាងការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ ។ ក្រោយពីការតែងធម្មនុញ្ញហើយ ដែលត្រូវរៀបចំធ្វើអស់រយៈពេលមួយឆ្នាំ អង្គការយូរណេស្កូ ក៏ត្រូវបានប្រកាសជាផ្លូវការនៅថ្ងៃទី ៤ ខែវិច្ឆិកា ឆ្នាំ ១៩៤៦ ហើយបានតំណាត់យកទីស្នាក់ការរបស់ខ្លួននៅទីក្រុងប៉ារីស ។ នៅខែធ្នូ ឆ្នាំ ១៩៤៦ អង្គការយូរណេស្កូត្រូវបានអង្គការសហប្រជាជាតិទទួលស្គាល់ជាអង្គការឯកទេសរបស់ខ្លួន ។

ចាប់តាំងពីពេលនោះមក រដ្ឋដែលបានចូលជាសមាជិកនៃអង្គការយូរណេស្កូក៏បានសន្យាគ្នាទៅវិញទៅមក ដើម្បីសម្រេចគោលបំណងរួម ។

ខ- គោលបំណងនៃអង្គការយូរណេស្កូ

គោលបំណងធំនៃអង្គការយូរណេស្កូ គឺការពារសន្តិភាព និងសន្តិ-

សុខអន្តរជាតិ ដោយធ្វើសហការយ៉ាងជិតស្និទ្ធរវាងប្រជាជាតិទាំងអស់ តាមរយៈការអប់រំ វិទ្យាសាស្ត្រ និង វប្បធម៌ ដើម្បីប្តូរគំនិតឲ្យយល់គ្នា និង ដើម្បីកាប់ឆេនូវការគោរពជាសាកលនៃយុត្តិធម៌ ច្បាប់សិទ្ធិមនុស្ស និងសេរីភាពសម្រាប់មនុស្សជាតិ ដោយពុំគិតពីការខែកពណ៌សម្បុរ ភេទ ភាសា ឬ សាសនា ដែលមានចែងនៅក្នុងធម្មនុញ្ញសហប្រជាជាតិ ។

គោលបំណងដែលនាំឲ្យគេបង្កើតអង្គការយូរណេស្កូនេះ ដោយមកពីគេយល់ថា សន្តិភាពដែលសង្ឃឹមតែទៅលើកិច្ចព្រមព្រៀងខាងវិស័យសេដ្ឋកិច្ចនិងទេ ហើយបាយបស់ផ្លាកិបាល ពុំអាចផ្តល់នូវការរួមរស់ជាមួយគ្នាឲ្យបានបិតបៃរឡើយ ។ សន្តិភាពត្រូវតែរៀបចំដោយពឹងផែមទៀតទៅលើការប្តូរចិត្តគំនិតឲ្យយល់គ្នា តាមការអប់រំ វិទ្យាសាស្ត្រ និង វប្បធម៌ រវាងមនុស្សជាតិទាំងអស់ក្នុងលោក ។

គ. មុខងារនៃអង្គការយូរណេស្កូ

អង្គការយូរណេស្កូមានមុខងារ ៣ គឺ:-សហប្រតិបត្តិការអន្តរជាតិខាងគំនិត (Coopération intellectuelle internationale),សកម្មភាពដើម្បីអភិវឌ្ឍន៍ (Action opérationnelle au service du développement) និង សកម្មភាពខាងសីលធម៌ (Action éthique)

១- សហប្រតិបត្តិការអន្តរជាតិខាងគំនិត

មុខងារនេះត្រូវធ្វើគ្រប់វិស័យនៃសកម្មភាពខាងចិត្តគំនិត និង ខាងការបង្កើត ដែលទាក់ទងនឹងការអប់រំ វិទ្យាសាស្ត្រ និង វប្បធម៌ គឺ :

- ត្រូវផ្សព្វផ្សាយចំណេះដឹង ចូរការពិសោធន៍គ្នា ពិភាក្សាឲ្យយល់ចិត្តគំនិតគ្នាពង្រីកការគោរពឯជាសន្តិវិធី ហើយនិងមិត្តភាពរវាងប្រជាជាតិ ដើម្បីឲ្យយល់នូវរបៀបរស់នៅរៀងៗខ្លួន ។

- ផ្តល់សិទ្ធិឲ្យមនុស្សម្នាក់ៗ ចូលរួមក្នុងវឌ្ឍនភាពនៃវិទ្យាសាស្ត្រ និងវប្បធម៌ ដែលជាបេតិកភ័ណ្ឌរួមរបស់ជាតិ ។ វប្បធម៌ត្រូវតែទទួលនូវការគោរព និង ការការពារ ។

- បង្កើតបណ្តាញនៃអ្នកឯកទេស ដូចជា អ្នកអប់រំ អ្នកវិទ្យាសាស្ត្រ សិល្បករ អ្នកសារពត៌មាន ដែលត្រូវចូលរួមក្នុងសមាគមជាតិ ឬ សហពន្ធអន្តរជាតិ ដោយមានសហការពីអង្គការយូណេស្កូ ។

- ត្រូវរៀបចំធ្វើសន្និសីទ រៀបចំអង្គការអន្តរជាតិ បង្កើតគណៈកម្មាធិការប្រឹក្សាពិគ្រោះ ប្រមូលឯកសារ គ្រោងនិងអនុវត្តកម្មវិធីនៃការស្រាវជ្រាវផ្សាយលទ្ធផលនៃសកម្មភាពដែលបានធ្វើ ។

- បង្កើតបទបញ្ជាអន្តរជាតិ „ដូចជា អនុសញ្ញា„ កិច្ចព្រមព្រៀងដែលសុំឲ្យប្រទេសទាំងអស់គោរពនូវគោលការណ៍ នៅក្នុងវិស័យអប់រំ វិទ្យាសាស្ត្រ និង វប្បធម៌ ។ ឧទាហរណ៍ : អនុសញ្ញាជាសាកល

សម្រាប់សិទ្ធិនៃអ្នកនិពន្ធ (១៩៥៦) ។ អនុសញ្ញាសម្រាប់ការពារសម្បត្តិ
វប្បធម៌ នៅពេលមានសង្គ្រាម (១៩៥៤) ។ កិច្ចព្រមព្រៀងនៃការ
នាំចូលវត្ថុ ក្នុងវិស័យអប់រំ វិទ្យាសាស្ត្រ ឬ វប្បធម៌ (១៩៥០) ។ល។

២- សកម្មភាពដើម្បីអភិវឌ្ឍន៍

ត្រូវជួយឧបត្ថម្ភដល់ប្រទេសដែលឆ្ពោះ ទៅរកការចំរើនលូតលាស់
ខ្លះជំនួយបញ្ចេកទេស ដូចជា :

- ជួយពង្រីកការអប់រំ «ឱ្យអាហារូបករណ៍សិក្សា ដើម្បីបង្កើន
ចំណេះវិជ្ជាឯកទេស ។

- ជួយផ្តល់វិធី និង បច្ចេកទេសថ្មី សម្ភារៈសិក្សា រៀបចំផែន
ការអប់រំ ប្រយុទ្ធប្រឆាំងនឹងអនក្ខរកម្ម ។

- ពង្រីកវិទ្យាសាស្ត្រ បង្កើនវិជ្ជាជាន់ទាបសម្រាប់ស្រោវជ្រាវរកធនជាន
ជម្មជាតិ បង្កើតបណ្ណាល័យសាធារណៈ និង ឧស្សាហកម្មសៀវភៅ ។

៣- សកម្មភាពខាងសីលធម៌

- ប្រឆាំងនឹងការកំហែងគំរាមដល់សន្តិភាព, ផ្តន្ទាទោសគ្រប់អំពើ
ឈ្លានពាន ។

- ប្រយុទ្ធនឹងការរើសអើង និង ការប្រកាន់ពណ៌សម្បុរ សាសន៍
ភាសា សាសនា និង នយោបាយ ។

ឃ. រចនាសម្ព័ន្ធនៃអង្គការយូណេស្កូ

(*STRUCTURE DU L'UNESCO*)

យូណេស្កូ មានអង្គការ៣: មហាសន្និបាត(*Conférence générale*) ក្រុមប្រឹក្សាប្រតិបត្តិ (*Conseil exécutif*) និង លេខាធិការដ្ឋាន (*Secrétariat*) ។

- មហាសន្និបាត

សមាសភាព

មហាសន្និបាតត្រូវមានអ្នកតំណាងនៃរដ្ឋជាសមាជិកចូលរួម ។ រដ្ឋាភិបាលនៃរដ្ឋជាសមាជិកនីមួយៗ ត្រូវជ្រើសរើសអ្នកតំណាងរបស់ខ្លួន ៥ នាក់ យ៉ាងច្រើន ទៅរួមក្នុងមហាសន្និបាតនេះ ។ សព្វថ្ងៃ យូណេស្កូ មានរដ្ឋជាសមាជិក ១១២ ។

មុខងារ

មហាសន្និបាតត្រូវសម្រេចគោលដៅធំៗរបស់អង្គការ :

- ត្រូវសម្រេចកម្មវិធីដែលក្រុមប្រឹក្សាប្រតិបត្តិដាក់ជូន ។
- ត្រូវកោះប្រជុំសន្និសីទអន្តរជាតិ ដែលទាក់ទងនឹងការអប់រំ វិទ្យាសាស្ត្រ វប្បធម៌ ឬ ការផ្សាយចំណេះដឹងទៅ បើប្រសិនជាមាន ។
- ត្រូវឲ្យយោបល់ទៅអង្គការសហប្រជាជាតិ ខ្ទង់ជាអប់រំ វិទ្យាសាស្ត្រ និង វប្បធម៌ ដែលយល់ថាមានសារៈសំខាន់ដល់ប្រជាជាតិ ។

- ធ្វើការប្រជុំជាធម្មតា យ៉ាងហោចណាស់ ក្នុងមួយឆ្នាំពីរដង តែអាចធ្វើសម័យប្រជុំវិសាមញ្ញ តាមការកោះប្រជុំរបស់ប្រធាន ឬតាមសេចក្តីស្នើរបស់សមាជិក ។

ខ្លឹមគ្រប់សម័យប្រជុំសាមញ្ញនៃសន្និបាត ប្រធានត្រូវជូនដំណឹងសន្និបាតនូវសេចក្តីរាយការណ៍ស្តីអំពីសកម្មភាពផ្សេងៗ របស់អគ្គការយូណេស្កូ ដែលអគ្គនាយករៀបចំធ្វើ ។

- ស្នើសុំតែងតាំងអគ្គនាយកដោយសន្និបាត ។

៣- លេខាធិការដ្ឋាន

លេខាធិការដ្ឋានជាអង្គការប្រតិបត្តិ សម្រាប់ការងារធម្មតារបស់អគ្គការយូណេស្កូ ហើយនិងសម្រាប់អនុវត្តសេចក្តីសម្រេចរបស់មហាសន្និបាត និង ក្រុមប្រឹក្សាប្រតិបត្តិ។ លេខាធិការដ្ឋានមានមន្ត្រីដ្ឋការ (នាយក អ្នកឯកទេស អ្នកវាយតម្លៃ) និយោជិត និង អ្នកដទៃ ។

មន្ត្រីរដ្ឋការត្រូវជ្រើសរើសក្នុងចំណោមបុគ្គលិក ដែលមានគុណសម្បត្តិខ្ពស់និងមានសមត្ថភាពបច្ចេកទេសគ្រប់គ្រាន់ ហើយត្រូវមានអភ័យឯកសិទ្ធិដូចគ្នានឹងអ្នកការទូតដែរ ។

លេខាធិការដ្ឋានត្រូវដឹកនាំដោយអគ្គនាយកមួយនាក់ ជ្រើសតាំងដោយមហាសន្និបាត សម្រាប់ទីតាំង ៦ ឆ្នាំ ។ អគ្គនាយកជាឥស្សរជនជាន់ខ្ពស់នៃអង្គការយូណេស្កូ ហើយត្រូវមានអគ្គនាយករងមួយនាក់

ជាអ្នកជួយធ្វើការអម ។

អគ្គនាយកត្រូវទទួលបន្ទុកព័ត៌មានកិច្ចការរដ្ឋបាល ត្រូវរៀបចំធ្វើការប្រជុំមហាសន្និបាត ការប្រជុំក្រុមប្រឹក្សា និងការប្រជុំគណៈកម្មការរបស់អង្គការយូណេស្កូ រៀបចំគម្រោងកម្មវិធីរបស់អង្គការ ដាក់ជូនឲ្យក្រុមប្រឹក្សាពិនិត្យ ហើយនិងគ្រោងថវិកា ។ អគ្គនាយកត្រូវជូនសេចក្តីពយការណ៍ស្តីអំពីសកម្មភាពរបស់អង្គការទៅរដ្ឋជាសមាជិក និង ទៅក្រុមប្រឹក្សាប្រតិបត្តិ ។

លេខាធិការដ្ឋាន ចែកចេញជាសាខា ៦ គឺ :

- ផ្នែកវិជ្ជាជាក់លាក់ (Secteur de l' éducation)
- ផ្នែកវិជ្ជាជាក់លាក់ និង ធម្មជាតិវិទ្យា (Secteur des Siences exacte et naturelles
- ផ្នែកសង្គមសាស្ត្រ មនុស្សសាស្ត្រ និង វប្បធម៌ (Secteur des Siences sociales , des siences humaines et de la culture)
- ផ្នែកពត៌មាន (Secteur de l' information)
- ផ្នែករដ្ឋបាល (Secteur de l' administration)
- ផ្នែកគោលការណ៍អន្តរជាតិ និង កិច្ចការតុលាការ (Secteur des normes internationales et des affaires juridiques) . . .

ផ្នែកទំាងមួយៗត្រូវមានអនុអគ្គនាយក (Sous - Directeur général)

មួយនាក់ជាអ្នកដឹកនាំ ។

៤- គណៈប្រតិភូអចិន្ត្រៃយ៍ និង គណៈកម្មការជាតិ

(Délégations permanentes et commissions nationales)

រដ្ឋជាសមាជិកត្រូវតាំងគណៈប្រតិភូអចិន្ត្រៃយ៍របស់ខ្លួនទៅអមអង្គការយូណេស្កូ ។ គណៈប្រតិភូនោះត្រូតាំងការិយាល័យរបស់ខ្លួននៅទីក្រុងប៉ារីស ហើយត្រូវទទួលបន្ទុកធ្វើការទាក់ទងយ៉ាងជិតស្និទ្ធរវាងអង្គការយូណេស្កូ និង រដ្ឋាភិបាលរបស់ខ្លួន ។ សព្វថ្ងៃ គណៈប្រតិភូដែលតាំងអមអង្គការយូណេស្កូ នៅទីក្រុងប៉ារីស មាន៨៥ ។

រដ្ឋជាសមាជិកនីមួយៗអាចបង្កើតគណៈកម្មការជាតិរបស់ខ្លួន ដើម្បីទាក់ទងនឹងសេខាធិការដ្ឋានៃអង្គការយូណេស្កូ និង គណៈកម្មការជាតិឯទៀត ។ (សូមរំលឹកអានអង្គការយូណេស្កូ និង សាធារណៈរដ្ឋខ្មែរ)។

៥- អង្គការក្រៅក្រុមទំនាក់ទំនងរដ្ឋាភិបាល (Organisations non- Gouvernementales)

គណៈកម្មការពុំមែនស្ថិតតែជាអង្គការពិសេសរបស់រដ្ឋាភិបាលទេ ។ អង្គការយូណេស្កូបានទាក់ទងនឹងអង្គការឯកជន និង អង្គការជាតិក្រៅក្រុមទំនាក់ទំនងរដ្ឋាភិបាលនានាជាច្រើន ដែលច្រមូលផ្តុំអ្នកឯកទេសគ្រប់ផ្នែក ។ សព្វថ្ងៃនេះ អង្គការយូណេស្កូបានទាក់ទងជាផ្លូវការជាមួយនឹងអង្គការទាំងនេះចំនួន ៦២៦ ។

ជ- ចរិកានៃអង្គការយូណេស្កូ

ដើម្បីទ្រទ្រង់សកម្មភាពខ្លួនក្នុងការបំពេញ ប្រយោជន៍ដល់ប្រទេសជាសមាជិក អង្គការយូណេស្កូបានពឹងផ្អែកទៅលើថវិកាពីរផ្នែក គឺ : ថវិកាធម្មតា (Budget ordinaire) និង ថវិកាពិសេស (Budget spécial)

- ថវិកាធម្មតាបានមកពី ប្រាក់វិភាគទាន ប្រចាំឆ្នាំនៃរដ្ឋជាសមាជិក ដែលត្រូវបង់ជូនទៅអង្គការ ។

- ថវិកាពិសេសបានមក ពីមូលនិធិពិសេស នៃអង្គការ សហប្រជាជាតិ ធនាគារពិភពលោក អំណោយឯកជន ជួយរបស់អង្គការ ឬ សមាគម រដ្ឋឯទៀតៗ ។

សម្រាប់ការិយបរិច្ឆេទ ๑๙๗๑ - ๗๒ អង្គការយូណេស្កូមានថវិកាសរុបចំនួន ๘๙. ๙๙๖. ๕๖๐ ដុល្លារអាមេរិកាំង សម្រាប់អនុវត្តកម្មវិធីរបស់ខ្លួន ។

(លើកក្រោយ នឹងជូនជ្រាបពីអង្គការយូណេស្កូនិងសាធារណរដ្ឋខ្មែរ)



កង្ខេយ្យសុត្តនិយាយ

ទស្សនាវដ្តី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ

ឆ្នាំទី ៤៣ ខែ វិច្ឆិកា

ព.ស. ២៥១៥ គ.ស. ១៩៧១

- ភ្នំពេញ -



ទស្សនាវដ្តី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ

បេញរាល់ខែ ពី ពុទ្ធសាសនបណ្ឌិត្យ

ចាត់ចែងបោះពុម្ពផ្សាយដោយគណៈកម្មការមួយ មាន :

និពន្ធនាយក - អ្នករៀបចំ : លី ធាមតេង

គណៈកម្មការនិពន្ធ :

ព្រះពោធិវង្ស ស្ងួន-ហាយ

លោក ផល-ឥត អ្នកស្រី ទេព-សល់

បញ្ជីរឿង

អត្ថបទ	ទំព័រ
១— ផ្នែកសាសនា	
១— ចតុភរិបលក្ខ (ត) ព្រះភិក្ខុ ប៉ាង ខាត់ រៀបរៀង	៨៨៩
២— រឿងនាងសាមាវតី (ត) លោក ប៊ូ-ប៊ូ ប្រែ-រៀបរៀង	៨១១
២— ផ្នែកអក្សរសាស្ត្រ	
៣— តួរើរៀបដំឡើងវិញ លោក ផល-ទិត រៀបរៀង	៨៦២
៤— រឿងសាមកុក ឧកញ៉ា ឧ-កន ប្រែ-រៀបរៀង	៨៤៥
៣—ផ្នែកគំណត់—ប្រវត្តិការណ៍	
៥— អង្គការបូណោស្ត ឆិង សាការណារដ្ឋខ្មែរ	៨៧១

តម្លៃជាវ :

មួយឆ្នាំមាន ១២ សៀវភៅ . . . ២៣០រ០០ ។

អាណត្តិស្នងដាក់ថា : លោកនាយកវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា

ចតុរារិយសច្ច

ព្រះភិក្ខុ ប៉ាង ទាត់ រៀបរៀង

– ម្នាលភិក្ខុទាំងឡាយ ! កាមនេះ ជាហេតុ ។ល។ ជាបច្ច័យនៃកាម ទាំងឡាយ បានជាមនុស្សកាត់ដញ្ជាំងផ្ទះ ចូនំ កំហែងយកទ្រព្យក្នុងផ្ទះ ស្ទាត់ប្រកបផ្លូវ គប់កិរិយាអ្នកជវៃ ។ ព្រះរាជា ចាប់មនុស្សទាំងនោះ បានហើយ ត្រាស់បង្គាប់ឲ្យធ្វើកម្មករណៈ មានប្រការផ្សេង ។ គឺវាយ ដោយរំពាត់ ដោយផ្លៅ ដោយដំបង កាត់ដៃ កាត់ដើង កាត់ទាំង ដៃទាំងដើង កាត់ស្មៅតត្រៀក កាត់ច្រមុះ កាត់ត្រចៀកនិងច្រមុះ, ធ្វើ ពិលិង្គជាលិកកម្ម (ធ្វើដូចជាធ្នាំងដែលគេដាក់ទឹកត្រក់) គឺបកស្បែក ក្បាលចេញ ហើយយកដង្កាប់ចាប់ដែកដែលនេះដោយក្តឹងទៅដាក់លើ ក្បាល ធ្វើឲ្យខួរក្បាលពុះ, ធ្វើសង្ខមណ្ឌល (ធ្វើក្បាលឲ្យរលើងដូច សំបកស័ង្ខ) គឺចៀរក្រឡឹងស្បែកក្បាល ស្បែកមុខ យកឈើមូរសក់ ឲ្យជាប់ហើយទាញកន្ត្រាក់ស្បែកក្បាលចេញ ទើបយកថ្មទៅដុះលលាដ៍ ក្បាលឲ្យរលើង ឲ្យដូចជាសង្ខរលើង, ធ្វើរាហូមុខកម្ម (ធ្វើមាត់ឲ្យដូចជាមាត់ ពហួ) គឺយកកង្ហារដែកក្តក់មាត់ឲ្យហា យកប្រទីបដុតក្នុងមាត់ យក ពន្លាកដាប់មាត់ ឲ្យយារដល់គុម្ពត្រចៀកទាំងពីរ ធ្វើមាត់ឲ្យដូចជាមាត់

ភហូ, ធ្វើជោតិមាលិកកម្ម (ធ្វើមនុស្សមានខ្លួនដូចជាផ្កាក្ងើង) គឺយក
សំពត់ជ្រលក់ប្រេងហើយរុំសរីរៈទាំងអស់ ហើយឈួលក្ងើងឲ្យឆេះ, ធ្វើ
ហត្ថបជ្ជោតិកកម្ម (អំពើដែលគេដុតដៃ) គឺយកសំពត់ជ្រលក់ប្រេង
ហើយរុំដៃទាំងពីរ ហើយឈួលក្ងើងឲ្យឆេះ, ធ្វើឯរកវត្តិកកម្ម (ធ្វើឲ្យដូច
គេពន្ធាត់ស្បែកពពែ) គឺពន្ធាត់ស្បែកដូចពន្ធាត់ស្បែកពពែ ឆួតស្បែក
ពីត្រឹមកហួតដល់កជើង ហើយយកខ្សែចងភាញកន្ត្រាក់ពន្ធាត់យកស្បែក
ចេញ ហើយឲ្យយកអ្នកគោសនោះ ឈរលើស្បែកខ្លួនឯងនោះ ពាល់តែ
ដួលទៅ, ធ្វើចីរកវាសិកកម្ម (ធ្វើឲ្យដូចជាស្លៀកសំពត់សំបកឈើ)
គឺឆួតស្បែកពីត្រឹមកខ្មាក់មកខ្មុកត្រឹមចង្កេះ ហើយឆួតចំចង្កេះខ្មាក់មក
ត្រឹមកជើង ធ្វើឲ្យស្បែកខាងលើ គ្របលើសរីរៈខាងក្រោម មើលទៅដូច
ជាស្លៀកសំបកឈើ ធ្វើឯណេយ្យកកម្ម (ធ្វើឲ្យដូចជាជើងសត្វគ្រាយ)
គឺយកកងដែក ដាក់ត្រង់ដុំដៃទាំងពីរ លើកខ្លួនអ្នកគោសនោះ ដាក់
លើអណ្តាតទាំង ៤ មើលទៅឃើញមានសណ្ឋានដូចជើងគ្រាយ, ធ្វើព-
លិសមំសិកកម្ម (អំពើដែលគេថ្កត់មាត់ដោយកាង ឬ សន្ទូច) គឺយក
កាងទៅចោះឲ្យជាប់ទំងសាច់ស្បែក-សរសៃ ហើយភាញកន្ត្រាក់ឲ្យជាប់,
ធ្វើកហាបណាកកម្ម (អំពើដែលគេធ្វើឲ្យខូងសរីរៈប៉ុនកហាបណៈ) គឺគេ
យកចុងកាំបិតទៅខ្វៀលយកសាច់ ឲ្យមានរណ្តៅប៉ុនកហាបណៈ, ធ្វើ

ខាកបដិច្ចកកម្ម (អំពើដែលគេយកទឹកក្រូតស្រោច) គឺយកអាវុធទៅចាក់សាច់ ហើយយកទឹកក្រូតទៅស្រោចឲ្យលួចជ្រុះមាច់ចេញរហ័ទៅសល់តែឆ្អឹង, ធ្វើបលិឃបរិត្តកកម្ម (អំពើដែលគេធ្វើឲ្យដួចគេចង្កិលដើងគុល) គឺឲ្យអ្នកទោសដេកផ្អៀងម្ខាង យកដែកស្រួចទៅចោះប្រហោងត្រចៀកខាងលើ ឲ្យធ្លុះរហូតទៅដល់ប្រហោងត្រចៀកខាងក្រោម ហើយចាប់ដើងតាញចង្កិលឲ្យវិលខ្សាល់ដុំវិញ, ធ្វើបលាលបិឃកកម្ម (អំពើដែលគេធ្វើឲ្យដួចកណ្តាប់ចំបើង) គឺគេកាត់ពន្ទុះស្បែកចេញ យកដុំថ្មទៅគប់ដំបាឆ្អឹងជំនីរឲ្យខ្ទេច ហើយចាប់បួងសក់ឡើងត្រកាត់ត្រវែងឲ្យឆ្អឹងជ្រុះចេញ ទុកឲ្យសល់ទៅតែដុំសាច់, ស្រោចទឹកក្តៅ បណ្តេញរោមឲ្យដេញទាំ, ឲ្យដេកផ្ងារលើអណ្តាតទាំងរស់, កាត់ក្បាលដោយដាវ, សម្លាប់ឲ្យធ្វើខុក្ខវិនាសតែស្លាប់ក្នុងមិនោះ ។ ទេះ ជាអាទីនវៈនៃកាមទាំងឡាយ ។ល។

– ម្នាលភិក្ខុទាំងឡាយ ! កាមនេះ ជាហេតុ ។ល។ ជាបច្ច័យនៃកាមទាំងឡាយ បានជាមនុស្សប្រព្រឹត្តខុចរិត ដោយកាយ ដោយវាចា ដោយចិត្ត លុះស្លាប់ទៅ ទៅកើតឯអបាយ ទុគ្គតិ វិនិបាត នរក ។ ទេះ ជាអាទីនវៈនៃកាមទាំងឡាយ ។ល។

៣ – និស្សរណៈ : ធម៌ជាគ្រឿងរលាស់ចេញចាកកាម ។ ម្តេចគ្រាស់ថាបុគ្គលណា ជាគ្រឿងរលាស់ចេញចាកកាម ? ឧបាយជា

គ្រឿងកម្ចាត់បង់នូវឆន្ទរាគៈ ការលះបង់នូវឆន្ទរាគៈ ក្នុងកាមទាំងឡាយ ណា នេះ ជានិស្សរណៈជាគ្រឿងរលាស់ចេញនូវកាមទាំងឡាយ ។

-ម្នាលភិក្ខុទាំងឡាយ ! សមណៈនិងព្រាហ្មណ៍ មិនដឹងថា

๑- តម្រេកចំពោះកាមទាំងឡាយ ជាដូចគ្រឿងក្រេកក្រអាលផង

តាមានំ អស្សាទន្តេ អស្សាទនតោ,

๒- អាទីនវៈនៃកាមទាំងឡាយ ជាដូចទោសផង

តាមានំ អាទីនវន្តេ អាទីនវតោ,

๓- គ្រឿងរលាស់ចេញចាកកាមទាំងឡាយ ជាដូចគ្រឿងរលាស់ចេញចាកកាមផង

តាមានំ និស្សរណន្តេ និស្សរណតោ ។

ការពិត សមណៈឬព្រាហ្មណ៍ខោះ ធ្លើម្តេចឡើយកំណត់ដឹងនូវកាមទាំងឡាយនោះដោយខ្លួនឯងបាន? ឬក៏ទីធ្វើឱ្យជាំងឫគ្គលដទៃ ឱ្យកំណត់ដឹងនូវកាមទាំងឡាយនោះបាន ? សេចក្តីនេះ មិនជាហ៊ានៈទេ ។

ម្នាលភិក្ខុទាំងឡាយ ! សមណៈនិងព្រាហ្មណ៍ខ្លះ ដឹងថា

๑- តម្រេកចំពោះកាមទាំងឡាយ ជាដូចគ្រឿងតម្រេកផង

តាមានំ អស្សាទន្តេ អស្សាទនតោ,

๒- អាទីនវៈចំពោះកាមទាំងឡាយ ជាដូចទោសផង

តាមាន់ អាឥនវាញ្ហ អាឥនវាតោ,

៣-គ្រឿងរលាស់ចេញចាកកាមធាតុឯក ជាគ្រឿងរលាស់ចេញចាកកាមធាតុ

តាមាន់ ឯសញ្ញាណាញ្ហ ឯសញ្ញាណាតោ ។

តាមពិត សមណៈឬព្រាហ្មណ៍នោះ ឥតកំណត់ដឹងនូវគោសនៃកាមធាតុឯក ដោយខ្លួនឯងផង ដឹកនាំបុគ្គលដទៃឲ្យដឹងនូវគោសនៃកាមធាតុឯកនោះផង ។ នេះ ទើបជាហានៈ ។

សេចក្តីនិពន្ធ :

១-កិត្តុធាតុឯក! ចុះអ្វី ជាតម្រេកវបស់រូបធាតុឯក ហួចាន់អស្សាទៈ? ។ ខត្តិយកញ្ញា ព្រាហ្មណកញ្ញា គហបតិកញ្ញា អាយុ ១៥ឬ ១៦ ឆ្នាំ ដាស្រស់មិនខ្ចីស់ពេក មិនចាស់ពេក មិនស្គមពេក មិនធាត់ពេក មិនខ្មៅពេក មិនសពេក ដាស្រីមានសម្បុរល្អស្អាត សមរម្យ មានមែនឬទេ?

សូមទ្រង់ព្រះមេត្តាត្រាស! មានមែន ។

-ម្នាលកិត្តុធាតុឯក! សុខសោមនស្សដែលកើតឡើង ព្រោះអាស្រ័យសម្បុរល្អស្អាតសមរម្យនេះឯង ។ នេះ ជាតម្រេកវបស់រូបធាតុឯក ។

២- ម្នាលភិក្ខុចាំឆ្ងាយ! ចុះអ្វីជាគោសរបស់រូបចាំឆ្ងាយ ប្រាប់ចំ
អាចឹងវ៉ះ? កន្លងកាលជាងក្រោយមក ស្ត្រីចាំងនោះមានអាយុ ៨០
ឆ្នាំ ៩០ឆ្នាំ ១០០ ឆ្នាំ ជាស្ត្រីចាស់ជរា មានឆ្អឹងជំនីរគឹងកោងដូចបង្គន់
ផ្ទះ ដងខ្លួនកោងក្រងក់ កាន់ឈើច្រត់ ញ័រទ្រើក ដោយជរាបៀត-
បៀន មានវ័យជ្រុលភ្លេចហើយ ធ្មេញធ្លាក់គ្រហុប សក់ស្កូវសព្រោង
ក្បាលឆកពណ៌តត្រងាល ដើរភ្ជួញជ្រើរ ខ្លួនខុះដោយអាចម៍រុយ ។

អ្នកចាំឆ្ងាយឃើញថាដូចម្តេច? សម្បុរល្អស្អាតសមរម្យដូចពីដើមឬទេ? ។

ទេទេ! គានប្រាសៈ ។

ភិក្ខុចាំឆ្ងាយ! នេះ ជាអាទីនវៈរបស់រូបចាំឆ្ងាយ ។

- ម្នាលភិក្ខុចាំឆ្ងាយ! ស្ត្រីចាំងនោះ មានអាពាធលន់ទុក្ខឈឺ
ធ្ងន់ ដេកត្រាំ នៅកន្លង់ថ្កុកមូត្រទិដ្ឋលាមករបស់ខ្លួន គេជួយលើកទើប
ក្រោកបាន គេជួយឲ្យដើរទើបដើរបាន ឮសំណាងកាលពីដើមនោះ
អន្តរធានបាត់អស់ទៅ, គោសចាំឆ្ងាយកើតឡើងប្រាកដឬទេ?

សូមទ្រង់ព្រះមេត្តាប្រាសៈ ប្រាកដមែន! ។

ភិក្ខុចាំឆ្ងាយ! នេះជាអាទីនវៈរបស់រូបចាំឆ្ងាយ ។

- ម្នាលភិក្ខុចាំឆ្ងាយ! ស្ត្រីចាំងនោះ កាលគេយកសរីរៈទៅ
ចោលកន្លែងស្មសាន ស្លាប់អស់ ៣ថ្ងៃក្តី ៤ថ្ងៃក្តី កំពុងហើមប៉ោង មាន

សម្បុរខៀវ មានខ្ទុះហូរចេញ ។ សម្បុរល្អនៃស្ត្រីចាំងនេះ អន្តរាយជានបាត់អស់ទៅ តើសត្វតែងឡើងច្រាកដឬទេ ?

សូមទ្រង់ព្រះមេត្តាច្រើស ! ច្រាកដមែន ។

ភិក្ខុចាំង ! នេះជាអាទីនវៈរបស់រូបចាំងឯង ។

- ភិក្ខុចាំង ! ស្ត្រីចាំងនោះ កាលដែលគេយកសរីរៈទៅចោលកន្លងព្រៃស្មសាន ស្អែកចឹកស៊ីក្តី ភ្លាតចឹកស៊ីក្តី ត្រជកចឹកជាប់ស៊ីក្តី ស្វានកគេស៊ីក្តី បងកកគេស៊ីក្តី ឬណកជាតិផ្សេងៗ រុកជញ្ជក់ស៊ីក្តី ។ សម្បុរល្អនៃស្ត្រីចាំងនោះ អន្តរាយជានបាត់អស់ទៅ, តើសត្វតែងឡើងច្រាកដឬទេ ?

សូមទ្រង់ព្រះមេត្តាច្រើស ! ច្រាកដមែន ។

- ភិក្ខុចាំង ! ស្ត្រីចាំងនោះ កាលដែលគេយកទៅចោលកន្លងព្រៃស្មសាន នៅសល់តែគ្រោងឆ្អឹង ឥតមានសាច់ ប្រឡាក់ដោយឈាម ចងដោយសរសៃ ។ មិនមានសរសៃ ខ្ចាត់ខ្ចាយពាក់ព័ន្ធ ត្រង់នេះខ្លះត្រង់នោះខ្លះ ធ្លាក់នៅដោយឡែកពីគ្នា ។ សម្បុរល្អនៃស្ត្រីចាំងនោះ អន្តរាយជានបាត់អស់ទៅ, តើសត្វតែងឡើងច្រាកដឬទេ ?

សូមទ្រង់ព្រះមេត្តាច្រើស ! ច្រាកដមែន ។

ភិក្ខុចាំង ! នេះជាអាទីនវៈរបស់រូបចាំងឯង ។

- កិកូតាំងឡាយ ! ស្ត្រីតាំងនោះ កាលដែលគេយកទៅចោលនៅក្នុងព្រៃស្មសាន សល់តែឆ្អឹងខេ សដូចសម្បុរស័ង្ខ ពត់ពយគរនៅត្រង់នេះខ្លះត្រង់នោះខ្លះ កន្លងយូរឆ្នាំទៅ ពុកផុយខ្ទេចខ្ទី ។ សម្បុរល្អនៃស្រីតាំងនោះ អន្តរធានបាត់អស់ទៅ, តើសកើតឡើងក្រាកដឬទេ ?

សូមទ្រង់ព្រះមេត្តាត្រាស ! ក្រាកដមែន ។

កិកូតាំងឡាយ ! នេះ ជាអាទីនវៈរបស់រូបតាំងឡាយ ។

ភ- កិកូតាំងឡាយ ! ចុះអ្វីជាគ្រឿងរលាស់ចេញចាករូបតាំងឡាយ

រួចាំ ឯិសរ្ជរណា:? ។ ឧបាយជាគ្រឿងកម្ចាត់បង់នូវឆន្ទរាគៈ តាលេះបង់នូវឆន្ទរាគៈ ក្នុងរូប, នេះ ជាគ្រឿងរលាស់ចេញចាករូបតាំងឡាយ ។

- កិកូតាំងឡាយ ! សមណៈឬព្រាហ្មណ៍ មិនដឹងថា

១- តម្រេកចំពោះរូបតាំងឡាយ ថាជាគ្រឿងតម្រេក

រួចាំ អស្សាទន្តិ អស្សាទតោ,

២- អាទីនវៈរបស់រូបតាំងឡាយ ថាជាទោស

រួចាំ អាទីនវន្តិ អាទីនវតោ,

៣- ការរលាស់ចេញចាករូបតាំងឡាយ ថាជាគ្រឿងរលាស់

រួចាំ ឯិសរ្ជរណាន្តិ ឯិសរ្ជរណាតោ ។

នេះ មិនមែនជាហានៈទេ ។

– ភិក្ខុទាំងឡាយ! សមណៈនិងព្រាហ្មណ៍ ដែលថា

១– តម្រេកវបស់រូបទាំងឡាយ ជាផាសុ

រួចរាំង អស្សាទនៃ អស្សាទនោ,

២– អាទីនវៈរបស់រូបទាំងឡាយ ជាគ្រឿងតម្រេក

រួចរាំង អាទីនវស្មា អាទីនវោ

– ការរលាស់ចេញចាករូប ជាគ្រឿងរលាស់ចាករូប

រួចរាំង និស្សរណា នៃ និស្សរណោ ។ល។

ហេតុនេះជាហានៈ ។

សេចក្តីនិយាយ:

១- ភិក្ខុទាំងឡាយ! ពុះអ្វីជាតម្រេកវបស់វេទនា រួចរាំង អស្សាទនៈ? ភិក្ខុក្នុងសាសនានេះ ស្ងប់ចាកកាម ស្ងប់ចាកអកុសលធម៌ ចូលកាន់បឋមជ្ឈាន មានវិតក្កៈវិចារៈ មានបីតិសុខៈ ដែលកើតពីការស្ងប់អារម្មណ៍,កាលបើស្ងប់ហើយ សម័យនោះ ភិក្ខុនោះ មិនបានតិតៀតបៀនខ្លួនឯង មិនបានតិតៀតបៀនបុគ្គលដទៃ មិនបានតិតៀតបៀមខ្លួននិងបុគ្គលដទៃ មានតែចិត្តមិនប្រកបដោយឥទ្ធិបាតមិនរងវេទនា ជាចិត្តតែមួយ ។ នេះជាគតិសោលថា "តម្រេកវបស់វេទនា

អស់ផុតត្រឹមក្តីមិនព្យាបាទនេះឯង" ។

- ភិក្ខុទាំងឡាយ! ភិក្ខុក្នុងសាសនានេះ ចូលកន្លងទុតិយជ្ឈាន ចិត្តឡើងដល់ភាពខ្ពស់ប្រសើរ មិនមានវិតក្កៈវិចារៈមានតែបីតិនិងសុខៈដែលកើតពីសមាធិ ។ កាលបើរម្ងាប់វិតក្កៈ វិចារៈ ហើយសម័យនោះ ភិក្ខុនោះ មិនបានគិតបៀតបៀនខ្លួនឯង ។ល។ មានតែចិត្តវង្វេងវេទនាដែលមិនមានការព្យាបាទ ជាចិត្តតែមួយ ។ តថាគតពោលថា "តម្រេកបង់វេទនា អស់ផុតត្រឹមក្តីមិនព្យាបាទនេះឯង" ។

- ភិក្ខុទាំងឡាយ! ភិក្ខុ មានចិត្តជាឧបេក្ខា មានស្មារតីដ៏ខ្ជាប់ខ្ជួនវង្វេងក្តីសុខដោយកាយ ចូលតតិយជ្ឈាន ដែលព្រះអរិយៈសម្តែងថា "បុគ្គលដែលចូលតតិយជ្ឈាន តែងមានចិត្តជាឧបេក្ខា មានស្មារតី នៅជាសុខ ។ កាលបើអស់នៃវនៃចិតិ ក្នុងសម័យនោះ ភិក្ខុនោះមិនគិតបៀតបៀនខ្លួនឯង ។ មានតែចិត្តវង្វេងវេទនា ដែលមិនមានក្តីព្យាបាទ ជាចិត្តមួយ ។ តថាគតពោលថា "តម្រេកបង់វេទនាអស់ផុតត្រឹមក្តីមិនព្យាបាទនេះឯង" ។

ភិក្ខុទាំងឡាយ ! ភិក្ខុចូលកាន់ចតុត្ថជ្ឈាន មិនមានសុខនិងទុក្ខ មានសតិដ៏បរិសុទ្ធក្នុងឧបេក្ខា ព្រោះលះបង់សុខផង លះបង់ទុក្ខផង ។ សោមនស្សនិងទោមនស្ស កាលពីមុនមោះ រំលត់អស់ហើយ

លុះលះបង់ខ្លួវសុខហើយ សម័យនោះ កិក្ខុនោះ មិនគិតបៀតបៀនខ្លួនឯង ។ល។ មានតែចិត្តវង្វេងវេទនាដែលមិនមានក្តីភ្ញាក់ផ្អើលជាចិត្តតែមួយ ។ តថាគតពោលថា "តម្រេកវេទនា អស់ផុតត្រឹមតែមិនភ្ញាក់ផ្អើលនេះឯង" ។

២- កិក្ខុទាំងឡាយ ! ចុះអ្វីជាទោសវេទនាទាំងឡាយ វេទនាជាទុក្ខអាងីឯវ:? វេទនា មិនទៀង ជាទុក្ខ មានការប្រែប្រួលទៅជាធម្មតា នេះជាទោសវេទនាទាំងឡាយ ។

៣- កិក្ខុទាំងឡាយ ! ចុះអ្វីជាគ្រឿងរលាស់ចេញចាកវេទនាទាំងឡាយ វេទនាទំ និស្សរណ:? ។ ឆន្ទរាគៈជាគ្រឿងកម្ចាត់បង់ខ្លួវធន្លួកគ: ការលះបង់ខ្លួវធន្លួកគ: ក្នុងវេទនាទាំងឡាយ នេះ ជាគ្រឿងរលាស់ចេញខ្លួវវេទនាទាំងឡាយ ។

- កិក្ខុទាំងឡាយ ! សមណ:ឬព្រាហ្មណ៍ មិនបានដឹងខ្លួវតម្រេកវេទនាទាំងឡាយ ថាជាគ្រឿងត្រេកអរ ។ល។ នេះមិនមែនជាហាន:ទេ ។

- កិក្ខុទាំងឡាយ ! សមណ:ឬព្រាហ្មណ៍ដឹងខ្លួវតម្រេកវេទនាថាជាគ្រឿងត្រេកអរ ។ល។ នេះ ទើបជាហាន: ។

សេចក្តីកន្លងសូត្រនេះ នាំឲ្យយើងយល់ច្បាស់ថា ព្រះពុទ្ធជាអ្នក

ប្រាកដនិយម ទើបជាអ្នកយល់ត្រូវ ។ ទ្រង់សម្តែងធម៌ ទៅតាមការប្រាកដ និងតាមយល់ក្លឹត ព្រោះការណាបើយើងមើលឃើញរូបអ្វីមួយល្អ គួរជាទីពេញចិត្ត គួរជាទីគាប់ភ្នែក យើងមានការស្ងួចភាន់កើតតម្រេកចង់បានរូបនោះ ទោះជារូបអ្វីក៏ដោយ ជាបុរស ឬស្ត្រី រូបនោះគាញចិត្តយើង យើងចូលចិត្តមើល មើលហើយមើលទៀត មើលជាប់ចិត្តគាល់តែកើតតម្រេក "អស្សាទៈ" ។ សេចក្តីនេះ ទុកជាកត្តាមួយនៃការពិសោធ ។ តម្រេក "អស្សាទៈ" នេះ ជាធម៌មិនទៀងទាត់ ព្រោះរូបដែលគាញចិត្តនោះ ជារបស់មិនទៀង ។

(ដៅមានត)

រឿងព្រះនាងសាមាវតី

[ត]

លោក ប៊ូ-ប៉ូ ប្រែ-រៀបរៀង

ព្រះរាជា អញត្រូវទៅគាល់តែបាន ។

ព្រះនាងធ្វើជាទូលហាមឃាត់ជាដរាបហើយ ក្រាបទូលថា កាលបើដូច្នោះ ឯខ្ញុំម្ចាសក៏ទ័ងតាមស្តេចព្រះអង្គផង ទោះបីព្រះអង្គច្រាច់ឲ្យត្រឡប់វិញ ក៏មិនព្រមត្រឡប់ដែរ បានតាមស្តេចទៅជាមួយព្រះរាជាគាល់តែបាន ក្រាបទូលសេចក្តីថា ខ្ញុំម្ចាស់មិនដឹងថាអ្វីនឹងមានដល់ព្រះអង្គ ព្រះសម្ងួតខ្លួន ។ ព្រះរាជាទ្រង់អាសណៈព្រះកូសាមាលាគន្ធជាតិដែលព្រះនាងសាមាវតីជាប្រមុខទូលថ្វាយ ហើយសោយព្រះក្រយាហារដ៏មានឧត្តមរស ទ្រង់ជាក់ពិណលើព្រះខែនខាងព្រះសិរះហើយទ្រង់ផ្ងើលើព្រះខែន ។ ព្រះនាងមាគន្ធិយាធ្វើជាគ្រាច់ទៅ ។ មក ។ ហើយដកឆ្នុកផ្លាចាកប្រហោងពិណ ។ ពស់ច្រាសចាកអាហារអស់ពីរបីថ្ងៃលួនពេញចាកប្រហោងនោះ សប្បាយចិត្តទើបដកពពាងចេញលើទ័ព្រះបន្ទំ ។ ព្រះនាងមាគន្ធិយាឃើញពស់ ទើបស្រែកភ្ញាក់សម្លេងថា ពស់ព្រះអង្គ កាលតិះដៀលព្រះរាជា ដេរព្រះនាងសាមាវតីនឹងស្តេច

ចរិតរបស់ខ្លួនដោះ ទើបពោលថា ម្នាលផែនដីលូនដ៏អង្គុះនេះគ្មានបុណ្យទេ មិនជឿពាក្យរបស់អញម៉្លេះតាំងនេះក៏គ្មានសំរាំដែរ ណែនាំបានត្រូវ (ក្បាលរឹង) អ្នកឥតដឹងមិនបានអំពើសម្អាតព្រះពុទ្ធ ពួកឯង កាលព្រះអង្គនេះចរិតហើយ ទើបទៅសច្ឆាយប្តូរអ្វី កាលព្រះអង្គឥតដឹងព្រះជន្ម ៧ រស់ទៅលំបាកណាស់ ថ្ងៃនេះខ្ញុំម្ចាស់ឃើញ បុបិនដឹងក្រក់អាក្រក់ហើយ ព្រះអង្គបម្រើកាលខ្ញុំម្ចាស់ល្អហាមប្រាមថាមិនគួរស្តេចយាងទៅប្រាសាទនាងហាវតី តើមិនស្ងាត់បម្រុងសោះ ព្រះអង្គ (ទើបកើតហេតុកំណាចដូច្នេះ) ។ ព្រះពុទ្ធរតនយើញតាប់ហើយទ្រង់ស្តុតព្រះហប្តទ័យខ្លាចអំពីមរណភ័យ ទ្រង់ព្រះតម្រិះថា មើអស់នេះធ្វើដល់ប៉ុណ្ណេះ ចំណែកអញអាក្រក់មិនជឿពាក្យរបស់នាងមាគន្ធិយានេះ ប្រាប់អាការដែលមើអស់នេះលាមក គ្រាមុនចោះប្រហោងកូនចន្ទបំរបស់ខ្លួនអង្គុយ (មើលព្រះសមណគោតមត្រង់ផ្នែងនោះ) គ្រាមួយទៀតផ្ទៃមាន់ ដែលអញបញ្ជូនទៅឲ្យត្រឡប់មកវិញថ្ងៃនេះលែងពស់លើដំណេកហើយ បានកើតបីដូចជាគឺសេចក្តីក្រោធឲ្យនេះក្តីច្រាលហើយ ។ ចំណែកព្រះសាមាវតីបានឮពាក្យទីក្រដាសដល់ស្រីបរិវារប្រាប់យ៉ាងថា នាងតាំងឡាយ ទីពឹងយ៉ាងដទៃរបស់ពួកយើងគ្មានទេ ពួកនាងចូរញ៉ាំងមេត្តាចិត្តឲ្យប្រព្រឹត្តទៅស្មើគ្នាតែម្តង កុងព្រះអង្គជាកំពូលមនុស្សនៃងវើ

ទិន្នខ្លួនផង កុំធ្វើសេចក្តីក្រោធចំពោះដល់អ្នកណា ។ ឱ្យ ។ ព្រះកាល
ទ្រង់គាន់ព្រះស្នែងធ្ងន់មានសណ្ឋានដូចស្នែង ដែលទឹងគោងបានដោយ
ត្រូវប្រើកម្លាំងមនុស្សដែលពាន់នាក់ ទ្រង់រាយវែងប្រទោះជាក់ផ្លាប់កូនសរ
ដ៏លាបថ្នាំពិសហើយទ្រង់ធ្វើព្រះនាងសាមាវតីទុកក្នុងវាងមុខ ទ្រង់ឲ្យ
នាងចាំងអស់ឈរបន្តគ្នាដោយលំដាប់ហើយ ពន្លឺងកូនសរត្រង់ទុរ-
ប្រទេសព្រះនាងសាមាវតី ។ កូនសរនោះហក់ត្រឡប់បែរមុខចំពោះ
ផ្លូវដែលមក ដោយអានុភាពនៃមេត្តារបស់ព្រះនាង បានតាំងនៅ ហាក់
ដូចជានឹងបួលទៅចាក់ព្រះហឫទ័យរបស់ព្រះរាជាហើយ ។ ព្រះរាជា
ទ្រង់ព្រះតម្រិះថា កូនសរដែលអញបាញ់ទៅ សូម្បីសិលាក៏ចោះខ្ទុះ
ទៅបាន សូម្បីទីភ្លាប់ខ្ទប់កំពង់អាកាសក៏មិនបានមាន ក៏កាលបើដូច្នោះ
កូនសរនេះវិលត្រឡប់បែរមុខចំពោះដល់ហឫទ័យរបស់អញ សេចក្តីពិត
សូម្បីកូនសរនេះក៏ឥតចិត្ត មិនមែនសត្វ មិនមែនជីវិត នៅតែដឹងគុណ
របស់នាងសាមាវតីនេះ ចុះអញជាមនុស្សក៏មិនដឹងគុណសោះ ។ ព្រះ
រាជា (ទ្រង់ព្រះតម្រិះដូច្នេះហើយ) ចោះឆ្លុចាល ទ្រង់គង់ព្រះហោង
ប្រណម្យអញ្ជលីទីដំណើរព្រះនាងសាមាវតី ត្រាស់ព្រះគាថានេះ
សេចក្តីថា ៖

ខ្ញុំរង្គើទៅព្រម ទន្ទឹមមុខ ដែលទាំងឡាយចាំងអស់ដងឆឹងឈឺងដល់

ខ្ញុំ សាមាវតី នាងចូរការពារខ្ញុំទុក នឹងនាងចូរជាទីពឹងរបស់ខ្ញុំចុះ ។

ព្រះនាងស្តាប់ព្រះពាក្យតម្រាស់របស់ព្រះរាជាហើយ មិនបានទូលថា ប្រពៃហើយ ព្រះអង្គដ៏ប្រសើរ ព្រះអង្គចូរដល់ខ្ញុំម្ចាស់ជាទីពឹងចុះ (ដូច្នេះទេ) ក្រាបទូលថា បពិត្រព្រះមហារាជ ខ្ញុំម្ចាស់ដល់លោកឯណាថាជាទីពឹង សូម្បីព្រះអង្គក៏ចូលដល់លោកនោះឯងថាជាទីពឹងចុះ ។

ព្រះនាងសាមាវតី ជាសាវិការនៃព្រះសម្មាសម្ពុទ្ធគោលដូច្នេះហើយ ក្រាបទូលថា ៖

សូមព្រះអង្គ កុំបានដល់ខ្ញុំម្ចាស់ថាជាទីពឹងឡើយ ខ្ញុំម្ចាស់ដល់លោកឯណាថាជាទីពឹង លោកនោះជាព្រះពុទ្ធ ព្រះមហារាជ លោកនោះជាព្រះពុទ្ធ រកអ្នកឲ្យក្រៃលែងជាងគ្មានទេ ព្រះអង្គចូរដល់ព្រះពុទ្ធអង្គនោះជាទីពឹងចុះ នឹងសូមព្រះអង្គជាទីពឹងរបស់ខ្ញុំម្ចាស់ ។

ព្រះរាជាទ្រង់ព្រះសណ្តាប់ពាក្យរបស់ព្រះនាងហើយត្រាស់ថា ឥឡូវនេះ ខ្ញុំខ្លាចទាំងណាស់ ហើយត្រាស់ព្រះគាថានេះ សេចក្តីថា ៖

ខ្ញុំរង្គើងវិលវល់ដោយក្រៃលែង គ្រប់ទិសឯងនឹងដល់ខ្ញុំសាមាវតី នាងចូរការពារខ្ញុំទុក នឹងនាងចូរជាទីពឹងរបស់ខ្ញុំចុះ ។

លំដាប់នោះ ព្រះនាងខំបន្ទន់ហាមឃាត់ព្រះរាជាដោយន័យមុនទៀត ក៏ត្រាស់ថា បើដូច្នោះ ខ្ញុំសូមដល់នាងផង ព្រះ

សាស្តាផង ជាទីពឹង នឹងខ្ញុំឲ្យពរដល់នាងខ្លួលថា មហាភជ ពរ
ប្អូរជាពរដែលខ្ញុំម្ចាស់ខ្លួលទុកហើយ ។ ព្រះភជាចូលទៅគាល់ព្រះ
សាស្តា ទ្រង់ដល់ព្រះអង្គជាទីពឹងហើយ ទ្រង់និមន្តដើម្បីសោយក្នុង
ព្រះភជវាំង ថ្វាយទានដល់ភិក្ខុសង្ឃអស់ ៧ ថ្ងៃហើយ ត្រាស់ហៅព្រះ
នាងសាមាវតីមកប្រាប់ថា ក្រោកទៅឯខ្លួលពរចុះ ។

ព្រះនាង – បពិត្រព្រះមហាភជ សេចក្តីត្រូវការរបស់ខ្ញុំម្ចាស់ដោយ
ប្រាកដជាដើមគ្មានទេ ប៉ុន្តែ សូមទ្រង់ប្រោសព្រះភជទានពរនេះដល់ខ្ញុំ
ម្ចាស់ ព្រះសាស្តាព្រមទាំងភិក្ខុប្រាំរយរូបស្តេចមកភត្តទីនេះជានិច្ចដោយ
ប្រការយ៉ាងណា សូមព្រះអង្គទ្រង់ធ្វើដោយប្រការយ៉ាងនោះ ពួកខ្ញុំ
ម្ចាស់នឹងស្តាប់ធម៌ ។

ព្រះរាជាថ្វាយបង្គំព្រះសាស្តាហើយក្រាបទូលថា បពិត្រព្រះអង្គ
ដ៏ចម្រើន សូមនិមន្តព្រះអង្គព្រមទាំងភិក្ខុប្រាំរយរូបស្តេចមកភត្តទីនេះ
ជានិច្ច នាងសាមាវតីជាប្រមុខប្រាប់ថា នឹងស្តាប់ធម៌ ។

ព្រះសាស្តា – មហាបពិត្រ ធម្មតាព្រះពុទ្ធទាំងឡាយស្តេចទៅ
ភត្តទីតែមួយកន្លែងជានិច្ចមិនគួរទេ ព្រោះមហាជនប្រាថ្នាចំពោះ ។

ព្រះរាជា – បើដូច្នោះ សូមព្រះអង្គទ្រង់បង្គាប់ភិក្ខុមួយរូប ព្រះអង្គ ។
ព្រះសាស្តាទ្រង់ចាត់ទុកលើព្រះអានន្ទ ។ តាំងអំពីខ្លួលព្រះតម្រាស់

មក អានន្ទនាំកិក្ខុប្រាំរយរូបទៅកាន់ត្រកូលជានិច្ច ។ ឯព្រះខេវិ
ទាំងនោះក៏និមន្តព្រះថេរៈព្រមទាំងភិក្ខុជាបរិវារឲ្យឆាន់ ទ្រង់ស្តាប់ធម៌
ជានិច្ច ។ ថ្ងៃមួយ ព្រះខេវិទាំងនោះ ទ្រង់ស្តាប់ធម្មកថារបស់ព្រះ
ថេរៈហើយ ទ្រង់ជ្រះថ្លា បានទ្រង់ធ្វើការបូជាធម៌ដោយសំពត់ឧត្តរា-
សង្គៈ គឺក្រមាចង្កឹ ប្រាំរយផត់ ។ ឧត្តរាសង្គៈមួយ ។ តម្លៃដល់ប្រាំ-
រយកហាបណៈ ។

ព្រះរាជាមិនទ្រង់ឃើញសំពត់របស់ពួកព្រះនាងដល់មួយសោះ ទើប
ត្រាស់សួរថា សំពត់ឧត្តរាសង្គៈរបស់ពួកនាងទៅឯណា ។

ព្រះខេវិ - សូមព្រះតេជៈ ថ្វាយដល់លោកជាម្ចាស់របស់យើង ។

ព្រះរាជា - លោកទទួលយកទាំងអស់ទៅឬ ។

ព្រះខេវិ - ពារម្ចាស់ ទទួលយកទាំងអស់ ។

ព្រះរាជាស្តេចចូលទៅរកព្រះថេរៈហើយត្រាស់សួរអាការ ដែលពួក
ព្រះខេវិថ្វាយសំពត់ឧត្តរាសង្គៈ ទ្រង់ព្រះសណ្តាប់ការៈដែលពួកនាងថ្វាយ
និងការៈដែលព្រះថេរៈទទួលទុកហើយ ត្រាស់ថា លោកម្ចាស់ សំពត់
ច្រើនណាស់មែនឬទេ លោកនឹងធ្វើដូចម្តេច ដោយសំពត់ប្រមាណ
ប៉ុណ្ណេះ ។

ព្រះថេរៈ - សូមថ្វាយព្រះពរ អាត្មាភាពកាន់យកតែល្អ ។ ដល់

អាត្មាភាពហើយ ឲ្យដែលសល់(អំពីនោះ)ដល់តិក្ខមានចរិយចាស់ ។

ព្រះរាជា - លោកម្ចាស់ចាំនឹងនោះ នឹងធ្វើដូចម្តេចដោយចរិយចាស់របស់ខ្លួន ។

ព្រះឥសី - លែកនឹងឲ្យដល់តិក្ខដែលមានចរិយចាស់ជាង ។

ព្រះរាជា - លោកចាំនឹងនោះនឹងធ្វើក្តីដោយចរិយចាស់របស់ខ្លួន ។

ព្រះឥសី - លោកធ្វើសំពត់បច្ចត្តរណៈ(កន្ទ្រាល) ។

ព្រះរាជា - ចុះសំពត់បច្ចត្តរណៈចាស់នឹងធ្វើជាអ្វី ។

ព្រះឥសី - ធ្វើជាសំពត់ក្រាលផ្ទៃ ។

ព្រះរាជា - ចុះសំពត់ក្រាលផ្ទៃចាស់នឹងធ្វើជាអ្វី ។

ព្រះឥសី - នឹងធ្វើជាសំពត់ជូតជើង មហារាជ ។

ព្រះរាជា - ចុះសំពត់ជូតជើងចាស់នឹងធ្វើជាអ្វី ។

ព្រះឥសី - នឹងដំឲ្យជាចំរៀកតូចចំរៀកធំ ហើយប្រថាប់លាយនឹងដីលាបជញ្ជាំង ។

ព្រះរាជា - លោកម្ចាស់ សំពត់ដែលថ្វាយលោកម្ចាស់ នឹងមិនថាត់បង់ឡើយ ព្រោះធ្វើដល់ប៉ុណ្ណោះ ។

ព្រះឥសី - សូមថ្វាយព្រះពរ មហាបពិត្រ ។

ព្រះរាជាទ្រង់ជ្រះថ្លា បង្គាប់ឲ្យកសំពត់ច្រាំរយមកទៀត ត្រាស់

ប្រាប់ឲ្យតម្កល់ខ្ទុកកន្ធឹដ៏ជិតព្រះបាទព្រះថេរៈបាន ។ ដូចបានឮមក ព្រះថេរៈបានសំពត់តម្លៃប្រាំរយកហាបណៈ ដែលគេតម្កល់ខ្ទុកជិតព្រះបាទថ្វាយដោយចំណែកប្រាំរយ ។ ជង្ឃ បានសំពត់តម្លៃមួយពាន់កហាបណៈ ដែលគេតម្កល់ខ្ទុកជិតព្រះបាទថ្វាយដោយចំណែកមួយពាន់ ។ ជង្ឃ បានសំពត់តម្លៃមួយសែនកហាបណៈដែលគេតម្កល់ខ្ទុកជិតព្រះបាទថ្វាយដោយចំណែកមួយសែន ។ ជង្ឃ ។ ចំណែកសំពត់ដែលបានដោយន័យដូច្នេះ មួយផ្នត់ ពីរផ្នត់ បីផ្នត់ បួនផ្នត់ ប្រាំផ្នត់ ដប់ផ្នត់ជាអាទិកម្មិនអស់ទេ ។ បានឮថា កាលព្រះតថាគតទ្រង់ប្រទានហើយ ព្រះថេរៈបានត្រាច់ទៅកាន់ជម្ពូទ្វីបទាំងអស់ឲ្យបាត្រចីវរបស់ខ្លួន ដល់បណ្តាភិក្ខុគ្រប់ ។ វិហារ ។

(មានសំនួរថា) ចុះព្រះថេរៈធ្វើដូចម្តេច ទើបបានសំពត់ច្រើនដល់ប៉ុណ្ណោះ ។

(មានចម្លើយថា) បានថាឮ ព្រះថេរៈកន្ធឹជាតិមុន កាលកើតជាជាងតម្បាញ បានថ្វាយកំណាត់សំពត់មួយបន្ទះប៉ុនបាតដៃព្រមទាំងម្ជុលមួយចំពោះព្រះបច្ចេកពុទ្ធមួយព្រះអង្គ ។ ព្រោះផលនៃការឲ្យទានកំណាត់ទើបព្រះថេរៈបានសំពត់មានចំនួនច្រើនដល់ប៉ុណ្ណោះ តាមចំនងនេះ ។

គ្រានោះ ព្រះនាងមាគន្ធិយោគិតថា អញធ្វើអំពើណា អំពើ

នោះមិនបានសម្រេចផលដូច្នោះសោះត្រឡប់ទៅយ៉ាងដដែរវិញ អញនឹងធ្វើដូចម្តេចទៀតអេះ កំយេញឧបាយមួយនេះល្អ កាលដែលព្រះរាជាស្តេចយាងទៅប្រពាតព្រះរាជឧទ្យាន ទើបបញ្ជូនសាសន៍ទៅដល់មាន (នាយមាគន្ធិយ:) សេចក្តីថា លោកមាចូរទៅគាន់ថ្វាយទានាងសាមាវតី ថ្វាយឲ្យក្អាកងារបេកឃ្មាំងសំពត់នឹងឃ្មាំងប្រេងកាត ហើយយកសំពត់ជ្រលក់ចុះក្នុងប៉ាតប្រេងកាតឲ្យជោកស្រួចរុំសសរ ប្រមូលនាងទាំងអស់នោះឲ្យទៅក្នុងផ្ទះមួលគ្នា បើឮថាជាតគន្ធីរពងង៉ក្រៅឲ្យជាប់ហើយយកប្រទីបមានដង់សម្រាប់គាន់ឆេះភ្លើង (ឲ្យឆេះសសរ) រួចក្អាមចុះដើរគេចទៅឲ្យហ៊ាស ។ នាយមាគន្ធិយៈទៅដែរទៅលើថ្វាសាទហើយ ថ្វាយឲ្យក្អាកងារបើកឃ្មាំងយ៉ាងប្រញាប់យកសំពត់ជ្រលក់ក្នុងប៉ាតប្រេងកាតហើយប្រដាប្រដងដុំសសរ ។ គ្រានោះស្រាប់តាំងឡាយមានព្រះនាងសាមាវតីជាប្រធានភាកសួរថា ធ្វើអ្វីហ្នឹង លោកមាស្តេចចូលទៅដំណ ។

នាយមាគន្ធិយ:- ព្រះនាងតាំងឡាយ ព្រះរាជាត្រាស់ថ្វាយឲ្យបេកតំណាត់សំពត់ជ្រលក់ប្រេងកាតរុំសសរតាំងនេះ ដើម្បីត្រូវការអ្វីឲ្យមាំមួន ព្រោះធម្មតាកូនតំណាក់ល្ងង់ គេប្រកបល្អក្នុងខ្លះអាក្រក់ក្នុងខ្លះដឹងបានដោយក្រ តុំទៅក្នុងសំណាក់ខ្ញុំព្រះអង្គឡើយ ព្រះនាងតាំង

ឡាយ ពោលដូច្នេះហើយលួងលោមព្រះនាងដែលស្តេចមកសាកសួរឱ្យ
ចូលទៅកាន់បន្ទប់ហើយបិទទ្វារដោកគន្ធីះនាងក្រៅជាប់យកភ្លើងឆួលឱ្យឆេះ
តាំងអំពីដើម រួចដើរចេញទៅបាត់ ។

ព្រះនាងសាមាវតីជាទេវីឃើញនូវតដល់នាងទាំងនោះថា កាលយើង
គឺអគ្គមហេសីទាំងឡាយគ្រាចនោកន្លងសង្សារដ៏គ្មានទីបំផុត ត្រូវភ្លើងឆេះយ៉ាង
នេះ សូម្បីព្រះពុទ្ធញាណក៏កំណត់មិនបានដោយ ពួកនាងចូរមិនប្រមាទ
ចុះ ។ ព្រះទេវីទាំងនោះកាលភ្លើងឆេះតំណាក់ ធ្វើកម្មដ្ឋានកំណត់វេទនា
ជាអារម្មណ៍ទុកក្នុងចិត្ត ពួកខ្លះសម្រេចទុតិយផល ពួកខ្លះសម្រេច
តតិយផល ។

គ្រានោះហើយ លោកតើបគោលទុកថា គ្រានោះឯងកិកុជា
ច្រើនរូប ត្រឡប់មកពីចំណូបាតកន្លងបច្ចាគត្តហើយព្រះដ៏មានព្រះភាគ
គង់ដោយពីណា ចូលទៅគាល់ដោយទីនោះ លុះចូលដល់ហើយទើប
ថ្វាយបង្គំព្រះដ៏មានព្រះភាគអង្គុយក្នុងចំណែកម្ខាង កិកុទាំងនោះកង្គុយ
ហើយក្នុងចំណែកម្ខាងពិត ឃានក្រោយទូលសេចក្តីនេះនឹងព្រះដ៏មាន
ព្រះភាគថា : បពិត្រព្រះអង្គដ៏ចំរើន ថ្ងៃនេះ កាលព្រះឃានុនេនស្តេច
ហោះទៅព្រះរាជនិវេសន៍ ភ្លើងឆេះខាងក្នុងព្រះបុរីហើយ ស្រីប្រាំរយ
នាក់មានព្រះនាងសាមាវតីជាប្រធានធ្វើមរណកាលហើយ គតិរបស់

ឧបាសិកាចាំដ៏នោះជាយ៉ាងណាទៅព្រះអង្គ ។ ម្នាលភិក្ខុចាំដ៏ឆ្លាយ
កន្ដឧបាសិកាចាំដ៏នោះ ឧបាសិកាជាព្រះសោតាបន្នក៏មាន ជាព្រះ
សកទាគាមិនីក៏មាន ជាព្រះអនាគាមិនីក៏មាន ភិក្ខុចាំដ៏ឆ្លាយឧបាសិកា
ចាំដ៏នោះត្រង់គ្នាមិនឥតផលទេធ្វើមរណកាលៈហើយ ។ លុះព្រះដ៏មាន
ព្រះភាគទ្រង់ជ្រាបសេចក្ដីនោះហើយ ឃានទ្រង់ឧទ្ទឹងឧទានេះក្នុងវេលា
នោះមានសេចក្ដីថា ៖

[នៅមានត]

ផ្នែកអក្សរសាស្ត្រ

គួរតែរៀបចំសង្គមសាសនាឡើងវិញ

ដោយ ធល-ទិត

ពួកកុមារនិស្ស័យ ឃោសនាអប់រំគ្នាថា "សាសនាដែលគម្រក់ជាងគេគឺ ពុទ្ធសាសនា ព្រោះសាសនានេះ រាំងកន្លែវការចម្រើនលូតលាស់របស់ប្រទេសជាតិ, រីឯពួកមនុស្សដែលគម្រក់ជាងគេវិញ គឺលោកសង្ឃ ព្រោះពួកនេះ ចោកគេស៊ីដើម្បីរស់ស្រួល, ឥតមានធ្វើការអ្វីសោះ" ។

សួរ:- តើការពិត យ៉ាងហ្នឹងមែនឬ ?

ឆ្លើយ:- និយាយអ៊ីចឹង ក៏ត្រូវម្យ៉ាងដែរ ព្រោះព្រះពុទ្ធក៏ទ្រង់ចាន់សារភាពថា "លោកអប់រឿងជាតិហើយ", ឯលោកសង្ឃវិញ ក៏លោកចាន់សារភាពដែរថា "ហោរស់នៅដោយហោរគេទៀ" អ៊ីចឹងមែន ។ ប៉ុន្តែ យើងក៏មិនត្រូវធ្វើរាក់ទឹថ្លង់ (មិនយើញមិនឮនូវការពិតនៃសកម្មភាពរបស់ពុទ្ធសាសនាខ្មែរនេះ) ដែរ ។

ពុទ្ធសាសនា ជាសាសនាសម្រាប់សាកលលោក ជាសាសនាប្រធាន៏ធ៏មហិច្ឆតារបស់មនុស្សលោកពិតប្រាកដ ប៉ុន្តែ ពុទ្ធសាសនានៅប្រទេសខ្មែរនេះ គេមិនត្រូវយល់ច្រឡំថា ជាពុទ្ធសាសនាសកល-

លោក ឬជាពុទ្ធសាសនាឥណ្ឌា - ពុទ្ធសាសនាសៀម - ពុទ្ធសាសនាលាវ - ពុទ្ធសាសនាចិន - ពុទ្ធសាសនាយួនជ្រើយ គឺពិតជា "ពុទ្ធសាសនាខ្មែរ" សុទ្ធសាធ ។ ដូចេ្នះ ជាប្រថមត្រូវស្គាល់ឲ្យច្បាស់ថា "ពុទ្ធសាសនា" ផ្សេង "ពុទ្ធសាសនាខ្មែរ" ផ្សេង ប៉ុន្តែ "ពុទ្ធសាសនាខ្មែរ" គឺកូនបង្កើតរបស់ "ពុទ្ធសាសនា" នោះឯង ។

- តើ "ពុទ្ធសាសនាខ្មែរ" នេះ មានភាពផ្សេងពី "ពុទ្ធសាសនា" ត្រង់ណាខ្លះ ?

- គឺត្រង់ចំណុចដែលខ្មែរបានបញ្ចូលបញ្ហាជាតិភ្ជាប់ជាមួយផង ។ ដូចពោលហើយថា "ពុទ្ធសាសនា ជាសាសនាអស់រឿងជាតិ" គឺសង្គ្រោះក្រោសមនុស្សទាំងអស់ឲ្យអស់រឿងជាតិ ។ ការអស់រឿងជាតិនេះ ពិតជាធ្វើឲ្យមនុស្សលោកបានសុខសន្តិភាពមែន ព្រោះវាអស់រឿងប្រកួតប្រជែងរកធ្វើជាតិនិងជាតិ ប៉ុន្តែបើមនុស្សលោកនោះតែមានរឿងជាតិមិនទ្រមអស់សោះ តើធ្វើម៉េចនឹងយើញភាពសុខសន្តិភាពតាមបំណងពុទ្ធសាសនាបាន? ។ ការដែលមនុស្សទុទ្ទោតុំទ្រមអស់រឿងជាតិនេះឯងហើយ ទើបខ្មែរអ្នកកាន់ពុទ្ធសាសនា សម្រេចចិត្តសម្រេចសម្រួលពុទ្ធសាសនានេះឲ្យស្របគ្នានឹងបញ្ហាជាតិបន្ថែមទៀត តាំងវិស័យទាំងឡាយ មានវិស័យបង្គមកិច្ច វប្បធម៌ អប់រំ និងវិស័យការពារជាតិជាដើម ។ ការបម្រួមសម្រួលបញ្ចូលពុទ្ធសាសនានឹងបញ្ហាប្រវេស-

ជាតិឲ្យស្រេចគ្នាតាមខេមរវិធីនេះឯងហើយ ទើបពុទ្ធសាសនានេះ ចាន់
ចេញជារូបថ្មីមួយទៀត មានឈ្មោះថា "ពុទ្ធសាសនាខ្មែរ" ជាហូរហែ
តាំងពីបុរាណកាលមក (មិនមែនទំនើបទេ) ។

– តើការចាត់ប្ចាំលបញ្ជាជាតិទៅក្នុងពុទ្ធសាសនាដោយវិធីណា ?

– ដោយវិធីយកពុទ្ធសាសនាធ្វើជាមូលដ្ឋានម្ខាង យកបញ្ជាជាតិជា
មូលដ្ឋានម្ខាង មកជាក់សម្រេចគ្នា ឲ្យដូចជាកង់ពីរដែលទ្រទ្រង់រទេះមួយ
ដើម៉ាំ ដូច្នោះ ។ ពុទ្ធសាសនា ចាត់ថាជាទ្រឹស្តីកម្ពុនិយម, ដើម្បីឲ្យទ្រឹស្តី
នេះប្រព្រឹត្តទៅបាន លុះតែមានមនុស្សអ្នកអនុវត្ត, អ្នកអនុវត្តនោះ ត្រូវ
តែជាអ្នកចេះដឹងជ្រៅជ្រះផង ចេះប្រតិបត្តិខ្ជិនឯងផង ចេះដឹកនាំគេឲ្យ
ប្រតិបត្តិបានផង ។ តើមានអ្នកណាដែលមានលក្ខណៈទាំងនេះពេញ
លេញជាងលោកសង្ឃ ? ដូច្នេះ ម៉េនិយាយពីពុទ្ធសាសនាខ្មែរ
ត្រូវតែនិយាយពីលោកសង្ឃខ្មែរគ្រាប់ជាមួយផង ពុំអាចកាត់ចេញពីគ្នា
បានឡើយ ។

ពាក្យថា "លោកសង្ឃ ម៉េតាមវិន័យ គឺជានាមរបស់ពួកតិក្ខុបួនរូប
ឡើងទៅ ប៉ុន្តែខ្មែរនិយមយួទៅហៅពាក្យថា "លោកសង្ឃ" នេះ សំដៅ
យក"អ្នកបួស" គឺ "បព្វជិតពុទ្ធសាសនិក" ទាំងអស់ ។ "ការកាន់ផ្ទះ"
ហៅថា "គេហកម្ម:" មានន័យថា "ការលះចោលនូវតែកាមជាគ្រឿងទាំង

ពួង ហើយទំសឹកក្បាជម្រះចិត្តយ៉ាងណាឲ្យតែរួចពីកិលេសដ៏សៅហួង" ។ នេះឯង ជាទំនងដៅនៃ "ពុទ្ធសាសនា" ។ ប៉ុន្តែ លោកសង្ឃពុទ្ធសាសនាខ្មែរ ថ្លែកពីនេះបន្តិច គឺត្រង់លោកប្រមូលយកបញ្ហាជាតិទៅដោះស្រាយផង ។

បញ្ហានេះ មានន័យខ្លីខ្លាយវែងឆ្ងាយណាស់ ខ្ញុំមិនចង់លើកមកដោះស្រាយទេ ប៉ុន្តែ បើមិននិយាយសោះ ក៏មិនអាចបង្ហាញភ័ស្តុតាងឲ្យយើញ នូវសកម្មភាពទ្រទ្រង់ជាតិរបស់លោកសង្ឃពុទ្ធសាសនាខ្មែរបានដែរ ។ ហេតុនេះ ខ្ញុំនឹងពណ៌នាត្រួស ។ ដូចតទៅ

សង្គមពុទ្ធសាសនិកខ្មែរ

បញ្ហាដែលចោទជាប្រថមចំពោះមនុស្ស គឺ"បញ្ហាសង្គម" ព្រោះមនុស្សត្រូវការរស់នៅជាសង្គមរួមគ្នា ។ ជាមួយនឹងរបបរួមគ្នាជាសង្គមនេះ សង្គមតែងតែចាប់ផ្តើមសកម្មភាពឡើងជាស្វ័យប្រវត្តិ ព្រោះថា: បើមូលហេតុនេះមិនមានស្ថេរភាពទេ សង្គមនោះៗ នឹងប្រែធារលាយទៅវិញដោយឯកឯង ។ អាស្រ័យហេតុនេះ ប្រជាជនខ្មែរដែលរស់នៅកាយប៉ាយពាសពេញប្រទេស តែងរួមគ្នាជាក្រុមៗ ហើយបន្តខ្សែសង្វាក់ប្រពៃណីគ្នាជាំងប្រទេស ។ ដើម្បីឲ្យស្របនឹងពុទ្ធសាសនាដែលខ្លួនជឿគាន់នោះ, ប្រជាជនខ្មែរក៏ដ្រើសយកអង្គការពុទ្ធសាសនាមកបញ្ចូ

សម្រួលជាមួយជាន់ជួបជុំគ្នា គឺ ទាំងបង្កើត "វត្តអារាម" ឲ្យមានពាស
ពេញប្រទេស ។ ក្នុងមូលហេតុនេះឯង ទើបគេសង្កេតឃើញថា ពី
បុពណាកាល ក្នុងភូមិភាគណា ដែលមានប្រជាជនខ្មែរស្រុកខ្មែរ,
បញ្ហាបង្កើត "វត្តអារាម" តែងតែគេចាត់ទុកជាបញ្ហាប្រថមហើយជាចាំបាច់
ខ្លាតផង ។ វត្តអារាម គឺជាទីសម្រាប់ស្នាក់នៅនៃព្រះសង្ឃពុទ្ធសាសនិក
ប៉ុន្តែ ខ្មែរបានរៀបចំផ្សំសម្រួលឲ្យទៅជា "មជ្ឈមណ្ឌលនៃសង្គមជាតិ"
ផងដែរ ។ បើវត្តអារាមអាចទៅជា "មជ្ឈមណ្ឌលសង្គមជាតិ" យ៉ាងនេះ
ហើយ លោកសង្ឃដែលអាស្រ័យនៅក្នុងវត្តនោះ ។ តំមិនអាចដោះដៃ
ចេញពីការណ៍យតិចដែលចាត់ចងទំនងសង្គមបានដែរ ។ ដូច្នេះ ការ
ជ្រើសយកវត្តធ្វើជាមជ្ឈមណ្ឌលសង្គមនេះ មានប្រយោជន៍ច្រើនយ៉ាងគឺ:
ឲ្យងាយស្រួលដល់ការប្រតិបត្តិផ្នែកសាសនាផង ងាយស្រួលដល់ការចាត់
ចងគ្រប់សង្គមផង បានលោកសង្ឃពុទ្ធសាសនិកដែលជាទីជឿទុក
ចិត្តនៃប្រជាជនរួមជាសកម្មផង ។

មជ្ឈមណ្ឌលសង្គម

លុះបង្កើតបានជា "មជ្ឈមណ្ឌលសង្គម" នេះពេញលក្ខណៈហើយ
ប្រជាជនទៅជិតខាងជុំវិញ ដែលធ្លាប់ហៅថា "ឧបាសកដើរវត្ត"នោះ ។
តែងតែនាំគ្នាទៅរួមប្រជុំជារៀងរាល់សប្តាហ៍ (ចំពោះមនុស្សធាស់ ។)

ដើម្បីសិក្សាទូវិសីលធម៌ (សមាធានសីល) និងអប់រំតំនិតប្រាជ្ញាស្មារតី (ចម្រើនភាវនា) ដោយវិធីស្តាប់ព្រះសង្ឃពន្យល់ ស្តាប់ធម៌ទេសនា) និងដោយវិធីស្មឹងស្មៃ បើយជាពិសេសទៀត ជាមធ្យោបាយជាក់ទង្គិតគ្នាដឹងនូវព្រឹត្តិការណ៍ផ្សេង ។ និងបត្តគ្នានូវវប្បធម៌ទូទៅ ។ ចំណែកខាងប្រជាជន តាំងចាស់តាំងក្មេងទូទៅ នែងនៃទៅរួមប្រជុំពុំដែលខាននៅពាល់ពិធីបុណ្យប្រចាំឆ្នាំ ដូចជា បុណ្យចូលឆ្នាំ បុណ្យកឋិន បុណ្យភ្ជុំបិណ្ឌ និងបុណ្យពិសេស មានបុណ្យផ្កា បុណ្យទ្វន បុណ្យសព ជាដើម ។ ការជួបជុំគ្នានេះឯង ជាជាតុសំខាន់បំផុតនៃសង្គម ដែលមិនមានមធ្យោបាយណាប្រសើរជាងនេះឡើយ ព្រោះអាចមានឱកាសដុសខាត់នូវអារ្យធម៌ជាតិ និងផ្សព្វផ្សាយរវាងគ្នានូវវប្បធម៌ដ៏ល្អសង្គម បានយ៉ាងងាយ ។ ក្រៅពីនេះ មានបញ្ហាមួយទៀត គឺការអប់រំ ។ ក្នុងវិស័យនេះ ឱកាសកាន់តែច្រើន កាលបើអ្នកណាមានកូនចៅគ្រប់អាយុសិក្សាហើយ តែងតែនាំយកកូនចៅនោះទៅឲ្យនៅវត្ត ជាទំនៀមទម្លាប់ ។ លោកសង្ឃ បើតាមពិត មិនត្រូវចាត់ទុកថាជាអ្នកមើលក្មេងក្នុងភូមិអត្រឹមតែប៉ុណ្ណោះទេ ព្រោះខ្ញុំស្គាសនាតម្រូវឲ្យលោកសង្ឃកែវកែតឹកតឿការស្វាត់ស្ងប់ល្អ ប៉ុន្តែ លោកសង្ឃខ្មែរ បែរជាលូកដៃទៅចូលបញ្ហាក្មេង ៗ នៃសង្គមមកអប់រំចង្អាត់បង្រៀនជាសាធារណៈទៅវិញ ។ នេះ បញ្ជាក់ឲ្យយើញថា "លោកសង្ឃខ្មែរ" កំពុងតែណើយតិចស្រាយបញ្ហាជាតិដែរ ។

ក្នុងនៅវត្ត តែងតែកើនចំនួនឡើងជាលំដាប់ទៅតាមការរីកចម្រើនឡើង នៃសង្គមមនុស្ស ហើយខ្វះដែលមានវ័យល្មមបួសបាន ក៏ធ្វើតពេលបួសកាន់ផ្នួស ដើម្បីអប់រំចម្ទុំនិស្ស័យសុចរិតផង ដើម្បីបន្តការសិក្សាតទៅទៀតផង ។ ដំណើរនេះ ក៏បណ្តាលឲ្យកើតជាបញ្ហាមួយឡើង គឺការខ្វះទីលំនៅ ។ ដូច្នេះ ការស្តាបនាកុដិ សាលា វិហារ ចង្កូន ពេញចាយ ។ល។ ក៏ត្រូវតែប្រជាជនដើងវត្តនាំគ្នាដោះស្រាយ(ទានពុំបាន) ព្រោះជាបញ្ហា ទាក់ទងនឹងកូនចៅរបស់ខ្លួនផង ទាក់ទងនឹងសង្គមរបស់ខ្លួនផង ។

ចំណុចត្រង់នេះ គួរឲ្យយើងរំពឹកពាក្យអ្នកខ្វះដែលនិយាយថា "យើងចាញ់ចោកលោកសង្ឃ ព្រោះនាំគ្នាធ្វើកុដិសាលាឲ្យលោកសង្ឃនៅ ឥតអំពើ" ។ ការិះគន់នេះ គឺជាការចំកន្តែងសេចក្តីពិតខាំងស្រុង ។ ហេតុអ្វីក៏យើងមិនសួរត្រឡប់ទៅវិញថា : តើខ្មែរធ្វើកុដិព្រោងព្រាតនេះ ដើម្បីឲ្យលោកសង្ឃឥណ្ហានៅ ឬក៏ ឲ្យកូនខ្មែរនៅ ? តើសាលាដែលខ្មែរស្ថាបនានោះ មិនគឺសម្រាប់ខ្លួនយើងទៅអង្គុយប្រជុំគ្នាទេឬ?, គប្បីជ្រាបថា កុដិសាលានោះ មិនមែនធ្វើសម្រាប់ឲ្យលោកសង្ឃមកពីស្រុកទេវតាណានៅអាស្រ័យទេ គឺពិតជាលោកសង្ឃខ្មែរ យុវជនខ្មែរ កុមារខ្មែរ និងខ្លួនយើងហ្នឹងឯងជាអ្នកប្រើប្រាស់ ។ ឧទាហរណ៍ ដូចជា សព្វថ្ងៃនេះ សូម្បីតែសាលារៀនចេញទៅនៅក្រៅវត្តហើយ ក៏យុវជនខ្មែរពាក់ម៉ឺនាក់

នៅតែទៅសុំសម្ភក់នៅអាស្រ័យក្នុងវត្ត កកកុញរៀងរាល់ឆ្នាំ ដូចជាវត្ត
ឧណ្ណាលោម បទុមវតី សាកវ័នតេជោ តែវព្រះភ្លើង ជាដើម ។

តាមការសង្កេតស្ថិតិខ្ញុំទៅ យើងអាចឃើញថា លោកសង្ឃដែល
នៅក្នុងវត្តនាទីក្រុងចាំនោះ មានចំនួនតិចជាងក្នុងវត្តពីរ - បីភាគ គឺ
កុដិនិមួយៗ បើមានលោកសង្ឃពីរ - បីអង្គ, ឯកូនក្មេង មានចំនួនខ្លីង
ទៅដល់ជាងដប់នាក់ ។ ជាពិសេស គេលស្រុកទេសកើតអសន្តិសុខ
ដូច្នេះទៀត យុវជនដែលរត់មកសុំសម្ភក់នៅវត្ត រឹតតែកើនឡើងជាខ្លាំង ។
សូមទៅមើលចុះ ! គ្មានកុដិណាដែលគ្មានក្មេងនៅណោនណាន់នោះទេ
ហើយចេះតែឃើញចូលមកសុំសម្ភក់នៅថែមស្ទើរៀងរាល់ថ្ងៃ ប៉ុន្តែ នៅ
ម្តេចកើត បើវាណោនណាន់ណាស់ទៅហើយ ។ ក្នុងរឿងនេះ, តាម
យោបល់ខ្ញុំថា បើរដ្ឋាភិបាលជាតិយើងយកមេធាចាយចាស់តិលនេះមក
ជួសខាត់ប្រើវិញ ខ្ញុំជឿជាក់ថា ជាតិយើងពិតជាអាចដោះស្រាយបញ្ហា
យុវជនសិក្សានេះបានយ៉ាងងាយ ដោយមិនចាំបាច់អស់លុយកាក់ជាតិអ្វីបន្តិច
សោះឡើយ ។ ការប្រឹងប្រែងរបស់រដ្ឋាភិបាល គឺគ្រាន់តែជួយអប់រំ
ជម្រុញយ៉ាងណា ឲ្យសប្បុរសជនពុទ្ធសាសនិកនោះបញ្ចេញសទ្ធាជ្រះថ្លា
នាំគ្នាបង្កើតវត្តអារាមឲ្យបានច្រើនឡើងទៀត ព្រមទាំងសាងកុដិសាលា
ឲ្យបានគកកុញកុំឲ្យខ្វះខាត, ជាពិសេស នៅទីក្រុងនីមួយៗ ត្រូវរដ្ឋការ

គ្រោងដ៏ទុកសម្រាប់ផ្លូវត្តអាចមកក្នុងសង្កាត់នីមួយៗឲ្យបានច្រើនមែនទែន
រួចនិមន្តលោកសង្ឃឲ្យទៅគង់ដួយណែនាំចិត្តសន្ធរដ្ឋាភិបាល
ការឲ្យស្ថាបនាកុដិសាលាជាបន្តបន្ទាប់ទៅ ពាលតែធួនល្មមនឹងចំនួនយុវជន
ជាតិយើងសម្អាក់អាស្រ័យទៅ តាមរបៀបអនាម័យគ្រប់គ្រាន់ ក្រោមកិច្ច
អាណាព្យាបាលរបស់លោកសង្ឃ ។ វិធានការដោះស្រាយនេះ អាចផ្តល់
ផលទៅដល់យុវជនខ្មែរអ្នកក្រីក្រខ្លះទៅ ឲ្យមានលទ្ធភាពបន្តកិច្ចសិក្សាបាន
ស្រួលដោយឥតចាំបាច់ខាតបង់ផង ឲ្យបានជិតស្និទ្ធនឹងសាសនាផង វប្ប
ធម៌ចាំបាច់បង់ខាតថែរក្សាជាតិផង ហើយវាតួនាទីចំណូលចិត្តនិយមរបស់
សង្គមពុទ្ធសាសនិកខ្មែរនេះផង ។ មធ្យោបាយចាស់គំរើនេះ គឺជា
ការណែនាំកិច្ចរបស់សង្គមពុទ្ធសាសនិកខ្មែរដែលជាប់អនុវត្តមកច្រើនសតវត្ស
ហើយ ជាមធ្យោបាយមានប្រសិទ្ធភាពណាស់ រហូតមកសម័យសព្វថ្ងៃ
នេះទៀត ក៏នៅតែមានប្រសិទ្ធភាពណាស់ដែរ ឧទាហរណ៍ដូចជា សង្គម
ពុទ្ធសាសនិកខ្មែរចង់សាងកុដិឬសាលាមួយ គេមិនចាំបាច់គិតគ្រោងដើម
ទុនទុកទេ, គឺប្រើតែប្រាប់ប្រជាពលរដ្ឋតាមវត្តនីមួយៗ គេគ្រាន់
តែប្រកាសឲ្យបណ្តាំមួយម៉ាត់ម្តងម៉ាត់ម្តង, តែភាគច្រើនរបស់ប្រជាជនខ្មែរ កំហួរហៀរ
ចូលមកគ្រប់ចូក ពាលតែកើតទៅជាកុដិសាលាខោះៗបានយ៉ាងឆាប់ ។
ចំណុចនេះ គួរតែយើងនាំគ្នាសរសើរបើរបបនិយមរបស់សង្គមពុទ្ធសាសនិក

ខ្មែរណាស់ ព្រោះលទ្ធិកុម្មុយនិស្តគេអាចធ្វើរបៀបនេះកើតបានដែរតែគ្មាន
សេរីភាពប្រជាជនដូចជាពុទ្ធសាសនានេះទេគឺធ្វើបានដោយការប្រើអំណាច
បង្ខិតបង្ខំយ៉ាងខ្លាចផ្សា ។ ប៉ុន្តែ បើមិនធ្វើរបៀបនេះក៏ហ៊ានទៅចុះសូម
ឲ្យតែអ្នកខ្លះដែលធ្លាប់រៃគន់នោះ កុំមានប្រសាសន៍រៃគន់ថា "យើងចាញ់
ចោកលោកសង្ឃ" តទៅទៀត ប្រយត្នតែអស់កុងសាលាទៅ ពិតជា
ឃុំវដនខ្មែរមួយភាគធំដែលក្រីក្រ អស់ទំពឹង រឹតតែខ្លួចវាសនាថែម
ទៅទៀតពុំខាន ។

- តើកូនខ្មែរដែលទៅនៅវត្ត សិក្សាអ្វីខ្លះ ?

- ការពិភាក្សាអំពីការសិក្សា របស់កូនខ្មែរដែលទៅនៅវត្តពីសម័យ
បុរាណ មិនគួរឲ្យជឿបានទេ ព្រោះវាស្ទើរតែរលត់ចាត់អស់ទៅហើយ
ប៉ុន្តែ នៅមានកំសត់តាងជាគំរាកំណាស់ ។ ពីដើម, សាលារៀន
មិនមាននៅក្រៅវត្តទេ, កូនខ្មែរត្រូវតែទៅនៅវត្ត ដើម្បីសិក្សាទូរទៅលះ
វិជ្ជាខ្លួនៅ មានអក្សរសាស្ត្រ បរិយាសាស្ត្រ ទំនៃសាស្ត្រ និងវិជ្ជា
បច្ចេកទេសផ្សេងៗ ជាដើម ។ ការសិក្សាអក្សរសាស្ត្រ ជាកត្តាមិន
ឲ្យអក្សរខ្មែរសាសាជាតិសាបសូន្យរហូតដល់សព្វថ្ងៃ, ការសិក្សាបរិយា-
សាស្ត្រ នាំឲ្យខ្មែរប្រកាន់ខ្ជាប់ខ្លួនចំខ្មែរមិនម្លាប់ប្រពៃណីជាតិរហូតមក,
ការសិក្សាទំនៃសាស្ត្រ នាំឲ្យខ្មែរជាមនុស្សមានអារម្មណ៍ផុតភាពក្រៃផ្ទៃ,

ឯការសិក្សាវិជ្ជាបច្ចេកទេសផ្សេងៗ ដូចជាខាងសំណង់ ខាងជំនាង ខាងវេជ្ជកម្ម ខាងយុទ្ធវិធី ខាងតន្ត្រី ខាងវិចិត្រពេទ ខាងគណិតវិជ្ជា ។ល។ រឿងនេះជារឿងពិត, ខ្មែរចាស់ៗ នៅរស់សព្វថ្ងៃជាសាក្សីស្រាប់ តែមិនមែនត្រឹមតែពាស្ត្រប្រជាធម្មតាទេ សូម្បីឥស្សរជនជាន់ខ្ពស់ មានស្តេចព្រះជីវិទាម៉ឺនមុខមន្ត្រីសេនាបតីកវីបណ្ឌិតជាដើម ក៏សុទ្ធតែបានទទួលការសិក្សាវិជ្ជាសាស្ត្រពាំងនេះអំពីវត្តដែរ ។ ភស្តុតាងមួយទៀត ដូចជាក្នុងវណ្ណកម្មរឿងពុំខាវ តែនេនពុំនិងនេនពេជ្រ មិនមែនត្រឹមចេះស្វាធ ចេះច្រៀង ចេះផ្គុំខ្លួយ ចេះមន្តវិជ្ជាស្នេហ៍ វិជ្ជាហោកប៉ាច់ណោះទេ ថែមទាំងចេះធ្វើគោកលក់ផង ។ ក្នុងករណីនេះ គេនាំគ្នានិះគន់ពុំនិងពេជ្រថា ជាអ្នកមានកំហុសចំពោះពុទ្ធសាសនា ប៉ុន្តែបើនិយាយពីកស្តុតាងវិញ តើគួរបញ្ជាក់ពីការសិក្សាក្នុងវត្តនៅសម័យនោះបានដែរឬទេ? តែបានពិតណាស់ ។ អាស្រ័យការចេះដឹងពីវត្តនេះឯង ទើបបានជាយុវជនដែលចេញអំពីវត្ត នៅនោរួមក្នុងសង្គមគ្រួសារវិញ, កាគច្រើន, អាចធ្វើប្រជាប់ប្រជារប្រើប្រាស់ជាការចាំបាច់បាន រហូតដល់ធ្វើផ្ទះសម្បែងខ្លួនក្តារ រនេះសាលី ហើយអាចនៅជាគ្រូហ្មាមើលដំណឹ នៅជាអ្នកមានវិជ្ជាការពារភូមិស្រុក ជាពំនឹងរបស់សង្គមជាតិញាតិមិត្តបានយ៉ាងប្រពៃ ។

- តើអ្នកណា ជាគ្រូបង្រៀន ?

- មកដល់ត្រង់នេះ យើងកាន់តែយើញយ៉ាងច្បាស់ក្រឡែតហើយ

ថា គ្មានអ្នកណាក្រៅពីលោកសង្ឃខ្វែរទេ ។ ដើម្បីនឹងឲ្យកាន់តែជាក់ច្បាស់ឡើងទៀត យើងត្រូវពិនិត្យពីអត្ថការគ្រប់គ្រងមជ្ឈមណ្ឌលសង្គម គឺ "វត្ត"នោះសិន ។ បើតាមលក្ខន្តិក: , វត្តនីមួយៗ ជាសម្បត្តិសាធារណៈ គឺជាសម្បត្តិរួមរបស់ប្រជាជន ប៉ុន្តែ គេតែងតែប្រគល់ការគ្រប់គ្រងពេញសិទ្ធិទៅឲ្យលោកសង្ឃជាអាណាព្យាបាល ។ ឯឧបាសក មាននាទីត្រឹមតែជួយឧបត្ថម្ភប៉ុណ្ណោះ ។ ការគ្រប់គ្រងនេះ បើនិយាយតាមសម័យនិយមថា នៅក្រោមកិច្ចដឹកនាំនៃគណៈកម្មាធិបាលមួយចំនួន ដែលមានប្រធាន ១ រូប គឺវៅអធិការ, អនុប្រធាន ២ រូប គឺគ្រូសូត្រធ្វើឆ្នាំ និងសមាជិកជាច្រើនរូប ។ សមាជិកទាំងនោះ សុទ្ធតែជាលោកសង្ឃទាំងអស់ ដែលចែកជាផ្នែកគណៈកម្មការមួយៗ គឺផ្នែកយោសនាការ= ទាក់ទិនកិច្ចការយោសនាអប់រំពន្យល់ប្រជាជនខ្លួនៗ (ធម្មកថិក), ផ្នែកអប់រំ= ទាក់ទិនកិច្ចការបង្ហាត់បង្រៀនខ្លួនវិញ្ញូខ្លួនៗ ដល់សិស្សទាំងគ្រហស្ថទាំងបព្វជិត (អាចារ្យបង្រៀន), ផ្នែកស្ថាបនកម្ម=ទាក់ទិនកិច្ចការដឹកនាំការស្ថាបនាកុដិ-សាលា-វិហារជាដើមក្នុងវត្ត និងដឹកនាំការស្ថាបនាស្ពាន-ថ្នល់-ស្រះ-អណ្តូងជាដើមក្រៅវត្ត រហូតដល់មានជួយចង់ចំនង់ចំពីកនិងធ្វើផ្នែរសម្បើងឲ្យអ្នកស្រុកខ្វះខៀតផង ហើយជាពិសេស មានការណីយកិច្ចជាទីម្រឹក្សារបស់អ្នកស្រុកក្នុងកិច្ចការស្ថាបនាផ្សេងៗ ទៀតផង, ផ្នែកវេជ្ជកម្ម= ទាក់ទិនកិច្ចការជួយព្យាបាលជំងឺលោកសង្ឃនិងភ្ញៀវវត្ត ព្រមទាំងឧបាសក-ឧបាសិកាខ្លួនៗ

(គ្រូហ្មូ), ផ្នែកគណនេយ្យ = ខាងកិច្ចការដួយគ្រួតគ្រាគុកណ្ដាបចំ
មជ្ឈមណ្ឌលឲ្យគង់នៅជាសាធារណប្រយោជន៍, ផ្នែកសិល្បវិជ្ជាការ=ខាង
កិច្ចការដឹកនាំលោកសង្ឃនិងក្មេងណា ដែលមានសុឆន្ទៈ ឲ្យចេះដឹងនិងឲ្យ
មានសមត្ថភាពខ្ពាំងតូចតែស័ក្តិសិទ្ធិដោយបុព្វនិមិត្ត និងយុទ្ធសិល្បផ្សេង ។ ជា
ដើម ។ វិជ្ជាអស់នេះ មានចេញពីលោកសង្ឃក្នុងវត្តពិតប្រាកដណាស់
ទើបបានជាមានប្រពៃណីថា មេទ័ពខ្មែរណា ដែលត្រូវដឹកនាំកងទ័ពទៅធ្វើ
សង្គ្រាម តែងតែទៅកោះលោកសង្ឃជាគ្រូ ឬក៏ និមន្តលោកសង្ឃជាគ្រូ
នោះមកប្រគំព្រំប្រសិទ្ធិឲ្យជាមុនស្រេច ទើបចេញទៅច្បាំង ។ ការណ៍យ-
កិច្ចអស់នេះ បើប្រតិបត្តិឲ្យត្រឹមត្រូវ យើញថា មានចំនាស់ទំនឹងពុទ្ធសា-
សនាជាច្រើន, ជាពិសេសដូចជា វិជ្ជាពេទ្យ និងវិជ្ជាយុទ្ធសិល្បមន្តអាគម
ដែលលោកសង្ឃពុទ្ធសាសនាមិនគួរឲ្យមាននៅប្រហែកប្រថល់សោះ ព្រោះ
ក៏ជាបញ្ហាជាតិសុទ្ធសាធ ប៉ុន្តែលោកសង្ឃពុទ្ធសាសនិកខ្មែរ ចែរជាយក
មកបញ្ចូលក្នុងកម្មវិធីគ្រប់គ្រងរបស់ខ្លួនពេញទី ។ នេះឯង ដែលតែងតែ
បញ្ជាក់ថា "ពុទ្ធសាសនាខ្មែរ" ផ្សេងពី "ពុទ្ធសាសនា" កាន់តែជាក់
ច្បាស់ទៀត ។ គួរកត់សម្គាល់ថា "វិជ្ជាពេទ្យនិងវិជ្ជាមន្តអាគម" នេះ
ពិតមែនតែវាហួសសម័យនេះទៅហើយ ប៉ុន្តែវាជាការសំខាន់ណាស់នៅ
សម័យនោះ ។ ក្រៅពីការណ៍យកិច្ចទាំងនេះ លោកសង្ឃទាំងអស់
ត្រូវទៅទទួលយកវិភាគទាន (ដើរបិណ្ឌបាត) មកចិញ្ចឹមជីវិតខ្លួនឯងផង

ចិញ្ចឹមក្មេង ។ ក្នុងវត្តផង ។

-តើអ្នកណា ជាអ្នកធ្វើវិភាគទាន ?

-អ្នកដែលត្រូវធ្វើវិភាគទានគឺឧបាសក-សិការដ្ឋនោះឯង ។

ត្រង់នេះ មានអ្នកខ្លះនិយាយថា "យើងចាញ់ចោកលោកសង្ឃ ព្រោះយកប្រាយចឹកទៅចិញ្ចឹមពួកមនុស្សឥតការងារ" ។ ចេះយើងយើញនូវការណ៍យកចិត្តរបស់លោកសង្ឃពុទ្ធសាសនិកខ្មែរយ៉ាងនេះហើយ តើយើងថាលោកមិនធ្វើការបានឬទេ ? ការនិយាយនេះពិតជាគ្មានវិចារណញ្ញាណទាំងស្រុង ។ បើថាយើងចាញ់ចោកលោកសង្ឃ, ម្តេចក៏មិនថាលោកសង្ឃចាញ់ចោកយើងផង ? ព្រោះលោកបានញុះញង់ប្រជាជនយើងច្រើនយ៉ាងមានការគ្រប់គ្រងមិនល្អ ណាស់ក្នុងមនិងអបរំកូនខ្មែរជាដើម ។ ការងាររបស់មនុស្ស មិនដែលដូចគ្នាទាំងអស់ទេ, បើយើងប្រកាន់ថា តាល់តែធ្វើដូចយើង ទើបឈ្មោះថាជាអ្នកធ្វើការងារ, នេះក៏ល្មើជាអ្វីបានហើយ ។ ដូចជាអ្នកស្រែនិយាយថា ពួកអ្នករដ្ឋការជាមនុស្សឥតធ្វើការងារទេ ព្រោះមិនដែលឃើញមកភ្ជួរស្រែម្តងសោះ ។ មិនត្រូវនិយាយយ៉ាងនេះទេ ព្រោះយើងធ្វើការទាំងអស់គ្នា ប្លែកតែការងារទាំងនោះខុសគ្នាប៉ុណ្ណោះ ។ បើប្រកាន់ថាត្រូវតែធ្វើការឲ្យដូចៗគ្នា នោះលោកម៉ៅធេងក៏ កំពប់បញ្ចូលក្នុងមនុស្សឥតការងារដែរ ព្រោះគាត់មានទៅធ្វើ

ស្រែចម្ការឯណា។ ។ ដូច្នេះ បើមិនឲ្យទំពុកតួដល់លោកដើម្បីរស់ផង តើលោកអាចបំពេញកិច្ចបម្រើការនោះបានឬទេ? ប្រៀបដូចជាគ្រូបង្រៀនឥតប្រាក់ខែ តើអាចធ្វើការទៅកើតឬទេ? ។ រឿងនេះ មិនគួរនិយាយទេ គួរតែសរសើរទៅវិញទើបសម ព្រោះលោកសង្ឃខ្មែរធ្វើការឲ្យសង្គមខ្មែរយ៉ាងត្រឹមត្រូវបំផុត ហើយសុំត្រឹមតែមួយរស់ប៉ុណ្ណោះ ទោះរស់នោះស្រួលធូរធូលាយ ឬអត្តៈខាត់រហមរហាមយ៉ាងណាក៏បានដែរ លោកមិនដែលប្រើសិទ្ធិតមការអ្វីសម្រាប់សេចក្តីសប្បាយ ឲ្យសមនឹងមុខតំណែងការងារបស់លោក ដូចជាអ្នកផងឯទៀតពាល់តែសោះ ។ ចំណុចនេះអាចបង្ហាញឲ្យឃើញម្យ៉ាងទៀតថា សេរីភាពធ្វើវិភាគទានរបស់ឧបាសក-សិកាដើងវត្ត មានទូលាយគ្រប់គ្រាន់ណាស់ ព្រោះគ្មានការគម្រឹតភាគឬតម្រូវបន្ទុំណាមួយឡើយ ។ គេអាចធ្វើវិភាគទានជាប្រាក់ ជាអង្ករ ជាស្រូវ ជាឧស ជាឈើ ជាបន្ទែបង្ការ ។ល។ ជាបាយមួយវែកសំណុកមួយក្តារ ក៏បាន ដោយលៃតៅតាមកម្លាំងសទ្ធានិងធនធាន ហើយបើគ្មានអ្វី ឬមិនរៀបធ្វើវិភាគទានសោះ ក៏បានដែរ គឺថា អ្នកណាមានក៏ធ្វើទៅ, អ្នកណាអត់ក៏ហ៊ីទៅ ។ ហេតុនេះហើយ ទើបបានជាលោកសង្ឃតែងធ្វើដំបូន្មានប្រៀនប្រដៅគ្នាថា "យើងជាអ្នកបួស មិនត្រូវរើសអើងថាធ្ងាញ់ឬមិនធ្ងាញ់, ល្អឬអាក្រក់, ត្រជាក់ឬក្តៅ, គ្រប់គ្រាន់ឬខ្វះខាត, ស្រួលឬលំបាកអ្វីទេ, បើបានអ្វី, បរិភោគប្រើប្រាស់សន្តោសតាមរបស់

នោះទៅ ព្រោះយើងជាអ្នករស់ដោយគេចិញ្ចឹម ត្រូវតែធ្វើខ្លួនឲ្យគាប់ចិត្តគេ ហើយត្រូវធ្វើការងារឲ្យបានច្រើន ព្រោះយើងមកបួសនេះដើម្បីអប់រំខ្លួនឲ្យមានអំណត់ទំហន់តស៊ូធ្វើការងារហួតបុងចំផុត...” ។ អ្នកខ្លះឃើញលោកសង្ឃសម្បូណ៌ចង្ហាន់ទៅពេលបុណ្យសុន្ទរកថាមង្គលភ្លាម ដូចជាបុណ្យក្តុំ បុណ្យចូលឆ្នាំ ឬបុណ្យដែលគេនិមន្តទៅជាដើម តែងនិយាយថា លោកសង្ឃសម្បូណ៌ធាន់ណាស់ ។ លោកសម្បូណ៌មែន ប៉ុន្តែក្នុង ១ ឆ្នាំ មាន ៣៦០ ថ្ងៃ សម្បូណ៌តែប៉ុន្មានថ្ងៃប៉ុណ្ណោះ ចុះប៉ុន្មានរយថ្ងៃទៀតនោះ ម្តេចក៏មិនគិតឲ្យលោកផង ? ។

រឿងនេះ មានតែអ្នកធ្លាប់បួស និងពួកក្មេងវត្តទេ ដែលដឹងច្បាស់ ។ ចំពោះរឿងវិភាគទាននេះ ក៏គួរយើងសើរើយកមកគិតជាថ្មីដែរ ព្រោះថាយើងប្រគេនបាយដល់លោកសង្ឃ ជាការត្រូវតែធ្វើដើម្បីឲ្យលោករស់នៅធ្វើការឲ្យយើងពិតមែនហើយ ប៉ុន្តែលោកសង្ឃគ្មានពោះឯណាធាន់ទុកពីរបីចម្អែតម្នាក់ឯងបានទេ, ក្រៅពីមួយចម្អែត លោកត្រូវបែកចាយឲ្យក្មេងវត្តរស់ដែរ ។ តើក្មេងទាំងនោះ ជាកូនអ្នកណា? គឺសុទ្ធតែជាកូនខ្មែរពិត ។ ។ ចុះបើកូនខ្មែរទាំងនោះអាស្រ័យវត្តហើយបានរៀនសូត្របេះដឹងខ្ពង់ខ្ពស់ទៅអនាគត មិនគឺកូនខ្មែរជាអ្នកបេះដឹងទេឬ ? ។ យើងមានចំណង់ថា ឲ្យកូនខ្មែរបេះដឹងច្រើនឡើង ដើម្បីគ្រប់គ្រងរាស្ត្រទេសជាតិឲ្យថ្កើងថ្កានទៅអនាគត, លុះកូនខ្មែរទាំងនោះ ពឹងផ្អែកបាយបាត្រ

ហើយច្រើនសិក្សាបានរបៀនដឹងខ្ពង់ខ្ពស់ទៅ តើមិនគួរឲ្យយើងគ្រែកអរទេឬ? ព្រោះតែវិភាគទានបាយមួយវែករបស់យើងរាល់ថ្ងៃ អាចសង្គ្រោះជីវិតនៃខ្មែរឲ្យមានចំណេះវិជ្ជាក្នុង ១ ឆ្នាំ ៗ រាប់ម៉ឺននាក់បាន ។

ផ្ទុយទៅវិញ បើយើងយោសនាពន្យល់ឲ្យគ្នាផ្តាច់ឫសពីពីធីរបស់ជីវិតទាំងនោះអស់ គឺឲ្យលែងធ្វើវិភាគទានជាក់ជាក្រលោកសង្ឃទៅវិញ តើមិនឈ្មោះថា "ជាអ្នកកាត់ប្រយោជន៍កូនខ្មែរក្រីក្រ" ទៅហើយឬ? កាត់ពិតប្រាកដណាស់ ។ រឿងនេះ បើតាមយោបល់ខ្ញុំថា គួរតែរដ្ឋការជាតិយើង ជួយមធ្យោបាយអប់រំយ៉ាងណាឲ្យប្រជាជនខ្លួនទាំងប្រទេសយល់ជាក់ច្បាស់ ពីប្រយោជន៍បុណ្យកុសលនិងប្រយោជន៍ជាតិរួមគ្នា ដើម្បីឲ្យវត្តែនាំគ្នាធ្វើវិភាគទានជាក់ជាក្រឬ ប្រគេនទេយ្យទានដល់លោកសង្ឃឲ្យដូចពីបុរាណកាល សូម្បីត្រឹមតែបាយមួយវែកក្នុងមួយថ្ងៃ ក៏ពិតជាអាចជោះស្រាយបញ្ហាយុវជនសិក្សាបានយ៉ាងធូរ ឥតបាច់ចំណាយថវិកាជាតិសោះ ហើយជាជំនឿរបស់សង្គមជាតិយើងស្រាប់ផង ប្រៀបដូចជាបួសចុំហើយ ដែលគេគ្រាន់តែជោះមុខបន្តិចក៏អាចឆ្លាយរួមកមិនខានៗ

—មានពាក្យរិះគន់ម្យ៉ាងទៀតថា "មិនគួរឲ្យប្រាក់ខែទៅព្រះសង្ឃអង្គខ្លះដែលធ្វើការរដ្ឋការទេ ព្រោះលោកមានវត្តនៅស្រាប់ មានបង្ហាន់ធាន់ស្រាប់, តើយកប្រាក់ទៅធ្វើអ្វីដែរ?

- ពាក្យរិះគន់នេះ ស្តាប់ទៅដូចជាពិរោះដែរ ប៉ុន្តែវាគ្រាន់បង្ហាញ

ន្ទូវការលួងលន់របស់អ្នកនិយាយទៅវិញទេ ។ ចំពោះបង្ហាន់មានស្រាប់ ឬគ្មានស្រាប់ដូចយើងដឹងពីខាងដើមហើយ ។ លោកសង្ឃពុទ្ធសាសនិកខ្មែរ ក្រៅពីដោះស្រាយបញ្ហាដ៏តែខ្លួន លោកពុំមានបញ្ហាប្រពន្ធកូនបង្កើតទេ ប៉ុន្តែ មានកូនចៅច្រើនណាស់ដែលត្រូវចិញ្ចឹម ។ កូនរបស់លោកគឺកូនខ្មែរដែលទៅសុំនៅស្នាក់អាស្រ័យសិក្សាក្នុងវត្តនោះឯង ។ លោកមួយអង្គ អាចចំនុកបម្រុងកូនខ្មែរបានពីដប់នាក់ទៅម្ភៃនាក់ ដោយសារនិច្ចកត្តត្រឹម ២ ពាន់ទៅ ៣ ពាន់ប៉ុណ្ណោះ ។ យើងជាគ្រហស្ថអាចធ្វើដូចលោកបានឬទេ? ។ យើងមានប្រពន្ធមួយនិងកូនតែពីរបី មិនដែលចិញ្ចឹមកូនខ្មែរណាក្រៅពីកូនខ្លួនបានផង ហើយថែមទាំងត្អូញត្អែរថា ប្រាក់ខែប្រាំមួយប្រាំពីរពាន់ចាយមិនគ្រាន់, ខ្លះទៀតប្រាក់ខែជាងមុនចិញ្ចឹមបានប្រពន្ធកូនពីរបីនាក់, ចុះលោកសង្ឃដែលមាននិច្ចកត្តមួយពាន់ប្លាយទៅពីរពាន់ប្លាយ អាចចិញ្ចឹមកូនជាតិរាប់សិបនាក់បាន, ហេតុអ្វីក៏មិនឲ្យយើងពេញចិត្តទៅវិញ? ។ គួរកត់សម្គាល់ថា លោកសង្ឃ គ្មានរឿងយកលុយទៅចំផ្ងាញចោលទំនិញស្រែ ទំនិញស្រាបារាំ ទំនិញល្បែងនាលា ឬការតុបតែងលែងខ្លួនហ៊ឺហាទេ, ការចាយវាយរបស់លោក សុទ្ធតែជាសាច់ការទាំងអស់ មានប្រយោជន៍ពិត ហើយភាគច្រើនជាប្រយោជន៍ជាតិទៀតផង ដូចជាចិញ្ចឹមកូនជាតិ ជួសជុលសម្បត្តិសាធារណៈ ដួយសង្គ្រោះក្នុងសង្គមកិច្ចជា ដើមដែលផ្ទុយពីការចាយវាយរបស់គ្រហស្ថឆ្ងាយណាស់ ។ ចំពោះ

ចំណុចនេះ ថើតួរវិញ, រដ្ឋការជាតិត្រូវតែប្រគេនទិញកត្តលោកសង្ឃឲ្យ ច្រើនជាអតិបរមា ព្រោះការនេះ វាជាមធ្យោបាយដោះស្រាយបញ្ហាយុវជនខ្មែរសិក្សាបានមួយផ្នែកធំដែរ ដែលជាបញ្ហាជាតិពិតៗ ។

គេថា : ការបួសនាំឲ្យខាតប្រយោជន៍ជាតិ ព្រោះនាំឲ្យអ្នកធ្វើការតិចទៅ, ឯអ្នកដេកស៊ីមានច្រើន ។ សម្តីនេះពិភេះណាស់ ព្រោះវាត្រូវទំនឹងគំនិតជឿនលឿនៃមនុស្សលោក ប៉ុន្តែ វាជាទស្សនៈខ្វះមូលដ្ឋានពិតទាំងស្រុង ។ កាតព្វកិច្ចដ៏ខ្ពង់ខ្ពស់របស់ព្រះសង្ឃ មានការពិតដូចដែលយើងនិយាយរួចហើយ, មិនតែប៉ុណ្ណោះ នៅមានប្រពៃណីមួយទៀត ដែលគួរឲ្យយើងយកចិត្តទុកដាក់គិតារណា គឺការបួសហើយសឹកវិញនៃកូនខ្មែរ ។ តើបួសដើម្បីអ្វី? ហេតុអ្វីក៏សឹកមកវិញ? ប្រសិនជាបួសដើម្បីទៅនិព្វានមែន មិនគួរសឹកមកវិញទេ, ការពិតគឺខ្មែរពុទ្ធសាសនិក ពុំមែនបួសដោយចោះបង់ចោលជាតិចោលសោះឡើយ ។ ក្នុងន័យនេះ យើងឃើញគ្រប់គ្នាថា យុវជនខ្មែរមួយភាគ មានមធ្យោបាយសិក្សាគ្រប់គ្រាន់, តែយុវជនខ្មែរមួយភាគធំទៀត ខ្វះមធ្យោបាយសិក្សាមិនអាចដោះស្រាយបាន ទើបចូលខ្លួនទៅពឹងសង្គមជាតិ គឺសង្គមពុទ្ធសាសនិកខ្មែរនេះឯង ដោយការអាស្រ័យនៅក្នុងវត្តខ្លះ ដោយការកាន់ផ្ទះហើយសិក្សា (បួសរៀន) ខ្លះ ។ នៅមានយុវជនខ្មែរមួយភាគទៀត ទោះមានមធ្យោបាយគ្រប់គ្រាន់ហើយក្តី ប៉ុន្តែគេមានសេចក្តីពេញ

ចិត្តខឹងផ្ទួស ក៏នាំគ្នាទៅបួសហើយសិក្សាវិជ្ជាសាស្ត្រខ្លួនទៅដូចជាយុវជនមិនបួសនោះដែរ ។ លុះបញ្ចប់កិច្ចសិក្សាហើយ ក៏សឹកមកវិញ រួចទៅប្រកបការងារ ក្នុងសង្គមគ្រួសារខ្លះ ក្នុងប្រកបចំណូរដៃការស៊ីវិលខ្លះ ក្នុងក្របចំណូរដៃការគេហានខ្លះ ជាហូរហែមក មានចំនួនដល់ទៅ ៩៨ ភាគរយ ។ បើយើងរិះគន់ថា "នាំឲ្យខាត" ហេតុអ្វីក៏មិនរិះគន់យុវជនជាសិស្សពាំងអស់ថា "នាំឲ្យខាត"ផង? ព្រោះមិនធ្វើការដូចគ្នា ហើយសិក្សាក៏ដូចគ្នាទៀត, ប្លែកតែសម្លៀកបំពាក់និងវិន័យតឹងរ៉ឹងខុសគ្នាប៉ុណ្ណោះ ។ ឬក៏គេចង់និយាយថា: មកពីយុវជនជាសិស្សស៊ីឃ្មុយមែ-ខ្ទួនហើយសិក្សា, ឯលោកសង្ឃនាន់ឃ្មុយសង្គមជាតិហើយសិក្សា? ។ បើអ៊ីចឹងមែន យុវជនដែលគាស្រ័យទៅក្នុងវត្ត ត្រូវរាប់បញ្ចូលក្នុងចំពួកអ្នកបួសដែរឬ? បើស៊ីឃ្មុយអ្នកស្រុកដែរ! ។ ក្នុងសម័យដឿនលឿននេះ គេតែងចង់ឲ្យសង្គមជាតិចេះរួបរួមគ្នាកសាងប្រទេសជាតិ ដើម្បីឲ្យបានជាកម្លាំងមាំ, ចុះបើសង្គមពុទ្ធសាសនិកខ្មែរចេះរួមគ្នាចិញ្ចឹមកូនជាតិឥតរើសមុខ ឲ្យរៀនសូត្របានចេះដឹង រាប់មិនបានប្រមាណមិនអស់ យ៉ាងនេះទៅហើយ តើហេតុអ្វីក៏មានបញ្ហាខ្ជឿនលឿនខ្លះបែរជារិះគន់ទៅវិញ? អស្ចារ្យមែន! ។ ការបួសនេះមិនត្រឹមតែគ្មានខាតប៉ុណ្ណោះទេ វាថែមទាំងឲ្យជាតិចំណេញយ៉ាងធំសម្បើមទៀតផង គឺជាកត្តានាំឲ្យខ្មែរដែលអួតថាកាន់ពុទ្ធសាសនានោះបានស្គាល់រសជាតិពិតប្រាកដនៃពុទ្ធសាសនាផង នាំឲ្យយុវជនជាតិយើងដែលក្រីក្រខ្លះ

មធ្យោបាយសិក្សានោះមានផ្លូវដោះស្រាយ៩ភ្លាមៗជាមួយសង្គមជាតិ ជាន
ស្រួលផង នាំឲ្យសង្គមជាតិតែតែចេះរួបរួមគ្នាជួយដោះស្រាយបញ្ហាជាតិ
ប្រសើរឡើងផង ដែលសុទ្ធតែជាការដោះស្រាយ ដោយមធ្យោបាយឥត
ចាំបាច់ពឹងពាក់ថវិកាជាតិឡើយ ។ ចំពោះព្រះសង្ឃ២ភាគរយ ដែលពុំព្រម
សឹកមកវិញនោះ ក៏មិនមែនជាអ្នកធ្វើឲ្យខូចប្រយោជន៍ជាតិដែរ ព្រោះ
លោកមានការងើយកិច្ចបម្រើជាតិយ៉ាងច្រើនលើសលុប ដូចដែលយើង
ពណ៌នាហើយ គឺជាក្រុមអភិជ្ញាសមជ្ឈមណ្ឌល ជាអ្នកអាណាព្យាបាល
ខុចគ្គម្កុតជាតិ ជាអ្នកអប់រំ ជាអ្នកដឹកនាំការប្រតិបត្តិធម៌ផ្សេងៗ និង
ជាអ្នកផ្តល់ខាងគំនិតប្រាជ្ញា ។ល។ លោកសង្ឃទាំងនេះ លោកស្ម័គ្រ
ចិត្តនៅបួស ព្រោះតែពេញចិត្តនឹងសេចក្តីចរិសុទ្ធនៃសាសនា ម៉្យោះហើយ
ការងារទាំងឡាយ ដែលលោកខំចំណាយកម្លាំងនិងសតិបញ្ញាធ្វើយ៉ាងណា
មមាញឹកសម្រាប់សង្គមជាតិ ដោយឥតមានតាមទាត់ថ្លៃអ្វីត្រៅពីសុំតែ
មួយរស់ ក៏ហាក់ដូចជាគ្មានតម្លៃ ប៉ុន្តែ ផលនៃការងាររបស់លោកទាំង
ប៉ុន្មាន តែងតែធ្លាក់ទៅជាផលប្រយោជន៍សង្គមជាតិទាំងអស់ ព្រោះ
លោកគ្មានប្រពន្ធកូនសម្រាប់ខ្វល់មតិបន្តអំពីលោកឡើយ គឺត្រូវតែ
បានទៅជាផលប្រយោជន៍សង្គមជាតិជាស្ងួយប្រវត្តិ ដែលមិនគួរឲ្យយើង
គិតចារម្ភអ្វីឡើយ ។ ដូច្នេះ បើឲ្យសម, គួរតែប្រគេនមហាកិត្តិយស
ដល់លោក ព្រោះជាមនុស្សការងារហើយធ្វើការដោយចង់ធ្វើ, មិនមែន

ធ្វើដោយគេចង្អុលដូចជាពួកកុម្មុយនិស្តទេ, ជាពិសេស ឥតត្រូវការតម្រឹតយកតម្រៃតាមកម្ទាំងអ្វីផង ផលនៃការងារបស់លោក គឺជាផលសម្រាប់សង្គមជាតិជាស្ថិយប្រវត្តិផង ។

សកម្មភាពរបស់ "ពុទ្ធសាសនិកខ្មែរ" សូម្បីតែភាគតូចមួយ ក្នុងបណ្តាសកម្មភាពសំខាន់ៗ ពាំងឡាយ ដែលបានរៀបរាប់មកនេះ ក៏ល្មមឲ្យគេយល់បានថា "ពុទ្ធសាសនាខ្មែរ" មានភាពផ្សេងពី "ពុទ្ធសាសនា" មែន ទោះបីកើតចេញពី"ពុទ្ធសាសនា"មកក៏ដោយ, ជាពិសេសអាចឲ្យយើងយើញច្បាស់ នូវលក្ខណៈសំខាន់ក្នុងកិច្ចការបម្រើប្រទេសជាតិ នៃសង្គមពុទ្ធសាសនិកខ្មែរពីបុរាណកាលផង ។ ការនិយាយថា "គួរតែរៀបចំសង្គមសាសនាឡើងវិញ" នេះ មិនមែនមានន័យថា ត្រូវបំបាត់ចោលនូវគោលដើមពុទ្ធសាសនា ហើយបង្កើតសាសនាថ្មីណាមួយឡើងនោះទេ ប៉ុន្តែ មានន័យថា ត្រូវតែយើងពិនិត្យសិក្សាឡើងវិញ នូវសកម្មភាពនៃ"ពុទ្ធសាសនាខ្មែរ" ហើយអនុវត្តឲ្យម៉ឺងម៉ាត់ នូវគោលការណ៍នៃបុព្វបុរសយើងឡើងវិញ ដើម្បីកុំឲ្យ"ពុទ្ធសាសនា"និង"ជាតិខ្មែរ"ប្រែក្លាយជាសត្រូវនឹងគ្នា, បានសេចក្តីថា យើងនៅតែយក"ពុទ្ធសាសនា" ជា"មូលដ្ឋាន" សម្រាប់ចង់ដំហរដែលថែ ប៉ុន្តែ យើងត្រូវតែចេះស្រង់យកផលប្រយោជន៍នៅលើមូលដ្ឋាននេះ ឲ្យបានពិតប្រាកដ ដល់ប្រទេសជាតិយើងផង។ ផ្លូវដែលនាំឲ្យយក"ផលប្រយោជន៍"នោះយើងមិនចាប់ស្រែក

ដង្ហើយហៅភេទអ្នកណាឲ្យមកដេកគិតត្រួសត្រាយភេជាថ្មី នាំឲ្យខាតពេលវេលាទេ យើងអាចយកផ្លូវជាមគ្គិករបស់បុព្វបុរសយើង (ដូចពោលខ្លះមកនេះ) ទៅសម្រួលអនុវត្តតាមកាលៈទេសៈ ពិតជាអាចសម្រេចបានហើយ, ពោះបីផ្លូវនោះ ចាស់ស្ទើរលុបបាត់ ក៏គង់ភាពប្រសិទ្ធភាពនៅឡើយ ហើយយើងនាំគ្នាធ្វើ ឲ្យកាន់តែរូលំទូលាយទៀត ទោះវ៉ាទំនឹងតែតែមានប្រសិទ្ធភាពស្រួលខ្លាំងឡើង ។ មកដល់បញ្ហាថ្ងៃនេះ យើងចេះតែនៅចោទសួរគ្នាថា "តើពុទ្ធសាសនា" ជាទំនាក់ទំនងការលូតលាស់ចម្រើនដែរឬទេសជាតិឬទេ? សំនួរនេះ យើងអាចឆ្លើយខ្លួនឯងបានហើយ បើយើងមានសុភនិច្ឆ័យ ព្រមទាំងបានចេះដឹងប្រវត្តិនៃ"ពុទ្ធសាសនាខ្មែរ" នេះ ។ ដូច្នេះ យើងគួរតែអប់ការយល់ច្រវ៉ាថា "ពុទ្ធសាសនាខ្មែរ ជាសត្រូវរបស់ខ្មែរ"នេះទៅ! ។

សាច់ក្លែបខ្ចីទំពុំតិតនី
ប្រឹងតែក្រែងភ្ញីសំបករក្រៅ
មិនស្រាយរញ្ជាដាផ្សែ។
កែតែឈ្មោះហៅប្រយោជន៍អី

ផល ទិត

រឿងសាមកុក

ឧកញ៉ាវិបុលរាជសេនា ឆ្ង-កង

ប្រែ - រៀបរៀង

(ក)

រឿងសាមកុកទុកជាឃ្លាស្ត្រ　　អ្នកវាងវៃធ្លាសបើបានអាន
នឹងជេះឧបាយកលចំណាន　　ទាំងមានសន្ដានស្នេហាជាតិ

ឃ្លោ-អ៊ុន

ព្រះរាជបុរោហិត ដែលព្រះសណ្ដាបង់ប្រគល់យល់ព្រមផង ទើបតាំងឲ្យសុមាំអ៊ីលឿនចិត្តអាចារ្យធំ ឯភរិយាខំឧបាយនោះកំតាំងឲ្យចូលដំណេកនិយាយត្រួតត្រា ចូលដំតាំងចូអ៊ីជាប្អូនឲ្យថ្លែងថានាយគាហាមឯក ហើយតាំងចូហ៊ីន, ជាអនុប្អូនបង្កើតណាត់គាជាន ឃ ហានស្ដាំ - ក្ងែង, ឯចូអ៊ីនឯចូហ៊ីន,ចូអ៊ីនចូណាត់គាជាន ឃ ហានតាមហែម្ភាសាចំនួន ១០០, បើនរណាដើរតាមទាន់ឲ្យហែ ចូនទៅសម្លាប ហើយចូសាងតាំងមនុស្សទុំនុកទុកចិត្តចាំថែរក្សាផ្នែនដី, ឲ្យពួកត្រួតពិនិត្យក្សាចូសាងចាំយប់ - ថ្ងៃ ។

ក្នុងខណៈនោះ, ពួកចារ្យអស់នាម៉ឺននាងកំនាំចូលទៅនៅពឹងព្រះរាជបុរោហិតជាច្រើនណាស់, សុមាំអ៊ុយឃើញដូច្នោះក៏ភ្ញែងធ្វើជាឈឺមិនចូន

ចូលគាល់ជាយូរថ្ងៃ, សុមាំស៊ូនឹងសុមាំចៀវជាបុត្រសុមាំអ៊ុយើញដូច្នោះក៏
មានសេចក្តីខ្មេមខ្សត្រូចចិត្ត នាំគ្នាលាចេញពីនាទីពាដការ, ឯចូសង
និងទីប្រឹក្សាទាំង៩នាក់ក៏នាំគ្នាសេពសុពលថ្ងៃមិនជាប់, ចូសងនោះតែង
ខ្ជួនដូចជាព្រះចៅចូហង បើមានត្រឿងបណ្តាការពីបណ្តាអាណាខែត្រ
ក្រៅនាំទៅថ្វាយ ចូសងក៏រើសលាក់ទុកយកវបស់ល្អតាមគាប់អធ្យាស្រ័យ
ទៀតនឹងជានាម៉ឺនពួកក្រុមពាំង ក៏ថែមទៅញុះញង់ចូសងថា: ឲ្យចូសង
ចូលទៅជ្រើសរើសពួកស្រីស្នំរបស់ព្រះចៅចូហងដែលមានតមកអំពីព្រះចៅ
ចូយ៉ាយនោះមកទុកប្រមែប្រមែណា៧-៨ នាក់ ចូសងក៏ធ្វើតាម ហើយឲ្យ
ជ្រើសរើសស្ត្រីខែត្រក្រៅបណ្តាដែលមានរូបល្អមានវណ្ណត្រកូលយកមកទុក
សម្រាប់ត្រឿនរាំចំរើនាទីប្រលោមចិត្តប្រហែល៤ ឬ ៥នាក់ ទើបឲ្យចាត់ជាង
យកទៅធ្វើផ្ទះគេហស្ថានប្រមាណ៩០០ឬ ៦០០ ។

លុះអំណើះតមក, ហោអាន់បានឲ្យទៅរកខ្ជួនក្លួនឲ្យជាគ្រូមើលមក
ពីស្រុកពេងឆ្នួនក្លួន, វេលានោះ ឈ្មោះតេងយៀងក៏ទៅទៅទីនោះផង,
ហោអាន់ក៏ប្រាប់ក្លួនឲ្យថា : យើងយល់សប្តិឃើញសត្វរុយប្រហែល ១០
ហ៊ីរមកទំនៅចុងច្រមុះយើង តើជាល្អឬអាក្រក់ប្រការម្តេច ? មួយទៀត
អ្នកចូរមើលជតារាសីយើងនេះ តើនឹងបានជាទ័មហាឧបភាដឬទេ! ទើប
ក្លួនឲ្យទំនាយថា : ដែលលោកយល់សប្តិឃើញសត្វរុយជាសត្វស្មោក

គ្រោក, ឯច្រមុះប្រៀបដូចដើមឈើខ្ពស់មានកូនត្រអូប តម្លៃលោកមានឋានៈបណ្ដាស័ក្តិមែនហើយ ត្រូវតែប្រយ័ត្នកុំឃើញដោយលោកសក្ការៈជារបស់ល្អ បើមិនស្តាប់មុខជាមានអន្តរាយ ដូចឱ្យលំបាក់ជាន់មកត្រូវដើមឈើខ្ពស់ចាក់រលំចុះ បើលោកលះលោកចេញបាន ខុសប្រាហ៍ផ្ចង់ចិត្តគិតតម្រង់ខ្លួនឱ្យនៅក្នុងសីលធម៌សុចរិត ក៏អាចនឹងស្ថិតយសស័ក្តិសម្បត្តិជាសិរីវឌ្ឍនាការតទៅ ។

តេជយៀងបានស្តាប់កូនឱ្យថាដូច្នោះក៏ទំនឹងណាស់ ទើបឆ្លើយថា: ខំនាយយល់សប្តិយ៉ាងនេះ ហាក់បីដូចមនុស្សមិនចេះរៀនតាមក្បួនតម្រាស្តាប់យកតែតាមពាក្យដូនតាមកខំនាយ ទើបកូនឱ្យប្រកែកថា: ខ្ញុំយើងនេះប្រាកដជាមិនបានរៀនតាមតម្រាមែន តែយើងបានឮចាស់ទុំលោកនិយាយទុកមកថា : បើនរណាមិនស្តាប់ពាក្យបុពណ គង់នឹងមានភ័យអន្តរាយដែរ។មកពីនេះលើអ្នកនោះមិនឱ្យដឹងខ្លួនទាន់ ថាហើយក៏ក្រោកក្រគាត់ដៃដើរចេញទៅ, ហោរាន់និងតេជយៀងឃើញដូច្នោះក៏អស់សំណើចហើយថា កូនឱ្យនេះ វាជាមនុស្សខ្លួចចិតទេ ។

ឯកូនឱ្យត្រឡប់ទៅដល់ស្រុកតេជឆ្លួនកូន ក៏ពណ៌នាសេចក្តីតាមសម្តីហោរាន់ និងតេជយៀង និយាយនោះឱ្យឪពុកធំខ្លួនស្តាប់គ្រប់ប្រការ ឪពុកធំឮដូច្នោះក៏ភ័យណាស់និយាយថា ហោរាន់និងតេជយៀងគេជានាម៉ឺននៅក្នុងត្រកូលយួសេដ្ឋ ហេតុអ្វីបានជាចៅឯងហ៊ានទៅនិយាយដូច្នោះ

ភ្លួនឡូឆ្លើយថា : ហោអាន់និងតេងយៀងជាមនុស្សដល់នូវសេចក្តីស្លាប់ ហើយនឹងតេងយៀងនោះនឹងស្លាប់, ភ្លួនឡូឆ្លើយថា : ហោអាន់និងតេងយៀងនោះរូបនិងលក្ខណៈកំរិយាសាច់ឈាមចេញឲ្យឃើញជាបិសាចទៅហើយ មិនយូរប៉ុន្មានឡើយភ័យនឹងមកដល់ វានឹងសម្លាប់ខ្លួនឯង, អាពុកធំមិនដឿដេរភ្លួនឡូថាអាត្រើលចង្អុតកុំនិយាយផ្តាស ។

ឯចូសងនិងហោអាន់ នូវតេងយៀង, លីស៊ីន, តេងបិត, បិតហ្លួននោះតែងនាំគ្នាទៅស្វែងជាញ់សត្វម្រឹគបក្សីរាល់ថ្ងៃជាមិនដាច់. ចូអ៊ីឃើញដូច្នោះក៏និយាយហាមឃាត់ចូសងជាបងថា: អ្នកបងមានយសស័ក្តិដល់ប៉ុណ្ណោះហើយដែលនឹងមកនាំគ្នាទៅជាញ់សត្វម្រឹគបក្សីក្នុងព្រៃនោះមិនសមគួរសោះ ខ្លាចក្រែងសត្រូវវាលបទៅធ្វើអន្តរាយនឹងថ្លស់ការដល់វា, ចូសងឮប្អូននិយាយដូច្នោះត្រឡប់ជាខឹងប្រឡោតស្រែកគំហកដេរប្អូនថា : អញមានបុណ្យដល់ប៉ុណ្ណោះហើយ មនុស្សពាំងអស់ក៏នៅក្នុងកណ្តាប់ដៃអញ នរណានឹងអាចមកហ៊ានធ្វើអន្តរាយអញបាន, ហ្លួនហួបក៏ចូលទៅនិយាយហាមឃាត់ចូសងដូចពាក្យចូអ៊ីដូច្នោះទៀត ចូសងក៏មិនស្តាប់ ។

ខណៈនោះ, ព្រះថៅចូហងសោយរាជ្យបាន ១០ឆ្នាំ (ព.ស.៧៤២) ឯចូសងឃើញថាសុម៉ាអ៊ីឈឺមិនដែលចូលទៅគាល់ស្តេចសោះ ក៏មានចិត្តនោះកម្រើក ចេះតែធ្វើការអោកក្រក់ផ្សេង ៗ, បណ្តានាម៉ឺនមុខមន្ត្រីពាំងខ្លាយ ក៏នៅក្នុងកណ្តាប់ដៃចូសងពាំងអស់, លុះអម្ចងយូរមក ទើប

ចូសង្ឃតាំងលីសុិនឲប្រឹក្សាទឹងឲ្យធ្វើជាទៅហ្វាយស្រុកសៀងជីវ ទើប
បង្គាប់ឲ្យទៅលាសុម៉ាអ៊ុហើយឲ្យមើលអាការសុម៉ាអ៊ីផង ជាឈឺពិតមែន
ឫប្រការម្តេច, លីសុិនទទួលបង្គាប់ ហើយក៏លាចូសង្ឃទៅដល់ផ្ទះសុ៊ាអ៊ុ
ៗ ជិងដួច្នោះក៏និយាយនិងសុម៉ាស៊ូ សុម៉ាចៀរជាកូនថា: ដែលលីសុិន
មកនេះ គឺចូសង្ឃភ្លែងប្រើឲ្យមកមើលអាការចិតាឈឺមែន ឬម្តេចប៉ុណ្ណា
ទេ, ទើបសុម៉ាអ៊ីធ្វើជារំសាយសក់ ហើយយកកូយដណ្តប់ដេកបៃប
មនុស្សឈឺធម្មតា ឲ្យស្រីបម្រើ ២ នាក់ចូលទៅទ្រត្រងជម្ងាងម្នាក់ ហើយ
ពាចេញទៅទទួលលីសុិនឲ្យចូលទៅគំនាប់ហើយនិយាយថា: ខ្ញុំបាទមិន
បានដឹងសោះឡើយជាព្រះតេជព្រះគុណ លោកឈឺជាទម្ងន់ដល់យ៉ាងនេះ
សោះ វេលានេះព្រះចៅចូហងប្រើខ្ញុំបាទឲ្យទៅធ្វើទៅហ្វាយស្រុកសៀង
ជីវ បានជាខ្ញុំបាទចូលមកលាព្រះតេជព្រះគុណទៅឈរខែត្រហើយ ។

សុម៉ាអ៊ីបានឮដូច្នោះ ក៏ធ្វើជាធ្ងន់ត្រចៀកទើបភ្លែងថា: ដែលមាន
ព្រះតម្រាស់ត្រាស់ប្រើអ្នកឯងទៅធ្វើទៅហ្វាយស្រុកប៉ែងជីវនោះក៏ជាស្រួល
ណាស់ហើយ ព្រោះស្រុកប៉ែងជីវទៅជិតស្រុកក្រុងមានពាជការច្រើនចំឡែក
ទឹងបានហៅរកមកដោយងាយ លីសុិនថា: មិនមែនស្រុកប៉ែងជីវទេត្រាស់
ឲ្យខ្ញុំបាទទៅឈរស្រុកសៀងជីវទេតើ សុម៉ាអ៊ីអស់សំណើចហើយថា:
អ្នកឯងមកពីស្រុកសៀងជីវឬអ្វី! លីសុិនថា: លោកអាចារ្យឈឺធ្ងន់
ណាស់ហើយ បានជាមានប្រសាសន៍ដូចជារំរើរាយទៅ មនុស្សបម្រើ

ឆ្លើយប្រាប់ថា : លោកឈឺម្តងនេះធ្ងន់ជាងគេបង្អស់ទៅទៀត ហ៊ឺងត្រចៀក គេនិយាយអ្វីៗ លោកស្តាប់មិនសូវច្បាស់ទេ, ពីសុំនក៏ឲ្យយកក្រដាសនិងមកសរសេរសំបុត្រថា : ព្រះចៅចូរាងគ្រាស់ប្រើខ្ញុំបានឲ្យទៅធ្វើចៅហ្វាយស្រុកសៀងដីរ បានជាខ្ញុំបានចូលមកគាំទាប់លាលោកទៅ ហើយដូនទៅឲ្យសុម៉ាអ៊ីមើល ។

សុម៉ាអ៊ីយើញដូច្នោះ ក៏ឆ្លើយថា : ន! ឥឡូវប្រាសព្រះកដគាន ឲ្យអ្នកឯងទៅឈរស្រុកសៀងដីរហើយឬ អើ ស្រួលណាស់ហើយ, អ្នកឯងចូរឧស្សាហ៍ធ្វើពដការរក្សាខ្លួនកុំប្រមាទ ហើយយកដៃចង្អុលចំមាត់ ស្រីបម្រើក៏យកតឹកនឹងឆបរទៅឲ្យសុម៉ាអ៊ី។ សុំហើយក្លែងខ្លាក់ទឹកនឹងឆបរឲ្យហូរចេញមកវិញ ប្រាថ្នានឹងឲ្យលីសុនឃើញថាឈឺធ្ងន់មែន ហើយថាខ្លួនយើងសព្វថ្ងៃនេះក៏កាន់តែចាស់ជរាអាឥតការក៏ករម្រើកធ្ងន់ នឹងអស់ជន្មក្នុងថ្ងៃនេះ រុំថ្ងៃស្អែកមិនដឹងឡើយ, ឯសុម៉ាស៊ូ, សុម៉ាចៀវ ជាបុត្រយើងតាំង២ ក៏ជាមនុស្សតោតខ្លៅ ត្រូវអ្នកដួយអាណិតសង្គ្រោះប្រដែប្រដៅផងចុះ ហើយចូរដួយអនុគ្រោះនិយាយនឹងចូសងថា : យើងសុំផ្ញើបុត្រតាំង២ផងចុះ ហើយក៏ងាកខ្លួនច្រះដេកចុះធ្វើជាហត់ហឹបខ្លាំង, លីសុនក៏លាត្រឡប់ទៅប្រាប់ចូសងតាមពាក្យសុម៉ាអ៊ី នឹងប្រាប្តប្រាប់ហេតុតាមដែលឃើញអាការសុម៉ាអ៊ីឈឺត្រប់ប្រការ ចូសងបានឮដូច្នោះក៏ពេញចិត្តណាស់ ព្រោះមិនដឹងកលសុម៉ាអ៊ីហើយថា បើអាដែនេះវាស្លាប

ហើយ យើងក៏អស់សេចក្តីតក្ក ទោះយើងនឹងគិតធ្វើការអ្វីក៏បានដោយស្រួល ។

ក្រោយនោះ,សុមាំអ៊ុក្រោកឡើងនិយាយនឹងបុត្រទាំងពីរថា: លីសុនមកយើញថាឈឺយ៉ាងនេះហើយ មុខជានឹងទៅច្រាប់ចូសង មុខជាចូសងនឹងមិនសន្សំយូរដល់យើងទេ, យើងនឹងរិះគិតត្រៀមការទុកឲ្យព្រមបើចូសងចេញទៅដេញសត្វម្រឹគបក្សីកាលណា បើញបានការហើយយើងក៏នឹងធ្វើការ, បុត្រទាំង២ទទួលពាក្យហើយក៏ត្រៀមការទុកស្រេច។

លុះនៅមកក្នុងថ្ងៃ, ចូសងឲ្យតែងគ្រឿងសែនទុក ហើយទូលអញ្ជើញស្តេចព្រះចៅចូហង ឧងទាម៉ឺនទាំងពួងចេញទៅសែនសពព្រះចៅចូយ៉ាយទៅដំចន់កាបេងឡេង ហើយនឹងចេញទៅបាញ់សត្វ,ខណៈនោះចូអ៊ី, ចូហ៊ុន, ចូដានជាបួនកំនាំទាហានទៅតាមហែស្តេចផង, លុះចេញទៅដល់ក្រៅស្រុក ហ៊ិនហមក៏ចូលទៅចាប់ចង្កើរសេះចូសងទុកហើយថា: លោកជាធំនឹងនាំចង់ចូនចេញទៅក្រៅស្រុកនោះមិនគួរ ខ្លាចត្រែងមានអន្តរាយកើតឡើងក្នុងស្រុកមុខជានឹងការពារមិនទាន់ការ, ចូសងបានឮដូច្នោះក៏នឹកខឹងណាស់ស្រែកគំហកហើយថា: នាម៉ឺនទាំងពួងនៅក្នុងកណ្តាប់ដៃយើងទាំងអស់ហើយនរណាឡើយនឹងបង្អាបជាក្បត់បាន កុំបាច់និយាយឲ្យច្រើនទៅឡើយ ហើយក៏ឲ្យសេះទៅតាមស្តេច ។

សុមាំអ៊ុដំឆ៖ ចូសង,ចូអ៊ុ,ចូហ៊ុន,ចូឆាន និងនាយតាហានឈ្មោះ ហោអាន១,តេងយៀង១,តេងចិត១,ចិតហ៊ួន១,លីសុន១ ដែលជាមនុស្ស ខំនុកខុកចិត្ត ៤ នាក់នូវតាហានតាំងពួងតាមព្រះចៅចូហង់ចេញទៅតំនាប់ សងព្រះចៅចូយ៉ីយហើយហួសទៅប្រភាតព្រៃ សុមាំអ៊ុសប្បាយក្នុងចិត្ត ណាស់ ក៏ចូលទៅក្នុងទីក្រុង ទើបប្រើឲ្យកៅយីវតែងខ្លួនជានាម៉ឺនធំ មានតាហានកាន់សន្ទូរវែងមុខ ហែរក្រោយជាច្រើនឲ្យព័ទ្ធឡោមចូសង ខុក ហើយប្រើអង់ពួនជាសេនាបតីធំ មានតាហានហែមុខហែក្រោយ លើកទៅព័ទ្ធឡោមចូអ៊ុទៀត, ឯសុមាំអ៊ុក៏នាំពួកនាម៉ឺនថាស់ៗ ចូលទៅ គាល់នាងកួយថាយហៅជាព្រះពជមាតាព្រះចៅចូហង់ហើយទូលថា:វេលា នេះចូសងមិនគិតនឹករឭកដល់ព្រះបណ្តាំព្រះចៅចូយ៉ីយអស់ហើយ ដែល ទ្រង់បានផ្តាំផ្ញើសេចក្តីសុខទុក្ខឲ្យខំនុកបំរុង ព្រះចៅចូហង់នោះក៏ក្មេងពាំង អស់ គោះនឹងធ្វើការអ្វីក៏មែងធ្វើទៅតាមអំពើចិត្តពាំងអស់ គោះមាន សេចក្តីគាប់ខុសយ៉ាងណាក៏មិនត្រូវការនឹងពិតទូលដែលចូសងតាំងចិត្តប្រ-ព្រឹត្តអាក្រក់យ៉ាងនេះ យើញឮថ្លាស់ជាចេញស្តាត់ផែនដី ជាគេសឆ្ងល់ ណាស់ ទឹងស្ងៀមទៅមិនបានទេ, នាងកួយថាយហៅបានឮដូច្នោះក៏ ភ័យណាស់ថា: ឥឡូវព្រះមហាក្សត្រិយ៍ស្តេចទៅប្រភាតព្រៃ យើងក៏ គាល់បើគិតសោះហើយ, សុមាំអ៊ុទូលថា: ទូលព្រះបង្គំនឹងសុំធ្វើរឿង

ក៏វៀយព្រះភៀចូហង៑ថា: ឲ្យកំចាត់បណ្តាមនុស្សដែលជាប័ក្ខពួកសត្រូវ
នោះចេញ; ការគ្រានេះកុំឲ្យព្រះអង្គច្រង៑ាតក្តីឡើយ ជាក្មាក់ជារឲ្លួល
ព្រះបង្គំហើយនឹង១ឲ្លួលជាជុះឯង ។

ព្រះនាង៑ក្លួយថាយហៅ ក័ន៑កខ្លាចសុម៉ាអ៊ី ទើបបណ្តាយថា តាម
តែចិត្តលោកចុះ, សុម៉ាអ៊ីចេញពីព្រះភដ៑ង៑ភៅ ក៏ប្រឹក្សាន៑ងភៀវចេ
ហើយនឹង៑សុម៉ាហ៊ូដែលជាមនុស្សខំនុកឧកចិត្តរបស់ខ្លួន ចុះឈ្មោះជាមួយ
គ្នាធ្វើរឿង៑ក៉ាវ ប្រើឲ្យហង៑វុនតាមចេញភៅថ្វាយព្រះភៀចូហង៑, ឯសុម៉ាអ៊ី
ក៏នាំ១ហានភៅជាច្រើន ឲ្យ១ហានក្បែរពេង៑គ្រប់អន្ទៅដែលសម្រាប់
ដាក់គ្រឿង៑សស្ត្រាវុធ៑ង៑ង៑ពួង៑, ហើយក៏នាំ១ហានដើរភៅតាមថ្នល់
កែ្បរផ្ទះចូសង៑ភៅ នឹង៑ចេញភៅក្រៅស្រុកក្រុង៑, មាន១ហានម្នាក់
ចូលភៅច្រាប់នាង៑ឡៅ៑ជ្រៃន្ធចូសង៑ថា: ឥឡូវសុម៉ាអ៊ីនឹង៑គោយីនាំ
១ហានមកច្រើនណាស់ សុទ្ធតែកាន់សស្ត្រាវុធគ្រប់ដៃជិតដុំអ្នកអស់
ហើយ ប្រុង៑នឹង៑ធ្វើម្តេចមិនដាក់ប្លាស់ ។

នាង៑ម្លៅសីក៏ដើរចេញទោមុខផ្ទះ ហើយហៅនាយទ្វារដែលថែ
រក្សាផ្ទះនោះមកសួរថ: ចូសង៑តាមហែស្តេចភៅហើយ ឥឡូវសុម៉ាអ៊ី
នាំ១ហានមកព័ទ្ធច្រើនណាស មិនដឹង៑ជាគេប្រុង៑នឹង៑ធ្វើប្រការម្តេចទេ !
ភូតីជាមេរក្សាផ្ទះឆ្លើយថា: លោកកុំព្រួយព្រះចិត្តអ្វីឡើយ, ខ្ញុំបាទហើយ

និងអាចចេញទៅសួរឲ្យដឹងការ ថាហើយក៏នាំគាហានប្រមាណ៥០នាក់ ឡើងទៅលើសេនចន្ទាយ ក្រឡេកទៅឃើញសុម៉ាអ៊ីនាំគាហានចូលមកជិតកំពែង, ទើបឲ្យគាហានយឹតធ្នូបាញ់ចុះទៅ សុម៉ាអ៊ីនឹងដើរចូលមកមិនបាន ។

ស៊ីនហៀមនាយគាហានឈរជិតសុម៉ាអ៊ី ក៏ស្រែកឃាត់ហាមទៅថា កុំឲ្យបាញ់ធ្នូចុះមក ព្រោះលោកអ្នកធំនឹងអញ្ជើញចូលទៅនិយាយពាជការពីស្រុកខេសដង៏ បើនៅតែបាញ់ចុះមក មុខជាមានរឿងរ៉ាវនឹងគ្នាជាធំណាស់ , ស៊ីនហៀមស្រែកឃាត់ហាមដល់ដងទាដង , ទើបភួតីឃាត់គាហានមិនឲ្យបាញ់ ; សុម៉ាចៀវជាបុត្រសុម៉ាអ៊ី វេលានោះ បានលើកគាហានទៅមុនបិតា ទទួលចេញពីកំពែងស្រុកទៅដល់មាត់កំពង់ ក៏តាំងតង់គាហាននៅប្រចាំការរក្សាស្ពាន សុម៉ាអ៊ីក៏បង្គាប់គាហានឲ្យបិទទ្វារស្រុក ហើយឲ្យគាហានរក្សាស្រុកទុកយ៉ាងមាំមួន , ឯខ្លួនសុម៉ាអ៊ីក៏ចេញទៅត្រួតត្រារក្សាស្ពាន តែស្ពានដែលធ្លុងស្ទឹងនោះគ្មានសសរជាំបុរាណដែរ គឺជាស្ពានផែកណ្តែតលើទឹក ចោះយុក្តាបណ្តែតទេ សម្រាប់មនុស្សធ្លុងទៅមកបាន ។

សុខ៉ាឡាជាគាហានចូសង៏ ឃើញសុម៉ាអ៊ីធ្វើការដូច្នោះ ក៏ទៅប្រឹក្សាគ្នានឹងស៊ីមប៉ែដែលនោត្រតត្រគាហានចូសង៏ថា : សុម៉ាអ៊ីធ្វើការ

យ៉ាងនេះប្រហែលជាគំនិតគិតយ៉ាងម្តេចទៅវិញ , សុំនប៉ែថា : មើលទៅឃើញថ្លែកណាស់ បើដូច្នេះត្រូវយើងកុំទៅ គួរតែនាំគាហានបងស់យើងលើកទៅតាមស្តេចចុះ , សុម៉ាឡេវដីថា:អ្នកឯងនិយាយយ៉ាងនោះខ្ញុំមិនយល់ផងសោះ , សុំនប៉ែថា: បើដូច្នោះយើងនាំគ្នាទៅនៅក្រៅផ្ទះខ្ញុំចុះ ព្រោះជាទីស្ងាត់ ដើម្បីនឹងបានរិះគិតការនឹងគ្នា សុម៉ាឡេដីនឹងសុំនប៉ែក៏នាំគ្នាទៅ ។

នាងសុំនហៀនអេងជាបងស្រីសុំនប៉ែ ក្រឡែកឃើញសុំនប៉ែទៅដល់ក៏សួរថា:មានហេតុកេះអ្វីឬ ចានជាមានទឹកមុខបែបភ័យដូច្នេះ ដើរលេះលៀងថ្ងៃក។ ? សុំនប៉ែប្រាប់ថា: ព្រះចៅចូសងស្តេចទៅប្រពាតព្រៃ, សុម៉ាអ៊ីបិទទ្វារស្រុកអស់ទំនងជាគិតក្បត់ហើយចានជាធ្វើដូច្នេះ,នាងសុំនហៀនអេងថា: សុម៉ាអ៊ីធ្វើការបែបនេះ ខ្ញុំពិគ្រោះមើលឃើញថាមិនមែនជាក្បត់ទេ ដែលធ្វើការនេះប្រាថ្នាឲ្យនឹងកំចាត់ចូសងទេតើ , សុំនប៉ែតួដូច្នេះក៏ភ័យណាស់ថា បើគេធ្វើខុកដល់នាយទៅហ្មាយរបស់ខ្ញុំហើយខ្ញុំនឹងចានសេចក្តីសុខពីត្រង់ណា ។

នាងសុំនហៀនអេងថា : ចូសងនោះមិនចានជាមនុស្សមានសតិបញ្ញាដូចជាសុម៉ាអ៊ីទេ , មុខជានឹងចាញ់ឧបាយសុម៉ាអ៊ី, សុំនប៉ែថា: ពីមុំលមិញសុម៉ាអ៊ីបបួលខ្ញុំឲ្យចូលទៅធ្វើការជាមួយ ខ្ញុំនឹងចូលទៅស្រួល

ល្អប្រ ។ កុំចូលទៅស្រួលជាង ? នាងសុំនហៀនអេងថា : ធម្មតាជា
ជាតិបុរសសត្បាទុស័ត្យដូចខ្លួនប្អូនឯង បានទៅពឹងបុណ្យចូសង៍មកយូរ
ហើយ, វេលានេះបើយើញថាចូសង៍និងហាញ់ប្រៀបសុមាអ៊ី ហើយ
យើងត្រឡប់ទៅចូលទៅពឹងបុណ្យសុមាអ៊ីវិញ, អំណើះទៅមុខសុមាអ៊ី
ក៏មិនមែននឹងស្រឡាញ់អាណិតយើងប៉ុន្មាន, ទោះបីចូសង៍នឹងទៅជាអ្វី
គប្បីតែយើងនឹងប្លាស្លូនទៅនឹងចូសង៍តទៅទើបគួរ, សុំង៍ប៉ែក៍យល់ឃើញ
ត្រូវ ទើបនាំសុមាទៅដីនិងតាហានប្រមាណ ៥០ ទៅសម្លាប់មនុស្ស
ដែលរក្សាទ្វារនោះចេញ ហើយរត់ទៅរកចូសង៍, តាហានដែលរក្សាទ្វារ
ក៏នាំពតិមានទៅប្រាប់សុមាអ៊ី ។ឮដូច្នោះគិតខ្វាចក្រែងហ្លួនហម, តាហាន
ចូសង៍និងរត់តាមទៅផង ទើបឲ្យតាហានទៅហៅខ្លួនហ្លួមហម ។

ឯហ្លួនហមឃើញសុមាអ៊ីធ្វើដូច្នោះ ក៏ប្រឹក្សានឹងកូនប្រុសថា: យើង
នឹងគិតប្រការម្តេច ? កូនប្រុសឆ្លើយថា : ចូសង៍ទៅហ្នាយយើងទៅ
ហែស្តេច ដែលយើងនឹងចូលទៅគប់គិតរួមគំនិតនឹងសុមាអ៊ីនោះមិនគួរ
ទេ យើងត្រូវតែលបរត់ទៅតាមផ្លូវទិសឯត្បូង ទៅគេចទៅហ្នាយយើង
ទើបគួរ, ហ្លួនហមយល់ឃើញត្រូវ ទើបឡើងដំរះបរតម្រង់ទៅទិស
ឯត្បូងឃើញទ្វារបិទជិត ក្រឡេកទៅឃើញស៊ូហ្លួនជាបាវបម្រើខ្លួន ពី
ដើមបានធ្វើជានាយទ្វារ ទើបចាប់ឈើលើកឡើងឲ្យមើលហើយប្រាប់
ថា : ព្រះនាងក្លួយថាយហៅមានព្រះសារនីយ៍ប្រើឲ្យយើងចេញទៅក្រៅ
ដោយការប្រញាប់ ឯងចូរបើកទ្វារឲ្យយើងចេញទៅ ។

ស៊ូហ៊ិនថា : ខ្ញុំបានសុំមើលព្រះសារីរិយ៍ស័ន , ហ៊ិនហមធ្វើយថា: ចៅជាចាវយើងពីដើម ១កដការមមាញឹកដល់ប៉ុណ្ណេះហើយ ខ្ញុំមិនគួរមកទាំងអង់ធ្វើឲ្យយើងយូរដំណើរទេ , ស៊ូហ៊ិនក៏បើកទ្វារឲ្យភ្លាម, ហ៊ិន-ហមក៏ចេញទៅផុតមាត់ទ្វារហើយងាកមកនិយាយថា : សុមា"អ៊ីគិតក្បត់ហើយ ចៅកុំទៅឡើយ មកវិលទៅជាមួយនឹងយើងចុះ , ស៊ូហ៊ិនឮដូច្នោះក៏ភ័យខ្លាំងណាស់ គិតឃើញថា ខ្ញុំបើកទ្វារឲ្យហ៊ិនហមចេញរួចទៅនោះ ត្រូវមានទោសខុសជាទម្ងន់ ក៏ស្ទុះរកតាមទៅនឹងចាប់ហ៊ិនហមដេញក៏មិនទាន់ , ពួកនាយទ្វារឯទៀតក៏នាំពតិមានទៅច្រាប់សុមា"អ៊ីថា : ហ៊ិនហមរត់រួចទៅហើយ ។

សុមា"អ៊ីឮដូច្នោះក៏តើតវិតក្កណាស់ ទើបប្រឹក្សានឹងចៀវចេថា : ការដែលយើងធ្វើខាងអម្បាលនេះ មុខជាមនុស្សខាងក្រៅនឹងដឹងឮដោយសារតែហ៊ិនហមដែលរត់ចេញទៅ , ចៀវចេថា : ទោះបីមនុស្សខាងក្រៅនឹងដឹងយ៉ាងណាក៏មិនត្រូវខ្លាចអ្វី យើងត្រូវតែប្រឹងទំរក្សាស្រុកឲ្យមាំមួន វេលានោះសុមា"អ៊ីឲ្យហៅទៅអិន, តាន់-ថាយនាយពាហានចូសង ២ នាក់មកបង្គាប់ថា : អ្នកឯងត្រូវទៅច្រាប់ចូសងថា: យើងធ្វើការនេះមិនមែនគិតប្រទូសក៉ាយម្ចាស់ផែនដី និងចូសងទេ, អ្នកឯងកុំធ្វល់សង្ស័យអ្វីឡើយ យើងយល់ឃើញថា : ពាហានជាស្ត្រីគ្រប់ក្នុងពួកអ្នកឯងច្រើនណាស់ បើនឹងលាក់ទុកយូរទៅខ្លាចក្រែងមានអន្តរាយ យើងធ្វើដូច្នេះ

ប្រាប់ថ្នាំងឆ្លើយតបហានស្ដ្រីបច្ចក្ខពួកបងប្អូនរបស់អ្នកឯង ឲ្យចូលទៅជាខ្ញុំហ្នឹង បង្គាប់ហើយឲ្យទៅអិន, គាន់ថាយលើកចេញទៅ ; សុមាអ៊ីខ្ញាចក្រែងចូសងនឹងមិនស្ដាប់ពាក្យទៅអិន,គាន់ថាយ ទើបឲ្យហៅអិនតាយបុកនាយតាហានធំ ជាមនុស្សខំនុកចុកចិត្តរបស់ចូសងមក ហើយប្រើចៀវចេឲ្យតែងសំបុត្ររឿងក៉ាវតាមដំណើរដែលនិយាយនោះ ប្រគល់ទៅឲ្យអ៊ុនតាយបុក ហើយបង្គាប់ថែមថា : អ្នកឯងត្រូវប្រញាប់ទៅប្រាប់ចូសងថា : យើងនឹងចៀវចេបានប្ដេជ្ញាស្បថសច្ចាន់ឆ្នាំងគ្នាថា យើងគិតការដូច្នេះ មិនមែនគិតធ្វើអន្តរាយដល់គ្រប់គ្រួ ឬបុត្រកិយោរបស់ចូសងទេ យើងត្រូវតែលុបនឹងលើកយកតាហានរបស់បងប្អូនចូសងឲ្យចូលទៅជាខ្ញុំហ្នឹង ឯអ៊ុនតាយបុកទទួលសំបុត្ររកើយក៏លាចេញទៅ ។

ឯចូសងដំរេសេរបរបណ្ដាញសត្វលេងក្នុងកណ្ដាលព្រៃ មានតាហានទៅប្រាប់ថា : ឥឡូវនេះកើតហេតុកែវក្នុងស្រុកខ្ញាំងណាស់, សុមាអ៊ីប្រើឲ្យមនុស្សនាំសំបុត្ររឿងក៉ាមកថ្វាយព្រះចៅចាហង ដាសេចក្ដីដូចម្ដេចមិនបានដឹងជាប្រាកដ, ចូសងបានឮដូច្នោះក៏ភ័យណាស់ ចុះពីលើទៅគាល់ព្រះចៅចាហង ក្រឡេកទៅឃើញហង៉ុនគាន់សំបុត្រម៉ចម៉ាយក្រាបពីមុខព្រះភ័ក្ត្រ ចូសងក៏ទទួលយកសំបុត្រនោះប្រគល់ឲ្យអ្នកឯទៀតសូត្រថ្វាយទ្រង់ព្រះសណ្ដាប់ ។

ក្នុងរឿងក៉ានោះថា : ខ្ញុំសុមាអ៊ី ជានតាមស្ដេចព្រះ

ពជដំណើរមកពីស្រុកសៀវតាំង ចានធ្វើពជការថ្វាយមកកំយុរ ហើយ
កាលព្រះបិតារបស់ព្រះអង្គជិតអស់ព្រះជន្ម ទ្រង់ចានឲ្យហៅទូលព្រះបង្គំ
នឹងទ្រង់ព្រះករុណាហើយនិងចូសង់ចូលទៅក្រាបបង្គំគាល់ទៀបទី ព្រះបន្ទំ
ដែលទ្រង់ប្រឈួន ទ្រង់ចានលើកព្រះហស្តស្ទាបអង្អែលខ្នងទូលព្រះ
បង្គំ ហើយមានព្រះបន្ទូលផ្តាំផ្ញើទ្រង់ព្រះករុណានឹងពជការផែនដីឲ្យទូល
ព្រះបង្គំនិងចូសង់ឲ្យជួយទំនុកបំរុងព្រះអង្គតាមសុចរិតឥឡូវទូលព្រះបង្គំជា
ខ្ញុំយល់យើញថា ចូសង់គ្មានរំលឹកនឹកដល់ព្រះបណ្តាំព្រះបិតាព្រះអង្គដែល
ទ្រង់ផ្តាំផ្ញើនោះសូន្យសោះ , ដែលចូសង់ធ្វើការសព្វថ្ងៃនេះ គឺបំរុងនឹង
ក្បត់ផែនដី ចានជាតាំងឲ្យទៀតងជាមនុស្សទំនុកទុកចិត្តជាទីតៅកាំចូល
គាល់ដល់ខាងក្នុងចាន គឺឲ្យទៅចាំស្តាប់យកការអាថកំបាំង ហើយឲ្យ
ទៅរក្សាព្រះសែងនឹងគ្រាព្រះរាជ្ជាការសម្រាប់ពជ្ឈ , គ្រាមុនចូសង់ចាន
ទូលញុះញង់ឲ្យបណ្តេញព្រះមហេសីស្តាំធ្វេរបស់ព្រះបិតាព្រះអង្គ ឲ្យ ចង់
បៃតង្គាគ្រាតែក្បួយ១ព្រះអង្គទៅ ក៏ចានទ្រាំសេចក្តីទុក្ខទោមនស្សដល់ព្រះ
រាជវង្ស ឥឡូវទ្រង់ក៏យើញហើយថាការផែនដីតាំងពួង បើគេនឹងធ្វើអ្វី
ក៏មិនចានយកសេចក្តីក្រាបពិតទូលព្រះអង្គសោះបើ នឹង ឲ្យ រំលាង មនុស្ស
ទោសទុសដល់ស្លាប់ក៏មិនចានពិតទូលឲ្យទ្រង់ជ្រាបឡើយ ស្រេចនៅគេ
ហើយធ្វើតាមអំពើចិត្ត ។

មួយទៀត , ចង់ប្លន់នឹងស្ត្រីច័ក្កពត្តិរបស់ចូសង់ចាន់ប៉ុន្មាន , សុទ្ធ

តែហៅហ៊ានគំរាមកំហែងនាម៉ឺនចាស់ទុំធំតូចមិនញញើតខ្លាច ប្រើអំណាចបៀតបៀនសង្កត់សង្កិនបណ្តោកស្ត្រីឲ្យបានសេចក្តីក្តៅក្រហាយទូលទៅ , ចូសង ធ្វើតំដៅតាំងម្ទេះ ព្រោះមិនគិតដល់ព្រះបណ្តាំព្រះបិតាដែលផ្តាំផ្ញើនោះសោះឡើយ ខ្ញុំ ព្រះបង្គំនេះហើយអាចនៅរក្សាចាំព្រះបណ្តាំគ្រប់ប្រការ , សូម្បីតាំងបៀរចនិងសុមាំហ៊ូក៏សុទ្ធតែមានចិត្តគិតរក្សាទឹកដល់ព្រះគុណព្រះបិតារបស់ព្រះអង្គ ដែលទ្រង់បានប្រោសព្រះកដ្ឋានឲ្យមានយសដង្ហាបណ្តាសក្តិទឹនប្រាក់បៀវត្សរ៍ចិញ្ចឹមជីវិតដរាបមក ទើបប្រឹក្សាព្រមគ្នាចាត់ចែងឲ្យលើកសាលយោធាទៅចំរុះក្សាទីតេហស្ថានចូសងទឹងទីលំនៅបងប្អូនចូសង មុនទឹនធ្វើដូច្នោះ ខ្ញុំព្រះបង្គំជាខ្ញុំក៏បាននាំសេចក្តីទៅក្រាបទូលដល់ព្រះមាតារបស់ព្រះអង្គ ទ្រង់ក៏យល់ឃើញផងទើបទូលឲ្យគ្រាស់ព្រះបង្គំជាខ្ញុំផ្ទើរឿងរ៉ាវនេះនាំចូលមកក្រាបទូលថ្វាយព្រះអង្គ ខ្ញុំព្រះបង្គំជាខ្ញុំបានប្រែហង៍វុនឲ្យនាំមកថ្វាយ សូមឲ្យព្រះអង្គហូតដកងារបូសង ចូ ចូហ៊ុនចេញចាកតំណែង ហើយឲ្យលើកយកតាហានតាំងភ្ជួរទៅជាលួងវិញទូលព្រះបង្គំជាខ្ញុំទៅចាំរកទុកាសបានស្រួលទើបចូលមកក្រាបបង្គំគាល់ផ្ទាល់ខ្លួន ដើម្បីនឹងរិះគិតឲ្យមាំមួនជួយទំនុកបម្រុងព្រះអង្គ ឥឡូវទូលព្រះបង្គំជាខ្ញុំបានលើកតាហានតម្រង់ទៅត្រួតគ្រាវក្សាស្ពានទឹងផែនៅដំបន់ខ្ទុកហោចាំមើលការទុសត្រូវ ។

ព្រះចៅចូសងបានទ្រង់ព្រះសណ្តាបច្បាស់ ទើបគ្រាស់ប្រាប់ចូ-

សង់ថា : អ្នកនឹងគិតប្រការម្តេចទៅវិញបើការយ៉ាងនេះ ? ចូសង់បាន
ឮប្អូញត្មោះកំភ័យស្ងួតស្ងាំងកាំង ប្រែទឹកមុខស្លុតស្ងាំងដូចគ្មានឈាមសោះ
ខ្លួនច្រណា កំពោះខ្ទន់អស់ពាំងសង្កិន្តើចបែរក្លាងទៅពីគ្រោះនឹងចូអ៊ុថា :
សេចក្តីខ្លាចក្តៅផ្សានឹងមានមកដល់យើងគ្រានេះហើយ ខ្ញុ ! យើងអើយ
នឹងគិតដូចម្តេច ! ចូអ៊ុថា : ខ្ញុំឃ្លាតរំភើកលោកច្រើនដងហើយ លោក
មិនព្រមស្តាប់ខ្ញុំ ទំនែបចេះធ្វើតាមអំពេចិត្តខ្លាល់តែកើតវិប្បរិតអាក្រក់
ខុសយ៉ាងនេះហើយនឹងចេះដើម្បីម្តេច , ព្រោះសុម៉ាអ៊ុគេជាមនុស្សមានសតិ
បញ្ញាឆៀវឆ្លាតណាស់ , ស្ងួម្បីខុងចេងដែលជាមេប្រាជ្ញក្នុងលោកយ៉ាងដ៏
វិសេស ម្តេចកំនត់យកដំបៅដំខ្ទះសុម៉ាអ៊ុមិនជាន , យើងចង់ប្តូនចេះ
ប៉ុណ្ណេះគាលណាទើងរំពាន, ស្ងើនឹងថ្ងៃដែរគេឡើយ គួរហើយតែនឹងចង
ចំណងខ្លួនឯង ហើយចូលទៅសុំចំណុះចុះចូលគេទៅទើបនឹងរួចអាយុ
ជីវិត និយាយមិនទាន់ផុតមាត់ស្រាប់តែយើញស៊ុនប៉េនឹងសុម៉ាឡៅដ៏ទៅ
ដល់ នោះចូសង់ក៏សាកសួរសុខទុក្ខក្នុងពាក្យការ ឈ្លោះទាំង ២ ក៏ថ្វែងពាណីនាក់ចូការសុខទុក្ខក្នុងស្រុកទេសឲ្យស្តាប់ហើយថា គេតាំងរក្សាស្រុកវេលានេះជាការខ្ជាប់ខ្ជួនមាំមួនណាស់ ប្រៀបបីដូចគេវាយច្បាសដែតរឹងតាំង ឯខ្លួនសុម៉ាអ៊ុសោត គេក៏តាំងលើកពលទាហានមកប្រចាំការក្បាស្តាន លោកកុំអាលទន្ទ្រានចូលទៅឡើយ ត្រូវតែគិតរកឧបាយ

រក្សារូបកាយទៅសិនចុះ ។

ខ្ជួលហ៊ីនហមបំផាយសេះចូលទៅដល់ខៀត ចូសង៏ក៏សាកសួរពីកិច្ចការដការ ហ៊ីនហមក៏អធិប្បាយប្រាប់ថា : សុមា"អ៊ីគិតក្បត់ហើយ លោកចូរអញ្ជើញស្តេចគេចទៅស្រុកហ៊ីគោវិញចុះ ដើម្បីទឹងបានបញ្ចុះបញ្ចូលពលរេហ៍តែ៦រកគ្រឿងសស្ត្រាវុធឲ្យបានព្រម ហើយសឹមលើកទៅព័ទ្ធចោមសុមា"អ៊ី; ចូសង៏ថា : អស់មុខមន្ត្រីចាំង៏ពួង៏សឹង៏តាមហមកឯណោះចាំង៏អស់ ឯកវិយាបុត្រក៏នៅក្នុង៏ក្រុង៏ឯណោះគ្រប់គ្នា បើទឹងគិតដកហ្វាទៅចោល ឃើញជាពុំបាន ហ៊ីនហមថា : បើលោកគិតអាឡោះអាល័យកវិយាបុត្រហើយមានតែកុំធ្វើសង្គ្រាម ត្រូវតែព្រមខ្ជួនលំនោនកាយទៅថ្វាយបង្គំសត្រូវទៅ ដែលគិតដូច្នេះឈ្មោះថាមិនស្រឡាញ់អាយុដ៏វែងខ្លួន ស្រឡាញ់កវិយាបុត្រជាជាង៏ដ៏វែងខ្លួន ខ្ញុំបាទមិនបានយល់ឃើញផង៏សោះ ព្រោះជាជាតិតាហានហើយ មិនត្រូវទៅស្រឡាញ់ដ៏វែងអ្នកដទៃទេ គិតតែការពាររក្សាដ៏វែងខ្លួនទុកឲ្យគង់ ចូសង៏ក៏មិនស្តាប់ពាក្យហ៊ីនហមសោះ គិតតែស្រណោះអាឡោះអាល័យដល់កវិយាបុត្រ ហើយក៏យំហូរទឹកភ្នែកជោកអស់ចាំង៏មុខមាត់ ។

ហ៊ីនហមថា : ពីនេះទៅស្រុកហ៊ីគោក៏ជាមិនឆ្ងាយប៉ុន្មានទេ ទៅប្រហែលជា៣-៤ មោ"ង៏គង់ដល់ពីនោះ មានចំណីអាហារបរិបូណ៌ណាស់ បើទឹងបម្រុងឲ្យពលរេហ៍បរិភោគបាន ១ ខែ ២ ខែ ទឹងត្រៀមការបានព្រម

សុំឲ្យលោកខំរិះគន់ពៅចុះកុំឲ្យបង្អង់ឲ្យយូរការនឹងអសារប្រយោជន៍ ចូ-
សឯងថា : ការគ្រានេះធំពន្ធឹកណាស់ តែទំស្រួតរហ័សនឹងថ្ងស់ការ ចាំ
យើងត្រិះរិះឲ្យល្អិតល្អិនសិន លុះនៅបានមួយស្រេចក់ ស្រាប់ទៅអិន តាន់
ថាយពៅដល់ ហើយនិយាយនឹងចូសឯងថា : សុម៉ាអ៊ីធ្វើការគ្រានេះ មិន
មែននឹងគិតធ្វើអន្តរាយដល់លោកទេ, ធ្វើតែល្មមនឹងលើកយកភាហាន
រថស់លោកនិងភាហានរបស់បងប្អូនលោកជាក់ពៅភាហានហ្នឹងប៉ុណ្ណោះ,
ចូសឯងមិនគាន់យល់ឃើញផងក៏នៅស្ងៀម ហើយអិនតាយបុកដែលជា
មនុស្សខំនុកឧុកចិត្តរបស់ចូសឯងពៅដល់ទៀត អធិប្បាយប្រាប់សេចក្តី
ថា : សុម៉ាអ៊ីនឹងចៀវតាំងសច្ចាស្បថស្បាន់នឹងគ្នាថា គិតធ្វើការគ្រា
នេះ មិនបានធ្វើអន្តរាយដល់លោកទេ ហើយចៀវចេញទំបុត្រមកដល់
លោក ឲ្យលោកប្រគល់ឲ្យភាហានទាំពៅឲ្យសុម៉ាអ៊ី ឯខ្លួនលោក ។ កុំ
ព្រួយឡើយមិនជាអ្វីទេ ឲ្យលោកស្រួតពៅរកកំយោបុត្រចុះ ចូសឯង
ស្តាប់យល់ត្រូវនឹងគំនិតខ្លួនក៏ធូរស្រាលក្នុងចិត្តច្រើន ។

ហ៊ិនហមចេះតែតឿនថា : ការក្តៅកើតឡើងដល់ប៉ុណ្ណោះហើយ នៅ
តែស្តាប់ពាក្យគេផ្តួសផ្តាសទៀត មិនរិះគិតកែខ្លួនឲ្យមាំមួន ទំតែថា
មុខពៅកាន់សេចក្តីស្ងាប់វិញ ឯចូសឯងដល់ពេលកណ្តាលយប់នោះ ក៏
បង្កើតសេចក្តីទុក្ខសោកសៅក្តៅក្តួលក្នុងខុច ចេះតែពិចារណានឹងរកឧបាយ
ដែលនឹងកែខ្លួនក៏គ្មានឃើញច្រកល្អកសោះ រំលោះចូសឯង ក៏ហួតក្រប៉ែ

ភាន់នៅដៃ គិតត្រាំក្រែជាខ្លុកដកដង្កើមធំ ទឹកភ្នែកកំហូរច្រឡំលាយនឹងនឹងសំបោរ គិត ។ ៗ ទៅនៅតែឯកោឧកាកាយ តាំងពីពេលបាយព្រលប់ជាប់ដល់ភ្លឺស្វាង ភ្លឺស្វាង ព្រះសុរិយោគ្មានសាយនាបន្តិចសោះ ទឹងរកច្រកចន្លោះពុំឃើញសោះឡើយ ហ្ន៎ិនហមចេះតែគឿនថា លោកអ៊ែគិតតាំងពីក្បាលព្រលប់រហូតដាល់ព្រឹកហើយ ម្តេចឡើយមិនមានប្រសាសន៍ជាបានឃើញឧបាយយ៉ាងណាខ្លះ សូមប្រាប់ឲ្យខ្ញុំបាទដឹងផងនឹងបានធូរចិត្តចូសងថាល់គំនិតលើកក្រប៉ីឡើងនិយាយថា : យើងមិនលើកទឹពៅឲ្យលំបាកថាមានទេ បើគេនឹងដកហូតងារយើងចេញក៏តាមការចុះ យើងនឹងបានអង្គុយដេកស៊ីតាមសប្បាយ ។

ហ្ន៎ិនហមបានឮពៅហ្នាយថាដូច្នោះ ក៏ស្រែកទ្រហ៊ោយំដោយសំឡេងខ្លាំងហើយក្រោកដើរចេញពីទីនោះទៅហើយថា : ចូជនជាអាពុកចូសងនេះ អ្នកខ្លួនថាជាមានសតិបញ្ញាមានបុត្រា ៣ នាក់ក៏មិនប្រៀនប្រដៅឲ្យវិជ្ជារចេះដឹងក្នុងផ្លូវរកការទៀតហប្បញ្ញាដូចជាគោឬក្របីវិស័យ ស្រដីហើយក៏យំដើរទៅ វេលានោះទៅអិន និងតាន់ថាយ ចូលទៅនិយាយនឹងចូសងថា បើលោកព្រមចំណុះចុះចូលគេហើយ ត្រូវចាត់ចម្រើឲ្យនាំគ្រាសម្រាប់ងារចូលទៅដូនសុម៉ាអ៊ីឲ្យអស់សង្ឃឹយចុះ ចូសងបានឮដូច្នោះ ទើបប្រគល់គ្រាសម្រាប់ងារឲ្យទៅអិននិងតាន់ថាយមានសម្តីបញ្ជាឲ្យម្នាក់ឈ្មោះអៀងចុង បើញដូច្នោះ ក៏ស្រែកយំចូលទៅ

ដណ្តើមតាញយកគ្រាហើយថា: លោកចាលពាលតាហានតាំងអស់ចេញ
ហើយនឹងបង្ខូនខ្ញុំបានបង្ហាន់ទៅទួលអាជ្ញាណាកម្មគេចុះ ខ្ញុំបានឃើញ
ថាមិនផុតពីសេចក្តីស្លាប់នាកណ្តាលទីផ្សារឡើយ , ចូសង៏ថា: សុមាអ៊ី
គេជាមនុស្សល្អត្រឹមត្រូវណាស់យើង៏យល់ច្បាស់ថាគេមិនបង់ស័ត្យវាទីទេ,
ថាហើយក៏ហុចគ្រាទៅឲ្យទៅអ៊ុននិង៏តាន់ថាយហើយផ្តាំពាក្យថា: អ្នកចូរ
នាំគ្រានេះទៅជូនសុមាអ៊ីផង៏ចុះ, ហើយថា : ការនោះកុំឲ្យសុមាអ៊ីសន្ទិះ
សង្ស័យនឹង៏យើង៏ : ទៅអ៊ុន , តាន់ថាយក៏លែត្រឡប់ចូលទៅក្នុង៏ក្រុង
វិញ , ឯចូសង៏ក៏រៀបដំណើរនឹង៏តាមទៅក្រោយ ។

គ្រានោះអស់បណ្តាពួកតាហាន បានឃើញចូសង៏គ្មានគ្រាសម្រាប់
ដាវហើយក៏នាំគ្នាគេចរត់ខ្ចាត់ខ្ចាយអស់ទៅ សល់នៅតែបង៏ប្អូនចូសង៏ ៣
នាក់ នឹង៏ពួកនាម៉ឺនដែលជាទំនុកទុកចិត្តរបស់ចូសង៏ , ក៏នាំគ្នាដើរមួយ
កង៏ចូលទៅក្នុង៏ក្រុង , លុះទៅដល់បុង៏ស្នានផែ ក៏នាំគ្នាចូលហៅទៅ
គំនាប់សុមាអ៊ី ។ថា: អញ្ជើញអ្នកបង៏ប្អូនទាំង៏៣នាក់ហួសទៅផ្ទះចុះ , តែ
អស់នាម៉ឺនជាស្ត្រីច័ក្ខុពួកទាំង៏ប៉ុន្មាននាក់នោះ សុមាអ៊ីឲ្យនាំខ្លួនយកទៅ
ជាក់គុកទាំង៏អស់ , ចូសង៏បង៏ប្អូន៣នាក់ដើរទៅនោះគ្មានមនុស្សម្នាដើរ
ទៅតាមសោះឡើយ , លុះហ៊ូនហមដើរទៅបុង៏ស្នាន សុមាអ៊ីអង្គុយ
នៅលើខ្នង៏សេះ ក្រឡេកឃើញហ៊ូនហមដើរចូលមក ក៏លើកដៃបង្គុំ
ហើយស្រែកថា: អ្នកហ៊ូនហមហេតុម្តេចបានជាមកធ្វើខ្ញុំគេយ៉ាង៏នេះ ?

ហ៊ានហមមិនដឹងបើនឹងធ្វើយតបថាយ៉ាងម្តេច , ក៏ទំដើរទុនដាក់មុខចុះតម្រង់ទៅផ្ទះ . ឯសុមាអ៊ុកនៅរង់ចាំស្តេចនៅឡើយនោះ , លុះព្រះចៅចូសង៍យាងមកដល់សុមាអ៊ុកអញ្ជើញស្តេចចូលទៅក្នុងព្រះភដារាំង , ឯផ្ទះចូសង៍ទឹងបង់ប្អូនទាំង៣នាក់នោះ សង់ទៅរៀបលំដាប់គ្នាមានកំពែងព័ទ្ធជុំតែ១ជាមួយគ្នា , សុមាអ៊ុកប្រើឲ្យគាហានចំទ្វារចាក់សោគ្រប់ប្រកទ្វារ ហើយបង្គាប់ទៅអ្នកស្រុកក្រៅកំពែងភូមិរបស់ចូសង៍នោះចំនួនមនុស្ស ៨០០ ប្រាយថា: អស់អ្នកកាលគ្នាត្រូវត្រួតគ្រាប្រយ័ត្នឲ្យមាំមួន , បើចូសង៍ទឹងបង់ប្អូនទាំង២នាក់រត់ទៅបាន អស់អ្នកកាលគ្នាត្រូវមានទោសដល់ស្លាប់ , ចោអ៊ីឃើញចូសង៍ជាទុក្ខទោមនស្សខ្លាំងណាស់ក៏ស្តីថា: ស្រូវអង្ករស្បៀងអាហារក្នុងផ្ទះគ៌អស់ហើយ អ្នកបងត្រូវមានសំបុត្រទៅដល់សុមាអ៊ុសុំខ្ចីស្រូវគេស៊ីសិន , បើសុមាអ៊ុឲ្យស្រូវយើងខ្ចី ក៏ឃើញថាសុមាអ៊ុនិងមិនធ្វើអន្តរាយដល់យើងមែន , ចូសង៍យល់ឃើញត្រូវ ទើបធ្វើសំបុត្រប្រគល់ឲ្យអ្នកស្រុកដែលយាមរក្សាកាន់ទៅជូនសុមាអ៊ុ ។ក៏ឲ្យគាហានដឹកនាំស្រូវអង្ករ១០០ទៅប្រគល់ឲ្យដល់ផ្ទះចូសង៍ ។ ក៏ផ្ងរសោយចិត្តបាត់ភ័យថាអ្នកទើបនិយាយបង្គំដល់ប្អូនទាំង២ថា: សុមាអ៊ុមិនបានគិតធ្វើអន្តរាយដល់យើងទេ ត្រង់ពិតហើយ ។

។ណ:នោះ , សុមាអ៊ុបង្គាប់គាហានឲ្យទៅចាប់ខ្លួនទៀតង ដែលចូសង៍តាំងឲ្យធ្វើជាតៅកាំក្រុមទាំងនោះ នាំទៅវាយតិចារណាសួរយក

សេចក្តីថាខ្លួនបានគប់គិតនឹងចូសងប្រឆំនឹងធ្វើការទ្រុស្តក្បត់ផែនដីមែនឬទេ ? លុះវាយសួរតៅកាំខ្លួលជាស័ត្យថា ខ្ញុំបានគប់គិតធ្វើការក្បត់នឹងចូសងមែន នោះតាហានបានសួរថា : ខ្លួនគិតការក្បត់តែ២នាក់នេះទេឬ ? យើងមិនទាន់ដឹងទេ , តៅកាំឆ្លើយស្តាត់ថា : កាលគិតគ្នានោះ គឺហោអាន់១ , តេងយៀង១ , លីស៊ុន១ , តេងប៊ីត១ , ប៊ិតហ៊ួន១ , នាម៉ឺនទាំង៥នាក់នេះ បានគិតការជាមួយនឹងខ្ញុំបានហើយនឹងចូសង , សុម៉ាអ៊ីឲ្យចាប់ឈ្មោះទាំង៥នាក់មកសួរទៀត ក៏ឆ្លើយខ្លួលសារគ្រប់ ហើយឲ្យការថា : បានសញ្ញាគ្នាថាពួកខែតនឹងតាំងធ្វើការ , សុម៉ាគុំឲ្យដូច្នោះក៏ឲ្យជាក់ច្រវាក់ពាក់កណ្តាលខ្លួនឲ្យមាំមួនទាំង៥នាក់ ។

ស៊ូហ៊ួននាយទ្វារដំរបសុម៉ាអ៊ីថា : ហ៊ួនហមបង្គោតខ្ញុំបានឲ្យបើកទ្វារថាមានព្រះតម្រាស់ត្រាស់ប្រើ លុះចេញផុតទៅគោលគោសថាលោកជាក្បត់ , សុម៉ាអ៊ីថា : ខ្លួនវាទេតើដែលក្បត់នោះ ម្តេចមកភ្លែងថាយើងជាក្បត់វិញថាហើយបង្គាប់តាហានឲ្យទៅចាប់ ហ៊ួន ហម នឹង ប័ក្ខពួកហើយនឹងចូសងទាំងបងប្អូននាំទៅ បង្គាប់ឲ្យយកទៅជាក់គុកទាំងអស់គ្នា , ទើបសុម៉ាអ៊ីប្រឹក្សានឹងអស់នាម៉ឺនទាំងពួងថា : អាពួកក្បត់គិតមិនត្រូវទាំងអស់នេះ វាខ្លួលសារគ្រប់អស់ហើយ នឹងក្បាវាពុកមិនស្រួលទេ ពួកមន្ត្រីទាំងអស់គ្នាក៏យល់ឃើញតាម , នោះសុម៉ាអ៊ីក៏នាំឲ្យមនុស្ស

ទោសចាំងអស់នោះ ប្រហែល១០០០នាក់ទៅប្រហារជីវិតកណ្តាលទីផ្សារ ហើយឲ្យរឹបទ្រព្យរបស់បញ្ចុះក្នុងព្រះឃ្លាំងហ្លួង ។

មានស្ត្រីម្នាក់ជាបុត្រីហេហ្ស៊ីឡេង ជាភរិយាចៅវុនសុក ប្អូនចូសង ចៅវុនសុកស្លាប់យូរហើយ នាងនេះនៅជាមេម៉ាយ មានកូនប្រុស១, គ្រាមួយបិតានាងនោះ ទឹងឲ្យនាងមានស្វាមីថ្មីទៀត នាងមិនព្រមចេញ ពាក្យស្បថសច្ចាទ់ថាលែងយកប្តីសោះ , ហើយអារស្ទឹកត្រចៀកខ្លួន ចោលចន្តិចទៅ , កាលចូសងមានទោសជាប់ត់ បិតានាងនោះភ័យខ្លាចក្រែងកូយមានទោយផង ទើបបង្ខំឲ្យនាងនោះមានប្តី នាងមិនព្រម ទើបយកកាំបិតកាត់ចុងច្រមុះខ្លួនឯងចន្តិចប្រាថ្នាឲ្យបង់នោម , មនុស្សម្នាក្នុងភូមិនោះឃើញដូច្នោះភ័ក្តីណាស់ថា ជាតម្កាមនុស្សយើងរាល់គ្នាប្រាថ្នានឹងតាត់តែងរូបកាយឲ្យល្អ . ពុះនេះហេតុអ្វីបានជាអ្នកស្រីមកកន្ត្រើរូបខ្លួនឲ្យបង់នោមទៅដូច្នោះ ? នាងនោះឆ្លើយថា : យើងធ្វើដូច្នោះព្រោះមិនប្រាថ្នាយកប្តីទៀតឡើយ ។

មនុស្សទាំងពួងថា: ចូសងបងថ្លៃអ្នកមានទោសក្បត់ , បិតាអ្នកខ្លាចក្រែងអ្នកកូយខុសទៅផង , បានជាបង់ឲ្យអ្នកមានប្តី ដើម្បីឲ្យផុតត្រសែខាងចូសង , នាងតបថា: ប្រពៃណីជាកូនស្រី កាលមិនទាន់មានប្តីត្រូវតាំងនៅក្រោមអំណាចបិតា បើមានស្វាមីកាលណាត្រូវសាមកនៅក្រោមអំណាចស្វាមីវិញ បើស្វាមីបានយសង្គ្រោះឯក្តីស័ក្តិជាសុខក៏

ត្រូវបានសុខតាមស្វាមី បើស្វាមីបានទទួលទុក្ខយ៉ាងណា ភរិយានោះ
ក៏រមែងបានទទួលទុក្ខលំបាកតាមស្វាមីជាធម្មតា កាលស្វាមីមានជីវិតរស់
នៅបានស្រឡាញ់គ្នាយ៉ាងណា បើអស់អាយុសង្ខារទៅ ក៏ត្រូវនៅស្រ-
ឡាញ់យ៉ាងនោះ រៀបចូសង៏នៅមានបុណ្យចេះទៅពីងបុណ្យគេ លុះ
ឃើញគេមានទុក្ខទោសត្រឡប់គេចដោះខ្លួនចេញដូច្នេះឃើញថា ជាមនុស្ស
អកតញ្ញូពេកណាស់ គឺជាមនុស្សមិនស្គាល់គុណគេដូចសត្វតិរច្ឆាន.
សេចក្តីរឿងនេះ ក៏ជ្រួតជ្រាបទៅដល់សុមាអ៊ីុ ។ គិតថា: ចិត្តនាងនោះជា
មនុស្សស័ត្យត្រង់យ៉ាងនេះកម្រណាស់ ទោះបើឪពុកជាមនុស្សចិត្តអា-
ក្រក់យ៉ាងណា ចិត្តម្តាយក៏ជាមនុស្សល្អត្រឹមត្រូវ គួរយើងនិងទៅសុំយក
កូននាងនោះមកចិញ្ចឹមទុក ដើម្បីតបសេចក្តីតាមអាឪពុកតទៅ សុមាអ៊ីុក៏ឲ្យ
ទៅសុំកូនប្រសនាងនេះមកចិញ្ចឹមជាបុត្របុណ្យធម៌ ។

ចៀវចេកក៏ចូលទៅដល់បសុមាអ៊ីុថា: ប៉ុន្តែពួកចូសង៏នៅមិនទាន់អស់ទេ
សុមាឡាដ៏ធំសុំនបើ២នាក់នេះ ក៏សម្លាប់នាយគ្រាហើយតត់ទៅរកចូ-
សង៏ខ្លះទៀតចុង្គាក់ទៀត កាលគ្រាចូសង៏ជួនគ្រាឲ្យនាំមកជូនលោក
អៀវចុង្គាក់ដណ្តើមយកទុក ទាំង៣នាក់នេះគួរនិងយកទោស សុ-
មាអ៊ីុតបថា: អ្នកទាំង៣នាក់នេះ ពេញជាមនុស្សសត្យានុស័ត្យពិតត្រង់ល្អ
នឹងទៅហ្វាយនាយតែបើគ្មានពួកយើងដល់គេទេឬ គួរហើយនឹងតាំងឲ្យធ្វើ
នាប៉ុនតាមដំណែងដើមទៅវុះ បើយើងមិនយកទុសគេ ចិញ្ចឹមឲ្យធ្វើ

ការតទៅ គេក៏នៅមានសេចក្តីកតញ្ញូដ៏ធំគុណយើង នោះសុម៉ាអ៊ុកឲ្យ
ហៅឈ្មោះចាំង៣នាក់ទៅចិញ្ចឹមឲ្យធ្វើមន្ត្រីក្នុងរាជការតាមនាទីដើម,ឈ្មោះ
ចាំង៣ក៏ធ្វើសេចក្តីគំនាប់ដោយគោរពយ៉ាងប្រពៃ ហើយលាចេញទៅ
សុំនប៉ែគិតដល់សេចក្តីដើមហើយក៏ជកដង្ហើមធំ ទើបប្រដុំនឹងសុម៉ាឡៅដ៏
អៀវចុងហើយនិយាយថា: រឿងនេះប្រសិនណាបើខ្ញុំមិនដឿតាមសំដីបង
ខ្ញុំហើយ កាលណាឡើយនឹងរស់ពនមានអាយុដ៏វែងទៅ លុះនិយាយ
ហើយ ចាំង៣នាក់ក៏បែកគ្នាទៅកាន់ទីលំនៅរៀងខ្លួន ។

សុម៉ាអ៊ីក្នុងខណៈនោះ ក៏សរសេរសំបុត្រទៅបញ្ជាះបញ្ជូលគ្រប់ខែត្រ
ដែនហើយដោតប្រកាសនោះទុកគ្រប់ភូវស្រុក ក្នុងសំបុត្រនោះថា បើ
នរណាជាស្ម័គ្រចិត្តពួកបួសងហើយរត់មកនៅក្នុងទីណា តំបន់ណា ត្រូវ
ឲ្យវិលបួលទៅនៅទីលំនៅផ្ទះរបស់ខ្លួនវិញឲ្យអស់ យើងមិនប្រកាន់ទោស
ទេ បើជានាម៉ឺនឬឥហានឲ្យបួលទៅនឹងឲ្យគង់ទីពជការដដែល បើជា
ភស្តុត្រូវឲ្យវិលត្រឡប់ទៅកាន់ទីលំនៅហាននឹងបានទំរកស៊ីធ្វើស្រែចំការត
ទៅ ។

(ជៅមានត)

អង្គការយូរណេស្កូ និង សាធារណរដ្ឋខ្មែរ

សាធារណរដ្ឋខ្មែរបានចូលជាសមាជិកនៃអង្គការសហប្រជាជាតិនៅ ខែធ្នូ ឆ្នាំ ១៩៥៥ ហើយបានចូលជាសមាជិកនៃអង្គការយូរណេស្កូ តាំង ពីថ្ងៃទី ១២ ខែតុលា ឆ្នាំ ១៩៥១ ។ នៅពេលនោះ "គណៈកម្មការ ខេមរជាតិទាក់ទងយូរណេស្កូ" (COMMISSION NATIONALE KHMERE POUR L'UNESCO) ក៏ត្រូវបានបង្កើតឡើង ។

ដើមឡើយ គណៈកម្មការខេមរជាតិទាក់ទងយូរណេស្កូស្ថិតនៅក្រោម ឧបាទនៃក្រសួងការបរទេស ។ លុះមកដល់ថ្ងៃទី ២៣ ខែឧសភា ឆ្នាំ ១៩៥៦ គណៈកម្មការខេមរជាតិនេះ ក៏ត្រូវបានផ្ទេរជាកម្សៃនៅក្រោម ឧបាទនៃក្រសួងអប់រំជាតិវិញ ។

ក - សមាសភាពនៃគណៈកម្មការខេមរជាតិទាក់ទងយូរណេស្កូ

គណៈកម្មការខេមរជាតិទាក់ទងយូរណេស្កូ មានសមាជិកជាង ២០ នាក់ ដែលជាតំណាងនៃទីស្តីការដ្ឋមន្ត្រីនានា អង្គការសាសនា អង្គការជាតិ ក្រៅក្រសួងរដ្ឋាភិបាល ហើយនិងឥស្សរជនឯទៀតៗ ដែលចាប់ អារម្មណ៍ទៅលើកម្មវិធីនៃអង្គការយូរណេស្កូ ។

គណៈកម្មការខេមរជាតិត្រូវមានការៈកិច្ច ៖

- បណ្តុះគ្រប់មជ្ឈដ្ឋានជាតិឲ្យមានខ្លឹមគតិសន្តិភាព និង ការយល់គ្នាជាអន្តរជាតិ ។
- បង្កើនគោលគំនិតខាងវិស័យអប់រំ វិទ្យាសាស្ត្រ និង វប្បធម៌ ។
- ចាក់ចាញ្ចមតិសាធារណៈ ឲ្យចាប់អារម្មណ៍ទៅលើគោលបំណង និង កម្មវិធីនៃអង្គការយូណេស្កូ ។
- ធ្វើការចាក់ចង្កាងជិតស្និទ្ធ ជាមួយនឹងអង្គការយូណេស្កូ និង គណៈកម្មការជាតិនៃប្រទេសជាសមាជិក ។
- ពិគ្រោះជាមួយនឹងសមាគម ឬ អង្គការទាំងឡាយ ដែលចាប់អារម្មណ៍ទៅលើបញ្ហានៃអង្គការយូណេស្កូ ។
- ស្រាវជ្រាវ និង ប្រមូលគ្រប់ឯកសារដែលចាក់ចងនឹងវិស័យអប់រំ វិទ្យាសាស្ត្រ និង វប្បធម៌ ។
- ផ្តល់ពត៌មាន និង យោបល់ទៅទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំជាតិ និង វប្បធម៌ស្តីពីមហាសន្និបាត សន្និសីទភូមិភាគ កម្មវិធី និង សហប្រតិបត្តិការគ្រប់ផ្នែកនៃអង្គការយូណេស្កូ ។

គ.រចនាសម្ព័ន្ធនៃគណៈកម្មការខេមរជាតិ

នាសម័យប្រជុំ នៅថ្ងៃទី ៣០ ខែមិថុនា និង ថ្ងៃទី ១០ ខែកញ្ញា

ឆ្នាំ១៩៧១ អង្គប្រជុំបានសម្រេចរៀបចំឡើងវិញនូវគណៈកម្មការខេមរជាតិខាងយូណេស្កូ និង លេខាធិការដ្ឋានអចិន្ត្រៃយ៍ ដោយយោលទៅតាមកាលៈទេសៈ ការកើនឡើងនៃកិច្ចការហើយនិងការចាត់ចង់កាន់តែច្រើនឡើងៗ រវាងសាធារណរដ្ឋខ្មែរ និង ប្រទេសឯទៀតៗក្នុងពិភពលោក ។

គណៈកម្មការខេមរជាតិខាងយូណេស្កូមានលោករដ្ឋមន្ត្រីក្រសួងអប់រំជាតិ និង វប្បធម៌ ជាប្រធាន និង អនុប្រធាន ៤ នាក់ ។

រីឯលេខាធិការដ្ឋានអចិន្ត្រៃយ៍ដែលត្រូវរ៉ាប់រងកិច្ចការរដ្ឋបាល និងការប្រព្រឹត្តទៅនៃគណៈកម្មការមានការិយាល័យពីរ ៖

- ការិយាល័យកម្មវិធីឯកទេស (Bureau de Programme spécialiste)
- ការិយាល័យរដ្ឋបាលទូទៅ (Bureau d ' Administration générale)

១-ការិយាល័យកម្មវិធីឯកទេសមានបែងចែកជា ៤ ផ្នែកគ

- ផ្នែកអប់រំ (Section d ' Education)
- ផ្នែកវិទ្យាជាក់លាក់ និង ធម្មជាតិវិទ្យា (Section de Science exactes et naturelles)
- ផ្នែកសង្គមសាស្ត្រ និង វប្បធម៌ (Section de Sciences sociales et humaines et de Culture)
- ផ្នែកពត៌មាន (Section d' Information)

២ - ការិយាល័យរដ្ឋបាលទូទៅបែងចែកជា ៣ ផ្នែក :

- ផ្នែករដ្ឋបាល (Section d' Administration

— ផ្នែកបដិសណ្ឋារកិច្ច (Section d' Accueil et de Réception)

— ផ្នែកបុគ្គលិក និង គណនេយ្យ (Section de Personnel et de Comptabilité)

ចាប់ពីពេលនេះទៅ គណៈកម្មការខេមរជាតិនិងទំព្រឹងអនុវត្តកម្មវិធីយូណេស្កូតាំងផ្នែកអន្តរជាតិនិងតាំងផ្នែកភូមិភាគ ដើម្បីធ្វើសហប្រតិបត្តិការជាមួយនឹងលេខាធិការដ្ឋានយូណេស្កូហើយនិងមជ្ឈមណ្ឌល ព្រមតាំងវិជ្ជាស្ថានភូមិភាគតាំងអស់ ។

ឃ– សកម្មភាពនិងសមិទ្ធិនៃគណៈកម្មការខេមរជាតិ

ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងទៅនេះ គណៈកម្មការខេមរជាតិទាក់យូណេស្កូបានទទួល ជាគុណប្រយោជន៍ដល់ប្រទេសជាតិ នូវ :

— ជំនួយពីមូលនិធិពិសេសនៃអង្គការសហប្រជាជាតិ ។

— ជំនួយបច្ចេកទេសពីកម្មវិធីសហប្រជាជាតិដើម្បីអភិវឌ្ឍន៍ (Programme de Nations Unies pour le développement –PNUD)

— ជំនួយពីកម្មវិធីធម្មតា (Programme ordinaire)

— ជំនួយពីកម្មវិធីសហប្រតិបត្តិការនៃរដ្ឋសមាជិកយូណេស្កូ ។

នៅឆ្នាំ ១៩៦៨ គម្រោងផែនការនៃសហប្រតិបត្តិការ (ONU-UNESCO - CAMBODGE) ត្រូវបានបង្កើតឡើង ដើម្បីការពារ និងដួសដុលប្រាសាទ :ហើយនិងមណ្ឌលយូណេស្កូចរន្តែប្រហែល ៨០០ ។ តែ ជាវាសនាអាក្រក់ ខេមរៈមិនា ឆ្នាំ ១៩៧០ សាធារណរដ្ឋខ្មែរត្រូវ

ត្រូវកាត់ដោយសង្គ្រាមស្ងាត់ឈាន ដែលបង្កើតឡើងដោយយួនយៀក
កុង—យៀកណាមខាងជើង ។ ម្ល៉ោះហើយ គម្រោងនេះក៏ពុំបានសម្រេចទៅឡើយ ។

សាធារណរដ្ឋខ្មែរដែលសម្បូណ៌ដោយចេតិកគ័ណ្ឌវប្បធម៌និងសិល្បៈ សង្ឃឹមថាអង្គការសហប្រជាជាតិ និង អង្គការយូណេស្កូនឹងធ្វើឲ្យបានសម្រេចនូវគម្រោងនេះ នៅពេលដែលសន្តិភាពនឹងត្រឡប់មានឡើងវិញ ។

នៅខែមិថុនា ឆ្នាំ ១៩៧០ ក្នុងក្របខ័ណ្ឌការពារសម្បត្តិវប្បធម៌ "គណៈកម្មាធិការជាតិ សម្រាប់កិច្ចការពារសម្បត្តិវប្បធម៌ ក្នុងករណីមានអាវុធសង្គ្រាម" (Comité National ponr la Protection de Biens culturels en cas de Conflit armé — COPROBIC) ក៏ត្រូវបានបង្កើតឡើងដែរ ដោយអនុលោមទៅតាមសេចក្តីសម្រេចនៃសន្និបាតអន្តរជាតិបាល នៅក្រុងឡាហេ នាថ្ងៃទី ១៤ ខែឧសភាឆ្នាំ ១៩៥៤ ។ សាធារណរដ្ឋខ្មែរបានចុះហត្ថលេខាលើអនុសញ្ញានេះនាថ្ងៃទី ២៥ ខែមេសា ១៩៦១ ។

ម៉្យាងទៀត ការបង្កើតសាលាគរុវិជ្ជាកសិកម្ម សម្រាប់អប់រំសាស្ត្រាចារ្យក្នុងវិស័យកសិកម្ម ក៏ត្រូវបានគ្រោងទុកហើយដែរ ។

នៅឆ្នាំ ១៩៦៩ សាធារណរដ្ឋខ្មែរមានទទួលរង្វាន់ (Mohamed reza Pahlavi " (មេដាយមាស និង ប្រាក់ ៥.០០០ ដុល្លារអាមេរិកាំង) ជាសក្ខីភាពនៃសកម្មភាពក្នុងវិស័យអក្ខរកម្ម ។

ក្នុងឆ្នាំកន្លងទៅនេះ រដ្ឋាភិបាលនៃសាធារណរដ្ឋខ្មែរបានបញ្ជូនគណៈប្រតិភូឲ្យទៅចូលរួមក្នុងសន្និសីទអន្តរជាតិ និង ភូមិភាគនានា ដែលរៀបចំឡើងក្នុងក្របខ័ណ្ឌនៃអង្គការយូណេស្កូ ។

គណៈកម្មការខេមរជាតិទាងយូណេស្កូបានបញ្ជូនបុគ្គលិកសិក្សាឲ្យទៅធ្វើកម្មសិក្សាខាងផ្នែកគណិតវិទ្យា វិទ្យាសាស្ត្រ វិធានការផែនការរដ្ឋបាលខាងការអប់រំ ផលិតកម្ម និង ការចែកសៀវភៅ ដែលបានរៀបចំឡើងដោយគណៈកម្មការជាតិឬអង្គការរដ្ឋនានា នៅទ្វីបអាស៊ី ។

ចំពោះបុណ្យរំឭកខួប សាធារណរដ្ឋខ្មែរបានចូលរួមក្នុងពិធីបុណ្យអង្គការសហប្រជាជាតិ បុណ្យសិទ្ធិមនុស្ស បុណ្យថ្ងៃអន្តរជាតិនៃអក្ខរកម្ម បុណ្យឆ្នាំអន្តរជាតិនៃការអប់រំ "១៩៧០" ។ សព្វថ្ងៃនេះគណៈកម្មការខេមរជាតិ ដោយមានជំនួយពីក្រសួងសាមីផ្ទាល់ កំពុងតែរៀបចំកម្មវិធីបុណ្យរំឭកខួបទី ២៥ នៃអង្គការយូណេស្កូ និង បុណ្យឆ្នាំអន្តរជាតិនៃសៀវភៅ ។

ក្នុងក្របខ័ណ្ឌសហប្រតិបត្តិការភូមិភាគ សាធារណរដ្ឋខ្មែរបានចូលជាសមាជិកនៃ "អង្គការភូមិភាគសម្រាប់ឧត្តមសិក្សា និង អភិវឌ្ឍន៍"Institut régional Pour l'Enseignement Supérieur et le Développement — RIHED) និងបានចូលជាសមាជិក នៃ "អង្គការរដ្ឋមន្ត្រីក្រសួងអប់រំនៃអាស៊ីភាគអគ្នេយ៍ „ (Organisation des Ministres de l'Education de l'Asie du Sud-Est — SEAMEO) នៅទីក្រុងបាងកក ។ នៅពេលធ្វើសន្និសីទដែលរៀបចំឡើងដោយអង្គ

ការពាំងពីរនេះ ទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំជាតិ និង វប្បធម៌ បាន បញ្ជូនអ្នកតំណាងទៅចូលរួមពុំដែលខានឡើយ ។

ដោយយល់ថា សាកលវិទ្យាល័យមានសារៈសំខាន់សំរាប់អភិវឌ្ឍន៍ជាតិ គណៈកម្មការខេមរជាតិបានស្នើសុំឲ្យអង្គការយូណេស្កូជួយផ្តល់ជំនួយ ណាមួយដើម្បីពង្រីកឧត្តមសិក្សា នៅសាធារណរដ្ឋខ្មែរទៅអនាគត ។

ដោយយល់ថា បញ្ហាបច្ចុប្បន្ននៃយុវជនជាបញ្ហាធំ នៅលើផែនការជាតិក៏ដូចជានៅលើផែនការអន្តរជាតិដែរ គណៈកម្មការខេមរជាតិបានធ្វើសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជានិច្ចជាមួយនឹងអគ្គស្នងការដ្ឋាននៃយុវជន ជាអង្គការជាតិទទួលបន្ទុកលើបញ្ហាយុវជនខ្មែរ ។ ដូចេ្នះហើយបានជាគណៈកម្មការខេមរជាតិ បានបញ្ជូននិស្សិតឲ្យទៅចូលរួមក្នុងមហាសន្និបាតនៃអង្គការសហប្រជាជាតិ និង មហាសន្និបាតនៃអង្គការយូណេស្កូ ដើម្បីបើកឲ្យយុវជនចូលប្រឡូកក្នុងកិច្ចការជាតិ និង ដើម្បីឲ្យយុវជនស្គាល់នូវដីវភាពនយោបាយ និង ការទូត ។

ង- សកម្មភាពនៃគណៈកម្មការខេមរជាតិ

ក្នុងខែមេសា ឆ្នាំ ម៉ាស មេសា ឧសភា មិថុនា កក្កដា សីហា និង កញ្ញា ឆ្នាំ ១៩៧១

១ - ការប្រជុំនិងសន្និសីទ

- ការចូលរួមនៃលោក ស៊ីសុវត្ថិឥស្សរៈ ឯកអគ្គរដ្ឋទូតប្រតិភូអចិន្ត្រៃយ៍ផ្ទាល់កិច្ចសាធារណរដ្ឋខ្មែរ អមអគ្គការិយាល័យ នៅទីក្រុងប៉ារីស និង លោក ផាន់ ជួយហាក់ ទីប្រឹក្សាវប្បធម៌នៃស្ថានឯកអគ្គរដ្ឋទូតខ្មែរ នៅប្រទេសបារាំង ក្នុងការប្រជុំស្តីពី « ផលិតកម្មនៃអត្ថបទផ្សាយដោយម៉ាស៊ីនក្រឿន » (Production des phonogrammes) ដែលបានធ្វើទៅទីស្នាក់ការយូណេស្កូ ពីថ្ងៃទី ១ ដល់ថ្ងៃទី ៥ មីនា ១៩៧០ ។

- ការចូលរួមនៃលោក ឃិះ ដៀវ ព្រឹទ្ធសាស្ត្រាចារ្យមហាវិទ្យាល័យវិទ្យាសាស្ត្រនៃសាកលវិទ្យាល័យភ្នំពេញ ក្នុងការប្រជុំសិក្ខាសាលាស្តីពីការស្រាវជ្រាវនៃការសិក្សាវិទ្យាសាស្ត្រដែលបានធ្វើទៅទីក្រុងតូក្យូ ពីថ្ងៃទី ១៥ កុម្ភៈ ដល់ថ្ងៃទី ១២ មីនា ១៩៧១ ។

- ការចូលរួមនៃលោក ស៊ីសុវត្ថិ ឥស្សរៈ ក្នុងការប្រជុំមហាសន្និបាតនៃមជ្ឈមណ្ឌលសិក្សាអន្តរជាតិ ស្តីពីការថែរក្សា និង ការដួសដុលសម្បត្តិវប្បធម៌ ដែលបានធ្វើទៅក្រុងរ៉ូម ពីថ្ងៃទី ២៦ ដល់ថ្ងៃទី ២៨ មេសា ១៩៧១ ។

- ការចូលរួមនៃលោក ជួង សារិន នាយកខាត់ខនវប្បធម៌ និង ជាអគ្គលេខាធិការនៃគណៈកម្មការទេសរដ្ឋមន្ត្រីជាតិទទួលយូណេស្កូ និង លោក ត្រឹង ងា នាយកស្តីទីនៃវិទ្យាស្ថានខ្មែរ - មនក្នុងការប្រជុំសិក្ខាសាលា ស្តីពីការសិក្សាវប្បធម៌ជ្វា នៅទីក្រុងហ្សាការតា ពីថ្ងៃទី ២៦ ដល់ថ្ងៃទី ២៨ មេសា ១៩៧១ ។

- ការចូលរួមនៃលោក ប៉ាន់សុធី រដ្ឋមន្ត្រីក្រសួងអប់រំជាតិ និងវប្បធម៌ លោកម៉ាំង មោរី នាយកជាតិមន្ទីរពិគានផែនការអប់រំ និងលោក ថាប់ គៀម បុគ្គលិកនៃស្ថានឯកអគ្គរដ្ឋទូតខ្មែរ នៅសិង្ហបុរី ក្នុងសន្និសីទអាស៊ីលើកទី ៣នៃរដ្ឋមន្ត្រីក្រសួងអប់រំ និងរដ្ឋមន្ត្រីទទួលខុសត្រូវខាងពិគានផែនការសេដ្ឋកិច្ច នៅសិង្គបុរី ពីថ្ងៃទី ៣១ ឧសភា ដល់ថ្ងៃទី៧ មិថុនា ១៩៧១ ។

- ការចូលរួមនៃលោក ជាម នៅ អធិការបឋមសិក្សា ក្នុងការប្រជុំសិក្ខាសាលា ស្តីពី " ការសិក្សាតាមរបៀបសោតចក្ខុវិញ្ញាណ " (Eneignement audio.Visuel) នៅទីក្រុងតូក្យូ ពីថ្ងៃទី ១៤ ឧសភា ដល់ថ្ងៃទី ១១ មិថុនា ១៩៧១ ។

- ការចូលរួមនៃលោក តាន់ មិល បុគ្គលិកនៃជាតិមន្ទីរពិគានផែនការអប់រំ ក្នុងការប្រជុំសិក្ខាសាលា ស្តីពីទស្សនៈនៃការស្ថាបនាសាលានៅទីក្រុងកូឡុំមប៊ូ (សិរីលង្កា) ពីថ្ងៃទី ១ សីហា ដល់ថ្ងៃទី ៣០ កញ្ញា ១៩៧១ ។

- ការចូលរួមនៃលោក ស៊ុំ សុវត្តិ ឥស្សរៈ លោក តាន់ តឹមហួន និងលោកជាន់ ប៊ួយ ហាក់ ក្នុងសម័យប្រជុំលើកទី ៤ ៣ នៃសន្និសីទអន្តរជាតិសម្រាប់ការអប់រំ នៅទីក្រុងហ្សឺណែវ ពីថ្ងៃ ១៩ ដល់ថ្ងៃទី ២២ កញ្ញា ១៩៧១ ។

- ការចូលរួមនៃលោក ខេម ហាកុង នាយកអគ្គិការិយាល័យនៃមធ្យមសិក្សាក្នុងការប្រជុំសិក្ខាសាលា ស្តីពីការសិក្សាភាសាអង់គ្លេសនៅទីក្រុងភ្នំពេញ ពីថ្ងៃទី ១៦ ដល់ថ្ងៃទី២២ កញ្ញា ១៩៧១ ។

- ការចូលរួមនៃលោក ម៉ែន ឈុំ ទីប្រឹក្សាបច្ចេកទេសអមទីស្តីការក្រសួងអភិវឌ្ឍន៍សហគមន៍ក្នុងការប្រជុំសិក្ខាសាលា ស្តីពីការអប់រំមនុស្សពេញវ័យ នៅក្រុង ប៉ុ ចាយ (ប្រទេសឥណ្ឌា) ពីថ្ងៃទី ១៩ ដល់ថ្ងៃទី ២៦ កញ្ញា ១៩៧១ ។

២- អាហារូបករណ៍

- ការផ្តល់អាហារូបករណ៍នៃយូណេស្កូជាថ្នូ ដល់និស្សិតដែលមានឈ្មោះតាមតារាងនេះ :

- លោក អ៊ុន សាផុន	. . .	២០ខែ	ចាប់ពីថ្ងៃទី ១ មករា ១៩៧១
- - ប៉ែន មារ៉ូ	. . .	១២ -	- ១១ កញ្ញា ១៩៧០
- - គីម សួង	. . .	១២ -	- ១១ កញ្ញា ១៩៧០
- - សូ ឌុនហួ	. . .	១២ -	- ១ មីនា ១៩៧១
- - អ៊ុំ អ៊ិន	. . .	២៤	- ១៥ កញ្ញា ១៩៧០

៣- កម្មសិក្សា

- លោក ភូច តៅ.ហេ ប្តូរគំនិតនៃនាយកដ្ឋានទាក់ទងវប្បធម៌ និង

យស់ ថៃ បុគ្គលិកនៃជាតិមន្ទីរវិជានផែនការអប់រំ ធ្វើកម្មសិក្សាខាងវិជានផែនការ និងខាងរដ្ឋបាលនៃផែនការអប់រំ នៅទីក្រុងញ៉ាវដែល្ង ចំនួន៦ខែ ចាប់ពីថ្ងៃទី ១ កញ្ញា ១៩៧១ ។

- លោក ហុង ថែម បុគ្គលិកនៃគណៈកម្មាធិការជាតិអចិន្ត្រៃយ៍ នៃទេមរយោនកម្ម ធ្វើកម្មសិក្សាខាងការផ្សាយនិងផលិតកម្មសៀវភៅ នៅទីក្រុងតូក្យូ ពីថ្ងៃទី ១០ កញ្ញា ១៩៧១ ចំនួន ៤ ខែ ។

រៀបរៀង

ដោយបុគ្គលិកនៃលេខាធិការដ្ឋាន

នៃគណៈកម្មការទេមរជាតិខាងយូណេស្កូ

ទីស្នាក់ការ : វិថីពាកបាទក្រហមខ្មែរ

ទូរស័ព្ទ : ២.៤០៦៤



អង្គុត្តរនិកាយ

ទស្សនាវដ្តី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ

ឆ្នាំទី ៤៣ ខែ ឆ្នូ

ព.ស. ២៥១៥ គ.ស. ១៩៧១

- ភ្នំពេញ -



កង្ខាវិតរណិយា

ទស្សនាវដ្តី ផ្សាយពាក់ព័ន្ធសាសនា និង អក្សរសាស្ត្រ

បេញ្ញារាល់ខែ ពី ពុទ្ធសាសនបណ្ឌិត្យ

ចាត់ចែងបោះពុម្ពផ្សាយដោយគណៈកម្មការមួយ មាន :

និពន្ធនាយក - អ្នករៀបចំ : លី ធាមតេង

គណៈកម្មការនិពន្ធ :

ព្រះពោធិវង្ស សូរ-ហាយ

លោក ផល-ឥត អ្នកស្រី ពេជ-សល់

បញ្ជីរឿង

អត្ថបទ	ទំព័រ
១— ផ្នែកសាសនា	
១— ឥទ្ធិពលទេពធម៌បួនយ៉ាង ព្រះពោធិវង្សសូរ ហាយ រៀបរៀង	៩៨៣
២— ចតុរារិយសច្ច (ត) ព្រះភិក្ខុ ប៉ាង ខាត់ រៀបរៀង	៩៩៩
៣— រឿងនាងសាមាវតី (ត) លោក ប៊ូ-ប៊ូ ប្រែ-រៀបរៀង	១០១០
២— ផ្នែកអក្សរសាស្ត្រ	
៤— វប្បធម៌ និង បញ្ហាសង្គម .លោក លី ធាមពេង រៀបរៀង	១០១៩
៥— រឿងសាមកុក ឧកញ៉ា នូ-ហន ប្រែ-រៀបរៀង	១០២៥
៦— កវីនិពន្ធ : ចចកទកចិត្ត ដោយ ដាល-ទិត	១០៥២
៣— ផ្នែកកំណត់—ប្រវត្តិការណ៍	
៧— សាសនាតាមទៅប្រទេសខ្មែរ ស្រង់ពីសេចក្តីរាយការណ៍នៃគណៈកម្មការជាតិ ខាងវប្បធម៌ក្នុងសន្និសីទលើកទី ៧ នៃសហភាពសមាជិកសភាអាស៊ី	១០៥៥

តម្លៃជាវ :

មួយឆ្នាំមាន ១២ សៀវភៅ . . . ២៣០រ០០ ។

អាណត្តិសូមដាក់ថា : លោកនាយកវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា

ឥទ្ធិបាទធម៌ ៤ យ៉ាង

រៀបរៀង ដោយព្រះពោធិវង្ស ស្វរ ហាយ

ឧមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

ឥទ្ធិបាទធម៌ ៤ យ៉ាង

១- ឆន្ទៈ ការពេញចិត្ត, ស្រឡាញ់, ប្រាថ្នា;

២- វីរិយៈ ការខំប្រឹងប្រែង, ព្យាយាមមិនដាច់;

៣- ចិត្តៈ ការយកចិត្តទុកដាក់, ការគិតគូរឿយៗ;

៤- វីមំសា ការពិចារណា, ការត្រិះរិះរឿយៗ ។

ធម៌ដែលមានឈ្មោះថា "ឥទ្ធិបាទ" នេះ កាលបើបុគ្គលណា មានបរិបូណ៌ រមែងញុំាងបុគ្គលនោះឲ្យសម្រេចប្រយោជន៍ក្នុងផ្លូវលោក ឬ ផ្លូវធម៌ពុំខាន ។

គុណធម៌ទាំង ៤ប្រការ ដែលមានឈ្មោះថា "ឥទ្ធិបាទ" នេះ ប្រែថា "ធម៌ទុកដូចជាដើរសង្រាប់ដំរីឆ្ពោះទៅរកប្រយោជន៍" ឬថា "ធម៌ដូចជាជំហានដើរដើម្បីចំពេញកិច្ចការឲ្យបានសម្រេច" ។ ដូចយ៉ាង ឆន្ទៈ ដែលប្រែថា "ការពេញចិត្ត, ការស្រឡាញ់, ការប្រាថ្នា" នេះ ជា

គុណធម៌ដ៏ប្រសើរ ព្រោះថា ការណ៍យកចិត្តគ្រប់យ៉ាងដែលយើងត្រូវបំពេញ ដើម្បីឲ្យបានសម្រេចដល់ទីដៅនោះ ត្រូវតែមានសេចក្តីពេញចិត្ត, សេចក្តីស្រឡាញ់ ចំពោះប្រយោជន៍ណាមួយ ឲ្យជាប់នៅក្នុងចិត្តជារឿយ។ គឺថាត្រូវមានសេចក្តីប៉ុនប៉ងជ្រាបថា ចំពោះប្រយោជន៍ដែលខ្លួនត្រូវការ ឲ្យដឹតដក់នៅក្នុងចិត្តជានិច្ច ទើបជាបច្ច័យជួយដំកនាំ ជួយផ្តល់កម្លាំងឲ្យ វីរិយៈ ចិត្តៈ វីមំសា ជាប់តទៅទៀត ព្រោះឥទ្ធិបាទធម៌ទាំង៤នេះ កាលបើឆន្ទៈមានកម្លាំងបរិបូណ៌ហើយ ក៏អាចជួយឧបត្ថម្ភចំពោះ វីរិយៈ ចិត្តៈ វីមំសា ទៅទៀតបាន ។ ធម៌ទាំង៤នេះ មាននាទីផ្សេងៗគ្នា តែថា ត្រូវជាប់ទាក់ទងរួមកម្លាំងជាមួយគ្នា ប្រកបដោយសាមគ្គី ទើបញុំាងប្រយោជន៍ឲ្យសម្រេចទៅបាន ដោយហេតុថា « ឆន្ទធម៌ កាលបើមាននៅក្នុងសន្តានចិត្តគ្រប់គ្រាន់ហើយ ក៏រមែងដឹកនាំ វីរិយៈ ចិត្តៈ វីមំសា ឲ្យលឿនទៅជាមួយគ្នាបានដោយល្អ » ។

ប្រយោជន៍គ្រប់យ៉ាង ដែលជាទីដៅរបស់មនុស្សអ្នកត្រូវការទាំងអស់គ្នា សុទ្ធតែត្រូវមានឆន្ទៈ គឺសេចក្តីពេញចិត្ត, សេចក្តីស្រឡាញ់ជាប្រធាន ទើបអាចដំរុញអ្នកត្រូវការឲ្យមានកម្លាំងឈានទៅមុខបាន ។ បន្ទាប់មកទៀត វីរិយៈ គឺសេចក្តីប្រឹងប្រែង, ខ្នះខ្នែង ជាប់នៅក្នុងចិត្ត កាន់តែមានកម្លាំងឡើងទៀត មិនអាចនាំឲ្យស្អាក់ស្តើរ មិនអាចនាំឲ្យងាក់ចុះរោលក្នុងកិច្ចការរបស់ខ្លួនឡើយ ។ លំដាប់តមក វីមំសា

គឺការពិចារណា , ការត្រិះរិះរឿយ ។ ក៏មានកម្លាំងក្លៀវក្លាកើតឡើង ។ ដោយអំណាចនៃកម្លាំង របស់ធម៌ទាំង៣ខាងដើម ជួយជូនដំណើរមកហើយ ។ វីមំសាធម៌នេះ មានន័យសម្រាប់វិនិច្ឆ័យកាត់សេចក្តីរបស់ហេតុការណ៍គ្រប់យ៉ាង ជាធម៌សម្រាប់ត្រួតពិនិត្យពិចារណាមើលខ្លួរហេតុផលនៃប្រយោជន៍ទាំងក្នុងបច្ចុប្បន្នទាំងក្នុងអនាគតថា ប្រយោជន៍នេះ ឲ្យផលយ៉ាងណា? មានអ្វីជាហេតុ ? ។ កាលបើវីមំសាធម៌នេះ មានកម្លាំងបរិបូណ៌ ក្នុងសន្តានរបស់បុគ្គលហើយ អាចញ៉ាំងប្រយោជន៍ណាមួយដែលខ្ជិនប៉ុនប៉ងនោះឲ្យសម្រេចដូចបំណង ។ ឥទ្ធិបាទធម៌ទាំង៤ ប្រការនេះ មានឥទ្ធានុភាពជាច្រើន ដែលនាំឲ្យបានសម្រេចផល ដូចសេចក្តីប្រាថ្នា យើញជាក់ច្បាស់ក្នុងកាលជាបច្ចុប្បន្ន ។

ឥទ្ធិបាទធម៌ ពុកដូចជាកម្មវិធីមួយដ៏ប្រសើរបំផុតរបស់បុរសស្ត្រីក្នុងលោក ដែលជាអ្នកត្រូវការស្វះពន្លះស្វែងរកប្រយោជន៍ ក្នុងផ្លូវលោកប្លែកក្នុងផ្លូវសាសនា ។ ឥទ្ធិបាទធម៌ ទាំង ៤ ជាធម៌ជាប់ទាក់ទងគ្នា មានសាមគ្គីដៃគាំទ្រកម្លាំងជាមួយគ្នា ទើបអាចញ៉ាំងប្រយោជន៍ឲ្យសម្រេចបាន, បើធម៌ទាំង ៤ នេះជាប់ចេញពីគ្នាមួយៗនោះ ពុំអាចមានកម្លាំងក្លៀវក្លាធ្វើប្រយោជន៍ឲ្យសម្រេចបានឡើយ ។ ឥទ្ធិបាទធម៌ ទាំង ៤ នេះ ជាព្រះពុទ្ធដីកា នៃព្រះសម្មាសម្ពុទ្ធ ដែលមានមកក្នុងគម្ពីរសុត្តន្តបិដកក៏មាន ក្នុងគម្ពីរអភិធម្មបិដកក៏មាន ។

ព្រះសម្មាសម្ពុទ្ធទ្រង់សម្តែង ៥ ធ្មិ្ទាឧបមិ គាំង ៤ នេះ ជាញឹក ញាយណាស់ ដើម្បីរំលឹកជាស់តឿនពុទ្ធបរិស័ទ ដែលជាសាវ័កសិស្ស គណរបស់ព្រះអង្គ ដោយហេតុបង់ឲ្យពុទ្ធសាវ័ក មានសេចក្តីស្រឡាញ់ ប្រយោជន៍បច្ចុប្បន្ន ឬប្រយោជន៍បរលោក ឲ្យបានជួបប្រទះ ឲ្យបាន សម្រេចដូចបំណង ។ ៥ ធ្មិ្ទាឧបមិ គាំង ៤ ប្រការ ដែលអធិប្បាយ មកហើយនេះឈ្មោះថាជាកម្មវិធីមួយប្រសើរ សម្រាប់លើកដំរកាពរបស់ មនុស្សក្នុងលោក ឲ្យបានសុខចម្រើនរុងរឿង ក្នុងកាលដែលរស់នៅក្នុង សង្គមមនុស្ស ។

សេចក្តីអធិប្បាយ របស់ ៥ ធ្មិ្ទាឧបមិ មកនេះ ជាអារម្ភកថា ខាងដើមនៃអត្ថបទ ៥ ធ្មិ្ទាឧបមិ ។ បន្ទាប់តទៅនេះ សូមអធិប្បាយ ពង្រីកសេចក្តីចំពោះ ៥ ធ្មិ្ទាឧបមិ គាំង ៤ ប្រការតទៅទៀត ដោយ ការលើកយកមកអធិប្បាយវែកញែក ក្នុងធម៌គាំង ៤ ប្រការ ជាញឹនម្តង មួយ ។ ឲ្យគ្រប់ធម៌គាំង ៤ ប្រការ ដូចតទៅនេះ

អធិប្បាយពង្រីកសេចក្តី

ធម៌គាំង ៤ ប្រការដែលមានឈ្មោះថា ៥ ធ្មិ្ទាឧបមិ នេះ មាន សេចក្តីល្អគួរហ្មត់ចត់ជ្រាលជ្រៅពិស្តារ ក្រៃលែងណាស់ ហើយច្រើនវែង និយាយចំពោះផ្លូវធម៌សុទ្ធ ។ តាំងតែវមានសេចក្តីពាក់ព័ន្ធទៅក្នុងផ្លូវលោក ខ្លះ សូមអធិប្បាយសេចក្តីបំបែរមកក្នុងផ្លូវលោកខ្លះ ដោយសង្ខេប :

១ – ឆន្ទៈ : ការពេញចិត្ត, ស្រឡាញ់, ជ្រះថ្លា ។

កុលបុត្តកុងព្រះពុទ្ធសាសនានេះ កាលបើត្រូវការចង់បានប្រយោជន៍ណាមួយ ក្នុងផ្លូវលោក ឬ ក្នុងផ្លូវធម៌ គប្បីចម្រើនឆន្ទៈ ឥទ្ធិបាទធម៌ ប្រកបដោយ ឆន្ទសមាធិ និង បធានសង្ខារ ។ ពាក្យថា "ឆន្ទសមាធិ" សំដៅយកការអប់រំចិត្តឲ្យល្អ ឲ្យចេញចាកអកុសលទាំងពួង មាននីវរណៈ៥ ជាដើម តាមសេចក្តីពេញចិត្តរបស់ខ្លួន ។ ពាក្យថា "បធានសង្ខារ" សំដៅយកការព្យាយាមជ្រើសរើស ប្រកបដោយបធានធម៌ ៤ យ៉ាង មានសំវរប្បធានជាដើម ។ ត្រង់ពាក្យថា "ចម្រើនឥទ្ធិបាទ" បានដល់ការចម្រើនសមថកម្មដ្ឋានទាំង ៤០ ប្រភេទមានអនុស្សតិ ១០ ជាដើម ។ យោគីអ្នកចម្រើនសមថកម្មដ្ឋាន គប្បីហាត់ពត់ចិត្ត ជាអកុសលរបស់ខ្លួន ឲ្យស្អាតបរិសុទ្ធផុតចាកនីវរណធម៌ ដើម្បីឈោងចាប់លោកុត្តរធម៌ ពាក់ព័ន្ធជាសម្បត្តិដ៏ប្រសើរបំផុតរបស់ព្រះពុទ្ធសាសនា ដែលព្រះសម្ពុទ្ធសម្តែងហើយថា លោកុត្តរធម៌ទុកជាទីជៀសនៃព្រះពុទ្ធសាសនាត្រឹមប៉ុណ្ណោះ ។ លោកុត្តរធម៌ដែលអរិយបុគ្គលបានសម្រេចនោះ ដោយហេតុតែមានឆន្ទិទ្ធិបាទនេះជាប្រធាន ។

សម្បត្តិរបស់ផ្លូវលោកមានច្រើនយ៉ាងគឺ កោតខ្លាច, តេរ៉ែឈ្មោះ, យសស័ក្តិ, សុខ, បរិវារ ដែលគេត្រូវបាន ត្រូវគប់ប្រសព្វ សុទ្ធតែកើតមកអំពីកម្លាំងឆន្ទៈ ដោយមានឆន្ទៈជាប្រធាន ដែលបិតនៅក្នុងចិត្តរបស់

គេជានិច្ចកាល ។ សម្បត្តិផ្លូវលោក រមែងជាទីចាប់អារម្មណ៍ របស់មនុស្សបុថុជ្ជន ពុំមាននរណាមួយចង់សេពចោលឡើយ សុទ្ធតែត្រូវការចង់បានគ្រប់ៗគ្នា ។ ព្រោះអាស្រ័យការចង់បាននេះហើយ ទើបមនុស្សក្នុងលោកគ្រប់ប្រទេស ប្រើសេចក្តីប្រាថ្នា, សេចក្តីប្រឹងប្រែង, ព្យាយាម, ស្រួតរួត ឈមមុខទៅរកសម្បត្តិផ្លូវលោក ចង់ឲ្យជួបប្រទះនូវលាភ, យស, សរសើរ, សុខ ដែលជាទីដៅរបស់មនុស្សបុថុជ្ជនក្នុងលោក ។

សម្បត្តិផ្លូវលោកដែលមាននៅលើផែនដី ជារបស់ស្អាតកំចាំងយ៉ាងណាក៏ដោយ គេអាចស្វែងរកបាល់តែឃើញ បាល់តែបាន ដោយអាស្រ័យធន្មៈ គឺសេចក្តីស្រឡាញ់ សេចក្តីប្រាថ្នានេះឯង ។ សម្បត្តិក្នុងលោកដែលឆ្ងាច់តែកំចាំង គេមើលមិនឃើញ មិនដឹង គេអាចរកឃើញបានដោយងាយ ឧទាហរណ៍ដូចលោហជាតុ គឺដែក, ស្ពាន់ និងមាសពេជ្រ, ប្រេងកាត, ប្រេងសាំង ដែលមានទៅក្នុងដី ឬក្នុងសមុទ្រ គឺគេអាចដឹង, អាចរកឃើញបាន ព្រោះហេតុអាស្រ័យមានធន្មៈជាប្រធាន ។ កាលបើមាន ឆន្ទៈ ហើយ វីរិយៈ ចិត្តៈ វីមង្សា ក៏មានជាប់តៗគ្នា ។

២- វីរិយៈ ការខំប្រឹងប្រែង, ព្យាយាមមិនដាច់ ។ ពាក្យថា "វីរិយៈ" មានសព្ទជាវេចនៈ គឺពាក្យដែលត្រូវប្រើផ្សំសព្ទជាមួយនឹងវីរិយ នេះជាច្រើនយ៉ាងគឺ ឧដ្ឋានៈ ប្រែថា "ការក្រោកឡើង,

ន្ត្រីម្ន ” ឯយោគ: ប្រែថា “ការឈានខាងមុខ” អដ្ឋិតិ ប្រែថា “ការ
ទ្រទ្រង់ដំណើរ” បរក្កម: ប្រែថា “ការខំប្រឹងខាងមុខ” អប្បដិ-
ឯណី ប្រែថា “ការមិនត្រឡប់សាមកក្រោយ” ។ ពាក្យទាំងអស់
នេះ រួបរួមសេចក្តីមក គឺការខំប្រឹងប្រែង , ការព្យាយាមមិនដាក់ធុរៈ
ចោល ។ ឥទ្ធិបាទធម៌ទី២នេះ មានសេចក្តីដូចគ្នានឹងឥទ្ធិបាទធម៌ទី ១
ដែរ គ្រាន់តែខុសគ្នាត្រង់ពាក្យថា ឆន្ទៈនិងវីរិយៈប៉ុណ្ណោះ ។

វីរិយៈ ជាឥទ្ធិបាទធម៌ទី២នេះ មានសេចក្តីពិស្តារ មានអត្ថដ៏
ជ្រាលជ្រៅណាស់ ក្នុងទីនេះ សូមធ្វើសេចក្តីអធិប្បាយដោយសង្ខេបដូច
ពណ៌នាតទៅនេះ

វីរិយៈ ដែលប្រែមកថា “ការខំប្រឹងប្រែង , ព្យាយាមមិនដាក់
ធុរៈចោល” បានន័យមកជាភាសាខ្មែរបស់យើងថា “ការយកចិត្តទុក
ដាក់ចំពោះកាតព្វកិច្ចណាមួយ” ដែលយើងត្រូវធ្វើ គឺជាកិច្ចផ្លាស់ខ្លួនក្តី
កិច្ចការរបស់ផ្ទៃក្តី របស់សាសនាក្តី ត្រូវតែយើងធ្វើដោយការប្រឹងប្រែង
ព្យាយាម អន្ទោកអន្ទោលខ្ជិលច្រអូសខ្ជិលច្រអែ ឈោងឈានទៅមុខ មិនដាក់ធុរៈ
ចោល ត្រូវប្រឹងសង្កាត់ខ្លួនឃាតចំពេញការណីយកិច្ចរបស់ខ្លួននោះឱ្យគាល់
តែសម្រេចប្រយោជន៍ មិនត្រូវតំអក់ចង្កោយឱ្យសេចក្តីឆ្កួលច្រអូសគ្របសង្កត់
ពាំងចង្អាក់ដំណើរនៃសេចក្តីព្យាយាមនោះបានឡើយ ។

វីរិយធម៌នេះ លោកពន្យល់ថា ជាចារីមួយរបស់ព្រះពោធិសត្វ ខុក

ថាជាកម្លាំងដ៏ប្រសើរបំផុត ដែលអាចជួយឧបត្ថម្ភគាំទ្រព្រះពោធិសត្វឲ្យ
បានត្រាស់ដឹងជាព្រះពុទ្ធ ដែលយើងធ្លាប់ដឹងហើយថា «វីរិយេ ឋារមិ,
វីរិយេ ឋិតេ » ។ អកុសលធម៌មួយ មានឈ្មោះថា កោសជ្ជៈ ប្រែ
ថា «សេចក្តីខ្ជិលច្រអូស» បានន័យថា « កិរិយាទ្រមក់, ការតំអក់តម្រង់
គ្រលែសគ្រលស , ខ្វែលខ្វល ចំពោះការណ៍យកចិត្តវបស់ខ្លួន ។
កោសជ្ជៈនេះ ជាគូប្រជាំងនឹងវីរិយៈ, កាលបើ វីរិយៈ មាន
កម្លាំងរឹងប៉ឹងក្លៀវក្លា ទើបអាចសង្កត់សង្កិនកម្ចាត់នូវ កោសជ្ជៈបាន ។
កោសជ្ជៈ ជាតួអកុសល ជាចោរ ជាខ្មោចមួយយ៉ាងធំ នាំឲ្យមនុស្ស
អ្នកខ្ជិលច្រអូសឲ្យថ្លង់ធ្លោយធ្លាក់ខ្លួន ទៅជាក្រអេហមរហាម ទៅជាល្ងង់
ខ្លៅយើញជាក់ច្បាស់ក្នុងបច្ចុប្បន្ននេះជាប្រាកដ ។ ច្បាប់ព្រះពុទ្ធសាសនា
បន្ទោស តិះដៀល បន្ទុះបង្អាប់ ចំពោះសេចក្តីខ្ជិលនេះជាអនេកប្បការ ។

បណ្តាកិច្ចការទាំងអស់ របស់មនុស្ស គឺ កិច្ចការផ្គាល់ខ្លួនក្តី កិច្ច
ការដទៃក្តី កិច្ចការសាសនាក្តី ច្រើនតែមានឧបស័គ្គពាក់ស្អាក់ដំណើរនៃ
សេចក្តីព្យាយាមនេះជាធម្មតា ថ្វែកតែឧបស័គ្គខ្លះធំ ឧបស័គ្គខ្លះតូច ។ វីរ-
យធម៌នេះហើយ ដែលអាចតតាំងក្បាំងពុះពារចំពោះឧបស័គ្គទាំងអស់បាន
ដោយពិត ។ បុគ្គលណាមានព្យាយាម រមែងឈានកន្លងនូវសេចក្តីទុក្ខ
បាន អាចធ្វើប្រយោជន៍ឲ្យសម្រេចដោយសុវត្ថិភាព ឃើញជាក់ច្បាស់
ក្នុងបច្ចុប្បន្ន ។ ការណ៍នេះ បញ្ជាក់ឲ្យឃើញថា «សេចក្តីសម្រេច

ដូចចំណង់ទៅបាន ព្រោះសេចក្តីព្យាយាមតាំងអស់ ។ លោក, យស, កេរ្តិ៍ឈ្មោះ, សុខចម្រើន ដែលបុគ្គលមានបានបរិបូណ៌ហើយ ក៏សុទ្ធតែកើតឡើងដោយគុណព្រះធម៌ គឺសេចក្តីព្យាយាមនេះឯង ។

៣– ចិត្ត: ការយកចិត្តទុកជាក់, ការគិតគូរឿយ។ ។ ពាក្យថា"ចិត្ត"នេះ សំដៅយកតួចិត្តដែលជាអរូបធម៌ផង សំដៅយកចេតសិកផង ។ ចិត្ត ជាធម្មជាតសន្សំទុកនូវអារម្មណ៍, ជាធម្មជាតសម្រាប់គិតគូរឬថា ជាធម្មជាតផ្តើមគំនិតកន្លះណីយកិច្ចណាមួយ ។ ចិត្ត:នេះ តែងមានទៅក្នុងកាយ ប៉ុន្តែ មិនមានពណ៌សម្បុរយ៉ាងណា។ទេ ហើយអាចដឹងបានក្នុងអារម្មណ៍ផ្សេង។ ។ ចិត្តនេះ សូម្បីមិនមានរូបកាយឃើញច្បាស់ដ ប៉ុន្តែ មិនអាចបណ្តោយឲ្យនៅទំនេរដោយគ្មានច្បាប់សម្រាប់ខ្លួនានោះបានឡើយ គឺត្រូវតែយកច្បាប់ព្រះពុទ្ធសាសនា មកខ្លួនានចិត្ត ទើបប្រព្រឹត្តទៅដោយល្អបាន ។

ព្រះសម្មាសម្ពុទ្ធដែលត្រាស់ដឹងឡើងហើយ ទ្រង់សម្តែងធម៌ទេសនាប្រៀនប្រដៅសត្វលោកនោះ ឈ្មោះថា ខ្លួនានប្រៀនប្រដៅបង្រៀនបង្ហាត់ចិត្តរបស់សត្វលោកហ្នឹងឯង ។ ការខ្លួនាន, ការបង្រៀនបង្ហាត់ពត់ចិត្តដោយយកច្បាប់ធម៌មកជាបន្ទាត់របស់ចិត្ត ទើបចិត្តនោះបានបត្រឹមត្រូវល្អ ឈ្មោះថា ចិត្តបានទទួលផលនៃការអប់រំ ។ កាលបើចិត្តដែលគេអប់រំល្អហើយ អាចបង្ហាត់កាយកំចាឲ្យធ្វើ ឬនិយាយ ក៏ត្រូវផ្លូវល្អ

ដែរ ។ កាលបើកាយនិងវាចា ធ្វើត្រូវ និយាយត្រូវល្អហើយ រមែង
នាំមក នូវសោក , យស ឲ្យដល់បុគ្គលអ្នកនោះវិញ ដូចព្រះពុទ្ធភាសិតថា
« ចិត្តដែលគេទូន្មានហើយ ធ្វើក្តី និយាយក្តី សុទ្ធតែជាហេតុនាំមកនូវ
សេចក្តីសុខ សេចក្តីចម្រើន ប្រាកដោយពិត » ។ ធម៌ក្នុងព្រះពុទ្ធសា-
សនា មានបុញ្ញកិរិយាវត្ថុជាដើមនោះហើយ ទុកថាជាប្បាប់ទូន្មានគ្រប់
គ្រងចិត្ត ។ ដូច ចិត្តនិទ្ទេសធម៌ ពីរនេះ មានវិធីអប់រំចិត្ត ដោយ
សមថកម្មដ្ឋានមានប្រភេទ៤០ មានអនុស្សតិ១០ជាដើម ។ ក្នុងទីនេះ ពុំ
បានអធិប្បាយចំពោះធម៌នោះដោយសេចក្តីពិស្តារឡើយ សូមអធិប្បាយ
ដោយសង្ខេបដូចតទៅនេះ

១-) ទូន្មានចិត្តមិនឲ្យត្រេកអរក្នុងអារម្មណ៍ ,

២-) — ,, — ខឹង — ,, — ,

៣-) — ,, — រង្កៀង — ,, — ,

៤-) — ,, — ស្រវឹង — ,, — , ។

ការអប់រំចិត្ត ដោយវិធីទូន្មានប្រៀនប្រដៅ ឲ្យចិត្តប្រកបដោយសតិ-
សម្បជញ្ញៈ ឲ្យមានឧត្តមគតិតាមផ្លូវព្រះពុទ្ធសាសនា រមែងជាមូលហេតុ
មួយ ដូចជាដើងសម្រាប់ឈានឈោងចាប់យកប្រយោជន៍ ឲ្យបានសម្រេច
ដូចបំណង ។ ចិត្តដែលមិនបានអប់រំ អាចធ្វើឲ្យមនុស្សវិនាសដូចខាវ
ធ្វើអ្នកស្រុកឲ្យវិនាស, ចំណែកខាងចិត្តដែលបានអប់រំល្អហើយ អាចធ្វើ

មនុស្សឲ្យល្អបានដោយពិត ដូចមាតាបិតាអ្នកស្រឡាញ់កូន ខំនុកចម្រុងផ្តើមកូនឲ្យចម្រើនដូច្នោះដែរ ។

ចិត្តដែលបានទទួលការអប់រំល្អ ជាចិត្តបរិបូណ៌ដោយបុណ្យកុសលលោកប្រៀបដូចជាដើង ឬ កង់រទេះសម្រាប់ឈានដើរ ឬវិលទៅរកសេចក្តីចម្រើន ដើម្បីឲ្យបានសម្រេចប្រយោជន៍ ក្នុងផ្លូវលោក ឬ ក្នុងផ្លូវធម៌ពុំខាន ។ ព្រោះហេតុនេះ ធម៌ដែលនាំឲ្យសម្រេចប្រយោជន៍ ដោយផ្លូវចិត្តនោះឯង ទើបឲ្យឈ្មោះថា «ចិត្តិទ្ធិបាទ» ។

៤ – វីមំសា ការពិចារណា ការត្រិះរិះរឿយ។ ។ កុលបុត្រក្នុងព្រះពុទ្ធសាសនា កាលបើបានសិក្សា បានប្រតិបត្តិអប់រំតាមគន្ធង់នៃឥទ្ធិបាទធម៌ទាំង ៣ នោះហើយ គប្បីសិក្សាអប់រំតាមដំណើរ នៃ វីមំសិទ្ធិបាទទី៤នេះ តទៅទៀត ។ ឥទ្ធិបាទធម៌ទី៤ ដែលលោកប្រើពាក្យថា «វីមំសា»នោះ គឺបញ្ញាសម្រាប់ពិចារណាសាកល្បង, ពិសោធបន្ថែមលើធម៌ទាំង ៣ ខាងដើម ជាការវិនិច្ឆ័យ, ដម្រះមន្ទិល, ចោសសម្អាតត្រួតពិនិត្យថែមទៀត ។ ពាក្យថាវីមំសានេះជាឈ្មោះនៃប្រាជ្ញា។

កុលបុត្រក្នុងព្រះពុទ្ធសាសនា ដែលបានអប់រំខ្លួនតាមកម្មវិធីនៃឥទ្ធិបាទធម៌ រមែងបានទូវីមំសាសមាធិ និងបធានសង្ខារ ។ បញ្ញាដែលមានឈ្មោះថាវីមំសានេះ ជាបញ្ញាដ៏ល្អិតហួត់ចត់ជាទីបំផុត ដោយហេតុថា ជាធម្មជាតិសម្រាប់ស្ងាបស្ងួត ត្រួតពិនិត្យ, ពិសោធមើលជាអនុលោមប្បដិលោមទៅក្នុងកុសលធម៌ និងអកុសលធម៌ទាំងអស់ សម្រាប់

សូធ៌ឲ្យឃើញជាក់ច្បាស់ដោយដុំវិញ ឃើញច្បាស់ថា "នេះកុសលធម៌, នេះអកុសលធម៌" ។ មួយទៀត ការដឹងច្បាស់ថា "បញ្ចក្ខន្ធ ជាសភាវៈមិនទៀង ជាទុក្ខ ជាអនត្តា ហើយរំលឹកចូន្នានចិត្ត មិនឲ្យចិត្តប្រកបដោយឧបាទានក្នុងបញ្ចក្ខន្ធ ធ្វើចិត្តឲ្យនឿយណាយ ដិនឆ្អន់ចំពោះបញ្ចក្ខន្ធ ឲ្យក្រៀវក្រៃ ឲ្យអង់អាច ឲ្យសប្បាយរីករាយ ក្នុងការលះបង់នូវកិលេសកាមនិងវត្ថុកាម" ។ វីមំសា នេះ ជាបញ្ញាឈោងចាប់យកនូវសម្បត្តិដ៏ប្រសើរបំផុត គឺលោកុត្តរធម៌ទាំង ៩ ដែលមានទៅក្នុងព្រះពុទ្ធសាសនា ។

វីមំសិទ្ធិបាទ កាប់ថាជាធម៌ដែលចែរឈមទៅរកបរមត្ថប្រយោជន៍ផង ទៅរកសន្ទិដ្ឋប្រយោជន៍ផង ។ សេចក្តីអធិប្បាយមកនេះ ចំពោះតែវីមំសាក្នុងផ្លូវធម៌សុទ្ធ ពុំបានទាក់ទងទៅក្នុងផ្លូវលោកឡើយ ។ លំដាប់តទៅនេះ សូមធ្វើអធិប្បាយអំពីវីមំសាដែលទាក់ទងក្នុងផ្លូវលោក ដោយសង្ខេប ដូចសេចក្តីតទៅនេះ៖

បញ្ញា លោកាប់ថា ជាជ្ញាមួយរបស់ព្រះពោធិសត្វ ដែលយើងធ្លាប់ដឹងមកហើយថា "បញ្ញាជ្ញាមី" ។ ក្នុងមហោសធជាតក ដែលសម្តែងអំពីព្រះពោធិសត្វព្រះនាម មហោសធ ទ្រង់ប្រកបដោយជ្ញាជ្ញាឈ្វាសវៃជាទីបំផុត អាចដោះស្រាយបញ្ហាដ៏វិតវៃរបស់ព្រះអង្គ និងរបស់ប្រជាជនបានគ្រប់វិស័យ ឥតខ្វះសល់សល់ដំណាក់បញ្ហាណាមួយទេ ។ ព្រះមហោសធពោធិសត្វ ទ្រង់ធ្វើព្រះទ័យដ៏ក្រៃលែង ដោយបញ្ញា-

ចារមើ, អាចរក្សា, អាចគ្រប់គ្រង, អាចការពារប្រទេសជាតិមិនឲ្យថ្លស់ឡើយ ជាក់ខ្លួនឯងជាទាសភាពនៃជនបរទេសណាមួយឡើយ ។

បញ្ញា លោកពន្យល់ថា ជាពន្ធីមួយដ៏ប្រសើរបំផុត អាចនុះបំភ្លឺឃើញប្រភពហេតុការណ៍ក្នុងលោកគ្រប់ទាំងអស់ ។ ពន្ធីភ្លើង, ពន្ធីព្រះអាទិត្យ, ពន្ធីព្រះចន្ទ អាចបំភ្លឺបានប្រាកដ ចំពោះតែភ្នែកប៉ុណ្ណោះ ពុំអាចធ្វើបំភ្លឺឲ្យឃើញប្រាកដដល់ចិត្តផងបានឡើយ ។ សេចក្តីចម្រើនប្លុំថ្កើង ក្នុងផ្លូវលោក ដូចយ៉ាង លាភ, យស, បសំសា, សុខ ដែលកើតឡើងបានព្រោះអាស្រ័យបញ្ញារបស់មនុស្ស ពុំមែនកើតឡើងដោយសេចក្តីល្ងង់ខ្លៅទេ ។

បញ្ញា ប្រែថា "ការដឹងច្បាស់ខ្ពស់ ទាំងផ្លូវលោកទាំងផ្លូវធម៌" ព្រោះហេតុនេះ ទើបលោកវែកញែកបញ្ញាចេញជា ២ ប្រភេទគឺ

១-) លោកិយបញ្ញា ការដឹងច្បាស់សម្រាប់ប្រើក្នុងលោកិយ,

២-) លោកុត្តរបញ្ញា ការដឹងច្បាស់សម្រាប់ប្រើក្នុងលោកុត្តរៈ

លោកិយបញ្ញា ការចេះដឹងច្បាស់លាស់ក្នុងផ្លូវលោក ដែលគេនិយមតាមកាលៈទេសៈ ដូចការចេះដឹងក្នុងផ្លូវវិទ្យាសាស្ត្រផ្សេងៗ ជាប្រយោជន៍មុខ សម្រាប់គ្រប់គ្រងប្រទេសជាតិ ជីកនាំប្រទេសជាតិ ឲ្យមានវឌ្ឍនភាពនិងសុភមង្គល ឃើញជាក់ច្បាស់ក្នុងបច្ចុប្បន្ន ដោយពិត ។

បញ្ញា កាលបើបុគ្គលមានបរិបូណ៌ហើយ រមែងកម្ចាត់បង់បានន្ទូរសឹក

សត្រូវតាំងខាងក្នុងតាំងខាងក្រៅ ។ សឹកសត្រូវខាងក្នុងនោះ បានដល់កងកិលេសគ្រប់យ៉ាង មានលោភៈជាដើម, ឯសឹកសត្រូវខាងក្រៅនោះ បានដល់សឹកសត្រូវគឺមនុស្សប្រុសតូរ្យតន្ត្រីបាន មានពួកទេមិឡនិងរោរ ឬខ្លាដំរីជាដើម ។ ការកម្ចាត់សឹកសត្រូវ តាំងខាងក្នុងតាំងខាងក្រៅ ឲ្យរាក់បបូរបខ្ចាច ក៏ចាលទៅបាន ក៏ដោយគុណានុភាពនៃប្រាជ្ញាតាំងអស់ ។ អ្នកដែលបានរួចលះហាន: ថាជាអ្នកមានជីវភាពខ្ពង់ខ្ពស់ក្តី បានទទួលលាភ យស សរសើរ សុខ ក្តី ច្រើនតែកើតមកព្រោះអាស្រ័យបញ្ញា ។ មួយទៀត បុគ្គលអ្នកមានប្រាជ្ញា មានលទ្ធភាពអាចទទួលកិត្តិយសឈ្មោះសំឡេងល្បីល្បាញ ឃើញជាក់ច្បាស់ក្នុងបច្ចុប្បន្ន ហើយឆាបនៅជាស្ថាវរធ្យាយទៅក្នុងអនាគតដ៏វែងឆ្ងាយតទៅទៀត ។

ការបានទទួលជោគជ័យ លើសឹកសត្រូវខាងក្នុងក្តី លើសឹកសត្រូវខាងក្រៅក្តី រមែងប្រាកដឡើង ព្រោះអាស្រ័យបញ្ញាតាំងអស់ ។ មួយវិញទៀត បុគ្គលដែលគេកំណត់ថាជាអ្នកមានបញ្ញានោះ សំដៅយកមនុស្ស ដែលមានគោលគំនិតទៅក្នុងប្រយោជន៍សាធារណៈ ពុំមែនមានគំនិតត្រឹមតែប្រយោជន៍ផ្ទាល់ខ្លួននោះឡើយ ។ ការកត់សម្គាល់ ដើម្បីជាយដឹងថា "អ្នកណា មានប្រាជ្ញាខ្លាយ, អ្នកណា មានប្រាជ្ញាតូចបង្អែត" ដូចឧទាហរណ៍តទៅនេះ :

អ្នកដែលមានចិត្តលោភលន់ខ្លាំង, អ្នកដែលមានមហិច្ឆិតា ពង្រីកសេចក្តីប្រាថ្នា ឈមមុខទៅរកប្រយោជន៍ខ្លួន, អ្នកដែលស្រេវឆ្អែតពុលគំនិតក្នុងកិត្តិយសឋានន្តរសក្តិ, អ្នកដែលធ្ងន់គំនិតក្នុងអស្ថិមានះរឹងចចេស ប្រកាន់មាំ មិនស្តាប់ មិនចម្អែតម្រាប់អំពីអ្នកដទៃ, មនុស្សដែលធ្ងន់ដោយសេចក្តីក្រោធច្រើន, ធ្ងន់ដោយមោហៈច្រើនកាន់ច្រឡំ យល់ខុសជាត្រូវ យល់ត្រូវជាខុស ។

បុគ្គលទាំងពួក ដូចរៀបរៀងខាងលើនេះ អាចកំណត់សម្គាល់បានដោយងាយ ថាជាបុគ្គលមានប្រាជ្ញាតូចចង្អៀត ឬសម្គាល់បានថា ជាអ្នកមានគំនិតចំពោះតែប្រយោជន៍ខ្លួន ឬ ញាតិសន្តានរបស់ខ្លួន ។ បុគ្គលដែលមានគំនិតផ្តុំយអំពីនេះ ទើបឈ្មោះថា ជាអ្នកមានប្រាជ្ញាធំទូលាយ ដោយហេតុនៃគោលគំនិត ដែលគ្របដណ្តប់ទៅលើប្រទេសជាតិសាសនារបស់ខ្លួន ឲ្យមានសេរីភាព វឌ្ឍនភាព និងសុភមង្គល ទើបថ្កើងរុងរឿងវែងឆ្ងាយទៅក្នុងកាលអនាគត ។

ការកត់សម្គាល់អំពីមនុស្សអ្នកមានចិត្តលោភខ្លាំង អ្នកនោះ ច្រើនតែស្វែងរកទ្រព្យសម្បត្តិខុសគន្លងធម៌ មានការប្លែកប្រាស លួចឆក់ជាដើម, មានទ្រព្យសម្បត្តិបំបួលដោយផ្លូវខុសច្បាប់ ឥតភាន់ហិរិឧត្តប្បៈ អៀមខ្មាសខ្លាចចិត្តអកុសលមួយរះ តិតតែពីខាងមានបុនមកក្នុងតែម្យ៉ាង ។

បុគ្គលអ្នកលោកលន់ភ្នំង ខោះលោកលន់ចំពោះទ្រព្យសម្បត្តិក្តី ចំពោះយសសក្តិក្តី រមែងហ៊ានចំផ្លាញដីតែអ្នកដទៃថែមទៀត ។ ព្រឹត្តិការណ៍របស់បុគ្គលអ្នកលោកនេះ ច្រើនតែឆ្ងេង ឈ្លើយ នាំឲ្យអ្នកផងរិះគន់តិះដៀលពេចជ្រាយបានជាប្រាកដ ដោយហេតុនៃខោសដែលមិនបានអប់រំ តាមឥទ្ធិបាទធម៌ ដូចពណ៌នាមកនេះឯង ។

រីគ្រឹះស្ថាន មានគ្រឹះរា ជាគ្រឿងទល់
ទើបនឹងថ្កល់ ដល់តួផ្ទះ មិនបះស្រុត
ឯការសម្រេច កិច្ចអ្វីអ្វី នៃកុលបុត្រ
ត្រូវសម្បយុត្ត ដោយឥទ្ធិបាទ ធម្មជាតុបួន ។

— ឬថា —

អ្វីអ្វីដែលនឹងសម្រេចបាន
នោះគាល់តែមានឥទ្ធិបាទ
ដូចជាគ្រឹះស្ថានឬប្រាសាទ
ត្រូវមានគ្រឹះបាតជួយទ្រាំដែរ ។

ចប់ ទិត

ចតុរារិយសច្ច

ព្រះភិក្ខុ ប៉ាន ខាត់ រៀបរៀង

(៣)

កាលបើរូបនោះ មានការប្រែប្រួលទៅជាប្រការផ្សេង ។ ហើយ ព្រោះជាវិបរិណាមធម៌ ឬក៏ យើងមិនឃើញ, ពុំនោះ មិនបានរូបនោះ, ពុំនោះសោត បានរូបនោះមកហើយ តែរូបនោះ ប្រែប្រួលទៅ មិនឋិតនៅតាមសភាវដើម យើងមិនបានសម្រេចដូចចំណង់ យើងត្រឡប់ទៅជាទោមនស្សកើតទុក្ខព្រួយរន្ធត់វិលដល់ខួចចិត្ត ទៅជាមនុស្សឆ្កួតក៏សឹងមាន កើតទៅជាទោស "អាទីនវៈ" ។ សេចក្តីនេះ ក៏ពុកជាកត្តាមួយនៃការពិសោធដែរ ។

កាលបើយើង យល់ច្បាស់ថា ធម៌នេះជាទោស នាំឲ្យខូចចិត្ត នាំឲ្យខ្វល់ឥតប្រយោជន៍ យើងដកចិត្តយើងឲ្យផុតចេញពីរូបនោះ ចិត្តយើងរូបស្រឡះមិនជាប់ជំពាក់នឹងរូប នេះហៅថាចិត្តរួចស្រឡះ "និស្សរណៈ" ។

ធម៌ ៣ ប្រការនេះ ជាធម៌ពិត, ការយើញពិតនេះ ជាយថាភូត-ញាណ ជាធម៌ប្រក្រតី មានពិតប្រាកដ ទៅក្នុងជីវភាពមនុស្សយើងសព្វថ្ងៃនេះ ។

សេចក្តីដូចបានពោលនេះ បញ្ជាក់ច្បាស់ថា ពុទ្ធសាសនា មិនមែនជា ទុក្ខដ្ឋនិយម (Pessimisme) ឬជា សុខដ្ឋនិយម (Optimisme)

ទេ ។ យើងត្រូវគ្នាគប្បីកត់សម្គាល់ថា សេចក្តីត្រេកត្រអាលនេះជា
មានដើមនៃអាទីនវៈ សេចក្តីទុក្ខព្រួយដែលកើតឡើងពីរូបនេះជាអាទីនវ
ការធ្វើចិត្តឲ្យរួច ការលាស់ចោលនូវចិត្តជាប់ជំពាក់នេះ ឲ្យជាប់ស្រឡះ
ហើយពិចារណាធម៌នេះឲ្យយល់ច្បាស់ទៅតាមយថាភូតទស្សនញ្ញាណនេះ
ជានិស្សរណៈ ការលាស់ខ្លួនចេញគឺជាប្រកបចេញ ។ ព្រះសម្ពុទ្ធ
ទ្រង់ត្រាស់ទុកមានដើមនៃសូត្រនេះថា(១) បរិញ្ញាដកជាអញ្ញាតិត្តិយៈ មិន
យល់ធម៌នេះទៅតាមការពិតទេ, គឺមិនយល់ថា តម្រេកក្នុងតាមគុណ
ទាំង ៥ ប្រការនេះថាជាតម្រេកទេ, ទោសក្នុងតាមគុណទាំង ៥ ប្រការនេះ
ថាជាទោសទេ, ការលាស់ចិត្តចេញពីតាមគុណទាំង ៥ ប្រការនេះថាជា
ធម៌លាស់ចេញទេ, ពោលគឺមិនយល់ច្បាស់តាមយថាភូតទស្សនញ្ញាណ
ឡើយ ។ បើយល់ធម៌នេះមិនច្បាស់ទេ តើខ្លួនខ្លួនឯងដូចម្តេចកើត ?
ប្តូនឯប្រដៅប្រជាជនទាំងឡាយឲ្យយល់ធម៌នេះម្តេចកើត ?

ទស្សនាគាន (Conception) ក្នុងពាក្យថា "ទុក្ខ" នេះ គេអាច
យល់បានជា ៣ ប្រការគឺ :

---

๑ ឯវំ ភាទិនោ ភិក្ខវេ អញ្ញតិត្ថិយា បរិញ្ញាដកា ឯវមស្ស វចនីយោ:
๑- កោ បនាវុសោ កាមានំ អស្សាទោ; ๒- កោ អាទីនវោ ๓- កឹ និស្សរណំ ។
๑- កោ រូបានំ អស្សាទោ; ๒- កោ អាទីនវោ; ๓- កឹ និស្សរណំ ។
๑- កោ វេទនានំ អស្សាទោ, ๒- កោ អាទីនវោ, ๓- កឹ និស្សរណំ ។

ក – ទុក្ខ ទុក្ខធម្មតាគឺទុក្ខទុក្ខ;

ខ – ទុក្ខ ទុក្ខដែលកើតពីវិបរិណាមធម៌,

គ – ទុក្ខ ក្នុងន័យថា សង្ខារទុក្ខ ។

សេចក្តីទុក្ខត្រង់ប្រការក្នុងដំណែលយើងនេះ ដូច ជាតិ, ជរា, ព្យាធិ, មរណៈ, សម្បយោគទុក្ខ ទុក្ខគឺការជួបប្រទះអ្វីមួយដែលមិនពេញចិត្ត, វិប្បយោគទុក្ខ ទុក្ខគឺការព្រាត់ប្រាសអ្វីមួយដែលជាទីពេញចិត្ត, យម្បិច្ឆំ ន លភតិ តម្បិទុក្ខ ទុក្ខគឺប្រាថ្នាអ្វីមិនបានដូចបំណង សោក បរិទេវ ទុក្ខ ទោមនស្ស ព្រមទាំងការយំកន្ទក់ទុក្ខ ចេតសិកទុក្ខ ទាំងអស់នេះទុកជាទុក្ខធម្មតាមិនហៅថាទុក្ខទុក្ខក៏ជាន។

ឯសុខវេទនា ឬសោមនស្សវេទនា ក៏ជាធម្មជាតិមិនទៀងទាត់ មិនបឹតបេរ, ធម៌នេះ តែងប្រែប្រួល បើមិនឆាប់ក៏យូរ ។ កាលបើធម្មជាតិនោះប្រែប្រួលហើយ តែងនាំឲ្យកើតក្តីលំបាក ព្រួយឥតល្អ មិនបាននៅស្រួលសោះឡើយ, វិប្បល្លាសធម៌ទាំងនោះ ក៏លោកពោលពាក្យបញ្ជូលថាជា ទុក្ខ ព្រោះជាធម៌ដែលកើតឡើងហើយធ្វើឲ្យមានការប្រែប្រួល ដែលហៅថា វិបរិណាមទុក្ខ ។ សេចក្តីទាំងពីរប្រការដូចបានពោលមកខាងលើនេះ មិនមែនជាធម៌លំបាកនឹងយល់ទេ ហើយឥតមានន័យណាប្រកែកដដែកក្តីទេ ។ សេចក្តីទុក្ខដែលព្រះសម្ពុទ្ធទ្រង់

ត្រាស់ទុកថា ជាអរិយសច្ចនោះ គេយល់ខ្លួនឯងហើយ ព្រោះជាធម៌ដែលគេអាចយល់ឃើញដោយឯកាយ ជាធម៌ដែលគេបានតាំសោធមើលឃើញត្រង់ពីរពត្រី ក្នុងដំរិតរបស់គេហើយ ។

ឯភាពទុក្ខខ ៣ ដែលហៅថា សំខារទុក្ខ ជាធម៌សំខាន់ណាស់ ហើយមានរូបជាទស្សនវិជ្ជា នៅក្នុងទុក្ខអរិយសច្ចនេះឯង, ធម៌នេះ ត្រូវមានសេចក្តីពន្យល់ស្អិតម៉ត់ចត់ ហើយមានការវែកញែកខ្លះបាន ព្រោះជាធម្មជាតិ ដែលយើងចាត់ទុក្ខថាជា "សត្វ" ជា "បុគ្គល" ឬក៏ថា "អញ" ថា "ខ្ញុំ" ខ្លះឯង ។

ពាក្យដែលយើងហៅថា "សត្វ" "បុគ្គល" ឬថា "អញ" "ខ្ញុំ" នេះឯង បើតាមទស្សនវិជ្ជាពុទ្ធសាសនា មិនគឺអ្វីជាខៃទេ គឺការផ្សំពស:ឬថាមពលនៃកាយនិងចិត្ត (L'homme n'est qu'ne chimie des quatres élèments) ដែលសុទ្ធតែជាធម្មជាតិប្រែប្រួល ដែលលោកចែកជា ៥ប្រការ ហើយហៅថា "ខន្ធបញ្ចក:" ។ ព្រះពុទ្ធត្រាស់ថា (១) ឧបាទានខន្ធបញ្ចក:នេះជា "ទុក្ខ" ដោយសង្ខេប សំខិត្តេន បញ្ចុបាទានក្ខន្ធា ទុក្ខា ។ មួយទៀត ក្នុងទំដៃ ក៏ទ្រង់បានបញ្ជាក់ថា ទុក្ខនេះ គឺខន្ធបញ្ចក:នេះឯង ដូចសេចក្តីដែលទ្រង់ត្រាស់

១- ធម្មចក្កប្បវត្តនសូត្រ

ទុកថា(១)"កិកូតាំងឡាយ ! អ្វីជាទុក្ខ? គឺឧបាទានក្ខន្ធទាំង៥នេះឯង"។ សេចក្តីនេះយើងគប្បីយល់ថា ទុក្ខនិងខន្ធបញ្ចកៈនេះមិនមែនជាធម៌ពីរផ្សេងគ្នាទេ ខន្ធបញ្ចកៈនេះឯងក៏គឺទុក្ខ ព្រោះថាបញ្ចកៈនេះហើយដែលកកើតទៅជាពាក្យថា "សត្វ"ថា"បុគ្គល" ។ ចុះអ្វីទៅដែលហៅថា ខន្ធបញ្ចកៈ ?

ក – ការប្រជុំជាតុកឺរូប "រូបក្ខន្ធ" (Agrègat de la matiére) ។ ពាក្យថាប្រជុំជាតុនេះ បានដល់ការប្រជុំជាតុ ៤ប្រការ = ចតុន្នំ មហាភូតានំ គឺ បឋវីធាតុ, អាបោធាតុ, តេជោ-ធាតុ, វាយោធាតុ, ព្រមទាំងឧបាទាយរូបរបស់មហាភូតរូបផង ។ ឯឧបាទាយរូបនេះ បានដល់ឥន្ទ្រិយ ៥ប្រការ គឺ ចក្ខុន្ទ្រិយ, សោតិន្ទ្រិយ, ឃានិន្ទ្រិយ, ជីវ្ហិន្ទ្រិយ និង កាយិន្ទ្រិយ ព្រមទាំងធម្មជាតិគូគ្នាទៅខាងក្រៅ គឺ រូប , សទ្ទ, គន្ធ, រស, ផោដ្ឋព្ព និងធម្មា-រម្មណ៍ ព្រមទាំងធម្មជាតិដទៃទៀត ដែលជាធម្មាយតនៈ ។ វិស័យ (Domaine) នៃធាតុទាំង៣ខាងក្នុងទាំង៣ខាងក្រៅ(អជ្ឈត្ត ពហិទ្ធា) ទាំងអស់នេះ ហៅថា រូបក្ខន្ធ ។

២- ការប្រជុំជាតុកឺវេទនា "វេទនាក្ខន្ធ" (Agrègat des

---

១ សំយុត្តនិកាយ ខន្ធវារៈ អដ្ឋកថា ស.ទី ៣៤ , ទំព័រ ៨៩ ។ ក្នុងគម្ពីរសំយុត្តនិកាយនេះ មានសេចក្តីនិយាយពីខន្ធបញ្ចកៈនេះច្រើនណាស់ គួរទៅមើលដើម្បីឲ្យមានការយល់ទូលាយ ។

sensations) ។ ការប្រជុំជាតុនេះ បានដល់ធម្មជាតដែលវេឝអារម្មណ៍ជាសុខ ឬ ទុក្ខ ឬក៏ អសុខមទុក្ខ ដែលដឹងបានដោយការចះពាល់កាយនិងចិត្ត ដោយអាស្រ័យអារម្មណ៍ដែលមកពីខាងក្រៅ ។ អារម្មណ៍នេះមាន ៦ ប្រការ គឺ ការចះពាល់ភ្នែក ដោយរូបដែលមើលឃើញ ហៅថា រូបារម្មណ៍, ត្រចៀក ដោយសម្លេងដែលឮ ហៅថា សទ្ទារម្មណ៍, ច្រមុះ ដោយក្លិនដែលចត់មក ហៅថា គន្ធារម្មណ៍, អណ្ដាត ដោយរសដែលភ្លក្ស ហៅថា រសារម្មណ៍ កាយ ដោយវត្ថុ ហៅថា ផោដ្ឋព្វារម្មណ៍ និងចិត្ត ដោយអារម្មណ៍របស់ចិត្ត គឺមនោគតិឬគំនិតដែលគេគិតផ្សេង ។ ហៅថា ធម្មារម្មណ៍ ។ អង្គ ឬ ឥន្ទ្រិយទាំង ៦ ប្រការនេះហើយ ដែលមានសម្តែងក្នុងទស្សនវិជ្ជាពុទ្ធសាសនា ។ ការវេឝអារម្មណ៍ដោយកាយនិងចិត្តនេះ ហៅថា វេទនាខន្ធ ។

ពាក្យថា "មនៈ" ដែលប្រើក្នុងទីនេះ ត្រូវនឹងពាក្យអង់គ្លេសថា "Mind" ឬពាក្យបារាំងថា "Pensée" ដែលគេប្រើក្នុងទស្សនវិជ្ជាពុទ្ធសាសនាខ្លះ ។ ក្នុងគម្ពីរបាលី លោកប្រើពាក្យ ៣ ម៉ាត់គឺ:

១– មនៈ សំដៅយកធម្មជាតដែលនៅកាន់អារម្មណ៍,

២– ចិត្ត ធម្មជាត ដែលបានទទួលអារម្មណ៍ហើយត្រិះរិះគិតពិចារណា,

៣– វិញ្ញាណ ធម្មជាតដែលពិចារណាហើយដឹងច្បាស់

ធម្មជាតិទាំង ៣ នេះ ដូចគ្នា តែលោកប្រើក្នុងន័យផ្សេងគ្នា ដូចបាន
ពោលមកនេះ ។

ដូច្នេះ យើងគប្បីយល់ថា "មន:" នេះមិនមែនជា " Spirit "ឬ "Esprit "ដែលផ្សែងពីធាតុ " Matter,,ឬ" Matiére "នោះទេ ពោលគឺ "មន:" នេះ ជាធាតុ=មនោធាតុ ។ យើងគប្បីចាំទុកថា ពុទ្ធសាសនា មិនយល់ថា " Spirit "ឬ"Esprit "នេះទុកជាផ្សែងពី (Matter)ឬ(Matière) ដូចជាវិធីនៃទស្សនវិជ្ជានិងលទ្ធិសាសនា(Religion) ដទៃៗនោះទេ ។ "មន:" ឬ "ចិត្ត"នេះ ជាអរូប ឬជាឥន្ទ្រិយមួយដូចជាចក្ខុនិងសោត: ដែរ ។ ក្នុងពុទ្ធសាសនា ដើម្បីរក្សាចិត្តកុំឲ្យសៅហ្មង ឲ្យចិត្តនៅផូរផង់ ថ្លាដូចដើម លោកពោលថា ត្រូវសង្រួមឥន្ទ្រិយនេះ ។ ព្រះសម្ពុទ្ធទ្រង់សម្តែងអំពីការសង្រួមឥន្ទ្រិយនេះច្រើនអនេកណាស់ដោយអនេកបរិយាយ ។ កាយយើងនេះ ប្រៀបដូចជាគេហដ្ឋាន ដែលមានទ្វារ ៩ ជួលគឺអាគន្តុកកិលេស ដែលហុយពីក្រៅ តែងចូលទៅតាមទ្វារទាំង ៩ នេះ ហើយប្រឡាក់ដល់ចិត្ត ធ្វើចិត្តឲ្យសៅហ្មង គរទៅជាឧបកិលេស ។ ឯចក្ខុនិងមន: ដែលទុកជាឥន្ទ្រិយនេះ ផ្សែងគ្នាដូច្នេះ អាយតន:គឺចក្ខុ និងរូបារម្មណ៍ខាងដើម បានដល់តន្លៃរបស់កាយដែលប៉ះរូប (Le monde des couleurs) និងរូបដែលមើលឃើញ(Des formes visibles) នេះជាផ្នែកចក្ខុន្ទ្រិយ ឯអាយតន:គឺ មន: និងរូបារម្មណ៍ខាងក្រោយ បានដល់

អង្គរបស់កាយដែលប៉ះរូបារម្មណ៍ពោលគឺ ឧត្តមគតិឬគំនិត ដែលជាធម្ម-
រម្មណ៍ (Le monde des idées, des pensées qui sont les objets mentaux) ជាផ្នែកមនិន្ទ្រិយ ។ ការពិនិត្យអារម្មណ៍នេះ យើងពិសោធ
ឃើញថា មានការផ្សេងគ្នា គឺវិស័យ (Domaine) របស់កាយផ្សេង
វិស័យរបស់អាយតនៈផ្សេង ។

យើងនិយាយថាឮ "ពណ៌" មិនបាន តែយើងនិយាយថាឃើញ
"ពណ៌"បាន ។ យើងនិយាយថាឃើញ"សម្លេង"មិនបាន តែយើង
និយាយថាឮ "សម្លេង" បាន ។ ដូច្នេះ ដោយអាស្រ័យអាយតនៈទាំង
៥ប្រការ ពោលគឺ ចក្ខុ, សោត, ឃាន, ជិវ្ហា, កាយ, ទើបយើង
បានដឹង នូវរូប សទ្ទ គន្ធ រស ផោដ្ឋព្វ ។ ឯអាយតនៈទាំង
៥ នេះ គ្រាន់តែជាចំណែកមួយនៃកាយទេ មិនមែនជាកាយទាំងមូល
ឡើយ, ចុះអ្វីទៀតជាមនោគតិឬគំនិត ? មនោគតិឬគំនិតនេះទៀត
សោត ក៏ជាចំណែកនៃកាយនេះដែរ តែមនោគតិឬគំនិតនេះ មិនអាច
ប៉ះពាល់អារម្មណ៍មួយបានឡើយ ទើបប៉ះពាល់បានក៏ដោយអាស្រ័យអាយ-
តនៈគឺ ចក្ខុ សោត ឃាន ជិវ្ហា ឬ កាយ ហើយដឹងបានដោយអា-
យតនៈមួយផ្សេងទៀតគឺមនៈនេះឯង ។ មនោគតិឬគំនិតនេះ មិន
មែនធម្មជាតិនៅដោយឡែកពីកាយ ដែលគេគប្បីដឹងបានដោយឥន្ទ្រិយ
ទាំង ៥ នោះទេ ។ ដោយពិត ធម៌នេះត្រូវភាក់ងឹងគ្នាទៅវិញទៅមក

ដោយអាយតនៈនៃកាយនេះឯង ឧបមាថា មនុស្សខ្វាក់ពីកំណើត មិនមានមនោគតិស្គាល់ពណ៌ គឺរូប (Le monde des couleurs , The world of coleur) ឃានទេ រៀរលែងតែដោយការប្រៀបធៀបដោយសម្លេង ឬ ដោយអារម្មណ៍ដទៃទៀត ដែលគេដឹងបានដោយអាយតនៈដទៃ ។ មនោគតិ ឬ គំនិត ដែលជាចំណែកនៃកាយនេះ តែងកើតឡើងដោយអាស្រ័យកាយ ហើយទើបបានដឹងទៅដល់មនៈ ទើបមនៈទទួលយកអារម្មណ៍នោះដោយឥន្ទ្រិយ គឺសញ្ញានេះឯង អង្គរបស់ខ្លួនដូចជាបក្ខិនីដ៏សោតៈដែរ ។

ក- ការប្រជុំជាតុកឺសញ្ញា (Agrégat des perceptions) "សញ្ញាខន្ធ" ។ សញ្ញាខន្ធនេះដូចវេទនាខន្ធដែរ មាន ៦ ប្រការ តាំងខាងក្នុងតាំងខាងក្រៅ គឺអាយតនៈ ៦ ខាងក្នុងនិងអារម្មណ៍ ៦ ខាងក្រៅ ។ អាយតនៈខាងក្នុងតាំង ៦ ប្រការនេះ ជាធម្មជាតចាត់ចែងដោយការប៉ះពាល់និងអារម្មណ៍ខាងក្រៅ គឺសញ្ញានេះឯង ដែលទទួលយកអារម្មណ៍ដោយកាយ និងដោយចិត្ត ។

ឃ- ការប្រជុំជាតុកឺ ការដ្ឋឹ "សង្ខារក្ខន្ធ" (Agrégat des formations) សង្ខារក្ខន្ធនេះ លោកពន្យល់ថាជាធម្មជាតិគឺចេតនាដែលដឹកនាំនិងតម្រង់ កុសលនិងអកុសលផង ហើយដែលគេបានដឹងថាជាតួ "កម្ម" (សំ កម្ម:) ។ ព្រះសម្ពុទ្ធទ្រង់បានបញ្ជាក់ទុកថា "ចេតនា" ជា

"កម្ម" ដូចព្រះដីកាថា (๑) ភិក្ខុទាំងឡាយ! តថាគត តែលថា "ចេតនាជាកម្ម" ព្រោះចេតនា ទើបបុគ្គលធ្វើកម្ម ដោយកាយ ដោយវាចាឬដោយចិត្ត = ចេតនាហំ ភិក្ខវេ កម្មំ វទាមិ ចេយិត្វា កម្មំ ករោតិ កាយេន វាចាយ មនសា ។ ចេតនានេះជាធម្មជាតិកើតពីចិត្ត គឺការបង្កើតរបស់ចិត្តឬជាសកម្មភាពរបស់ចិត្ត ។ ឯនាទីរបស់ចេតនាគឺការដឹកនាំចិត្តឲ្យធ្វើអំពើណាមួយជា កុសល អកុសល ឬ អព្យាក្រឹត ។ ចេតនាមាន ៦ ប្រការ ដូចវេទនានិងសញ្ញា ជាធម្មជាតិជាប់ពាក់ព័ន្ធ ដោយឥន្ទ្រិយខាងក្នុង ៦ ប្រការ និងអារម្មណ៍ខាងក្រៅ ៦ ប្រការ ដូចព្រះសាស្តាថា (២) "ភិក្ខុទាំងឡាយ! ចេតនា ៦ ប្រការនោះគឺ រូបសញ្ចេតនា សទ្ទសញ្ចេតនា គន្ធសញ្ចេតនា រសសញ្ចេតនា ផោដ្ឋព្វសញ្ចេតនា ធម្មសញ្ចេតនា" ។ តែវេទនា និងសញ្ញា មិនមែនជាសកម្មភាពនៃចេតនាទេ គឺមិនធ្វើឲ្យជាហេតុដែលនាំឲ្យកើតផលទេ ឬមិនផលិតកម្មវិបាកទេ ឯចម្ងល់ដែលជាសកម្មភាពនៃចេតនាដូចជា មនសិការ (Attention), សទ្ធា (Confiance) សមាធិ (Concentration), ឆន្ទ (Volonté), អធិមោក្ខ (Détermination),

---

๑ អង្គុត្តរនិកាយ ឆក្កនិបាត សៀវភៅទី ៤៦ ទំព័រ ๒๗๒ ។

๒ សំយុត្តនិកាយ នាយវគ្គទី ๑ សៀវភៅទី ๓๓ ទំព័រ ๑๓๙ ។

សញ្ញា (Sagesse), វីរិយ (Energie), ឆន (Désir), បដិឃ (Répulsion ou haine), អវិជ្ជា (Ignorance), មាន: (Vanité), សក្កាយទិដ្ឋិ (Idée du soi), ។ល។ ទើបជាធម៌ឲ្យផលជាកម្មវិបាក ឬ ផលិតកម្មវិបាក ។ បេតសិកធម៌នេះ គាំងអស់មាន ៥២ ប្រការ ដែលឲ្យកើតជាសង្ខារក្ខន្ធ ។

(ជៀមាន)

គ្រូតែឲ្យឯក	អាចចែកពេត	តាមប្រភេទ
ដឹងគាំងហេតុ	កេទុជាទ៍	អាទ្យបណ្ដាល
ដឹងគាំងថ្នាំ	ផ្សំត្រូវមុខ	ទុកព្យាបាល
ដឹងគាំងកាល	ស្រោលជារោគ	យោគក្សេម ។

ផល ឯកត

រឿងព្រះនាងសាមាវតី

[ត]

លោក ប៊ិ-ប៉ូ ប្រែ-រៀបរៀង

លោក មានមោហៈជាគ្រឿងចងរឹត ច្រាកដ (ច្បាស់) ដូចជារូបគួរមនុស្សព្រោលមានឧបធិជាគ្រឿងចង គឺសេចក្តីងងឹតចាមភាមហើយច្រាកដដូចជាទៅជាប់មិនជាប់ សេចក្តីកង្វល់មិនមានដល់អ្នកឃើញ ។

កំលុះព្រះអង្គត្រាស់យ៉ាងនេះហើយ ទ្រង់សម្តែងធម៌ដូច្នេះថា តិក្ខ ពាំងឡាយ ! ធម្មតាពួកសត្វទៅត្រាច់ទៅក្នុងវដ្ត: ដែលមិនប្រមាទអស់កាលជានិច្ចរមែងធ្វើចុបកម្មដែរ ព្រោះហេតុនោះ កាលត្រាច់ទៅក្នុងវដ្ត: ទើបសោយសុខខ្លះទុក្ខខ្លះ ។

ព្រះពាលកាលទ្រង់ព្រះសណ្តាប់ដំណឹងថា "ភ្លើងឆេះដំណាក់ព្រះនាងសាមាវតី" គោះបីស្តេចយាងមកដោយរហ័ស ក៏នៅតែមិនទាន់កាល, លុះស្តេចដល់ហើយត្រាស់ប្រើឲ្យលត់ភ្លើងដែលទៅឆេះផ្ទះ ទ្រង់ព្រះតម្រេកនឹងសព្វយ៉ាងទាំងទ្រង់មានពួកអាមាត្យចាមភាម តង់រំពឹងគិតដល់គុណព្រះនាងសាមាវតី ទ្រង់ព្រះតម្រិះថា "កម្មនេះរបស់អ្នកណាអេះ?" ទ្រង់ក៏ជ្រាបដោយព្រះវិចារណញ្ញាថា "ប្រហែលជានាងមាគន្ធិយ ឲ្យអ្នកណាធ្វើ

ច្រាកដ» ហើយទ្រង់ព្រះចិន្តាថា «បើអញ្ចាសម្តុតឲ្យខ្លាចហើយសាកសួរ នាងមុខជាមិនច្រាប់សេចក្តីពិតទេ អញនឹងសាកសួរដោយឧបាយថ្នាក់ថ្នមចុះ» ហើយទ្រង់ត្រាស់នឹងពួកអាមាត្យថា «លោកទាំងឡាយមុនអំពីពេលនេះខ្ញុំឲ្យតែក្រោកឡើង ក៏បេះតែរង្គើសនៅជុំវិញ ព្រោះសាមាវតីចាំតែស្វែងរកឱកាសធ្វើប្រទូសក៉ាយដល់ខ្ញុំជានិច្ចតែម៉្យាង នាងធ្វើមរណៈទៅ ខ្ញុំមានសេចក្តីសប្បាយចិត្ត នឹងបាននៅដោយសេចក្តីសុខ ។

ពួកអាមាត្យ – សូមព្រះតេជៈកម្មនេះ អ្នកណាធ្វើហ្ន៎? ។

ព្រះពជា – ប្រហែលជាអ្នកណា ដែលមានសេចក្តីស្រឡាញ់ព្រោះយើងធ្វើ ។

ព្រះឯនាងមាគន្ធិយានៅគាល់ក្នុងទីដិត បានឮដូច្នោះហើយ (កំពុងតំនិតក្នុងព្រះពជោបាយ)ក៏ក្រាបទូលថា អ្នកណាដទៃមុខជាមិនអាចធ្វើបានទេ ខ្ញុំម្ចាស់ធ្វើណ៎ាព្រះអង្គ! ខ្ញុំម្ចាស់ប្រើលោកអាមាត្យឲ្យធ្វើ ។

ព្រះពជា – លើកតែនាងចេញ អ្នកដទៃដែលមានសេចក្តីស្រឡាញ់ក្នុងយើង មិនមានទេ, យើងជ្រុះថ្លា, ទៅ! យើងឲ្យព្រះដល់នាង ។ ប្រើឲ្យមនុស្សច្រាប់ពួកញាតិវង្សខ្ញុំមកចុះ ។

ព្រះនាងផ្តើដំណឹងទៅដល់ពួកញាតិថា ព្រះពជាទ្រង់ជ្រះថ្លាឲ្យព្រះដល់ខ្ញុំ ចូរមកជាប្រញាប់ចុះ ។

ព្រះពជាទ្រង់បង្គាប់ឲ្យធ្វើសក្ការៈដល់ពួកអ្នកដែលមកដល់ហើយ ។

សូម្បីអ្នកដែលមិនមែនជាញាតិវង្សព្រះនាងសោះ ឃើញដូច្នោះ ឧស្សាហ៍ឲ្យសំណូកមកជាមួយនឹងគេ ប្រាប់ថា "ពួកខ្ញុំជាញាតិព្រះនាងមាគន្ធិយា" ។ ព្រះពជាទ្រង់បង្គាប់ឲ្យចាប់ពួកនោះទ្រង់ឥស់ហើយ បង្គាប់ឲ្យដឹករណ្តៅក្នុងព្រះលានលួង ជម្រៅប្រមាណត្រឹមឆ្កឹតឲ្យកអ្នកទោសទាំងនោះទៅឲ្យអង្គុយក្នុងរណ្តៅហើយ បង្គាប់ឲ្យយកអាចម៍ដីលុប ខាងលើឲ្យពេញកយចំបើង ហើយបង្គាប់ឲ្យដុតភ្លើង ក្នុងវេលាភ្លើងឆេះរំលាត់ស្បែកហើយ បង្គាប់ឲ្យយកនង្គ័លដែកក្លែរឲ្យជាដុំធំដុំតូចចម្រៀកធំចម្រៀកតូច បង្គាប់ឲ្យយកកាំចិតយ៉ាងមុត អារពន្លះសាច់អំពីកាងកាយនាងមាគន្ធិយាជាដុំៗ ហើយបង្គាប់ឲ្យយកសាច់ទាំងនោះឡើងកាន់ដើងក្រានចម្អិនដោយប្រេង ជាដូចជាទំពួចឲ្យនាងនោះឯងស៊ី ។

កាលថ្ងៃមួយ ពួកកិក្ខុសន្ទនាគ្នាក្នុងធម្មសភាថា "សេចក្តីស្លាប់បែបរបស់ឧបាសិកាអ្នកសម្បូណ៌ដោយសទ្ធាដូច្នេះ មិនសមគួរសោះ" ។ ព្រះសាស្តាស្តេចមកហើយត្រាស់សួរថា "ម្នាលកិក្ខុទាំងឡាយ ពួកអ្នកអង្គុយប្រជុំគ្នាដោយសម្ភីអ្វីហ្នា?" កាលពួកកិក្ខុក្រាបទូលឲ្យទ្រង់ជ្រាបហើយត្រាស់ថា "កិក្ខុទាំងឡាយ ទុំមិនគួរដល់ពួកស្រីមានព្រះនាងសាមាវតីជាប្រធានពិតហើយ ប៉ុន្តែគួរណាស់ដល់កម្មដែលខ្លួនធ្វើទុកមកក្នុងពេលមុន ទើបពួកនាងបានហើយ" កិក្ខុទាំងនោះទូលអាពាធនាថា បពិត្រព្រះអង្គដ៏ចម្រើនពួកព្រះនាងធ្វើទុកមកដូចម្តេច សូមព្រះអង្គត្រាស់ប្រាប់ដល់ខ្ញុំព្រះទាំងឡាយ

ទើបទ្រង់នាំអតីតនិទានមកដូចតទៅនេះ ៖

ក្នុងអតីតកាល ព្រះចុងព្រហ្មទត្តសោយរាជ្យនៅក្នុងនគរពារាណសី ព្រះបច្ចេកពុទ្ធ៨អង្គ តែងទៅឆាន់ (អាហារកត្តិ) ក្នុងព្រះដំណាក់លួងជានិច្ច ។ ស្រីស្រាំរយនាក់ចម្រើលោក ។ ក្នុងព្រះបច្ចេកពុទ្ធ ៨ អង្គនោះ ៧ អង្គទៅព្រៃហិមពាន្តមួយអង្គគង់ចូលឈាន នៅក្នុងព្រៃសាតមួយកន្លែងជិតឆ្នេរស្ទឹង ។ គ្រាថ្ងៃមួយ ព្រះរាជា កាលព្រះបច្ចេកពុទ្ធទាំងឡាយទៅហើយ ទើបទ្រង់នាំស្ត្រីទាំងនោះ ទៅក្រសាលទឹកក្នុងស្ទឹង ។ ស្ត្រីទាំងនោះ លេងទឹកក្នុងស្ទឹងនោះពេញមួយថ្ងៃ ឡើងមកវិញ ត្រូវងាបៀតបៀនខ្លាំងនឹកចង់អាងក្តៅ ក៏ដើរទៅមក។ដោយពោលថា អ្នកទាំងឡាយគប្បីមើលទីសម្រាប់ចង្អាត់ក្តៅ (អាំង) របស់ពួកយើង ឃើញព្រៃសាតនោះហើយ ឈរចាមរាមដោយសម្គាល់ថា គំនរស្មៅ ហើយដុតក្តៅឡើង ។ កាលបើស្មៅឆេះសុះអស់ទៅឃើញព្រះបច្ចេកពុទ្ធ ទើបចរចាគ្នាថា ពួកយើងវិនាសហើយ។ ព្រះបច្ចេកពុទ្ធរបស់ព្រះរាជាក្តៅឆេះ ព្រះរាជាទ្រង់ជ្រាបមុខជាឲ្យពួកយើងវិនាសពុំខានយើងត្រូវគ្នើលោកឲ្យឆេះល្អ គំនរឆេះសុះអស់ទៅល្អជាង ត្រង់គ្នាក៏ជួយរើសឧសមកពីខាងនេះពីខាងនោះ ហើយតរជាគំនរលើព្រះបច្ចេកពុទ្ធនោះថែមទៀត ។ គំនរឧសធំណាស់ ។ លុះពួកនាងដុតលោក[illegible]ក៏នាំចេញគ្នាទៅដោយសម្គាល់ថា លោកនឹងឆេះសុះក្នុងឥឡូវនេះ ។ ពីមុន

ពួកនាងគ្មានចេតនាក្នែងដុតទេ ក្រោយមកទើបមានចេតនាកម្មសម្លាប់។ តែ
ចើតុកជាជនពាំងឡាយ ដញ្ជូនយកនូសមួយតាន់រះនេះមកដុតព្រះបច្ចេកពុទ្ធ
ខាងក្នុងសមាបត្តិដូច្នេះសូម្បីត្រឹមតែអាការគីចំហាយកំម្តៅក៏មិនអាចធ្វើបាន
ព្រោះហេតុនោះក្នុងថ្ងៃទី ៧ ព្រះបច្ចេកពុទ្ធនោះ ទើបក្រោកទៅតាមសេចក្តី
សប្បាយ ។ ស្ត្រីពាំងនោះ នេះក្នុងនរកអស់សែនឆ្នាំជាច្រើន ព្រោះធ្វើ
កម្មនោះ, កាលក្នែងនេះផ្ទុះនេះទៅជាមួយដែរ ដូចទំនងនេះអស់រយ
អត្តភាព ដោយវិបាកដ៏សេសសល់នកម្មនោះឯង ។ នេះជាបុព្វកម្ម
រមស់ស្រីមានឧនាងសាមាវតីជាប្រធាន ។

កាលព្រះសាស្តា ត្រាស់អតីតនិទានយ៉ាងនេះហើយ កិកុពាំងឡាយ
ទូលសួរព្រះសាស្តាតទៅទៀតថា បពិត្រព្រះអង្គដ៏ចម្រើន នាងខុជ្ជុត្តរ
គមដោយកម្មអ្វី មានបញ្ញាច្រើនដោយកម្មអ្វី សម្រេចព្រះសោតាបត្តិ-
ផលដោយកម្មអ្វី? ជាអ្នកចម្រើរបស់អ្នកដទៃដោយកម្មអ្វី? ។

ព្រះសាស្តា— កិកុពាំងឡាយ ក្នុងរដ្ឋកាល ព្រះរាជាអង្គនោះឯង
(ព្រះបាទព្រហ្មទត្ត) ព្រះបច្ចេកពុទ្ធមួយអង្គ (អង្គដែលត្រូវក្នែងនេះកង
រឿងមុន) ដូចគ្នា ស្ទៀងទាងគម្ពីរបេទ្ទិច ។ ទើបស្រីឧបដ្ឋាយិកាម្នាក់
ដណ្តប់សំពត់កម្ពលហើយកាន់ផ្តិលមាស (ធ្វើដូចលោកចីបាត្រ) ខ្នងគម
សម្តែងអាការគ្រាប់ភៅនៃព្រះបច្ចេកពុទ្ធនោះ(ធ្វើគ្រាប់) ពោលថា ព្រះ
បច្ចេកពុទ្ធបរិសុទ្ធ ពាំងឡាយ គ្រាប់ភៅយ៉ាងនេះនិងយ៉ាងនេះ ។ នាង

តមដោយផលនៃកម្មនោះ ។

កំកន់ថ្ងៃជាដំបូង ព្រះរាជា និមន្តឲ្យព្រះបច្ចេកពុទ្ធទាំងនោះគង់ក្នុងព្រះដំណាក់ហើយបង្គាប់ឲ្យរាប់ចាត្រ ឲ្យជាក់ច្បាស់ច្បាស់ថាត្រូវហើយថ្វាយ ។ កាលចាត្រភេញដោយច្បាស់ច្បាស់ស្រេច ព្រះបច្ចេកពុទ្ធទាំងឡាយ ចេះតែផ្ទាស់ប្តូរ (ដៃ) គាន់ ។ ស្រីនោះឃើញលោកធ្វើដូច្នោះ ទើបថ្វាយរង្វេលក្បុក ៨ របស់ខ្លួន ហើយពោលថា និមន្តលោកម្ចាស់ទាំងឡាយ ជាក់ចាត្រលើរង្វេលនេះហើយគាន់ទៅចុះ ។ ព្រះបច្ចេកពុទ្ធទាំងនោះ ធ្វើដូច្នោះហើយសម្ងំមើលនាង ។ នាងដឹងសេចក្តីប្រាថ្នារបស់ពួកលោកហើយ ក៏ពោលថា សេចក្តីត្រូវការដោយរង្វេលទាំងនេះមិនមានដល់ពួកខ្ញុំទេ , ព្រះករុណា ! រង្វេលទាំងនេះខ្ញុំលះបង់ដល់ព្រះករុណាម្ចាស់ទាំងឡាយតែម្តង និមន្តយកទៅចុះ ។ ព្រះបច្ចេកពុទ្ធទាំងនោះ ឆាន់ខ្លួចយកនិមន្តហើយៈទៅគាន់ញាក់ក្តុំនន្តមួលកៈ ។ សូម្បីសព្វថ្ងៃនេះ រង្វេលទាំងនោះក៏នៅមានដដែល (ឥតឆាត់បង់ឬខូចទេ) ។ នាងមានបញ្ញាច្រើនទ្រទ្រង់ព្រះត្រៃបិដកពុំកបាន ដោយផលនៃកម្មនោះ ។

នាងបានសម្រេចសោតាបត្តិផល ដោយវិបាកនៃការឧបដ្ឋាកដែលខ្លួនធ្វើដល់ពាក្យបច្ចេកពុទ្ធទាំងឡាយ ។ នេះជាបុព្វកម្មរបស់នាង កន្លងព្រះពុទ្ធ (មិនមានព្រះពុទ្ធ កើតឡើង) ។

កំពង់កាលនៃព្រះសម្មាសម្ពុទ្ធ ទ្រង់ព្រះនាមថា តិស្សៈ ជាតិសេដ្ឋ
នគរពារាណសីម្នាក់ ក្នុងវេលាមានស្រទោលដ៏ចម្រើន កំពាន់កញ្ចក់អង្គុយ
តែងខ្លួន ។ លំដាប់នោះ កិក្កនីទ័ណាស្រុតមួយរូប ដែលស្ថិតស្ថាល
របស់នាង ចានទៅដើម្បីឃើញនាង ។ មែនពិត កិក្កនីពាំងឡាយ
សូម្បីតែស់អាសវៈហើយ ក៏ច្រាំថាដើម្បីឃើញត្រកូលឧបដ្ឋាកក្នុងវេលា
រសៀល ។ ក្នុងខណៈនោះ ស្រីបម្រើណាម្នាក់ ក្នុងទីជិតសេដ្ឋីតា
ក៏មិនមាន ។ ទើបនាងនិយាយនឹងកិក្កនីនោះថា ខ្ញុំសំពះព្រះនាងម្ចាស់
សូមហុចប្រែងគ្រឿងប្រដាប់ខ្ទុះឲ្យដល់ខ្ញុំមួយរំពេច ។ ព្រះថេរីនឹកក្នុងចិត្ត
ថា បើអញមិនយកប្រែងនេះឲ្យដល់នាង ។ កំនឹងចងអាយាតក្នុងអញហើយ
នឹងទៅកើតក្នុងនរក បើយកឲ្យនាង, នឹងត្រូវទៅកើតជាអ្នកបម្រើរបស់អ្នក
ដទៃ ប៉ុន្តែការជាអ្នកបម្រើរបស់អ្នកដទៃ ល្អជាងការធ្លាក់ក្នុងនរក ។
ព្រះថេរីនោះ អាស្រ័យសេចក្តីអាណិតអាសូរកំបានយកប្រែងនោះឲ្យដល់
នាង ។ នាងខ្ជិលក្លាជាអ្នកបំរើបម្រើរបស់អ្នកដទៃដោយផលនៃកម្មនោះ ។

ថ្ងៃមួយទៀត កិក្កនីពាំងឡាយ សន្ធនាគ្នាក្នុងពេលធម៌ថា ស្ត្រីប្រុំរយ
មានព្រះនាងសាមាវតីជាប្រធាន ត្រូវភ្លើងដុតឆេះក្នុងដំណាក់ ពួកញាតិ
នាងមាគន្ធិយាត្រូវអណ្តាតភ្លើងចំបើងឆេះពីលើ ហើយត្រូវក្លែរដោយនង្គ័ល
ដែក, ដុំសាច់នាងមាគន្ធិយា ត្រូវចម្អិននឹងប្រែងដ៏ពុះខ្លាល ពួកណា
ហ្ន៎ ឈ្មោះថារស់នៅក្នុងលោកនេះ ពួកណាឈ្មោះថាស្លាប់ហើយ ។

ព្រះសាស្តាស្តេចមកដល់ហើយសួរថា តិត្ថិតាំងឡាយ ពួកអ្នកអង្គុយប្រជុំគ្នាដោយសន្ទីអ្វីកាលពួកតិត្ថិក្រាបទូលថា ដោយសន្ទីឈ្មោះនេះហើយត្រាស់ថា តិត្ថិតាំងឡាយ មនុស្សពួកណាមួយប្រមាទ ហើយមនុស្សពួកនោះ សូម្បីនៅរស់អស់រយឆ្នាំ ក៏ឈ្មោះថាស្លាប់ហើយតាំងអស់ មនុស្សពួកណាមិនប្រមាទ មនុស្សពួកនោះសូម្បីស្លាប់ហើយ ក៏ឈ្មោះថានៅរស់ពិត ព្រោះដូច្នោះ នាងមាគន្ធិយានៅរស់ក្តី ស្លាប់ហើយក្តី ក៏ឈ្មោះថាស្លាប់ហើយតាំងអស់ ស្រីប្រុសរួយនាក់មានឧបាសិកាសាមាវតីជាប្រធានសូម្បីស្លាប់ហើយ ក៏ឈ្មោះថានៅរស់ពិត ព្រោះថាអ្នកមិនប្រមាទ ឈ្មោះថាមិនស្លាប់ ហើយបានត្រាស់គាថាតាំងនេះ ថា :

អប្បមាទោ អមតំ បទំ បមាទោ មច្ចុនោ បទំ
អប្បមត្តា ន មីយន្តិ យេ បមត្តា យថា មតា ។
ឯតំ វិសេសតោ ញត្វា អប្បមាទម្ហិ បណ្ឌិតា
អប្បមាទេ បមោទន្តិ អរិយានំ គោចរេ រតា
តេ ឈាយិនោ សាតតិកា និច្চំ ទឬ្ហបរក្កមា
ផុសន្តិ ធីរា និព្ពានំ យោគក្ខេមំ អនុត្តរំ ។

សេចក្តីមិនប្រមាទ (១) ជាផ្លូវនៃសេចក្តីមិនស្លាប់ (២) សេចក្តី

---

១ បានដល់ការប្រុងប្រយ័ត្ន ពាក្យនេះជាឈ្មោះស្មារតីដែលបានតាំងប្រុងជានិច្ច ។
២ ពាក្យថាមិនស្លាប់ នេះជាឈ្មោះព្រះនិព្វានព្រោះព្រះនិព្វានមិនមានចាស់ មិនមានស្លាប់។

ប្រមាទ ជាផ្លូវនៃសេចក្តីស្លាប់, ជនទាំងឡាយ ដែលមិនប្រមាទហើយ ឈ្មោះថាមិនស្លាប់ ជនទាំងឡាយដែលប្រមាទហើយ(១) ពុកដូចជាមនុស្សស្លាប់ទៅហើយ ។ ពួកបណ្ឌិត ជ្រាបច្បាស់ដំណើរនេះដោយចំណែកគ្នា (ទើបបិតនៅ) ក្នុងសេចក្តីមិនប្រមាទ រីករាយក្នុងសេចក្តីមិនប្រមាទ, បណ្ឌិតទាំងនោះ ជាអ្នកត្រេកអរក្នុងធម៌ជាគោចរ(២)នៃអរិយបុគ្គលទាំងឡាយ មានការពិនិត្យជាប្រក្រតី មានព្យាយាមជាប់តគ្នា មានសេចក្តីប្រឹងប្រែងមាំមួនជានិច្ចជាអ្នកមានប្រាជ្ញា តែងតាល់ត្រូវនូវព្រះនិព្វានជាទីក្សេមក្សាន្តចាកយោគ ដែលជាគុណជាតដ៏ប្រសើរបំផុត ។

(នោមានត)



ប្រហែសបាត់ ប្រយ័ត្នគង់

ពីថា

ប្រហែសទាំងឲ្យបាត់ទ្រព្យធន
បាត់ជីពបាត់ជន្មប្រទេសជាតិ
ប្រយ័ត្នទើបគង់មិនបង់ខាត
អ្នកមានមារយាទត្រូវប្រយ័ត្ន

ផល ទិត

ឥណ្ឌូចិន និង បញ្ហាសន្តិភាព

លោក លី ជាមតេជ រៀបរៀង

បញ្ហាសង្គមបានចាប់ផ្តើមនៅគ្រប់ប្រទេសទាំងអស់ ទុសគ្នាតែត្រង់ ប្រទេសចម្រើនមានចំណែកផ្សេង គឺចាប់ខាងផលវិបាកដែលកើតពីសេចក្តីចម្រើននោះខ្លាំងភេក នាំឲ្យសង្គមលឿនហួសទុសរបៀបរបប; ឯប្រទេសដែលកំពុងកសាងខ្លួន ដូចប្រទេសយើងខ្មែរជាដើម មានចំណែកត្រង់ដែលនៅខ្វះខាតរចនាសម្ព័ន្ធខាងសង្គម តុំងាន់ចាន់រៀបរយ ត្រូវតាមចង្វាក់សេដ្ឋកិច្ច និងនយោបាយ ។ ក្នុងអត្ថបទនេះយើងសូមលើកយក តែបញ្ហាបែបទី ២ មកអធិប្បាយ ព្រោះមានទាក់ទងនឹងប្រទេសជាតិយើង ។

ចំពោះប្រទេសថ្មី ឬប្រទេសកំពុងរៀបចំ, បើគេពោលពីបញ្ហាសង្គមហើយ គេមិនអាចផ្តាច់បញ្ហានេះ ឲ្យផុតពីវប្បធម៌បានឡើយ ។

ហេតុអ្វី ក៏យើងយល់ដូច្នេះ ?

យើងឆ្លើយវិញថា: សង្គមកិច្ច និង វប្បធម៌ ជាគូគ្នា ដូចសេដ្ឋកិច្ច គូនឹងនយោបាយដែរ ឬថាទាំងបួននេះអាស្រ័យគ្នាទៅវិញទៅមកជាបណ្តាញប្រទាក់គ្នាក្នុងកិច្ចការសាងជាតិដូច្នេះផងក៏រឹតតែត្រូវ ។ ព្រោះថា នយោបាយនឹងរុងរឿងបាន តាល់តែពលរដ្ឋមានស្ថានជីវភាព

ខ្ពស់ល្អដែរ ហើយនឹងធ្វើឲ្យស្ថានជីវភាពខ្ពស់ទៅតាមតាល់តែពលរដ្ឋមាន
ចណីអាហារ គ្រឿងប្រើប្រាស់សង្វ័ណចរិកាវសមស្ថន ពោលគឺសេដ្ឋកិច្ច
ចម្រើន, មានការចេះដឹងជ្រៅជ្រះ អាចយល់ព្រឹត្តិការណ៍ស្រុកទេស
ចុះសភាស ស្គាលតម្លៃជាតិ មានស្មារតីជាតិពិតប្រាកដ ពោលគឺ
វប្បធម៌ចម្រើន និងមានជីវិតរស់នៅដោយមនោរម្យក្នុងប្រទេស ពោលគឺ
សង្គមកិច្ចចម្រើនដែរ ។ បើនិយាយឲ្យងាយស្តាប់ថា ទេយ្យាធិយ
សេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ គឺជាកង់ទាំងបួនសម្រាប់រថ ពោលគឺ
ប្រទេស ត្រូវតែបរទៅឲ្យបានស្រួលគ្នា ។ ប៉ុន្តែ ជាងរចនា តោង
តែគិតគូរអស្ចារ្យយកកង់ណាប្រើការអ្វី កង់ណាគួរបន្ថែមអ្វី ឲ្យធំតូច
វិលមុខ វិលក្រោយដែរ ។ ការគិតគូរនេះ អាស្រ័យទៅតាមស្ថានភាព
និងបញ្ហារបស់ស្រុកនីមួយៗផង ។

ចំពោះស្រុកចម្រើនថ្មី ឬកំពុងតែរីកចម្រើន គេច្រើនតែយកមធ្យោ-
បាយវប្បធម៌ ជួយដឹកមុខ ទាញអូសសង្គមកិច្ចឲ្យធាប់បានរៀបរយ ។
បើនិយាយម្យ៉ាងទៀតថា : គេបង្ហាត់បង្រៀនពលរដ្ឋឲ្យចេះដឹងឲ្យមាន
ស្មារតីជាតិ ឲ្យធាប់យល់បញ្ហា ឬខ្លួលយកបទបញ្ជាតិច្បាប់ណាមួយបាន
ធាប់ហ័សនិងត្រឹមត្រូវផង ។ បើពុំនោះទេ បទបញ្ជាតិផ្សេងៗ សេចក្តី
អំពាវនាវ និងប្រកាសផ្សេងៗ ពុំអាចមានឥទ្ធិពលជាប់លាប់បានក្នុងសន្ទាន

ចិត្តភាលវដ្ឋឡើ យ ដូចភាក្យខ្មែរយើងថា : ចាក់ទឹកលើក្បាលពា ឬផ្ទុំប៊ី ឲ្យក្រមើស្តាប់ ។

បើយើងគោលដល់ការបង្ហាត់បង្រៀននេះ យើងនឹកឃើញក្តាម ថា : សត្វថ្លៃ ការបង្ហាត់បង្រៀនកំពុងចម្រើន សាលារៀនជុះជាល, គ្មានក្មេងទំនេរនៅផ្ទះលេងដូចតាំដើមទេ គេទៅសាលាអស់ហើយ រហូតដល់ឧត្តមសិក្សា កំពុងប្រព្រឹត្តទៅយ៉ាងសកម្ម មានកើតជាបញ្ហាលឿនហួសអ្វីខ្លះទៅផងហើយ ។ ពិតមែនណាស់, ការចម្រើននេះ មិនអាចប្រកែកបានទេ ។ បើចម្រើនពិតៗ យ៉ាងហ្នឹង ម្តេចក៏យើញនៅមានស្មារតីជាតិស្អប់ស្តើងម្ល៉ះ ? ទំនងជាមានទៅខ្លះខាតអ្វីៗតែដំណឹង គួរតែពិចារណារកហេតុផលនេះផងចុះ ។

១- ចំពោះការបង្ហាត់បង្រៀនក្នុងថ្នាក់ គោងមានផែនការច្បាស់ជាគោលដៅ តើយើងនាំគ្នាទៅកាន់ទ្រង្វាយណា ? ហើយកុំរហ័សផ្ទាស់ប្តូរគោលដៅ មុនពេលដែលយើងពុំទាន់ចាំងបានទៅដល់ម្តងផង នោះ ។ រួចហើយ កុងគោលដៅនេះជាលំដាប់ថ្នាក់ គឺធ្វើជាកម្មវិធី, ឧបមាថា: នៅបឋមសិក្សាក្មេងអាយុប៉ុន្មាន ? សមឲ្យស្គាល់បញ្ហាជាតិប៉ុនណា ? មធ្យមសិក្សាក្មេងដំណាំ គួរឲ្យកើនដល់បញ្ហាជាតិត្រឹមណា? ដល់ឧត្តមសិក្សាចោទធំដំបញ្ហាជាតិដល់រឿងអ្វី ? ឯអ្នកណានាំត្រូវស្គាល់

ផ្លូវឱ្យច្បាស់ គោងដឹងនិងចេះប្រើវិធីដឹកនាំឱ្យប្រាកដ និយាយឱ្យចំ គឺស្គាល់ចញ្ចើជាតិទាំងនេះឯងឱ្យច្បាស់លាស់មុនសិស្សសិន ទើបណែនាំសិស្សទៅរួច ។

២— ចំពោះ ការផ្សាយ ឬបង្ហាត់បង្រៀនខាងក្រៅថ្នាក់វិញ នេះជាបញ្ហាខ្លះខ្លួលយណាស់ ហើយជាវិធីបង្ហាត់បង្រៀនប្រយោលមិនផ្ទាល់ (Indirect) ផង គឺថា អ្នកទទួលផល អាចទទួលដោយមិនដឹងខ្លួនក៏បានដែរ ។ តើការបង្ហាត់បង្រៀននេះ ធ្វើតាមអ្វីខ្លះ ? មានច្រើនមធ្យោបាយដែលអាចធ្វើបាន ដូចជា ៖

ក— តាមសៀវភៅចោះពុម្ពផ្សាយ : គោងធ្វើយ៉ាងណាឱ្យសម្បូណ៌សៀវភៅប្រលោមលោក ទស្សនាវដ្តី អត្ថាធិប្បាយ រឿងព្រេង រឿងប្រឌិត រឿងខ្លី រឿងល្ខោន កំណាព្យកាព្យឃ្លោង ។ល។ ហើយក្នុងនោះ សុទ្ធតែជាគ្រឿងពត់ហាត់បណ្តុះនិស្ស័យល្អៗផង ដៀសវាងរឿងពុល នាំឱ្យវង្វេងក្នុងគន្លា ។

ខ— តាម កុន-ល្ខោន : គោងតាក់តែងដំណើររឿងកុន រឿងល្ខោន ទៅតន័យបណ្តុះនិស្ស័យមនុស្សសិន ប៉ុន្តែមិនមែនជាទ្រឹស្តីសុទ្ធទេ មានកំប្លែង កំសត់ រំភើបលាយជាសិល្បៈផងដែរ កុំឱ្យអ្នកមើលធុញថប់ ហើយដឹងខ្លួនថាគេកំពុងតែអប់រំនោះ ។

គ— តាម វិទ្យុ-ទូរទស្សន៍ គោងមានកម្មវិធីហាយដោយប្រិច

ចង្អាតចង្រៃនផងដែរ ដៀសវាងកុំបង្ហាញរូប ឬរឿងបរទេសណាដែល គេចោទចង្អាខុសឆ្គាយពីយើង ដូចស្រុកជាកំង អាមេរិក អង់គ្លេស ដែលគេជាអារ្យៈទៅហើយនោះ ។ ផ្ទុយទៅវិញ ចំណុចរឿងគេ ត្រង់ណាដែលចោទស្រុចនឹងយើង ត្រូវតែច្រញ្ជាប់រកមកបង្ហាញគ្នីគ្នា យើងដែរ ។

ឃ— តាមសន្ទិស័ទ-ចាប់កថា : គោងមានក្រុមចលិតដើរពន្យល់ ណែនាំតាមមជ្ឈដ្ឋានដែលមានមនុស្សជាក្រុមៗ ដើម្បីឲ្យអ្នកស្រុក អ្នក អប់រំ អ្នកសិក្សា ជុះនិស្ស័យខាងស្មារតីជាតិ ខាងការចេះដឹងខ្ពស់ឡើង ចានសាយភាយឡើង ។ល។

ប្រមូលន័យទាំងនេះមក ចានសេចក្តីថា ការរៀបរយសង្គមឲ្យ មានលក្ខណៈល្អ គោងតែប្រើមធ្យោបាយវប្បធម៌ឲ្យលឿនទៅមុនជ្រាំ សិន, បើគិតតាមពេលវេលាន់ យ៉ាងហោចណាស់ក៏ប្រើពេលពីបីឆ្នាំទៅ ឆ្នាំសិន គឺគាស់កម្រឹតចេះដឹងរបស់អ្នកស្រុក ឲ្យជុះឡើងប្រហែលៗគ្នា (មិនចានស្មើគ្នាភ្លឹ) សឹមយើងចាប់ផ្តើមសង្គតិន័យសង្គមកិច្ចជាក្រោយ ។ ពង់អោះមិនមែនមានន័យតែសង្គមកិច្ចទេ គឺទៅទាំងន័យសេដ្ឋកិច្ច និង

នេះបាយផងជាមួយគ្នា ម្ល៉ោះហើយ ពេលនោះបញ្ហារៀបរយសង្គម
ក៏បានសេចក្តីបម្រើនសម្រាប់ថ្នាក់ខ្ពង់ខ្ពស់ ។ គ្រប់ចង្អាក់ខ្សែងជាមិនខាន ។

រួមសេចក្តីថា ការដោះស្រាយបញ្ហាសង្គម ស្ថិតនៅលើវប្បធម៌
មួយភាគធំ ហើយអាចខុសវប្បធម៌នេះ ជាមធ្យោបាយដោះស្រាយផង ។
បើដូច្នេះ ប្រទេសដែលកំពុងរៀបចំថ្មី មានប្រទេសខ្មែរយើងនេះជាដើម
គោងតែយកបញ្ហាផ្សាយវប្បធម៌ មកអនុវត្តឲ្យបានហ្មត់ចត់ គ្រប់ជ្រុង
ជ្រោយវប្បធម៌ ដើម្បីជួយរៀបចំសង្គមជាតិយើង ។

រឿងសាមកុក

ឧកញ៉ាវិបុលរាជសេនា ន្ - ភន

ប្រែ - រៀបរៀង

(ក)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ អ្នកវាងវៃឆ្លាសបើបានអាន
នឹងបេះខួរយកលចំណាន ទាំងមានសន្តានស្នេហាជាតិ

យូរ-អ៊ុន

សាមកុកខ្សែ ៨១

តាំងពីព្រះចៅចូសង តាំងសុម៉ាអ៊ីឡាជាទីមហាឧបរាជ ហែហ្វ៊ាប៉ាមិនព្រមចំណុះសុម៉ាអ៊ី កំកេណ្ឌពលបាន៣០០០ជិតលើកទៅវាយស្រុកឡុកអៀង ហែហ្វ៊ាប៉ាអស់ដៃរត់ទៅជួលព្រះចៅឡៅសៀន កៀងអ៊ុយនឹងហែហ្វ៊ាប៉ាលើកទ័ពទៅវាយស្រុកអេងដីរ ខូចខាតរេហ៍ពលច្រើនរិលទៅស្រុកហាន់គុងវិញ ព្រះចៅចូសងសោយរាជ្យបាន៣ឆ្នាំ (ព.ស.៣៩៤) សុម៉ាអ៊ីស្លាប់ ក្រោយពីគោះ១ឆ្នាំ ព្រះចៅស៊ុនគួនសុគតស៊ុនលៀងរាជឱរសឡើងសោយរាជ្យ ចាត់ដូតាត់កេកដាមេទ័ពលើកទៅវាយស្រុកវ៉ុយកុក ដូតាត់កេកដាក្បត់ ព្រះចៅស៊ុនលៀងឲ្យសម្លាប់ . កៀងអ៊ុយ ហែហ្វ៊ាប៉ាច្បាងនឹងទ័ពសុម៉ាស៊ូ ។

ព្រះចៅចូសងក៏តាំងសុម៉ាអ៊ីឲ្យជាទីមហាឧបរាជ មានគ្រឿងយស ៩ យ៉ាងតាមបណ្តាសក្តិ សុម៉ាអ៊ីទៅមិនព្រមទទួលងារព្រះចៅចូសងក៏ប្រ-

គល់ឲ្យខៀតដល់២គ្រា ទើបសុមាអ៊ុព្រមទទួលជារដាទីមហាឧបពាដទើប ព្រះចៅចូសងចង្គាមសុមាអ៊ុនិងបុត្រឱ្យនិយាយពាដការស្រុកខេស វេលា នោះសុមាអ៊ុកឱ្យស៊ើបរកចំកូពួកចូសងក្នុងស្រុកនោះយើញ ថា អស់ហើយ នៅសល់តែហៃហ្គីចាដែលជាសែស្រឡាយនៃចូសង ។ តាំងឱ្យធ្វើចៅ ហ្វាយស្រុកហងដីវ ចានត្រួតគ្រានិយាយពាដការលើអាណាខ្វែត្រតាំង ពួងដែលត្រូវឡើងខ្វែហងដីវ សុមាអ៊ុគិតថា : បើប្រសិនណាជាហៃហ្គី ចាដឹងថាចូសងជាអន្តពាយហើយ ក៏មិនលែងឡើយនឹងសងសឹកវិញមុខ ជារហ័ពលតាំងពួងនឹងចានសេចក្តីលំបាក គិតដូច្នោះហើយក៏ ចាត់ប្រើ តាន់ថាយឱ្យកាន់គ្រាព្រះតម្រាស់ចេញទៅយកខ្លួនហៃហ្គីចា" ។

ឯហៃហ្គីចា"ដឹងខ្លួនថា: ចូសងអន្តពាយហើយ ក៏ឱ្យគិតរឹតតែកូដលំខ្លួន ឯងណាស់ តែនៅគិតនឹងធ្វើការសងសឹកកែខ្លួន ទើបប្រមូលពាហាន ចានខ្ញុំ.ooo នាក់ហើយចាត់ចែងនាយទ័ពនាយកង ត្រៀមការដែលនឹង លើកទៅវាយក្រុងឡុកអៀងនោះគួយហ្គីយជាចៅហ្វាយស្រុកចាស់ដឹងការ កំនាំពាហានជាស្ងួគ្រចំកូពួករបស់ខ្លួនលើកទៅកំចាត់ហៃហ្គីចា" គួយហ្គីយ កាន់លំពែងដំរសេះបំផាយចូលទៅស្រែកដេរហៃហ្គីចា"ថា: ឯងនេះជាពូជ ព្រះពាដវង្ស គួរឬមកគិតក្បត់ផែនដី ហៃហ្គីចា"ក៏ស្រែកដេរថា: ឯងចាន តឹងបុណ្យដីដូនដីតារបស់អញ ក៏ចានទៅជាសុខដពាមក អាសុមាអ៊ុ វាគិតកំចាត់សែចូរចេញទាំងអស់ ម៉េចឯងទៅយើញថាក្អូខៀត ឯង នេះមិនមែនជាចកូពួកអាក្បត់ទេឬ ? គួយហ្គីយចានឮដូច្នោះក៏ខឹង

ខ្លាំងណាស់ ឡើងដល់សេះកំលាំងចូលទៅ ហៃហ្វិចាំកំពាំងចូលស្ទឹ
គ្នាបានប្រមាណ១០ក្មេង គួយហ្វិយថយកម្លាំងកំបំផាយសេះរត់ ហៃហ្វិ
ចា"បានចំណាប់កំដៃញដិតតាមទៅ ។

ឯតាន់ថាយដែលសុម៉ាអ៊ីប្រើឱ្យនាំគាហានកាន់សំបុត្រទៅហៅខ្លួន
ហៃហ្វិចា"នោះ ទទួលលើកពលទៅប្រទះកំដីធំថា ហៃហ្វិចា"ទឹងគួយហ្វិយ
ចំពុងតវិទ្វិតបៈគ្នា កំលើកពលយោធាវាយប្រសព្វចូលទៅព្រួតថែមទៀត
ហៃហ្វិយចា"ឃើញថាទឹងតទល់ពុំឈ្នះ ព្រោះតាន់ថាយវាយខ្លួចំពីមុខ
ចូលមកសម្លាប់ពួកពលច្រើនណាស់ កំប្រះត្រឡប់នាំគាហានដែលសល់
ពីស្លាប់នោះរត់ចូលទៅស្រុកហាន់តុង ស្វាមីកំពុងចូលធ្វើជាខ្ញុំព្រះចៅ
ឡៅសៀន, ពួកនាយគយកំឱ្យអ្នកល្បាតចូលទៅប្តឹងកៀងអ៊ុយដែលឈរ
ក្សាស្រុកហាន់តុង, កៀងអ៊ុយសង្ស័យណាស់ ទើបប្រើគាហានឱ្យ
ចេញទៅដេញដោលយកសេចក្តីពិត, លុះបានសេចក្តីពិតហើយ កំនាំ
ហៃហ្វិចា"ចូលទៅជួបនឹងកៀងអ៊ុយ, ធ្វើសេចក្តីគំនាបគ្នាហើយ ហៃ-
ហ្វិចា"កំយំ, ហើយកំណាំមាហេតុរឿងដែលក្តៅក្រហាយមិនសប្បាយ
ចិត្តនឹងសុម៉ាអ៊ីសម្លាបចូសនោះគ្រប់ប្រការ, កៀងអ៊ុយស្តាប់ហើយឆ្លើយ
ថា : អ្នកមកដោយផ្លូវឆ្ងាយណាស, ដែលគាំងចិត្តជាស្វាមីកំពុងជាខ្ញុំព្រះ
ចៅឡៅសៀនគ្រានេះ ឃើញថាមិនបង់ប្រយោជន៍ទេ, ព្រោះព្រះចៅ
ឡៅសៀនពេញជាពួជព្រះកងវង្សក្សត្រិយ៍, និយាយហើយ កំហៅហៃ

ហ៊ីប៉ាចរិកាតអាហារគ្នាជាមួយគ្នាហើយសួរថា : អាសុម៉ាអ៊ីអាពុកនឹងកូន
ពន្យាយពីការស្រុកខេសនោះ តើអ្នកបានឮព័ត៌មានធ្វើដាំចំរូងចំកស់
ដល់ស្រុកសែឈួនដែរឬទេ ? ។

ហៃហ៊ីប៉ាឆ្លើយថា : អាកញ្ញាស់សត្រូវផែនដីនោះ; តាំងពីខ្ញុំឃើញ
ពាក្យគិតតែនឹងចេញក្បត់ព្រះចៅចូសឯងដរាប តែខ្លាមិនទាន់សម្រេចតាម
គំនិតរបស់ពាក្យនោះឃើញថាពាក់ព័ន្ធនឹងគិតការដល់ស្រុកខេសផងមិនទាន់បាន ,
ខ្ញុំសំឡឹងមើលឃើញមនុស្សល្អ។ មានសតិបញ្ញានាំបានពលរេហ៍ច្រើនមាន
២ នាក់, បើសុម៉ាអ៊ីប្រើមើធ្វើការសង្គ្រាមស្រុកតាំងតាំង និងស្រុកសែ-
ឈួន តែគង់នឹងអន្តរាយដោយថ្វីដៃមនុស្សនោះ, កៀងអ៊ីយសួរថា:
តាំង ២ នាក់នោះឈ្មោះអ្វីខ្លះ ? ។

ហៃហ៊ីប៉ាឆ្លើយថា : ម្នាក់ឈ្មោះចុងហោយ ជាបុត្រចុងហ៊ីវពួក
ស្រុកអេងដីវ កាលអាយុបាន ៧ ខួប បិតានាំមើគាល់ព្រះចៅចោគីវ
ឲ្យលេងក្បែរថ្ងាយទ្រង់ព្រះសណ្តាប់ ចុងហោយឆ្លៀវឆ្លាតណាស់ថា
ថាយ ទុកមួយរំពេចព្រះចៅចោគីតំទ្រង់ក្រោសប្រាណាស់, លុះ
ធំឡើងបិតាគីប្រដៅឲ្យដឹងតម្រាពីជ័យសង្គ្រាម, ហើយបានសិក្សា
ចំណាត្រកងសិល្បសាស្ត្រសម្រាប់ការហាន កាលព្រះចៅចោគីទិវង្គតមើ
គឺបានឡើងជាទីសួលឯងចៅក្រុមអាល័ក្ស រហូតមកដល់ផែនដីព្រះចៅ

ចួយ៉ាយ, សុម៉ាអ៊ុនធីងចៀរចេកំកោតក្រែងរែងខ្លាចចុងហោយណាស់, នៅមានម្នាក់ទៀតឈ្មោះតេងាំយ ជាបុត្រពួកស្រុកធីអៀងបិតាស្លាប់ចោលតូច ចិត្តគាហានហ៊ានក្លា ចូលចិត្តចងធ្លៅមេទ័ពមេកង, ស្ទូងរកវិជ្ជាការពិជ័យសង្គ្រាមស្ទាញស្ទាត់ណាស់, សុម៉ាអ៊ុកឹកប់អាន ហើយតាំងឲ្យជាទីទាំពាន់កុនជើ ស្រដីត្រួតត្រាលើគាហានទាំងពួង, ឈ្មោះទាំង ២ នាក់នេះ ប្រាកដជាមនុស្សស្រស់ស្រួចពិតណាស់ ។

អៀងអ៊ុយបានឮដូច្នោះក៏អស់សំណើចហើយថា : ខ្ញុំពីគ្រោះម៉ែលភៅយើញថា អាក្មេងទាំង ២ នាក់នេះ ថ្លើដែរពន់ធឹងមកតស៊ូនឹងខ្ញុំមិនបានទេ ថាហើយក៏នាំហៃហ៊ូប៉ាចូលភៅគាល់ព្រះចៅឡៅសៀនក្នុងស្រុកសែឈួន ថ្វាយបង្គំហើយទូលថា: សុម៉ាអ៊ូវរ៉ះគិតកម្ចាត់ចូសងចេញ ហើយរាន់ធឹងមកធ្វើអន្តរាយ ដល់ហៃហ៊ូប៉ា ។ ក៏រត់ចូលមកស្នាមក័ត្តិថ្វាយខ្លួនជាខ្ញុំព្រះអង្គ, ឯព្រះចៅចូហង៉ក៏នៅខ្ជិសេចក្តីណាស់, ទូលព្រះបង្គំជាខ្ញុំឃើញសុម៉ាអ៊ីអាពុកនិងកូនវាធ្វើការយ៉ាងនេះ នឹងដណ្តើមយកពាជសម្បត្តិជាប្រាកដ, ទូលព្រះបង្គំជាខ្ញុំពិគ្រោះមើលឃើញថា ស្រុកវ៉ុយកុកវែលនេះ មុខជានឹងរៀរភេយថយភៅហើយ, ទូលព្រះបង្គំជាខ្ញុំក្សាស្រុកហាន់តុងមកក៏យូរណាស់ហើយ ស្រូវអង្ករសៀវអាហារក៏ចម្រើនបរិបូណ៌, ទាំងរេហ៍ពលសេនាគាហានក៏មានកម្លាំងប្រៃនណាស់ហើយ

ទូលព្រះបង្គំជាខ្ញុំនឹងសុំអាសាចេញទៅវាយយកស្រុកវុយកុកថ្វាយ ជាព្រះ
រាជអាណាខែត្រនៃព្រះអង្គ និងតាំងឲ្យហែហ្វ៊ូវជានាយទ័ពមុខចេញទៅ
ធ្វើការ មុខជានឹងបានសម្រេចតាមប្រាថ្នាជាប្រាកដ ។

ហ៊ុយវុយសេនាបតីធំធ្វើយ : ខៀវអ៊ូននិងតាំងអ៊ុនមានសតិបញ្ញា
មានច្បាំងខ្លាំងពូកែ ជាខាហានឯករបស់យើងក៏ស្លាប់អស់ទៅហើយ
ក្នុងស្រុកយើងសព្វថ្ងៃនេះអស់មានមនុស្សល្អសោះ នឹងលើកទ័ពទៅក្នុង
ឥឡូវនេះឃើញថាមុខជាមិនសម្រេចការ, ហេតុនេះគួរពិចារណាកុំអាល
ស្រាលរហ័ស ត្រូវតែគិតឲ្យឃើញផ្លូវប្រយោជន៍ច្បាស់ហើយសឹមលើក
ទៅធ្វើការ, ខៀងអ៊ុយធ្វើយថា : លោកមានប្រសាសន៍នោះ ខ្ញុំបាទ
មិនយល់ឃើញផងសោះ, ថ្ងៃ-យប់-វ១ និង ឆ្នាំ ចេះតែកន្ធឹងលឿនទៅ
មិននៅបង្អង់ឈប់ឲ្យយើងទេ នឹងរង់រេចាំឲ្យបានការ ក៏នឹងខូចវេលា
ខទេទៅ លោកចាំពេលណាទើបបានការនឹងលើកទៅនោះសោត,
ហ៊ុយវុយតបថា : បុរាណមានពោលទុកមកថា មេទ័ពមេកងដែលនឹង
គិតធ្វើការសង្គ្រាមនោះ គប្បីឲ្យពិគ្រោះមើលកម្លាំងនិងសេចក្តីត្រិះរិះការ
ហើយទ្រឹងសេនាខាហាន ទ្វារគ្រឿងសស្ត្រាវុធរបស់ខ្លួននឹងសត្រូវ បើ
មើលទៅឃើញថាមានដំណើរហើយទើបធ្វើការ, បើមិនទាន់ស្គាល់ការ
ស្រាលធ្ងន់ទេមិនគួរទៅ យ៉ាងដូចអ្នកគិតទៅធ្វើការគ្រានេះ ពោះបីកាល
មហាឧបរាជដែលលោកជាមនុស្សមានសតិបញ្ញាស្រួច មានដីវិតរស់

នៅឡើយ ក៏លោកមិនទាន់អាចធ្វើទេ ។

កៀងអ៊ុយថា : ខ្ញុំបាទនៅក្នុងស្រុកហាន់តុងនោះ ក៏បានពាក្រាំ ពួកស្រុកលើ ក្នុងស្រុកកៀងឃើញថា មុខជាវាទំងមកចំណុះចុះចូលខ្ញុំ បាទទាំងអស់, បើខ្ញុំបាទនឹងលើកទ័ពចេញធ្វើការគ្រានោះ នឹងចេញ សំបុត្រឲ្យទៅបញ្ចុះបញ្ចូលពួកស្រុកកៀង គង់នឹងមកចូលពុំខាន, ខ្ញុំ បាទនឹងជាក់ពួកនោះឲ្យជាទាហានជួន, បើនៅមិនទាន់បានស្រុកវុយកុក ទេ, ក៏គង់នឹងធ្វើអាណាខែត្រទាំងពួនដែលឡើងស្រុកវុយកុកនោះ ឲ្យ នៅក្នុងកណ្តាប់ដៃខ្ញុំបាទឲ្យបាន, ព្រះចៅឡៅសៀនត្រាស់ថា : បើ អ្នកនឹងយកអាសាយើងទៅវាយស្រុកវុយកុកគ្រានេះ អ្នកចូរត្រិះរិះឲ្យល្អិត សិន ដើម្បីរៀបចំម្រុងជើងការឲ្យសេនាទាហានធ្វើការឲ្យពេញដៃយក ជ័យជំនះឲ្យបាន ទើបនឹងមិនចង់ប្រឈឹបនឹងសត្រូវ ។

កៀងអ៊ុយក៏ក្រាបបង្គំលាទាំងហែហ្ហឹប៉ាត្រឡប់ទៅស្រុកហាន់តុងវិញ , លុះទៅដល់ហើយ ក៏ចាត់ចម្រើឲ្យនាំសំបុត្រចេញទៅបញ្ចុះបញ្ចូលស្រុក កៀង ហើយទើបប្រឹក្សាគ្នាថា យើងនឹងឲ្យកុអាន់និងលីហុំម ទាំង ២ នាក់នេះ នាំទាហាន ១៥.០០០ លើកទៅវាយគួយហ្ហួយចៅហ្វាយស្រុក អេងជីវ ឲ្យទៅតាំងបន្ទាយនៅភ្នំកុកសាន់ជា ២ បន្ទាយធ្វើការបណ្តោះ អាសន្ន ហើយសឹមយើងលើកទ័ពតាមទៅជាក្រោយ លុះប្រឹក្សាគ្នា ហើយ ទើបចាត់ចែងរៀបចំសេះនិងគ្រឿងសស្ត្រាវុធស្រូវអង្ករស្បៀង

អាហារ ហើយចាត់ការកុអាន់និងលីហ៊ុមលើកទ័ពទៅ, លុះទៅដល់ភ្នំ
កុកសាន់ក៏ញែកទាហានចេញជា ២ កង ក្នុង ១ កង ៧.៥០០ តាំងបន្ទាយ
ព័ទ្ធភ្នំកុកសាន់, កុអាន់តាំងនៅទិសខាងកើត, លីហ៊ុមនៅទិសខាងលិច ។

ទាហានកងត្រវែលក៏ចាត់ចម្រើសេះឲ្យបួលទៅប្តឹងដល់គួយហ្គួយថា
កៀងអ៊ុយស្រុកហាន់តុងឲ្យលើកកងទ័ពមកតាំងព័ទ្ធភ្នំកុកសាន់ តាំង
បន្ទាយ ២ គួយហ្គួយដឹងដូច្នោះ ទើបចាត់ចម្រើសេះឲ្យទាំសំបុត្របួលទៅ
ប្តឹងជាផ្លូវពដការដល់ស្រុកឡុកអៀង, ឯតាន់ថាយដែលកាន់សំបុត្រ
ចេញទៅហៅខ្លួនហៃហ៊ីប៉ា" ក៏ទៅមិនទាន់ត្រឡប់វិលបួលទៅក្រុងវិញ,
គួយហ្គួយឲ្យតាន់ថាយនាំទាហាន ៥០.០០០ លើកពលទៅតល់ក៏លើក
ចេញពីបន្ទាយ លុះឃើញពលតាន់ថាយច្រើនណាស់ និងតល់ពុំបាន
ក៏នាំទាហានត្រឡប់បួលបន្ទាយវិញ ឯតាន់ថាយក៏ឲ្យទាហានតាំងបន្ទាយ
ព័ទ្ធទុកតាំង ២ បន្ទាយ ហើយបំបែកកងទ័ពឲ្យទៅស្កាត់ដើមផ្លូវកាត់ប្រចាំ
ផ្លូ, ឯកុអាន់និងលីហ៊ុមនៅបន្ទាយ ដាច់អស់ស្រូវអង្ករសម្រាប់អាហារ ។

គួយហ្គួយលើកកងទ័ពចេញទៅ ឃើញតាន់ថាយព័ទ្ធសត្រូវទុក
បានដូច្នោះក៏ត្រេកអរណាស់ ទើបបួលទៅក្នុងបន្ទាយហើយនិយាយនឹង
តាន់ថាយថា : ពួកសត្រូវនេះដាច់បាយទឹកអស់ហើយ, បានអាស្រ័យ
តែទឹកជ្រោះអូរដែលហូរចុះពីលើភ្នំ បើយើងរិះគិតបិទខប់អូរជ្រោះអស
ហើយ ទឹកក៏ហូរចុះទៅគ្មាន សត្រូវអត់ទឹកហើយគង់ទំនងយកម្ចាំងចុះ

យើងនឹងចូលកាប់យកបន្លាយកំសឹងបានដោយងាយ, តាន់ថាយយល់យើញថាត្រូវណាស់ ក៏ប្រមូលពាហានឲ្យទៅចំខមាត់អូរនោះអស់ ។

លុះហ៊ុមយើញពាហានអត់ទឹកជាច់អស់ ក៏នាំពាហានចេញពីបន្លាយនិងទៅដងទឹក ពួកពាហានតាន់ថាយក៏លើកគ្នាស្អាត់ផ្លូវ, លុះហ៊ុមយើញលើសកំឡាំងនាំពាហានចូលទៅក្នុងបន្លាយ, នោះកុអាន់យើញពាហានស្រេកទឹកណាស់ ក៏លើកចេញទៅហើយនាំពាំងលុះហ៊ុមឲ្យលើកទៅជា ២ កង ចំណងនឹងទៅដងទឹក នោះពាហានតាន់ថាយវាយស្អាត់ទុកនឹងចេញទៅមិនបាន ក៏នាំគ្នាត្រឡប់មកបន្លាយវិញ, ឯលុះហ៊ុមក៏ប្រឹក្សាថា: បើនឹងស្ងៀមនៅដូច្នេះក៏ពុំស្រួល ត្រូវតែនាំគ្នារត់ចេញទៅកុអាន់មិនព្រមចេញ ឆ្លើយថា : ដែលនឹងលើកទ័ពត្រឡប់ទៅនោះហើយ, បើនឹងនៅដូច្នេះដូចជានាំគ្នាមកស្តាប់អសារឥតការពាំងអស់, បើអ្នកមិនទៅក៏រាល់ចុះ, យើងត្រូវតែទៅ, ថាហើយក៏បបួលពាហានទៅប្រមាណ ៤០ នាក់ លុះវេលាកណ្តាលយប់ក៏រួយទំលាយចេញទៅ ពាហានតាន់ថាយក៏ចេញស្អាត់ទុក ហើយសម្លាប់ពួកនោះស្លាប់ពាំងអស់ ។

ឯខ្លួនលុះហ៊ុមត្រូវអាវុធរបួសពិការជាច្រើនអន្ទើរតែចេញទៅបាន ដើរសេះទៅតាមដងភ្នំសេសាន វេលាកណ្តាលយប់ងងឹតខ្លាំងណាស់ មិនដឹងកន្លែងណាមានទឹកផឹកសោះ ព្រោះស្រេកទឹកណាស់ បានលិទ្ធតែជាតិទឹកសន្សើមដែលជាប់ទឹងស្លឹកឈើ-ស្មៅ អត់អាហារអស់រាងៗ ២ យប់

២ ថ្ងៃ ទើបទៅប្រទះនឹងកងទ័ពកៀងអ៊ុយ ចុះពីលើសេះហើយក៏ចូលទៅរកកៀងអ៊ុយ ហើយពណិនារឿងក៏វៃទាំងពួងឲ្យស្តាប់កៀងអ៊ុយ មិនមែនថាខ្ញុំនិងព្រួងើយកន្តើយទេ គឺរៀបកងទ័ពហើយស្រូតមក ដែលយូរយ៉ាងនេះ ព្រោះចាំកងទ័ពស្រុកកៀងមិនឃើញមកឡើយ ថាហើយក៏ឲ្យតាហានទាំង២នាក់ទៅក្បាលជួសខ្លួនឯស្រុកសែឈួន កៀងអ៊ុយនិយាយនិងវៃហ្គីចាំថាអ៊ុយ យើងបង្អង់ចាំកងទ័ពស្រុកកៀងអ៊ុយយូរណាស់ហើយក៏មិនឃើញមកឡើយ ឥឡូវកងទ័ពដែលឲ្យលើកទៅតាំងនៅទីក្នុកុកសាន់នោះ មុខជាអន្តរាយនឹងសត្រូវអស់ហើយ យើងនិងរិះគិតប្រការម្តេច ទើបនឹងកែយកដំយល់ដំនេះសឹកសត្រូវបាន ។

វៃហ្គីចាំថា ខ្ញុំបានយល់ឃើញថាកងទ័ពស្រុកអេងជីវ លើកចេញទៅពីខ្នងលីហ៊ុមកុអាន់ជាប់ហើយ បើយើងលើកទៅចូលតាមផ្លូវភ្នំឆ្ងីវថោសាន់ ក្រោយស្រុកអេងជីវវាយចូលទៅ នោះគួរយ៉ាយ តាន់ថាយ ក៏និងលើកទ័ពត្រឡប់មកតនឹងយើង កងទ័ពកុអាន់ក៏មិនបានអន្តរាយ កៀនអ៊ុយបានឮដូច្នោះក៏មានសេចក្តីត្រេកអរពន់ប្រមាណណាស់ថាដែលអ្នកគិតឧបាយយ៉ាងនេះ យើញថានឹងមានជ័យជំនះជាប្រាកដណាស់ ចូរអ្នកស្រូតរួតគិតលើកកងទ័ពចេញទៅឲ្យទាន់ការចុះ ។

ខណៈនោះ តាន់ថាយប្រឹក្សានឹងគួយហ្គួយថា លីហ៊ុមរួតរត់ចេញខ្លួនទៅបានហើយ មុខជាប្រាប់កៀងអ៊ុយ ។ គង់ទឹងដឹងដំណឹងថា យើង

លើកកងទ័ពមកព័ទ្ធទៅទីនេះ មុខជាលើកទ័ពវាយចូលមកតាមផ្លូវក្នុងនីវ៉ៅសាន់ សូមឲ្យអ្នកលើកទ័ពទៅចាំស្កាត់ទៅដំបន់ខៀវស៊ុយជាដើម កុំឲ្យប្រចាំជួនបាន, ខ្ញុំបាទនឹងលើកទ័ពទៅវាយកៀងអ៊ុយដែលវាយសង្កត់ចូលមកដល់ក្នុងនីវ៉ៅសាន់នោះ បើកៀងអ៊ុយដឹងថា យើងស្កាត់កាត់ផ្លូវប្រចាំជួនបានហើយ គង់ទឹងមានព្រួយភ័យបែកទៅជាប្រាកដ: គួយហ្ជីយយល់ឃើញត្រូវ ក៏លើកទ័ពចេញទៅតាមដែលគិតគ្នា ។

វេលានោះ, ពួកកងល្បាតចាត់បម្រើសេះឲ្យទៅប្រាប់កៀងអ៊ុយថា កងទ័ពស្រុកអេងជីវ៉ៅលើកចេញមកច្រើនណាស់, កៀងអ៊ុយក៏ឡើងសេះកាន់លំពែងស្រួតនាំទាហានចេញទៅតទល់, គាថាយក្រឡេកឃើញកៀងអ៊ុយក៏ស្រែកថា អញដឹងហើយថា ឯងនឹងលើកទ័ពវាងចូលទៅផ្លូវនេះ បានជាអញលើកមកចាំទទួល ថាហើយក៏ចរនេះកាំជាវចូលប្រយុទ្ធគ្នា. កៀងអ៊ុយកំលំពែងចូលច្បាំងនឹងគាន់ថាយបាន ៣ ក្ខេង, គាន់ថាយក៏ប្រះវត់នាំទាហានឡើងទៅលើក្នុងនីវ៉ៅសាន់, កៀងអ៊ុយមិនតាមទៅឯង ទៅ តាំងបន្ទាយទៅដើងភ្នំនោះ ហើយទាហានទៅស្រែកដេរបញ្ជឹចិត្តគាន់ថាយឲ្យចុះមកតស៊ូគ្នា, គាន់ថាយក៏លើកទាហានចុះមកច្បាំងតនឹងកៀងអ៊ុយជាច្រើនវេលាមិនចាញ់មិនឈ្នះ ។

ហែហ្ជីប៉ានិយាយនឹងកៀងអ៊ុយថា : យើងច្បាំងគ្នាក៏ច្រើនវេលាណាស់ ហើយមិនទាន់ចាញ់ឈ្នះគ្នា នឹងទៅយូរណាស់ក៏មិនបាន ក្រែង

សត្រូវនឹងគិតកលឧបាយប្រទូសក៉ាយយើង សុំឲ្យលោកលាទ័ពថយទៅសិនចុះ ដើម្បីយើងនឹងគិតកលឧបាយដទៃយកជ័យជំនះវិញឲ្យបាន ។

មានពួកលក្ខាតមកប្រាប់ថា : គួយហ្គីយលើកកងទ័ពទៅស្ពាត់នៅដើមផ្លូវហើយ, មុខជាយើងនឹងបញ្ជូនពួកប្រចាំជួនមិនស្រួលទេ, កៀងអ៊ុយព្រួយចិត្តណាស់ ក៏ឲ្យហៅហ្គីប៉ាំសាយកងទ័ពទៅសិន , កៀងអ៊ុយក៏លើកទ័ពចេញទៅជាក្រោយ, ឯខ្លួនគាន់ថាយឲ្យដឹងថា : កៀងអ៊ុយរំសាយទ័ពទៅហើយក៏ចាត់មេទ័ពមេកងចេញជា ៥ កង ឲ្យដេញវាយខ្លួចំពីក្រោយចណ្តាយទៅម្ខាងមួយកង, ឯខ្លួនគាន់ថាយក៏លើកតាមទៅជាក្រោយ ។

ខណៈនោះ, កៀងអ៊ុយក៏ទៅកំងចុងទ័ពពីក្រោយ, គាន់ថាយក៏ពារំលាយចូលទៅមិនបាន ត្រឡប់នាំទាហានវាត់ចេញ, គួយហ្គីយក៏លើកទាហានស្ពាត់ ឯកៀងអ៊ុយក៏ព្រួតចោមរាយរំលាយចេញបានតែទាហានកៀងអ៊ុយស្លាប់ច្រើនណាស់ ដែលសល់នៅនោះតិចជាងស្លាប់ទៅទៀត កៀងអ៊ុយនាំទាហានទៅប្រទះនិងកងទ័ពសុម៉ាស៊ូ ជាបុត្រសុម៉ាអ៊ី ។

កាលដំបូង កៀងអ៊ុយលើកទ័ពទៅវាយស្រុកអេងជី ទើបគួយហ្គីយឲ្យមានសំបុត្រទៅសុំកងទ័ពសុម៉ាអ៊ី ក៏ចាត់ប្រើសុម៉ាស៊ូជាបុត្រលើកទ័ពមកជាពល ៩០.០០០ សុម៉ាស៊ូដឹងថា កៀងអ៊ុយចាំងនឹងគួយហ្គីយ

ហើយ កំលើកចំពាក់ស្កាត់នៅដើមផ្លូវ សុម៉ាស៊ូនេះ ទ្រង់ទ្រាយមុខ
មូល ចបូរមាត់ក្រាស់ ស្មឹកត្រចៀកយារធំ ក្អែកខាងស្តាំមានពកធំទំ.
ហាំប៉ុនផ្លែប៉ែន មានពេម ៤០ ឬ ៥០ សរសៃ លុះក្រឡេកទៅឃើញ
កងចំពាក៏ងអ៊ុយលើកមក កំឡើងសេះកំដារចេញទៅ ។

ក៏ងអ៊ុយក្រឡេកឃើញទឹងណាស់ ស្រែកថា : អាក្មេងព្រមក
ប៉ុណ្ណោះ គួរឬអង់អាចមកតទឹងអញ ថាហើយក៏ចំដាយសេះចូលទៅ
ប្រយុទ្ធគ្នាទឹងសុម៉ាស៊ូៗ បាន ៣ ក្មេងឃើញលើសកម្លាំងក៏នាំគាហានថយ
រត់ទៅ ក៏ងអ៊ុយក៏នាំគាហានទៅដល់ទីគយហែប៉ែនគួនដែលជាគយ
ស្រុកសែឈួន គាហានបើកទ្វារទទួលក៏ងអ៊ុយចូលទៅហើយក៏ចិទ្ធាប់
ទៅវិញ សុម៉ាស៊ូត្រឡប់តាមទៅក៏ឲ្យគាហានចំណាយទ្វារ គាលខុងចេង
ជិតទឹងស្លាប់នោះ បានប្រដៅគាហានឲ្យរៀនបាញ់ធ្នូសំដៅឈើក្រាស់
មនុស្សម្នាក់បាញ់ម្តងបាន ១០ព្រួញ នោះគាហានដែលនៅលើសើន
តំពែងក៏បាញ់ធ្នូចម្រុះបើដូចគ្រាប់ភ្លៀង ត្រូវគាហានសុម៉ាស៊ូស្លាប់ច្រើន
ណាស់ សុម៉ាស៊ូខូចខាតពលច្រើនណាស់ ក៏លើកថយទីពត្រឡប់ទៅ
វិញ ។

ឯគុអាន់ដែលក្បាលថ្នាយនៅស្បែកភ្នំកុកសាន់ លុះលីហ៊ុមរត់ទៅ
ហើយក៏រង់ចាំមើលកងទ័ពជួនមិនឃើញ ពួកគាហានដាច់ទឹកខ្លាំងណាស់
លុះទឹងហែកចំណាយចេញក៏មិនរួច ទើបបើកទ្វារបន្ទាយនាំគាហាន

ចេញគំនាប់ចុះចូលនៅទឹងគួយហ្ហ៊ីយ, ឯកៀនអ៊ុយលើកកងទ័ពទៅធ្វើការ
គ្រានោះ ខូចខាតទាហានច្រើនណាស់, លុះត្រឡប់ទៅស្រុកហាន់តុង
ក៏ឲ្យសមសែមដួសជុលកំពែង និងសើនចន្លាយដែលបាក់បែកឲ្យមាំមួន
ឡើងវិញ, សុម៉ាស៊ូក៏លើកទ័ពត្រឡប់ទៅស្រុកឡុកអៀង ហើយចូល
ទៅប្តឹងការពាដការដល់ចិតា ។

គ្រានោះ ព្រះចៅចូយ៉ាយសោយរាជសម្បត្តិបាន ១៣ ឆ្នាំ (ព.ស.
៧៨៤) ទទួលដល់ខែកន្ទ្របទ សុម៉ាអ៊ីមានជម្ងឺឈឺធ្ងន់ណាស់ ឃើញ
ថាមិនរស់ហើយក៏ឲ្យរកខ្លួនសុម៉ាស៊ូនិងសុម៉ាចៀវជាបុត្រទាំង ២ ឲ្យចូល
ដល់គ្រែទីដំណេក ក៏និយាយថា ! ចិតាបានជាតិមហាឧបរាជនិយាយ
រាជការទាំងផែនដី ដោយស័ត្យ ដោយធម៌ មិនបានគិតរៀចទឹងផែន
ដី, តែមានមនុស្សខ្វះក្លែងថាចិតាជាក្សត់និងផែនដី, យើងអាស្រ័យ
ស័ត្យសុចរិតរក្សាខ្លួនមិនឲ្យអន្តរាយ, វេលានេះចិតាទឹងស្លាប់ហើយ ត្រូវ
ចៅនៅជាខ្ញុំរាជការគេទៅ, ចូរតាំងចិត្តស័ត្យត្រង់ស្មោះមីក័ត្តិទឹងអម្ចាស់ផែន
ដីឲ្យគ្រាតែអស់ជីវិត បើទឹងធ្វើការកុំគប្បីធ្វើចិត្តនោះស្រួលហ៎ស ត្រូវ
តែត្រិះរិះឲ្យល្អិតល្អន់ចេសឹមធ្វើ លុះនិយាយផុតពាក្យសុម៉ាអ៊ីក៏ដាច់ខ្យល់
ស្លាប់ សុម៉ាស៊ូ សុម៉ាចៀវក៏នាំសេចក្តីក្រាបបង្គំទូលព្រះចៅចូរាជ
ថា : សុម៉ាអ៊ីជាបិតារនិច្ចកម្ម នោះព្រះចៅចូរាជក៏គ្រាស់បង្គាប់ឲ្យចៅ
ភ្ញាក់ងារធ្វើតែដការសពតាមទម្លាប់ទំនៀមមហាឧបរាជ ហើយឲ្យហែ

សពនោះទៅបញ្ចុះទុកក្នុងម៉ុងក្នុងក្រុងឡងអៀង មានចារឹកជាអក្សរខុក
តាមប្រពៃណី ហើយតាំងសុម៉ាស៊ូជាទីសេនាបតីធំ តាំងសុម៉ាចៀវជាទី
ទៀវគីសៀងបុងគុន ឲ្យស្តីពជការត្រួតត្រាលើនាយពាហនពាំងពួង ។

ទំងថ្ងៃពីព្រះចៅស៊ុនគួនដែលទៅស្រុកកាំងតាំង ក៏តាំងស៊ុនតេង
បុត្រនាងស៊ីហ៊ូយិនជាទីថៃស៊ូ លុះស៊ុនតេងធ្វើការកិរិយាក្រ៉ូយដីតៃទៅ
ក៏តាំងស៊ុនហោជាបុត្រនាងហងហ៊ូយិនជាទីថៃស៊ូ ពុះកន្ទុងយូរមក ស៊ុន
ហោវ៉ៃខញុះញង់ព្រះចិតាឲ្យខ្ញាល់ ពាល់តែដកហូតជារស៊ុនហោចេញ
ចាកទី ស៊ុនហោបានសេចក្តីទំងក្តៅគុំគួនដោយអៀនខ្មាស ក៏ក្រុំចិត្ត
កើតជារោគឈឺស្គមស្ងាប់ ព្រះចៅស៊ុនគួនក៏ទ្រង់ព្យាបាលបុត្រនាងហួ.
ហ៊ួយយិនឲ្យជាទីថៃស៊ូ គ្រានោះឡុកស៊ុនទំងជូកាត់កំនដែលជាមនុស្សល្អ
មានសតិបញ្ញាក៏ស្ងាប់អស់ទៅ មានមន្ត្រីម្នាក់ឈ្មោះជូកាត់កេតបាន
និយាយត្រួតត្រាពជការទាំងពួង ។

នោះកាលថ្ងៃ ១ កើត ខែផល្គុនរំលង ១ ឆ្នាំទៅទៀត បង្កើតហេតុ
ព្យុះធំរលកក្នុងមហាសមុទ្រក៏កម្រើកខ្លាំង ទឹកក៏ជោរជន់ឡើងលិចអស់
ស្រុកកាំងតាំង ក្នុងស្រុកនោះដំរៅទឹកប្រហែល ៨ ហត្ថ ព្យុះក៏បក់ដក
យកដើមឈើធំ ដែលដុះនៅក្នុងមុខផ្ទះស៊ុនសិត អណ្តែតឡើងទៅ
លើអាកាស ហើយដើមនោះក៏ ធ្លាក់ចុះមកចំតក្បែរទ្វារក្រុងស្រុកកាំង
តាំង ចុងមុតចុះជាប់ទៅក្នុងដី ព្រះចៅស៊ុនគួនឃើញថ្ងៃកណាស់ក៏ឲ្យ

ឥតាល់ ព្រោះមិនដឹងជាល្អឬអាក្រក់, ព្រះអង្គក៏ជាទុក្ខក្នុងព្រះទ័យចាប់ប្រឈួនភេគជាប់ប្រមាណ ១ ឆ្នាំ ភេគក៏កម្រើកឡើង ទ្រង់ឃើញថាមុខជាមិនរស់ព្រះជន្ម, ក៏ត្រាស់ឲ្យហៅដូកាត់កេកនិងលីតាយជានាម៉ឺនធំទាំង ២ នាក់ឲ្យចូលទៅដល់ទីបន្ទំ, ហើយទ្រង់ក៏ផ្តាំផ្ញើស្រុកទេសនឹងបុត្រកំលោះប្រជារាស្ត្រ ហើយក៏សោយទិវង្គត កាលដឹតនិងរលត់ព្រះជន្មនោះនៅក្នុងខែពិសាខ (ព.ស.៧៩៥) ព្រះជន្ម ៧១ ឆ្នាំ សោយរាជ្យបាន ២៤ ឆ្នាំ ។

ដូកាត់កេកនិងបណ្តាមុខមន្ត្រីធំតូចទាំងពួង ក៏លើកស៊ុនលៀងឲ្យសោយរាជសម្បត្តិជំនួសព្រះបិតា, ព្រះចៅស៊ុនលៀងក៏ឲ្យតែងការព្រះសពហើយហែទៅបញ្ចុះទុកនៅទីដំបន់ទៀវឡេងតាមប្រពៃណី ហើយឲ្យចារឹកជាអក្សរថាទីនេះបញ្ចុះព្រះសពព្រះចៅតៃហង់តេ ។

ខណៈនោះ, មានបម្រើស៊ើបការនាំពត៌មានទៅថ្វាយដល់សុម៉ាស៊ូក្នុងស្រុកឡុកអៀងថា: ព្រះចៅស៊ុនគួនសុគតហើយ, សុម៉ាស៊ូដឹងដូច្នោះទើបប្រឹក្សានឹងអស់នាម៉ឺនមុខមន្ត្រីធំតូចទាំងពួងថា : យើងនឹងលើកទ័ពទៅវាយយកស្រុកកាំងតាំងតើអស់អ្នកពាល់គ្នានឹងយល់ឃើញប្រការម្តេច ? ហៅទូនទីប្រឹក្សាថា ដ្បិតវេលានេះមិនទាន់មានឧកាសឲ្យស្រួលសែ្តលនឹងលើកទ័ពទៅធ្វើការនោះ ព្រោះស្រុកកាំងតាំងមានទន្លេសមុទ្រជាំងនៅទីរបាំង បើនឹងលើកទ័ពទៅធ្វើការសង្គ្រាមក៏វាយពុំបាន, បេ

ដូច្នេះហើយបានជាខ្ញុំបាទយល់ឃើញថា បើលើកទ័ពទៅធ្វើការវែលានេះ
ក៏មិនបានទេ, ព្រោះស្រុកខេសរបស់នរណា ។ ក៏ដោយ ត្រូវតែត្រួត
ត្រាក្សារៀងខ្លួនប្រសើរជាង បើបានចន្ទោះស្រួលវេលាណា សឹមលើក
ទ័ពទៅវាយយកដ៏យដំនែតែម្តង សុម៉ាស៊ូថា : ដែលនិងចង្អុរធ្លាំចាំឲ្យ
មានចន្ទោះឧកាសនោះដឹងជាកាលណា អាយុសង្ខារបស់យើងនិងយឺន
ទៅបានប៉ុន្មានឆ្នាំទើបនឹងមានចន្ទោះឧកាស, សុម៉ាចៀវជាប្អូនសុម៉ា-
ស៊ូថា : ស៊ុនគួនស្ងាប់ហើយឬ បានជាស៊ុនលៀងសោយរាជសម្បត្តិ
ជួសបិតា, អាយុក៏នៅក្មេង ខ្លៃចាំងសេចក្តីគិត, បើយើងនឹងលើកទ័ពទៅ
ធ្វើការសង្គ្រាមឃើញនឹងបានតែម្តង, សុម៉ាស៊ូយល់ត្រូវផង ទើបប្រើឲ្យ
អង្គសង្ឃជានាយពាហនធំនាំពាហន ១០ ម៉ឺន, ឲ្យប្អូយីវៀមនាំពាហន
១០ ម៉ឺន ឲ្យសុម៉ាចៀវជាប្អូនជាមេកងធំ លើកទៅវាយស្រុកកាំងតាំង
កាលលើកទ័ពទៅគ្រានេះក្នុងខែ កត្តិក លុះលើកទៅដល់ដែនស្រុកកាំង
តាំងហើយ សុម៉ាចៀវក៏ឲ្យប្រមូលនាយទ័ពនាយកងចាំងពួងចូលទៅ
ប្រឹក្សាថា : អាណាខែត្រស្រុកកាំងតាំងចាំងពួងមាំមួនណាស់ ពីត្រឹម
ស្រុកតាំងហ៊ុន ព្រោះមុខស្រុកនោះមានប៉មកំពែងធំ ជាទីប្រជាប់ខ្លួប់
ចាំងសង្ឃខាងធ្វេង-ស្តាំ ដែលនិងកាប់ចូលទៅនោះកម្រណាស់ យើង
ត្រូវតែរៀបចំចាត់ចែងឲ្យស្រួលបួល ថាហើយក៏បង្គាប់ឲ្យអង្គសង្ឃ និង
ប្អូយីវៀមចាំង ២ នាយ ឲ្យនាំពាហនម្នាក់ ៣០.០០០ ជាប៉ែកធ្វេង-

ស្តាំ ហើយផ្តាំថា កុំអាលឲ្យលើកវាយ ត្រូវឲ្យចាំកងទ័ពហ្លួង ទ័ពមុខ និងទ័ពធ្វេងស្តាំលើកទៅព្រមហើយ សឹមឲ្យជួយគ្នាវាយប្រសព្វតែម្តង ហើយឲ្យអាវដុនជានាយទ័ពលេខ ៥០.០០០ ហើយបង្គាប់ថា : អ្នកលើកទៅដល់មាត់កំពង់ហើយឲ្យស្តាទផែធ្វេងទេនូ ទៅបានហើយក៏ឲ្យហានចេញជា ២ កងស្រួតវាយយកប៉មធ្វេងស្តាំ បើវាយបានហើយទើបបានសេចក្តីគាប់ប្រសើរណាស់ នោះអាវដុនក៏លើកទៅ ។

ឯដូកាត់កេកស្រុកកាំងតាំងដឹងថា សុម៉ាចៀវស្រុកវុយកុកលើកទ័ពទៅ ក៏ឲ្យប្រជុំនាម៉ឺនមុខមន្ត្រីធំតូចទាំងទីប្រឹក្សាចាំងពួងចូលទៅព្រមគ្នា ហើយនិយាយថា : សុម៉ាចៀវលើកទ័ពមកគ្រានេះ ទើបបាននរណាចេញទៅតទល់ គេងហាងនាយទាហានធំឆ្លើយថា : ស្រុកតាំងហ៊ុននោះជាកម្លាំងស្រុកកាំងតាំង ទាំងស្រូវអង្ករស្បៀងអាហារក៏បរិបូណ៌ហើយមានប៉មបន្ទាយមាំមួនជាទីស្រួលណាស់ បើស្រុកតាំងហ៊ុនខូចហើយ ឃើញថាប៊ូធៀងក៏ជាអន្តរាយ គួរយើងទើងរក្សាស្រុកកាំងហ៊ុនទុកឲ្យមាំមួនចុះ ។

ដូកាត់កេកឆ្លើយថា : អ្នកនិយាយនោះត្រូវណាស់ អ្នកចូរធ្វើមេទ័ពទឹកនាំពល ៣.០០០ លើកចេញទៅ លីតី តងដូ ឡេវ៉ាបៅ នាយទាហាន ៣ នាក់នេះ នាំទាហានម្នាក់ ១០.០០០ ជាមេទ័ពគោកលើកទៅជា ៣ កង ឯខ្លួនយើងនិងទ័ពហ្លួងជាដំនួយលើកតាមទៅ កាលនឹង

លើចូលវាយនោះ និងមានជាវអុចជាសញ្ញា បើបានឮសូរជាវជាសញ្ញា ក៏ឲ្យមេទ័ពស្រួតលើកចូលវាយឲ្យព្រមគ្នាទាំងគោកទាំងទឹក, តែងហាង ក៏លើកទ័ពទឹកមានទូកចម្បាំង ៣៥ នាំពល ៣.០០០ លើកទៅស្រុកតាំងហ៊ុន, ឯលីគី, តង់ជួ ខ្សោះជា នាំពលម្នាក់ៗ ១០.០០០ ជាទ័ពគោកលើកចេញទៅស្រុកតាំងហ៊ុនតាមផ្លូវគោក ជួកាត់កេកក៏លើកទ័ពហ្លួងទៅជាលំដាប់គ្នា ។

ខណៈនោះ អាវដុនជាមេទ័ពមុខសុម៉ាចៀវ ធ្វើស្ពានធ្វងទ្វេនាំកងទ័ពទៅដល់ត្រើយម្ខាងហើយក៏ប្រើហ៊ូនតែ ហ៊ូនចុង នាំគាហានចូលវាយច័មធ្វេងស្តាំ នោះនាយគាហានក្បាច័មស្តាំឈ្មោះខ្សៅលៀក ច័មធ្វេងឈ្មោះជួនតេក ច័មទាំង ២ នាក់នេះខ្ពស់ធំមាំមួនណាស់ ហ៊ូនតែ និងហ៊ូនចុង និងទំលាយចូលទៅក៏ពុំបាន ទើបកថយចេញទៅតាំងបន្ទាយខ្សៅលៀកនិងជួនតេកឃើញគាហានសត្រូវចូលមកច្រើនណាស់ និងបើកទ្វារច័មចេញដេញវាយមិនឃ្លានក៏រត់ទៅតែក្នុងច័ម គ្រានោះជាទេសកាលវង្វាណាស់ អាវដុនក៏នាំនាយទ័ពនាយកងទាំងពួងទៅសេពសុរានៅក្នុងបន្ទាយ កងប្រចាំការទើបឲ្យបម្រើសេះទៅប្រាប់ថា កងទ័ពទូកស្រុកតាំងតាំងលើកមកជាទ័ពទូក ៣០ នោះអាវដុន ក៏ចេញទៅក្រៅបន្ទាយក្រឡេកទៅឃើញកងទ័ពតិចម្ខាយ ប្រមាណមើលក៏ឃើញថាទូក ១ និងបន្ទុកគាហានបានតែ ១០០ ទើបត្រឡប់ចូលទៅក្នុងបន្ទាយវិញ ហើយ

បង្គាប់នាយទ័ពនាយកងទាំងពួងថា ទូក ៣០ និងបន្ទុកគាហាន ប្រមាណ ៣.០០០ យើងក៏មិនល្មមនឹងញ៉ាញ៉ីតខ្លាចសោះ ថាហើយបង្គាប់ឲ្យគាហានរក្សាបន្ទាយ ឯខ្លួនក៏ត្រឡប់ទៅផឹកស្រា និងនាយកងទៀត ក៏ស្រវឹងទាំងនាយនិងបាវ ។

ឯតេងហងនាយទ័ពក៏ឲ្យពួកទូកចូលតែបមាត់ច្រាំង ក្រឡេកទៅឃើញពលក្នុងរសាប់រសាយមិនបានរក្សាបន្ទាយឲ្យមាំមួន ឃើញបានចំណាប់ហើយក៏ប្រកាសដល់គាហានទាំងពួងថា យើងជាជាតិគាហានត្រូវតែតាំងចិត្តគិតរកសេចក្តីគាប់ប្រសើរដាក់ខ្លួន វេលានេះយើងត្រូវស្រូតរូតធ្វើសេចក្តីគាប់ប្រសើរឲ្យបានក្នុងថ្ងៃនេះ ថាហើយក៏បង្គាប់គាហានទាំងពួងឲ្យដោះមួក និងចេញគ្រប់គ្នា ហាមកុំឲ្យកាន់អាវុធវែង ឲ្យកាន់ក្រជ័និងដាវ នោះគាហានក្នុងបន្ទាយក្រឡេកឃើញដូច្នោះក៏សើចលេងមិនបានរាំងខ្លួនប្រាណ តេងហងក៏ដុតដាវឡើងជាសញ្ញា ៣ដង ហើយកាន់ដាវដៃ ២ លោតឡើងពីលើទូកតត់តម្រង់ទៅក្នុងបន្ទាយ· គាហានទាំងពួងក៏រត់តាមនាំគ្នាហែកំលាយបន្ទាយចូលទៅបាន ហាន់ចុងក៏កាន់លំពែងរត់ចេញទៅចាក់ចេងហង ។ ទាត់បានក៏កាប់និងដាវត្រូវពោះហាន់ចុងដួលចុះតេងហងស្ទុះទៅកាត់យកក្បាលបាន ឯហ្ជិនកែក្រឡេកឃើញហាន់ចុងស្លាប់ក៏ខឹងណាស់ កាន់ដាវវែងរត់ចូលទៅចាក់តេងហងភ្លាត់ប្រលួសទៅចន្លោះចង្កេះ តេងហងតាមយកដាវវែងបាន ហ្ជិនកែតេចរត់ត្រឡប់ថយ

តេឯហឯគ្រវែងកាប់នឹងជាវត្រូវដើងហ្ជិនកែដួលចុះ តេឯហឯក៏ស្ទុះទៅចាក់នឹងលំពែងត្រូវហ្ជិនកែស្លាប់ ឥហានតេឯហឯ ៣.០០០ ក៏ដេញកាប់សម្លាប់ឥហានអាវជុន ។ ក៏ខ្លើងសេះនាំឥហានហែកចំលាយបន្លាយរត់ចេញទៅ, លុះទៅដល់ស្ពានផៃ ពួកពលទាំងនោះខ្លាចស្លាប់ ក៏រត់ដណ្តើមជ្រែកជ្រៀតគ្នាធ្ងន់ទៅ មនុស្សចុះទៅច្រើនណាស់ លើសទម្ងន់ស្ពាននោះក៏បែករយៈផៃក៏លិចទៅ ឥហានក៏លង់ទឹកស្លាប់ច្រើនណាស់, អាវជុនខ្លួតឥតឥហានស្លាប់ក្នុងបន្លាយនិងស្លាប់ក្នុងទឹកប្រហែល ២ ភាគនៅសល់ ១ ភាគ, ខ្លួចឥតសេះនិងគ្រឿងសស្ត្រាវុធ គ្រឿងឧបភោគបរិភោគច្រើនណាស់ ក៏នាំឥហានដែលសល់នោះរត់ទៅរកសុម៉ាចៀវ។ ជានឹងសេចក្តីហើយ ត្រួតមើលការយើញថានឹងធ្វើការតទៅនោះជាលំបាកណាស់ ក៏លើកទ័ពត្រឡប់ចូលស្រុក ។

ឯជូកាត់កេកជាមេទ័ព និងនាយទ័ពនាយកងទាំងពួង ក៏លើកទ័ពត្រឡប់ចូលទៅស្រុកតាំងកុិន, លុះយើញតេឯហឯធ្វើការមានជ័យជំនះក៏ឲ្យចែកវង្វាន់ចំណាប់ដល់នាយទ័ពនាយកងនិងឥហានទាំងពួង តាមគុណានុរូប ហើយទើបប្រឹក្សានឹងក្លាក់ជារទាំងពួងថា សុម៉ាចៀវលើកទ័ពមកធ្វើការនិងយើងគ្រានេះ ចាញ់ប្រៀបយើងថយទ័ពត្រឡប់ទៅវិញ យើងបានចំណាប់ហើយ ត្រូវលើកតាមទៅតាំងបន្លាយក្លាប់ពីខាងទិសខាងត្បូង, ហើយឲ្យមានសំបុត្រទៅដល់កៀងអ៊ុយឲ្យលើកកងទ័ពមក

វាយខ្ជប់ពីម្ខាងខាងទិសឯដើង មុខជាបានស្រុកឡុកអៀនដោយស្រួល, បើបានហើយនិងបែងចែងដែនដីចែកគ្នាពាក់កណ្តាលម្នាក់ ថាហើយក៏ស្រូតកេណ្ឌពាហានឲ្យបាន ២០ ម៉ឺន ក៏លើកទៅវាយស្រុកវុយកុក លុះទៅដល់កណ្តាលផ្លូវក៏បង្កើតផ្សែងផុសឡើងអំពីដែនដីឲ្យងងឹតណាស់ សូម្បីអង្គុយទៅដឹងគ្នាក៏អើលមិនឃើញ, ចៀវអៀនទីប្រឹក្សាម្នាក់និយាយថា : ការប្លែកចង្កើតឡើងដូច្នេះអាក្រក់ល្អនិងអន្តរាយមេទ័ព សុំឲ្យលោកំលាយកងទ័ពត្រឡប់ទៅស្រុកកាំងតាំងសិនចុះ កុំអាលទៅវាយស្រុកវុយកុកឡើយ ។

ជូកាត់កេកបានឮដូច្នោះក៏ខឹងណាស់ : យើងនឹងធ្វើការធំឲ្យមានជ័យដំនះ អ្នកឯងនិយាយជាពាក្យអប្រិយឲ្យយើងដូច្នេះ នឹងឲ្យនាយទ័ពនាយកងនូវគេហានតាំងពួងខ្ជប់ចិត្តគំនិតឬ ? ថាហើយក៏បង្គាប់ឲ្យយកខ្លួនចៀវអៀនទៅសម្លាប់ចេញ, នោះនាយទ័ពនាយកងតាំងពួងនាំគ្នាអង្វរសុំទោសជូកាត់កេកឲ្យរួចពីសេចក្តីស្លាប់ នៃចៀវអៀនចេញពីពធការឲ្យទៅពក្ស្តេ ហើយក៏ស្រូតលើកទ័ពចេញទៅ, ឯតេងហងនិយាយនិងជូកាត់កេកថា : ខ្ញុំបានពីគ្រោះមើលឃើញថាតួយសុំនសៀនេះ, ជាទីមាំមួនណាស់, ពេញជាទីសំខាន់របស់ស្រុកវុយកុក, បើយើងវាយបានទីនោះហើយ មុខជាសុម៉ាស៊ូនឹងមានភ័យជាខ្លាំង ហើយយើងនឹងវាយតបូលទៅក៏មុខជានឹងបានដោយងាយ , ជូកាត់កេកយល់ឃើញត្រូវ

ក៏ឲ្យលើកទ័ពទៅតាមផ្លូវគយស៊ុនសៅ ។

ពួកគយល្បាតនាំយកសេចក្តីទៅប្តឹងដល់ខៀតតេកជាមេគយធំថា : កងទ័ពស្រុកកាំងតាំងលើកទ័ពមកច្រើនណាស់, ខៀវតេកយើញលើសកម្លាំងនឹងចេញតពុំបាន ក៏ឲ្យខ្លាគយក្បាច្បាប់ខ្លួនពីក្នុងបន្ទាយ, ផ្លូកាត់តេកក៏តាំងបន្ទាយព័ទ្ធខ្លាប់, ហើយឲ្យបម្រើសេះកាន់សំបុត្រទៅដល់កៀងអ៊ុយដូចគិតពុកមកនេះឯខៀវតេកក៏ឲ្យបម្រើសេះកាន់សំបុត្រទៅប្តឹងតាម ១ ភជការដល់ក្រុងឡុកអៀង ។

ងីសុងទីប្រឹក្សាម្នាក់និយាយនឹងសុម៉ាស៊ូថា: គ្រានេះផ្លូកាត់តេកលើកមកព័ទ្ធគយស៊ុនសៅនៅហើយ តែថាគយនោះមាំមួនណាស់, ព្រោះមានមនុស្សនៅត្រួតត្រាក្បាសុទ្ធតែខ្លាំងពូកែ , ទោះបីយ៉ាងណាក៏មិនជាអន្តរាយទេ ត្រូវតែយើងស្វែមនៅសិនចុះ កុំអាលលើកកងទ័ពចេញទៅជួយឡើយ, ព្រោះផ្លូកាត់តេកលើកទ័ពមកចម្ងាយឆ្ងាយណាស់, ទោះបីនឹងបានស្បៀងអាហារអ្វីច្រើនតិចក៏មិនយូរគង់នឹងអស់, បើកាលណាអស់ហើយ គង់រំសាយទ័ពទៅឯង, បើថយទ័ពវត់ទៅ សឹមយើងលើកទ័ពដេញតាមវាយពីក្រោយ មុខជាបានជ័យជំនះតែម្តង, ១មួយទៀតខ្ញុំបានខ្លាចក្រែងតែពីខាងជើង ព្រោះកៀងអ៊ុយនឹងលើកចុះមកជាទ័ពខ្លប់ប្រសព្វវាយត្រួតគ្នា, សុំឲ្យបាត់កងទៅប្រចាំការពារ, សុម៉ាស៊ូយល់ឃើញត្រូវ ក៏បាត់ឲ្យសុម៉ាចៀវនាំពលទៅជួយគួយហ៊ួយ ដើម្បីរក្សា

ការពារស្រុកអេងដីវ ហើយប្រើប្លុយយីរទៀមនិងអាវុធឲ្យនាំគាហាន លើកទៅផ្លូវគយសុំនសៀ ហើយកំជាប់ថា ឲ្យអ្នកឯងពាល់គ្នាចាំមើលចើដឹងខ្លួនជូកាត់កេកវត់ទៅហើយ ត្រូវស្រួតលើកគាហានដេញតាមវាយពីក្រោយ កុំឲ្យញាះញើតដៃឡើយ ។

ឯជូកាត់កេកក៏បង្គាប់ថា : ត្រូវឲ្យទំស្រុះគ្នាលើកវាយទំលាយបន្ទាយឲ្យបាន ហើយឲ្យពារទំលាយកំពែងចាំងកណ្តាលយប់កណ្តាលថ្ងៃ, បើនរណាគេចវេះដោះដៃមិនស្រុះចិត្តគ្នាធ្វើការនេះឲ្យបានតាមបង្គាប់ទេ និងកាត់ក្បាលចេញ នោះអស់ពួកគាហាន ក៏ទំស្រុះគ្នាពារទំលាយកំពែងចាំងកណ្តាលយប់កណ្តាលថ្ងៃ ឯកំពែងគយខាងដើងនោះឃើញថាមុខជាទំលាយចូលទៅបាន, ទៀតតេកឃើញដូច្នោះ ទើបគិតកលឧបាយធ្វើសំបុត្រឲ្យចម្រើកាន់ទៅដល់ជូកាត់កេកថា ទំនៀមស្រុកវុយតុក បើសត្រូវវាយមក ហើយអ្នកក្បាស្រុកទំការពារក្បាខ្លួនបានដល់ ១០០ ថ្ងៃហើយ មិនមានកងទ័ពស្រុកហ្លួងមកជួយទេ, អ្នកក្បាស្រុកនេះឃើញលើសកំឡាំងនឹងតទល់ពុំបាន មុខជានឹងនាំគាហានចេញមកសុំចំណុះចុះចូលសត្រូវតែម្តង, ឯបងប្អូនដែលនៅក្នុងស្រុកមោះក៏មិនជាគេសុខសុំងគ្នាអស់ ឥឡូវខ្លួនខ្ញុំឧស្សាហ៍ក្បាបន្ទាយមកបានប្រមាណ ៩៥ ថ្ងៃហើយក៏មិនឃើញកងទ័ពលើកមកជួយ, សុំឲ្យហោកបង្អង់ឲ្យខ្ញុំប្រហែល ១៥ ថ្ងៃសិន ឲ្យលុមខ្ញុំនឹងរៀបគិតចាត់ចែងការដែលនឹងនាំយោធាគាហាន

ចេញមកចំណុះចុះចូលលោកតែម្តង, នោះជូកាត់កេកក៏ដឿស្ងាប់ចិត្ត មិនបានបង្ខំគិតឲ្យទាហានទានទំលាយកំពែង ។

ឯខៀវតេកនោះ, លុះបញ្ជោតជូកាត់កេកដូច្នោះហើយ ក៏បង្ខំឲ្យរៀបចំកំពែងបន្ទាយពីខាងដើងដែលខ្លួចខ្លីទៅនោះឲ្យស្រួលបួលមាំឡើង, ហើយឲ្យទាហានកាន់អាវុធទៅត្រៀមប្រចាំការ ព្រមទៅលើសើនបន្ទាយ ហើយខៀវតេកស្រែកថា : ស្បៀងអាហារបស់អញនៅមានបរិបូណ៌, បើនិងចិញ្ចឹមពលទាហាន ១ ឆ្នាំទៀតអញក៏មិនខ្វាចទេ, អញត្រូវការអ្វីនឹងចេញទៅចំណុះឯង, ព្រោះឯងជាជាតិឆ្កែស្រុកតាំងកាំង, ជូកាត់-កេកបានឮដូច្នោះក៏ខឹងណាស់ ទើបបង្គាប់ទាហានឲ្យពារទំលាយកំពែង, នោះទាហានខៀវតេកក៏ទាំងគ្នាជាញាប់ធ្ងួចម្រុះចុះមក ព្រួញត្រូវមុតជូកាត់កេកធ្លាក់ពីលើសេះ ពួកទាហានក៏ពនាំចូលទៅក្នុងបន្ទាយ ជូកាត់កេកក៏មានសេចក្តីខឹងក្តៅណាស់ ក៏បង្គាប់ទាហានឲ្យបង្ខំពារទំលាយកំពែង ។

នោះពួកនាយទ័ពនាយកងមិយាយថា : ឥលូវនេះអស់ពលទាហានមកធ្វើការយ៉ាងណាស់ហើយ, បរិភោគបាយទឹកខ្សត់ម្ចាស់ធម្មតា បង្កើតជាជម្ងឺដំកាត់ច្រើនណាស់, ដែលលោកនឹងឲ្យចូលទៅពារទំលាយបន្ទាយមិនដាយបានទេ, ជូកាត់កេកខឹងខ្លាំងណាស់ថា : បើនរណាមិនសុខចិត្តគិតធ្វើពជការទេ ហើយមកប្រាប់ថាឈឺត្រូវឲ្យយកខ្លួនទៅសម្ងាប់ចេញ នោះអស់ពួកទាហានភ្ញាក់ហើយ ក៏ខ្វាចសេចក្តីស្ងាប់នាំគ្នាវាត់អស់

ជាច្រើន, ឈ្លួសមិនាយតាហានធំ ក៏នាំតាហានជាស្ម្រេចតួពួកវេជស់ ខ្លួនត់ទៅចូលស្រុកវុយកុក នោះមានតាហានចូលទៅប្រាប់ដូកាត់កេកថា តាហានត់អស់នៅស្តើងស្លួចណាស់ហើយ ឈ្លួសមិនាយតាហានធំ ក៏នាំតាហានត់ទៅចូលសត្រូវហើយ ដូកាត់កេកឮដូច្នោះក៏មានសេចក្តីភ័យណាស់ ទំដិះសេះចេញត្រួតមើលតាហានឃើញទៅស្លួចស្តើងណាស់ បើនឹងរងទៅទីនោះ ក៏តែតែបណ្តោយវាឲ្យសទៅមុខ ខ្លួនក៏កាន់តែស្តួមលឿនទៅច្រើន ទើបបង្គាប់ឲ្យរំសាយទ័ពត្រឡប់ទៅស្រុកកាំងតាំង ។

ឯកងឈ្លាតដឹងដូច្នោះ ក៏ចាត់បម្រើសេះទៅប្តឹងដល់ជួយវ៉ៃមៗ ក៏មង្វំលើកទ័ពទៅសង្កត់សង្កិនសម្លាប់តាហានដូកាត់កេក ស្លាប់ច្រើនណាស់ ដូកាត់កេកខ្លួចខាតតាហានគ្រានោះមានសេចក្តីអ័ប្រយសណាស់ ព្រោះកាច់តែតាមអំពើចិត្តតែម្នាក់ឯងហើយថ្ងូសការ ទើបនាំពលយោធាដែលសល់ពីស្លាប់ត់តម្រង់ទៅស្រុកកាំងតាំង ព្រះចៅស៊ុនលឿងជ្រាបថា ដូកាត់កេកវាមកួនមកឈឺនៅផ្ទះ ក៏នាំនាម៉ឺនធំតូចទៅសួរអាការ ។

ដូកាត់កេកមានសេចក្តីខ្លាសណាស់ ទើបនិយាយនិងនាម៉ឺនទាំងពួងថា ខ្លួនខ្ញុំទៅធ្វើការគ្រប់គ្រាគ្រប់កាលមានតែជ័យជំនះ គ្រានេះមានគ្រោះឲ្យថ្ងូសការទាំងរូបអង្គារៀបស្លាប់ ហើយខែមទាំងខ្លួចខាតតាហានជាច្រើន ឃ្លានសេចក្តីអ័ប្រយសណាស់ ព្រោះនាយទ័ពនាយកងទាំងពួងមិនបានជាចិត្តមួយនឹងគ្នាបានថ្ងូសឆ្ងាយដល់សត្រូវ បើនរណាតិះដៀល

និន្នាថាយើងចាញ់ទ័ព យើងនឹងចាប់ខ្លួនអ្នកនោះទៅសម្លាប់ចេញ, អស់មុខមន្ត្រីទាំងពួងក៏ឈឺចិត្តណាស់ លុះនឹងធ្វើយតបទៅដូកាត់កេកថាម្តេចពុំហ៊ាន ព្រោះញញើតខ្លាចដោយស័ក្តិយសជាធំ, ព្រះចៅស៊ុនលៀងក៏យាងត្រឡប់ទៅវិញ , ដូកាត់កេកក៏ដកហូតងារស៊ុនជុនដែលបានឱ្យធ្វើជានាយទាហានក្បាអង្គនោះចាកដំណែង ហើយតាំងទៀវអៀតនិងជូអ៊ុនឲ្យជានាយទាហានក្បាអង្គ, ឯស៊ុនជុននោះ ជាពូជព្រះពជវង្ស ជាបុត្រស៊ុនយ៉ង់ ជាក្មួយស៊ុនចេង ។ នោះជាប្អូនស៊ុនកៀនបិតាព្រះចៅស៊ុនគួន, លុះដូកាត់កេកហូតងារចេញ ក៏មានសេចក្តីខឹងណាស់ តែថាមិនដឹងនិងធ្វើប្រការម្តេច ក៏នៅស្ងៀមទៅ ។

(នៅមានត)

ចចកខកចិត្ត

ចចកមេមួយផើមគ្រប់វ៉ៃ។ គេចតាហ្វូងឆ្កែចូលព្រៃជ្រៅ
ចោលត្រង់កន្ទុយគ្រុយសំវៅ តម្រង់លំនៅនៃមិត្រភ័ក្តិ ។
លុះដល់គុហាជាជម្រក នៃមិត្រចចកដែលនៅស្ងាត់
ក្រោយពីខ្ជួលការពក់ពាក់ ក៏សុំសម្ងាត់ជាមួយផង ។
ចចកម្ចាស់ហាន់គ្មានគិតក្រែង រៀបចំកន្ទែងស្រួលកន្ទុង
ឲ្យមិត្រនិតនៅដូចបុរាណ រំលងច្រើនថ្ងៃលែងចា
ថា«នែសំឡាញ់! លួមចេញហើយ!» ចចកមេឆ្លើយអង្វរថា:
“ខ្ញុំមានផ្ទៃពោះគ្រប់មាស បើទំនងទៅណា ក្រែងឧបសគ្គ ។
ហេតុនេះ សូមមិត្រចិត្តប្រពៃ ឲ្យខ្ញុំគាស្រ័យនៅសម្ងាត់
ខម្រាំកើតកូនរួចគ្រោះថ្នាក់ ខ្ញុំនឹងលាអ្នកចេញទៅភ្លាម” ។
ចចកជាម្ចាស់ក៏ស្រុះស្រួល ខ្ជួលផ្គត់ផ្គង់យល់ព្រមតាម
លុះដល់ថ្ងៃដប់គ្រប់និយាម ចចកមេកាមក៏កើតកូន ។
មានញីមានឈ្មោះចោលប្រសាច រួចស្រេចពីល្ងាចមុនល្ងិតសូន្យ
ចចកម្ចាស់ផ្ទះតឿនថា “អូន! លួមនាងនាំកូនទៅហើយឬ?”។
ចចកបរទេសអេះក្បាលឆ្លើយ “ឈប់សិនបងអើយ! ខ្ញុំស្រែកព្រឺ
ទើបនឹងកើតកូនដូចអ្នកឈឺ ដល់ស្រាលជម្ងឺបួនប្រាំថ្ងៃ ។

ខ្ញុំនឹងនាំកូនចេញទៅក្រៅ . មិនទៅពាក់ពាមរំខានថ្ងៃ"
បបកមេផ្ទះជ្រះនិស្ស័យ ក៏ឲ្យអាស្រ័យនៅដោយស្រួល ។
លុះដល់កំណត់ថ្ងៃសន្យា បបកអនាថាជាស្រួលបួល
អាងបានបាន់បិតនិតនៅស្រួល ពុំគិតបបួលកូនទៅណា ។
បបកមេផ្ទះចិត្តស្មោះត្រង់ ឃើញគេពុំចង់ចេញយាត្រា
អត់ទ្រាំពុំបានក៏តឿនថា "ដល់ពេលសន្យានាងចេញហើយ" ។
បបកមានកូនដង្កើមធំ រៀបឫកមេខម្យុនមុខឆ្ងើយ
ថា "ខ្ញុំសុំចិត្តណាមិត្រអើយ ! ម្តេចឡើយមិនយោគយល់នេះផង ។
កូនខ្ញុំវ៉ាន់ទៅតូចតូចណាស់ បើដើរផ្តេសផ្តាសគ្មានដើមដង
លោតែបួបមនុស្សស្រួយដង់ឃ្នង ពិតជាគ្មានគ្រោះពុំខាន ។
សូមរង់ចាំវាធំបន្តិច ល្មមអាចរត់គេចរកស៊ីបាន
ខ្ញុំនឹងនាំគ្នាទៅពុំខាន សូមមិត្រប្រោសប្រាណកូនខ្ញុំផង" ។
បបកម្ចាស់ស្រុកយល់ទុក្ខមិត្រ មានចិត្តអាណិតជួយស្ងួនត្រង
ពាល់តែពួកកូនបបកផង កន្ធរវ័យតូចដូចប្រុសថ្មា ។
លុះឃើញពួកគេមិនគ្រេចេញ អ្នកផ្ទះនោះមិញក៏តឿនថា
"ម៉េចអូន! ល្មមចេញ ឬ យ៉ាងណា? កូនខាងគ្រប់គ្នាធំធំហើយ ! " ។
ឯមេបបកបញ្ជើកែក ស្រាប់តែបើកកែកគម្រោះឆ្ងើយ
"ដីះ! ម៉េចមកដេញអញត្រង់ឯង ម្តេចឡើយមិនចេញខ្លួនឯងទៅ!,, ។

ចចកមេផ្ទះភ្ញាក់សួរថា "នែនាង!អ្នកណាត្រូវចេញក្រៅ?"
ចចកមានកូនជួនធម៌ក្តៅ "អញ៎ឯងអើ!.ស្តាប់ចានទេ? ។
គុហានេះឆើតវាកើតឯង ហាងចានហួងវែងតាំបុរេ
ឥឡូវបើមិនចេញទៅទេ ប្រយ័ត្នកូនមេពុំប្រណី" ។
គេលនោះពួកកូនកូននោះមិញ មកព័ទ្ធជុំវិញប្រុងក្រញ៉ី
បង្ហាញចង្កឹមចាំងវែងខ្លី កំញ៉ាញ៉ាសម្តីលូនៗហឺន ។
ចចកម្ចាស់ស្រុកមុខខ្មៅបែ៉ មិនស្មានកូនមេគេជល់ម្ខឹង
ឆាល់ប្រកាកក្រសហួសចិត្តឹង មិនដឹងប្រឹងជ្រៀតតាមស្នៀតណា ។
ទឹងប្រើកម្ទាំងតាំងកំហែង ឆាស់ខ្លួនម្នាក់ឯងអីអនាថា
សត្រូវនៅផ្តុំជុំអាគ្នា ធ្វើម្តេចតែឯងជាទឹងមានដ៏យ ។
ទឹងស្តីតាំតាមផ្លូវប្លាប់ បើគេមិនស្តាប់ប្លាប់ទីណៃ
ព្រោះសុទ្ធតែគ្នាគេអ្នកណៃ មានតែដោះដៃទើបបានសុខ ។
អាស្លូរចចកកាចិត្តណាស់ ធ្លាប់ធ្វើជាម្ចាស់ភូមិហានស្រុក
ឥឡូវត្រូវប្រាន ឈានជ្រប់មុខ ដើរដេកសំកុកជង្រឹកក្បា ។
ព្រោះហេតុខុកចិត្តមិត្រអាក្រក់ ទើបគេឆាយធក់ជួនគុហា
ឆាល់តែអស់ហ៊ានទិវាសនា កំព្រាអនាថាគ្មានគ្រាចប់ ។ចប់រឿង—

សាសនាផ្សេង ៗ នៅក្នុងសាធារណរដ្ឋខ្មែរ

លោក លី ធាមតែង រៀបរៀង

---

១ - សេចក្តីផ្តើម :

ប្រទេសកម្ពុជា តាំងពីសម័យកើតជាវប្បធម៌ខ្លួន រហូតដល់ពេលពង្រីកវប្បធម៌ខ្លួនក្នុងសតវត្សរ៍ទី ១ មក តែងពេញចិត្តឲ្យមានសាសនាជាទីសក្ការៈរបស់ខ្លួនជាលំដាប់រៀងមក ។

សាសនាជាបឋម ដែលឧប្បត្តិកឡើងលើទឹកដីខ្មែរដើមនោះ គឺកើតពីជំនឿអ្នកស្រុកដែលគោរពតុ្សក្តិសិទ្ធិនៅតាមរូងភ្នំ តាមដើមឈើធំ និងតាមទន្លេសមុទ្រជាដើម ។ ប៉ុន្តែនៅភាគខាងចុងនៃសតវត្សរ៍ទី ១ នៃគ្រិស្តសករាជ ពួកព្រាហ្មណ៍មកពីឥណ្ឌា បាននាំគ្នាគ្នាជាច្រើនមករស់នៅលើទឹកដីយើង នាំយកលទ្ធិសាសនាមកផង ។ គេនាំគ្នារលាយខ្លួនទៅជាអ្នកស្រុកខ្មែរពិតប្រាកដ ។ គេនាំគ្នាបង្កើនវប្បធម៌ខ្មែរដែលមានស្រាប់មកហើយនោះឲ្យរ៉ែតែតែមានវិត្ថារកាពធំទូលាយឡើងទៀត ។ គ្រានោះ គេក៏នាំយកលទ្ធិសាសនាព្រាហ្មណ៍មកសាបព្រោះពេញស្រុកយើង ដូចជាមានចម្លាក់សិល្បកម្ម និងបុរាណវត្ថុជាច្រើន ព្រមទាំងទំនៀមទម្លាប់ខ្មែរជាច្រើនបែបនៅសល់ដល់សព្វថ្ងៃជាភស្តុតាងស្រាប់ ។ ជាមួយគ្នានេះ ព្រះពុទ្ធសាសនាបានចូលមកផងដែរ រហូតដល់ពេលក្រោយមក សាសនានេះ ក៏បានសាយភាយពេញពាសស្រុកខ្មែរ ត្រា

តែសព្វថ្ងៃឡើងវាសាសនាវដ្ឋតាមផ្លូវការ ។

ចាប់ពីសតវត្សរ៍ទី ១៤-១៥ តមក មានពួកជនជាតិអ៊ីរុបធ្លាំដំណើរ
រឿយ ។ មកកាន់ប្រទេសយើងក្នុងឋានៈជាអ្នកស្រាវជ្រាវប្បធម៌ខ្លះ ជា
អ្នកជំនួញខ្លះ មានចាំងចាមជនជាតិព័រទុយគេស៍ ជាតិអេស្បាញ៉ុល និង
ជាតិបារាំងមកបន្ត ។ គ្នាបញ្ចូលសាសនាគ្រិស្តមកក្នុងប្រទេសខ្មែរខ្លះ ។

នៅគ្រាប្រហាក់ប្រហែលគ្នានេះ អាណាចក្រចាម្ប៉ាដែលស្ថិតនៅ
ខាងឦសានប្រទេសយើងបានត្រូវបរាជ័យដោយសារសង្គ្រាមពង្រីកទឹកដី
ក៏ឃ្លានាំគ្នាចាំងគ្រួ ។ កៀសខ្លួនមកជ្រកនៅប្រទេសខ្មែរ នាំចាំងសា-
សនាអ៊ីស្លាមមកជាមួយផង ។

២ - វិវត្តន៍នៃសាសនាមួយ ។ :

ក - លទ្ធិព្រាហ្មណ៍ :

លទ្ធិព្រាហ្មណ៍ចូលមកប្រទេសខ្មែរពីកាគខាងចុងនៃសតវត្សរ៍ទី ១
តាមរយៈពួកព្រាហ្មណ៍មកពីឥណ្ឌាផ្នែកខាងត្បូង ដែលជាអ្នកដើរសំពៅ។
ពួកព្រាហ្មណ៍នេះ ឃានទុកដាក់ឥទ្ធិពលគ្នាធ្វើជាអ្នកកាន់អំណាចនៅលើស្រុក
ខ្មែរ ម្ល៉ោះហើយលទ្ធិព្រាហ្មណ៍ ក៏ត្រូវបានផ្សាយពេញស្រុកទេសយ៉ាង
រហ័ស តាមរយៈអំណាចរបស់អ្នកចាំងនោះ ។ ចាប់តាំងពីសតវត្សរ៍ទី ១
មកដល់សតវត្សរ៍ទី ១៣ គេឃើញភ្នែរដំណែលវត្តអារាម ប្រាសាទថ្ម
រូបចម្លាក់ជាដើមសម្រាប់គោរពសក្ការៈខាងលទ្ធិព្រាហ្មណ៍នេះ មានសេស

សល់ច្រើនណាស់ ។ វិជ្ជាគួនខ្មាត មានគម្ពីរវេទបញ្ចតន្ត្រៈ ឃុកណៈ និង កមាយនៈ ជាដើម ឃានផ្សាយទៅជាទំនៀមអ្នកស្រុកនិយមតាមប្រក្រតីទៅហើយ ។ ទីប្រជុំនៃតវិបណ្ឌិត ក៏នៅសល់កិត្តិនាមប្រាកដនៅឡើយ ដូចជាវត្តឥន្ទ្រាស្រម ក្នុងសម័យមហានគរ និងអ្នកប្រាជ្ញជាព្រាហ្មណ៍ច្រើនទៀត ដូចជាសិវសោម កវិន្ទ្រ យតិអមរការ គូបន្ទ្រទិវាករ ។ល។

ខ – ពុទ្ធសាសនា

ពុទ្ធសាសនាចូលមកប្រទេសខ្មែរ ស្របជាលគ្នានិងលទ្ធិព្រាហ្មណ៍ដែរ ប៉ុន្តែពុទ្ធសាសនាដំបូងនោះ ជាពុទ្ធសាសនាមហាយានដែលមានតស្តុតាងរូបលោកេស្វរៈនៅលើកំពូលប្រាសាទខ្មែរជាច្រើនក្នុងសតវត្សរ៍ទី ៨ ទៅទី១០ ។ លុះក្រោយមក ទើបមានពុទ្ធសាសនាថេរវាទខ្មែរ គឺដោយសារតែការផ្សាយរបស់ស្តេចអសោក ដែលបានចាត់សមណទូតទៅផ្សាយពុទ្ធសាសនានៅគ្រប់ទិសទី ។ ពេលនោះ មានសមណទូតពីរអង្គ នាមឧត្តរត្ថេរ ១ និងសោណត្ថេរ ១ បានធ្វើដំណើរមកផ្សាយក្នុងភូមិភាគជ្រោយសុវណ្ណភូមិជាភូមិភាគអាស៊ីបូព៌ាយើងនេះ ។

ក្នុងសតវត្សរ៍ទី ១៣-១៤ ពុទ្ធសាសនាបានរីកចម្រើន ហើយមានអ្នកនិយមគោរពប្រតិបត្តិដល់ភ្នក់ពួសំបំផុត ដំនួសលទ្ធិព្រាហ្មណ៍វិញ ។ វត្តអារាម និងចេតិយស្ថាន បានប្រតិសន្ធឡើងព្រោងព្រាតពេញផ្ទៃប្រទេស

ចាំងមួល ។ រសជាតព្រះសទ្ធម្ម ក៏ភ្លឺសុសសាយក្នុងមតិខ្មែរគ្រប់-ចាស់ប្រុស-ស្រី ។ ទម្លាប់ចាំងមួលមានសិល្បៈអក្សរសាស្ត្រ និង សីល-ធម៌ជាដើម ក៏មានឱនិន្នាការទៅខាងព្រះពុទ្ធសាសនាចាំងអស់ ធ្វើឲ្យបណ្តា-ជនខ្មែរជ្រួតជ្រាបរសនៃព្រះធម៌នៃព្រះពុទ្ធតែតែខ្លាំងក្លាឡើងរហូតមក ។ មួយទៀតដោយពេលនោះអ្នកស្រុកយើងទើបឆ្ងល់ផុតពីយុគសង្គ្រាម នាំឲ្យកើតចិត្តនឿយណាយនឹងសង្គ្រាម ហើយក៏កាន់តែស្រឡាញ់ព្រះពុទ្ធសាសនាខ្លាំងឡើង ។ ព្រោះជាទ្រឹស្តីប្រកបដោយសេចក្តីសុខ ។ រហូតមកដល់បច្ចុប្បន្ននេះ ព្រះពុទ្ធសាសនា ឋានឡើងជាសាសនារបស់រដ្ឋ ពេញបរិបូរ និងមានបណ្តាជនគោរពប្រតិបត្តិស៊ើរតែមួយរយៈកាតរយ ។ សព្វថ្ងៃមានព្រះសង្ឃ ៦៥.០៦២ អង្គ និងមានវត្តចំនួន ៣.៦៦៩ នៅតាមទីតាមដងបទចាំងអស់ ពេញផ្ទៃសាធារណរដ្ឋ ។

ចំណែកពុទ្ធសាសនាផ្នែកមហាយាន ក៏ឋានប្រតិស្ឋានវត្តអារាមព្រះវិហារជាច្រើនដែរ នៅទីក្រុងភ្នំពេញ និងនៅតាមខេត្តនានា ។ មានបរិស័ទរាប់មុឺននាក់ គោរពថែបមហាយាន បើយើងរាប់បញ្ចូលចាំងជនជាតិចិន ដែលរស់នៅក្នុងប្រទេសយើងផង ។

គ- សាសនាគ្រិស្ត :

ចាប់ផ្តើមពីសតវត្សទី ១៦ មក មានពួកជិតសាសនាកាតូលិកជាតិអឺរុប ឋានធ្វើដំណើរហូរហែមកកាន់ប្រទេសយើង ហើយព្យាយាម

ផ្សាយ និងសុំអនុញ្ញាតសិទ្ធិផ្សាយសាសនានេះទៀត នៅគ្រប់ភូមិភាគ
ក្នុងព្រៃ និងពញាឮ ដែលជាកំពង់ចំណតទូកសំពៅដឹកទំនិញក្រុងឧត្តុង្គ និង
តំបន់លង្វែក ដែលជាអតីតរដ្ឋធានីយើង ។ សាសនានេះ បានប្រតិស្ឋាន
ច្បាស់លាស់ក្នុងស្រុកខ្មែរពីគ.ស ១៦៦៥ ហើយបើបូកសរុបចំនួនពាំង
អស់ក្នុងគ្រានោះ មានប្រមាណជាជាងមួយពាន់នាក់ប៉ុណ្ណោះ ។ មក
ដល់ គ.ស ១៧៨៥ គ្រាដែលមានសង្គ្រាមជាមួយសៀម ចូលមកដល់
លង្វែក និងឧត្តុង្គ ពួកបរិស័ទគ្រិស្តសាសនា ក៏បានរត់ខ្ចាត់ខ្ចាយ ដូចជា
មាន ៣០០ នាក់ នៅនៅឯចុងដំបងនិងខ្លះទៀតនៅតាំងនៅតាមដងទន្លេ
មេគង្គ ពិសេសខេត្តកណ្តាល និង កំពង់ចាម ។ សព្វថ្ងៃនេះមានវិហារ
កាតូលិក ៦៤ ដែលតាំងនៅក្រុងភ្នំពេញមានវិហារធំមួយហៅថា កាតេ-
ដ្រាល (Cathédral) មានអ្នកគោរពសាសនានេះ ពាក់ព័ន្ធជនបរទេស
ដែលរស់នៅក្នុងស្រុកយើង ហើយនិយមសាសនាកាតូលិកនេះផង មាន
ប្រមាណជាមុឺននាក់ មានអ្នកបួសខាងប្រុស-ស្រី ១១១ រូប និងមានអាចារ្យ
៤៥ នាក់ ។ ក្នុងបណ្តាបព្វជិតនេះ មាននាយក ៣ រូប ហៅថា អេវ៉ែក
គឺ ១ អង្គនៅភ្នំពេញ, ១អង្គនៅបាត់ដំបង និង ១ អង្គទៀត នៅ កំពង់-
ចាម ។

ក្រៅពីលទ្ធិខាងកាតូលិក នៅមានខាង ប្រូតេស្តង់ ក៏បានចូល
មកប្រទេសខ្មែរដែរ ក្នុងរវាងសតវត្សរ៍ទី ២០នេះ ។ សព្វថ្ងៃកំពុងតែ

ផ្សព្វផ្សាយប្រមូលថវិស័ខតាមទីកន្លែង ។ ខ្លះដែរ ពិសេសនៅក្នុងទីក្រុង
ភ្នំពេញ ។

ឃ - សាសនាអ៊ីស្លាម :

សាសនាអ៊ីស្លាមចូលមកកាន់ស្រុកខ្មែរ តាមរយៈជនកៀសខ្លួន ជាតិ
ចាម្ប៉ា ក្នុងពេលសង្គ្រាមពង្រីកទឹកដី នៃសន្តតិវង្សអាណ្ណាម ពីសតវត្សរ៍
ទី១៥ ។ ពួកចាំងនេះ ចូលមករស់នៅជាបឋម គឺក្នុងភូមិភាគខេត្តកំពង់-
ចាម ត្រើយខាងកើតទន្លេមេគង្គ ចំនួនរាប់ម៉ឺននាក់ ប៉ុន្តែនៅសតវត្សរ៍ទី
១៨ អ្នកកាន់អំណាចខ្មែរបានដួយខុចតម្កើ ឲ្យពួកអ្នកកៀសខ្លួនចាំងនេះ
មានជីវិតភូមិស្នាន់រស់នៅតាមខេត្តនានា កុំឲ្យកកកុញចង្អៀតគ្នាពេក ។
មិនតែប៉ុណ្ណោះ ពួកអ្នកចាំងនេះបានចាំងទទួលឥទ្ធិពលសាសនាឥស្លាម
ខ្លះទៀត ពីពួកអ្នកប្រទេសជិតខាង ដែលធ្លាប់ចូលមកជួញដូរ ហើយ
បានជាក់ខ្លួនទៅជាជនជាតិខ្មែរពេញលក្ខណៈ គ្រាន់តែនៅគោរពប្រតិបត្តិ
សាសនាឥស្លាម ដែលមានជាប្រពៃណីតាំងពីដើមមក ។ គឺពីគ្រា
នោះមកហើយ ដែលប្រទេសខ្មែរបានចូលបន្ថែមសាសនាធំមួយទៀត
ដែលបរិស័ទឥស្លាមគោរពយ៉ាងហ្មត់ចត់ ព្រមទាំងរៀបចំឲ្យមានមេកោយ
អ្នកគ្រប់គ្រងរបៀបរៀបរយផង គឺមានឥមាំកម្នាក់ និងកូឈួយជា
ជួរការជួយចាត់ចែងការសព្វគ្រប់ ក្នុងសាសនានេះ ។ មានមេវិហារ
ហៅថា "ហាកិម" នៅគ្រប់គ្រងគ្រប់វិហារទាំងអស់នៅតាមភូមិ ហើយ

មានការរក្សាភ្ជួនឱ្នាតគម្ពីរ កុរអាន ជាគោលចារឹក ព្រមទាំងមាន
ធ្វើបូជនីយេសក៍ (AL-HADJ) នៅកាន់ទីមហាសន្និបាត គោរព
ព្រះអាល់ឡោះ (BAI T'ALLAH AL HARAN) នៅទីក្រុងឡាម៉ុច ជា
រៀងរាល់ឆ្នាំផង ។ ក្រៅពីនេះបានចាត់ឱ្យមានអាចារ្យហៅថា អ្នក
"អាឡឹម" សម្រាប់បង្រៀនក្ជួនឱ្នាតខាងសាសនាឥស្លាម នៅប្រចាំភូមិ
ណាដែលមានបណ្តាជនកុះករថែមទៀត ។ ចរិយ៍ទាំងនេះ នៅតែកាន់
ប្រពៃណីបុណ្យបៃព៉ម (កាន់សីលអំណត់) រក្សាវិន័យតាមទំនៀមនៅ
ភ៉ម៉ាជន យ៉ាងខ្ជៀងគត់ ។ សព្វថ្ងៃវិហារឥស្លាមមានចំនួន ១២០ នៅក្រុង
ភ្នំពេញ និងខេត្តនានា ព្រមទាំងកំពុងសាងវិហារជំមួយ នៅតណ្តាល
រដ្ឋធានីផង ។ មានសាសនិកឥស្លាមប្រមាណជិត ២០០.០០០ នាក់ ដែល
សុទ្ធជាខ្មែរ មិនសូវលាយជនបរទេសទេ ។

៣ - ផលប្រយោជន៍សម្រាប់បណ្តាជន :

លទ្ធិសាសនាទាំងអស់នេះ សុទ្ធតែបានផ្តល់ផលប្រយោជន៍ឱ្យ
បណ្តាជនខ្មែរតាមរបៀបបន្តិចមួយ តិចជាគ្រឹះសម្រាប់បណ្តុះបណ្តាលវប្ប-
ធម៌ខ្មែរ ឱ្យកាន់តែដុះដាលត្រកំត្រគាល់ឡើង ពិសេសគឺពុទ្ធសាសនា
ដែលបានចាក់ឫសមាំហើយ ដែលមានឥទ្ធិពលខ្លាំងជាងគេនោះ បាន
បណ្តុះខ្លួនគោរ តំនិតសីលធម៌ គ្រប់វិស័យ ឱ្យបណ្តាជនខ្មែរទាំងអស់ ។

ក្នុងពេលដែលប្រទេសកើតសង្គ្រាមច្រើនលើកពីមុន ។ មក និងក្នុង

ពេលដែលប្រទេសខ្មែរ ធ្លាក់ទៅជាអាណានិគមបារាំងលើកទី២ សត្រូវនិងអ្នកអាណានិគមបារាំងនោះ នាំគ្នាបំផ្លាញវប្បធម៌ខ្មែរ មិនឲ្យខ្មែរសិក្សាភាសាខ្មែរ មិនឲ្យខ្មែរសិក្សាស្នាដៃទំនៀមទម្លាប់ជាតិ ។ ពេលនោះ មានតែព្រះសង្ឃពុទ្ធសាសនិកទេ ដែលចិតចំថែរក្សាស្នាដៃវប្បធម៌ជាតិ ដែលបង្ហាត់បង្ហាញកូនខ្មែរឲ្យចេះតប្រកាន់ជាន់ៈកុំឲ្យភ្លេចស្នាដៃ អក្សរសាស្ត្រ និងប្រពៃណីជាតិបាន ។ លុះដល់ពេលផុតសង្គ្រាម គេបានស្រាវជ្រាវរកស្នាដៃតម្លៃជាច្រើនណាស់ នៅតាមវត្តអារាមពុទ្ធសាសនា ដើម្បីអ្នកសិក្សាសម័យក្រោយ យកមកធ្វើមេរៀនមេគំនិតពិចារណា ស្របតាមចង្វាក់វិទ្យាសាស្ត្រកំពុងចម្រើនសព្វថ្ងៃនេះ ។ ម្ល៉ោះហើយបណ្តាជនខ្មែរទាំងអស់គ្នា ទទួលស្គាល់ថា តើជាអារាមទាំងនេះហើយ ជាឃ្លាំងផ្ទុកទ្រព្យគោលចារឹកវប្បធម៌ខ្មែរ ។

រីឯសាសនាដទៃទៀត ក៏បានទុកក្តី និងពង្រីកចំណេះវិជ្ជាសម្រាប់សាសនិកបានរៀន ។ ខ្លួនដែរ ។ និយាយឲ្យខ្លីគឺ គ្រប់សាសនាសុទ្ធតែជាមេគំនិតបំប៉ននិងចម្រើនវប្បធម៌ ដល់ជនជាតិខ្មែរគ្រប់ៗ គ្នា ។

៤ - ក្រោះថ្នាក់ក្នុងពេលសង្គ្រាម :

ចាប់តាំងពីខែមេសា គ.ស ១៩៧០ មក ពួកសត្រូវឈ្មោះតានគឺវៀតកុង-វៀតណាមខាងជើង បានលើកទ័ពរាយលុកសាធារណរដ្ឋខ្មែរ ។ ពួកកុម្មុយនិស្តទាំងនេះឯង ជាសត្រូវនឹងសាសនាផង ម្ល៉ោះហើយគេព្យា-

យាមបាញ់កំទេច ឬ ចូលដុតចំផ្ទាញ ។ យកតំបាត់តំបាយព្រះសង្ឃពុទ្ធ-សាសនា បព្វជិតខាងកាតូលិកនិងអាចារ្យ-មេវិហារខាងសាសនាឥស្លាម ព្រមទាំងកុដិ សាលា វិហារ ឲ្យវិនាសបាត់បែក ឬ នេះអស់គ្មានសល់។ បដិមាករ ជាទីសក្ការៈ ក៏ត្រូវរង់រយចំបាក់ និងយកទៅជាន់ឈ្លីបន្ទោកតម្លៃយ៉ាងឈឺចាប់ ។ គម្ពីរដីកា ឬ ក្បួនខ្នាតផ្សេង ។ នៅក្នុងនោះ ក៏ត្រូវដុតចំផ្ទាញគ្មានសល់មិនតែប៉ុណ្ណោះ ។ ចាប់ចងធ្វើបាប ឬ សម្លាប់ដ៏យោរយៅចំពោះអ្នកប្រតិបត្តិសាសនាទាំងនេះផង ដែលមកដល់ត្រឹមខែ កញ្ញា ១៩៧១ នេះយើង ស្រង់បាន ការខូចខាត និងបាត់បង់ ដូចតទៅ :

ក - ខាងពុទ្ធសាសនា

- វត្តដែលត្រូវអន្តរាយ	មានចំនួន	២៤១ វត្ត
- ព្រះសង្ឃដែលសុគតយ៉ាងគរុណ	–	៤២ អង្គ
- ព្រះសង្ឃត្រូវរបួសនិងរងគរុណកម្ម	–	៩២ អង្គ
- ព្រះសង្ឃបាត់ខ្លួនដោយខ្លាំងចាប់	–	២១ អង្គ
- ព្រះសង្ឃកៀសខ្លួនមកជ្រកនៅភ្នំពេញ	–	៤៩២ អង្គ

ខ - ខាងសាសនាកាតូលិក

- វិហារដែលខូចខាត	មានចំនួន	១៣ វិហារ
- បព្វជិតបាត់បង់ជីវិត	–	៣ អង្គ

គ- ខ្លះដែលសិនរាំស្ទាម

- វិហារខ្ពស់ចាត ដែលបានពត៌មានច្បាស់ ខ្ពស់អស់ ៦ វិហារ

- វិហារនៅក្នុងតំបន់ភ្នំងងកាន់តាប់ ក្នុងាខ្ពស់ចាតដែរ តែមិនច្បាស់ចំនួន ។

៥ - សេចក្តីសន្និដ្ឋាន

តាមការរាប់រៀបមកនេះ យើញថា ប្រទេសខ្មែរបានផ្តល់សេរីភាពបរិបូណ៌ខាងដំនឿ ដែលបានតាំងចុះលក្ខខ័ណ្ឌនេះច្បាស់លាស់ក្នុងរដ្ឋធម្មនុញ្ញផង គឺថា : ពុទ្ធសាសនា ជាសាសនារបស់រដ្ឋ ប៉ុន្តែដំនឿចំពោះសាសនាដទៃទៀត ត្រូវបើកឲ្យមានដោយបរិបូណ៌ ។

ចាប់ផ្តើមពីមានលទ្ធិសាសនាមក ខ្មែរព្យាយាមធ្វើឲ្យមានការរីកចម្រើន ដោយខុកសាសនាជាគោលវប្បធម៌ជាតិ ដូចគោលមកក្នុងវគ្គ ៣ ស្រាប់ ប៉ុន្តែនៅពេលសព្វថ្ងៃ ស្រាប់តែមានសត្រូវ គឺពួកវៀតកុង-វៀតណាមខាងជើង មកបំផ្លិចបំផ្លាចឲ្យវិនាសអន្តរាធាន, ដូច្នេះ យើងខ្មែរទាំងអស់គ្នា សូមពាញអារម្មណ៌អស់លោកប្រតិកូដាទីគោរពតាំងឡាយមេត្តាជ្រាបពត៌មាននេះឲ្យបានពិតជាក់លាក់ ហើយសូមជួយប្រើប្រាស់ខ្លឹ-ពលរបស់លោកតាមមធ្យោបាយដែលមានរៀងៗខ្លួន ពេញសមត្ថភាពជួយសង្គ្រោះសាធារណរដ្ឋខ្មែរយើងខ្ញុំ ឲ្យបានរួចរោះអំពីវិលោកព្រៃផ្សៃពីពួកកុម្មុយនិស្តអាស៊ី ក្នុងពេលនេះផង គឺធ្វើយ៉ាងណា ឲ្យពួក

កុង-វៀតណាមខាងជើង គោរពដល់ច្បាប់អន្តរជាតិ ស្តីពីសម្បត្តិវប្ប-
ធម៌ក្នុងពេលសង្គ្រាម និង ចេះស្គាល់សិទ្ធិសេរីភាពរបស់មនុស្សជាតិផង
គ្នា តាមសេចក្តីប្រកាសជាសាកលនូវសិទ្ធិនៃមនុស្ស និយាយឲ្យចំ គឺឲ្យ
ពួកនេះឈប់រុកគួនឈ្មានពានសារធាណារដ្ឋខ្មែរ ដែលជាអ្នកស្តុតបូត
ស្រឡាញ់តែសន្តិភាពរៀបរយចាប់ពីពេលនេះទៅ ។

មួយទៀត យើងខ្ញុំសូមប្តឹងមតិសារធាណៈ ពិសេស ចំពោះអស់
លោកប្រតិភូជាទីគោរពទាំងឡាយថា លទ្ធិសាសនានានារបស់យើងទាំង
អស់គ្នា ដែលបានមកប្រតិស្ឋាននៅក្នុងសាធារណារដ្ឋខ្មែរនោះ តំពុង
តែត្រូវពួកកុម្មុយនិស្តអាស៊ីចំផ្ងាញសាសនា ឥញ្ជាំញីមើលងាយយ៉ាងខ្លាំង
ចំផុតហើយ ដូច្នេះ យើងទាំងអស់គ្នា ជាជនជាតិមានអរិយធម៌ចេះ
ស្រឡាញ់គោរពលទ្ធិសាសនាផ្សេង ។ ត្រូវក្រោកប្រឆាំងយ៉ាងម៉ឺងម៉ាត់
ចំពោះមារសត្រូវរួមរបស់យើង កុំបីបង្អង់ឡើយ ។

(ស្រង់ពីអត្ថបទពាយការណ៍ជូនគណៈកម្មការខាងវប្បធម៌នៃសន្និសីទ
សហភាពសមាជិកសភាអាស៊ីធ្វើនៅភ្នំពេញថ្ងៃ ១៦-២០ វិច្ឆិកា ១៩៧១)